ព្រះរាជាណាចក្រកម្ពុជា

— ជាតិ សាសនា ព្រះមហាក្សត្រ —

ក្រសួងសង្គមកិច្ច
អតីតយុទ្ធជន និងយុវនីតិសម្បទា

# ផែនការ ពង្រឹងសមត្ថភាព ផ្នែក

គាំទ្រគ្រួសារ



សុំកូន

ការថែទាំដោយឪពុកម្តាយធម៌

នៅប្រទេសកម្ពុជា
ឆ្នាំ ២០១៧-២០២៣

ការស្ថាបនាបន្ថែមតាមរយៈកំណែទម្រង់លើសមិទ្ធផលដែលមានស្រាប់

# មាតិកា


## ១. ទិដ្ឋភាពទូទៅសង្ខេបអំពីការការពារកុមារក្នុងប្រទេសកម្ពុជា៖ ការរកឃើញ និងអនុសាសន៍ក្តោបរួមសម្រាប់ការអភិវឌ្ឍសមត្ថភាព 10

| | | |
|---|---|---|
| អនុសាសន៍ទី ១ | កំណត់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ លើកកម្ពស់កិច្ចសហប្រតិបត្តិការអោយបានរឹងមាំ និងធានាឱ្យមានថវិកាគ្រប់គ្រាន់ | 15 |
| អនុសាសន៍ទី ២ | បង្កើតប្រព័ន្ធទិន្នន័យមេ ថ្នាក់ជាតិស្តីពីកុមារប្រឈម ការបំបែកចេញពីគ្រួសារ (ក្នុងករណីអន្តរាគមន៍បានចាប់ផ្តើមរួចហើយ) និងអំពីកុមារស្ថិតក្នុងការថែទាំជំនួស (ពោល គឺចាប់តាំងពីចូលកន្លែងថែទាំរហូតដល់ចេញកន្លែងថែទាំ ) | 20 |
| អនុសាសន៍ទី ៣ | ពង្រឹងវិស័យការងារសង្គមកិច្ច និងការបណ្តុះបណ្តាលអ្នកប្រកបវិជ្ជាជីវៈអាជីពវិស័យសង្គមទាំងអស់ | 25 |

## ២. ការគាំទ្រដល់គ្រួសារ៖ ការរកឃើញ និងអនុសាសន៍ការអភិវឌ្ឍសមត្ថភាព 30

| | | |
|---|---|---|
| អនុសាសន៍ទី ៤ | ផ្តល់ភាពអំណាចដល់ឪពុកម្តាយក្នុងការថែទាំកូនរបស់ខ្លួន ដើម្បីឱ្យគ្រួសារអាចនៅរួបរួមគ្នាបាន (ពោល គឺជាវិធានការបង្ការជុំទីមួយ) | 31 |
| អនុសាសន៍ទី ៥ | បង្កើតវិធានការសំណាញ់សុវត្ថិភាព ដើម្បីការពារកុមារប្រឈមហានិភ័យ នៅពេលការបង្ការជុំទីមួយពុំបានផល (ពោល គឺជាវិធានការបង្ការជុំទីពីរ) | 35 |
| អនុសាសន៍ទី ៦ | ពេលមិនអាចចៀសរួចពីការបញ្ជូនទៅកន្លែងថែទាំជំនួស ត្រូវផ្តោតកិច្ចខិតខំលើ «ការចាប់ផ្តើមជាថ្មី» (ពោល គឺជាវិធានការបង្ការជុំទីបី និងសមាហរណកម្ម) | 41 |
| អនុសាសន៍ទី ៧ | ណែនាំឱ្យមានយន្តការតាមដានប្រកបដោយប្រសិទ្ធភាព | 46 |

## ៣. ការថែទាំដោយឪពុកម្តាយធម៌៖ ការរកឃើញ និងអនុសាសន៍ផែនការអភិវឌ្ឍសមត្ថភាព 50

| | | |
|---|---|---|
| អនុសាសន៍ទី ៨ | ណែនាំឱ្យមានក្របខ័ណ្ឌការងារនីតិកម្មថ្នាក់ជាតិស្តីពីការថែទាំដោយឪពុកម្តាយធម៌ ជាផ្នែកមួយនៃការការពារសុខុមាលភាព និងការការពារផ្នែកច្បាប់សព្វជ្រុងជ្រោយ សម្រាប់កុមារ និងក្របខ័ណ្ឌគោលនយោបាយ | 53 |
| អនុសាសន៍ទី ៩ | ធានាឱ្យមានការផ្គត់ផ្គង់ហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ការថែទាំដោយឪពុកម្តាយធម៌ ដើម្បីអនុវត្តក្របខ័ណ្ឌការងារផ្នែកច្បាប់ និងគោលនយោបាយ | 58 |
| អនុសាសន៍ទី ១០ | បំពាក់លក្ខណៈសម្បត្តិគ្រប់គ្រាន់ដល់អ្នកប្រកបវិជ្ជាជីវៈ ដើម្បីអាចគាំទ្រអ្នកមើលថែដោយឪពុកម្តាយចិញ្ចឹមក្នុងតួនាទីជាអ្នកផ្តល់ការថែទាំកុមារ | 62 |
| អនុសាសន៍ទី ១១ | អ្នកថែទាំជាឪពុកម្តាយធម៌៖ ធានាឱ្យមានការវាយតម្លៃ ការត្រៀម និងការគាំទ្រក្នុងការតាមដានឱ្យបានគ្រប់គ្រាន់ | 66 |
| អនុសាសន៍ទី ១២ | កុមារ៖ ធានាឱ្យមានការវាយតម្លៃ ការត្រៀម និងការគាំទ្រក្នុងការតាមដានឱ្យបានគ្រប់គ្រាន់ | 71 |

## ៤. ស្មុំកូនៈ ការរកឃើញ និងអនុសាសន៍ការអភិវឌ្ឍសមត្ថភាព 75

| | | |
|---|---|---|
| អនុសាសន៍ទី ១៣ | ពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុងរវាងក្រសួងនានាដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូន ជាពិសេស គឺក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌ | 76 |
| អនុសាសន៍ទី ១៤ | បង្កើតលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ ដើម្បីកំណត់ឱ្យជាសុំកូនក្នុងប្រទេស ឬសុំកូនអន្តរប្រទេស (លំនៅដ្ឋានជាប្រចាំ) | 80 |
| អនុសាសន៍ទី ១៥ | ប្រកាសលក្ខណៈសម្បត្តិដែលអាចដាក់សុំយកកុមារទៅចិញ្ចឹមបាន ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ និងនៅមុនពេលការផ្គូផ្គងត្រូវបានធ្វើឡើង | 85 |
| អនុសាសន៍ទី ១៦ | ពិនិត្យឡើងវិញលើស្ថានភាពកុមារស្ថិតក្រោមការថែទាំ ដើម្បីពិនិត្យថាតើកុមារអាចទទួលអត្ថប្រយោជន៍ពីសុំកូន ឬយ៉ាងណា | 90 |
| អនុសាសន៍ទី ១៧ | បង្កើតបញ្ជីចុះឈ្មោះមួយ ដោយក្នុងនោះកុមារ ដែលមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបានទាំងអស់ នឹងត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិ | 94 |
| អនុសាសន៍ទី ១៨ | បង្កើតគណៈកម្មាធិការផ្គូផ្គង ដែលជាអ្នកទទួលបន្ទុកស្វែងរកឪពុកម្ដាយចិញ្ចឹមល្អបំផុតសម្រាប់កុមារ (ទាំងសម្រាប់សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស) | 98 |

## ៥. សុំកូនក្នុងប្រទេសនៅកម្ពុជា 103

| | | |
|---|---|---|
| អនុសាសន៍ទី ១៩ | ឪពុកម្ដាយចិញ្ចឹមត្រូវបានប្រកាសថា មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របសម្រាប់សុំកូន ហើយបានទទួលការបណ្ដុះបណ្ដាល និងការគាំទ្រសមស្របក្នុងអំឡុងពេលនីតិវិធីសុំកូនក្នុងប្រទេស | 104 |
| អនុសាសន៍ទី ២០ | លើកកម្ពស់សុំកូនក្នុងប្រទេស | 108 |

## ៦. សុំកូនអន្តរប្រទេសក្នុងប្រទេសនៅកម្ពុជា 112

| | | |
|---|---|---|
| អនុសាសន៍ទី ២១ | ផ្ដល់ព័ត៌មានអំពីលក្ខណៈសម្បត្តិ និងសេចក្ដីត្រូវការរបស់កុមារមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបាន ដែលត្រូវការសុំកូនអន្តរប្រទេស | 113 |
| អនុសាសន៍ទី ២២ | កិច្ចសហប្រតិបត្តិការជាមួយរដ្ឋទទួលបន្ទុក និងស្ថាប័ន ដែលមានតួនាទីទទួលស្គាល់គុណភាពសម្រាប់សុំកូនដែលមានចំនួនកំណត់ (AAB) | 117 |
| អនុសាសន៍ទី ២៣ | និយ័តកម្មលើទិដ្ឋភាពផ្នែកហិរញ្ញវត្ថុនៃការសុំកូន | 121 |

## ឧបសម្ព័ន្ធទី ១ បញ្ជីឈ្មោះបុគ្គលដែលបានជួបក្នុងអំឡុងបេសកកម្មនៅក្នុងប្រទេសកម្ពុជា 129

## ឧបសម្ព័ន្ធទី ២ បញ្ជីឈ្មោះបុគ្គលដែលបានទំនាក់ទំនង នៅក្រៅប្រទេសកម្ពុជា 134

# អារម្ភកថា

ក្នុងគោលដៅពង្រឹងការថែទាំជំនួសចំពោះកុមារឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផល និងធានាបាននូវឧត្តមប្រយោជន៍របស់កុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ (UNICEF) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) ប្រចាំកម្ពុជា បានធ្វើទំនាក់ទំនងជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេស្តីពីច្បាប់ឯកជនអន្តរជាតិ និងអង្គការសេវាសង្គមអន្តរជាតិឱ្យធ្វើការសិក្សាប៉ាន់ប្រមាណមួយដើម្បីពិនិត្យមើលសមិទ្ធផល និងបញ្ហាប្រឈម ដែលបានកើតឡើងចំពោះកិច្ចគាំទ្រគ្រួសារ ការថែទាំដោយឪពុកម្តាយធម៌ និងសុំកូន ព្រមទាំងទិសដៅផែនការកសាងសមត្ថភាព ដើម្បីជំរុញបន្ថែមកំណែទម្រង់វិស័យសុខុមាលភាពកុមារនៅកម្ពុជា។

លទ្ធផលនៃការសិក្សានេះបានផ្តល់នូវរបកគំហើញ និងអនុសាសន៍ល្អៗចំនួន២៣ សម្រាប់អនុវត្តរយៈពេលខ្លីនៅត្រឹមឆ្នាំ២០១៨ រយៈពេលមធ្យមនៅត្រឹមឆ្នាំ២០២៣ និងរយៈពេលវែងគឺក្រោយឆ្នាំ២០២៣។ ទន្ទឹមនឹងនេះដែរក៏មានការស្នើឱ្យរៀបចំបង្កើតបទដ្ឋានរួមមួយស្តីពីសុំកូនក្នុងស្រុក និងការពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមាឆ្នាំ២០០៦ បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៨ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០១១ ឱ្យមានសង្គតភាពទៅនឹងគោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ២០១០។

ក្រសួង ស.អ.យ នឹងពិនិត្យមើលអនុសាសន៍ខាងលើ ដើម្បីកែសម្រួលសម្រាប់អនុវត្តជាបន្តបន្ទាប់ទៅតាមលទ្ធភាពជាក់ស្តែងរបស់ក្រសួង និងអង្គការដៃគូពាក់ព័ន្ធ។ ខ្ញុំសូមឱ្យអគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានសុខុមាលភាពកុមារ រដ្ឋបាលសុំកូនអន្តរប្រទេស នាយកដ្ឋានពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវធ្វើការរួមគ្នា ដើម្បីធានាបាននូវឧត្តមប្រយោជន៍របស់កុមារ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអង្គការ UNICEF និងទីភ្នាក់ងារ USAID ប្រចាំនៅកម្ពុជា ដែលបានគាំទ្រ និងបន្តការគាំទ្រដល់ការថែទាំកុមារនៅកម្ពុជា និងសូមវាយតម្លៃខ្ពស់ចំពោះការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេស្តីពីច្បាប់ឯកជនអន្តរជាតិ និងអង្គការសេវាសង្គមអន្តរជាតិដែលបានខិតខំសិក្សាស្រាវជ្រាវនេះ។ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះការចូលរួមសហការពីនាយកដ្ឋានសុខុមាលភាពកុមារ មន្ទីរ ស.អ.យ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធដែលធ្វើឱ្យការសិក្សានេះទទួលបានជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

វង សូត

# បញ្ជីអក្សរកាត់

| | |
|---|---|
| AAB | ស្ថាប័នបានទទួលការទទួលស្គាល់គុណភាពសម្រាប់សុំកូន |
| AHC | មន្ទីរពេទ្យកុមារអង្គរ |
| UN Guidelines | គោលការណ៍ណែនាំអង្គការសហប្រជាជាតិសម្រាប់ការថែទាំជំនួសរបស់កុមារ |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ (គកនក) |
| DoJ | មន្ទីរយុត្តិធម៌ (ថ្នាក់ខេត្ត) |
| DoH | មន្ទីរសុខាភិបាល (ថ្នាក់ខេត្ត) |
| DoSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ថ្នាក់ខេត្ត) |
| FAST | គ្រួសារកាន់តែរឹងមាំនៅពេលជួបជុំគ្នា (គម្រោងរបស់អង្គការសង្គ្រោះកុមារ) |
| FCF | Family Care First |
| HCCH | សន្និសីទក្រុងឡាអេស្តីពីច្បាប់ឯកជនអន្តរជាតិ |
| ICAA | អាជ្ញាធរសុំកូនអន្តរប្រទេស |
| ILO | អង្គកាពលកម្មអន្តរជាតិ |
| IOM | អង្គការទេសន្តប្រវេសន៍អន្តរជាតិ |
| ISS | សេវាសង្គមកិច្ចអន្តរជាតិ |
| MoCR | ក្រសួងធម្មការ និងសាសនា |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| RCI | មណ្ឌលថែទាំកុមារកុមារ |
| PAPs | អនាគតឪពុកម្តាយចិញ្ចឹម |
| UNCRC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| UNCRC Committee | គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិកុមារ |
| WCCC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) |
| 3PC | កម្មវិធីភាពជាដៃគូសម្រាប់កិច្ចការពារកុមារ |
| 1993 HC | អនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៩៣ ស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស |

# សេចក្តីផ្តើម

ការវាយតម្លៃឯករាជ្យនេះ ត្រូវបានចាត់បេសកកម្មដោយនាយកដ្ឋានសុខុមាលភាពកុមារ និងរដ្ឋបាលសុំកូនអន្តរប្រទេសរបស់ក្រសួង ស.អ.យ ប្រទេសកម្ពុជាស្ថិតក្រោមការជួយសម្របសម្រួលរបស់អង្គការយូនីសេហ្វ។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងរួមគ្នា ដោយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់ឯកជនអន្តរជាតិ (HCCH)[1] តំណាងដោយ Laura Martinez-Mora និង Odeta Inte ជាមួយអង្គការសេវាសង្គមកិច្ចអន្តរជាតិ (ISS)[2] តំណាងដោយ Mia Dambach និង Maria Herczog។

គោលបំណងសំខាន់ៗនៃការវាយតម្លៃនេះជារួមគឺដើម្បីៈ

- កំណត់អំពីសមិទ្ធផល និងបញ្ហាប្រឈមនានាដែលមាននៅក្នុងក្របខ័ណ្ឌការងារការគាំទ្រដល់គ្រួសារ ការចិញ្ចឹមបីបាច់ ដោយឪពុកម្តាយធម៌ និងសុំកូន។
- ផ្តល់អនុសាសន៍ដោយប្រើប្រាស់សមិទ្ធផលនានាកន្លងមកជាដើមទុនឆ្លើយតបបញ្ហាប្រឈម និងទប់ស្កាត់ការអនុវត្តខុសច្បាប់ដែលអាចមាន។
- ស្នើឡើងនូវផែនការអភិវឌ្ឍសមត្ថភាពមួយ ដើម្បីស្ថាបនាបន្ថែមលើកិច្ចខិតខំ ដែលមានស្រាប់នៅក្នុងកំណែទម្រង់គួរជាទីកត់សម្គាល់លើប្រធានបទ ដែលកំពុងកើតមានក្នុងប្រទេសកម្ពុជា។ និង
- ចែករំលែកការអនុវត្តល្អពីបណ្តាប្រទេសដទៃ ដើម្បីជាមូលដ្ឋានផ្តល់ការជំរុញទឹកចិត្តដែលពាក់ព័ន្ធ។

នៅពេលត្រៀមសម្រាប់បេសកកម្មមកកាន់ប្រទេសកម្ពុជា ក្រុមស្រាវជ្រាវបានពិនិត្យលើឯកសារផ្សេងៗជាច្រើន (សូមមើលឧបសម្ព័ន្ធទី១) ហើយបានចូលរួមក្នុងការប្រជុំតាមបណ្តាញទូរស័ព្ទជាច្រើនលើកជាមួយអាជ្ញាធរ និងអ្នកដើរតួនាទីនានាក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស។ ក្នុងអំឡុងបេសកកម្មមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ២៨ សីហា ដល់ ថ្ងៃទី៦ កញ្ញា ឆ្នាំ២០១៦ អ្នកសរសេររបាយការណ៍បានពិភាក្សាជាមួយអ្នកមានតួនាទីជាង ៨០នាក់ ក្នុងរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តសៀមរាប។ ក្នុងចំណោមកិច្ចប្រជុំទាំងនោះ អ្នកសរសេររបាយការណ៍បានជួបជាមួយមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល ឪពុកម្តាយធម៌ មណ្ឌលថែទាំកុមារ (RCIs) អ្នកតំណាងរដ្ឋាភិបាលបរទេស និងទីភ្នាក់ងារសុំកូន។ ក្នុងពេលទស្សនកិច្ចទាំងមូល បុគ្គលិកអង្គការយូនីសេហ្វបានអមដំណើរក្រុមស្រាវជ្រាវផងដែរ។ បេសកកម្មនេះ រួមមានសិក្ខាសាលាពិគ្រោះយោបល់ចំនួនពីរលើក ធ្វើឡើងនៅថ្ងៃទី២ ខែកញ្ញា ដោយក្នុងនោះមានអ្នកចូលរួមប្រមាណ ១០០នាក់ មកពីរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នយុត្តិធម៌ សង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ បុគ្គលិកស្ថានទូត ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍ។ ការរកឃើញបឋម និងអនុសាសន៍របស់បេសកកម្មនេះ ត្រូវបានចែករំលែកនៅក្នុងក្រុមការងារបច្ចេកទេសតូចៗ។ ការធ្វើបែបនេះអនុញ្ញាតឱ្យអាចទទួលបានយោបល់ត្រឡប់សម្រាប់លទ្ធភាព ដើម្បីដាក់ឱ្យត្រូវទៅតាមបរិបទ និងលទ្ធភាពក្នុងការយកទៅអនុវត្ត។

របាយការណ៍បឋមដែលបានធ្វើឡើង បន្ទាប់ពីបេសកកម្មនេះ ត្រូវបានដាក់ជូនទៅអង្គការយូនីសេហ្វ និងក្រសួង ស.អ.យ កាលពីខែធ្នូ ឆ្នាំ ២០១៦ ដើម្បីសុំមតិយោបល់។ សេចក្តីព្រាងរបាយការណ៍ ត្រូវបានធ្វើបទបង្ហាញជាផ្លូវការ និងលើកយកមកពិភាក្សានៅក្នុង

1 សន្និសីទក្រុងឡាអេ ស្តីពីច្បាប់ឯកជនអន្តរជាតិ (HCCH) គឺជាអង្គការអន្តររដ្ឋាភិបាលមួយ ដែលធ្វើការសម្រាប់ការបង្រួបបង្រួមបែបឈានឡើងនៃវិធានច្បាប់ឯកជនអន្តរជាតិ។ HCCH បានអនុម័តឱ្យមានអនុសញ្ញាជាច្រើននៅក្នុងវិស័យការពារកុមារ និងច្បាប់គ្រួសារ ព្រមទាំងអនុសញ្ញាដទៃទៀត។ ក្នុងចំណោមអនុសញ្ញាទាំងនេះ អនុសញ្ញាមួយគឺ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងកិច្ចសហការទាក់ទងជាមួយសុំកូនឆ្លងប្រទេស ឆ្នាំ ១៩៩៣ (HC ឆ្នាំ ១៩៩៣) ដែលបានបង្កើតឱ្យមានបទដ្ឋានអប្បបរមា សម្រាប់ការការពារកុមារជាកម្មវត្ថុនៃសុំកូនឆ្លងប្រទេស ហើយអនុសញ្ញានេះទប់ស្កាត់ការចាប់ពង្រត់ ការលក់ ឬការជួញដូរកុមារ។ Laura Martinez-Mora គឺជាមន្ត្រីច្បាប់បង្គោលមួយនៅ HCCH ទទួលបន្ទុកតាមដានបន្តលើ HC ឆ្នាំ ១៩៩៣។ Odeta Inte គឺជាអ្នកពិគ្រោះយោបល់អន្តរជាតិស្តីពីសិទ្ធិកុមារ ការការពារកុមារ និងសុំកូន។

2 សេវាសង្គមកិច្ចអន្តរជាតិ គឺជា NGO អន្តរជាតិមួយស្ថាបនាឡើងក្នុងឆ្នាំ ១៩២៤។ អង្គការនេះ គឺជាបណ្តាញរបស់អង្គភាពថ្នាក់ជាតិចំនួន ១២០ និងមានអគ្គលេខាធិការដ្ឋានមួយជួយជ្រោមជ្រែងដល់កុមារ និងគ្រួសារប្រឈមមុខជាមួយបញ្ហាសង្គមស្មុគស្មាញ ជាលទ្ធផលកើតចេញពីទេសន្តប្រវេសន៍។ ISS មានឋានៈជាអ្នកផ្តល់ប្រឹក្សាដល់ក្រុមប្រឹក្សាអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសេដ្ឋកិច្ច និងសង្គម (ECOSOC) ក៏ដូចជាជាមួយអង្គការយូនីសេហ្វ និងស្ថាប័នអន្តររដ្ឋាភិបាលដទៃទៀតផងដែរ។ Mia Dambach គឺជានាយកមជ្ឈមណ្ឌលបង្អែកអន្តរជាតិ សម្រាប់សិទ្ធិកុមារដែលត្រូវបានដកហូតពីគ្រួសារ (IRC) ដោយ ISS គឺជាម្ចាស់ផ្ទះ ហើយសម្របសម្រួលលើកិច្ចខិតខំអភិវឌ្ឍការតស៊ូមតិ និងគោលនយោបាយ។ Maria Herczog គឺជាអ្នកពិគ្រោះយោបល់អន្តរជាតិផ្នែកគោលនយោបាយការការពារកុមារ និងជាអតីតសមាជិកគណៈកម្មាធិការ UNCRC។

សិក្ខាសាលាពិនិត្យឡើងវិញ រៀបចំឡើងដោយក្រសួង ស.អ.យ ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧។ របាយការណ៍ស្ថាពរបានពិចារណាទៅលើមតិយោបល់ និងអនុសាសន៍ដែលបានលើកឡើងក្នុងអំឡុងលំហាត់ការពិគ្រោះយោបល់ខាងលើ។

ដោយឡែក អាស្រ័យដោយពេលវេលា និងធនធានមានម្រិតកំណត់របស់យើងផ្ទាល់ ក៏ដូចជាលក្ខណៈដ៏ស្មុគស្មាញនៃការផ្តល់ការថែទាំជំនួសក្នុងប្រទេសកម្ពុជា យើងមិនសូវបានផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចទាក់ទងជាមួយការរីកដុះដាលនៃមណ្ឌលថែទាំកុមារនាពេលថ្មីៗនេះ និងអំពីមូលហេតុដែលធ្វើឱ្យមានការរីកដុះដាលនេះ ជាអាទិ៍ដូចជា ការវិភាគចរន្តការផ្តល់មូលនិធិ (អង្គការផ្តល់មូលនិធិធំៗ ម្ចាស់ជំនួយផ្នែកសាសនា និងម្ចាស់ជំនួយឯកជន)[3] និងការថែទាំតាមវត្តអារាមនោះទេ[4]។

ជាការពិតណាស់ មានការស្រាវជ្រាវដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានធ្វើឡើងរួចមកហើយ ផ្តោតលើចំណុចទាំងនេះ ក៏ដូចជាបញ្ហាទាក់ទងជាមួយការថែទាំជំនួសដទៃទៀត និងសុំកូនក្នុងប្រទេសកម្ពុជា (សូមមើលបញ្ជីគន្ថនិទ្ទេស)។ ដោយមានការស្រាវជ្រាវដ៏ច្រើនសន្ធឹកសន្ធាប់រួចមកហើយ ក្រុមស្រាវជ្រាវពុំមានបំណងចម្លងកិច្ចខិតខំដូចខាងលើយកមកធ្វើឡើងវិញឡើយ ហើយក៏ពុំមានបំណងបង្កើតរបាយការណ៍វែងអន្លាយមួយទៀត ដើម្បីគ្របដណ្តប់លើមូលដ្ឋានដែលមានការសិក្សាយ៉ាងច្រើនរួមកហើយនោះដែរ។

យោងតាមពេលវេលាបានកំណត់ របាយការណ៍នេះនឹងផ្តោតលើការផ្តល់អនុសាសន៍បែបអនុវត្តជាក់ស្តែង ដែលរៀបរចនាសម្ព័ន្ធក្នុងទម្រង់ជាផែនការអភិវឌ្ឍសមត្ថភាព។ របាយការណ៍នេះចាប់ផ្តើមឡើងដោយផ្តល់នូវអនុសាសន៍ «ក្តោបរួមទូទៅ» ដែលអាចអនុវត្តជាទូទៅ ហើយបន្ទាប់ពីនោះមានអនុសាសន៍ផ្តោតជាក់លាក់ និងសកម្មភាពជាក់ស្តែងដែលត្រូវបំពេញក្នុង រយៈពេលខ្លី (២០១៧-២០១៨) រយៈពេលមធ្យម (២០១៩-២០២៣) និង រយៈពេលវែង (២០២៣ និងហួសពីនោះ)។ អនុសាសន៍នីមួយៗព្យាយាមស្ថាបនាបន្ថែមលើកិច្ចខិតខំដែលមានស្រាប់នៅក្នុងក្របខ័ណ្ឌការងារផ្នែកច្បាប់ គោលនយោបាយ និងការអនុវត្ត (ព្រមទាំងអនុលោមតាមបទដ្ឋានអន្តរជាតិ) ក៏ដូចជាមេរៀនពាក់ព័ន្ធ ដែលបានរៀនសូត្រពីបណ្តាប្រទេសដទៃ។ ទាក់ទងជាមួយសុំកូន អនុសាសន៍ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាន ការទទួលខុសត្រូវក្នុងការធានាឱ្យមានប្រតិបត្តិការសុំកូនអន្តរប្រទេសត្រឹមត្រូវ ពុំអាចជាបន្ទុករបស់ប្រទេសកម្ពុជា តែម្នាក់ឯងបាននោះឡើយ ប៉ុន្តែក៏តម្រូវឱ្យមានការប្តេជ្ញាចិត្តយ៉ាងពេញលេញ និងសកម្មពីរដ្ឋទទួលបន្ទុកផងដែរ ដោយក្នុងនោះ រួមមានទាំងអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នត្រូវបានទទួលស្គាល់គុណភាពសម្រាប់សុំកូន។ ដោយមូលហេតុនេះហើយ ទើបអនុសាសន៍ក្នុងរបាយការណ៍នេះផ្តោតគោលដៅទៅលើរដ្ឋាភិបាល និងស្ថាប័នរបស់ប្រទេសកម្ពុជាក៏ដូចជារដ្ឋាភិបាល និងស្ថាប័ននៃប្រទេសដទៃផងដែរ។ ដោយឡែក យើងខ្ញុំបានទទួលការស្នើសុំឱ្យលើកឡើងនូវជំហានជាក់លាក់ស្តីពីវិធី ដើម្បីអាចអនុវត្តអនុសាសន៍នីមួយៗកំណត់អ្នកដឹកនាំក្នុងការអនុវត្តការងារ និងការគាំទ្រប្រកបដោយសក្តានុពលបញ្ជាក់ក្នុងតារាង។ យើងខ្ញុំជឿជាក់ថា មតិយោបល់ដែលបានស្នើឡើងទាំងអស់នេះនឹងត្រូវបានមើលឃើញថា ជាសកម្មភាពជាក់ស្តែង ដើម្បីយកទៅពិចារណាប្រសិនបើអនុសាសន៍ជាទូទៅត្រូវបានទទួលយក ដោយក្នុងនោះការសម្រេចចុងក្រោយត្រូវបានធ្វើឡើងដោយក្រសួងពាក់ព័ន្ធ និងភាគីពាក់ព័ន្ធនានា។ ការវាយតម្លៃរបស់យើងមានមូលដ្ឋានជាប្រព័ន្ធឈរលើបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ មានដូចជា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ សម្រាប់ការថែទាំជំនួស សម្រាប់កុមារ (គោលការណ៍ណែនាំអង្គការសហប្រជាជាតិ) និងអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣ ស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការទាក់ទងជាមួយសុំកូនអន្តរប្រទេស (អនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣)។

3 ឧទាហរណ៍ សូមមើលការសិក្សាស្តីពីគំរូការផ្តល់មូលនិធិ និងហិរញ្ញវត្ថុរបស់មណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា (នឹងត្រូវបោះពុម្ពផ្សាយនៅដើមឆ្នាំ ២០១៧) ដោយយូនីសេហ្វ និង Emerging Markets Consulting ដែលជាគម្រោងស្រាវជ្រាវមួយ ធ្វើការចងក្រងឯកសារ និងវិភាគអំពីរបៀបដែលមណ្ឌលថែទាំកុមារប្រតិបត្តិការ និងរក្សានិរន្តរភាពខ្លួនឯង ព្រមទាំងគំរូការផ្តល់មូលនិធិ និងគំរូហិរញ្ញវត្ថុនៃមណ្ឌលថែទាំកុមារប្រភេទផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា។

4 ការសិក្សាស្តីពីការអនុវត្តនៅតាមសហគមន៍ ការថែទាំជំនួសសម្រាប់កុមារក្នុងប្រទេសកម្ពុជា រួមទាំងការថែទាំនៅតាមវត្តអារាម បច្ចុប្បន្នកំពុងត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលច្បាប់ Coram ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ (នឹងត្រូវបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៧)។ បន្ថែមលើការសិក្សានេះ កម្មវិធីការការពារកុមារតាមវត្តអារាម បានដាក់បញ្ចូលសៀវភៅណែនាំការបណ្តុះបណ្តាល និងផែនការប្រតិបត្តិការ សម្រាប់ក្រសួងធម្មការ និងសាសនានឹងត្រូវបានរចនាឡើង សម្រាប់ឆ្នាំ ២០១៧ ដោយអ្នកពិគ្រោះយោបល់ដែលត្រូវបានជ្រើសរើស។

យើងខ្ញុំសូមទទួលស្គាល់ដោយចំហនូវដែនកំណត់ ដែលមានក្នុងបេសកកម្មរបស់យើង ដូចជាពុំមានទិន្នន័យគ្រប់គ្រាន់តាមតម្រូវការ បានចុះទៅទស្សនកិច្ចក្នុងខេត្តចំនួនបីប៉ុណ្ណោះ អ្នកដើរតួនាទីទាំងអស់ពុំបានចូលរួមគ្រប់ៗគ្នាពុំមែនគ្រប់ព័ត៌មានទាំងអស់ ដែលបានទទួលសុទ្ធតែអាចយកទៅពិនិត្យផ្ទៀងផ្ទាត់បានឡើយ។ មានកិច្ចខិតខំគួរជាទីកត់សម្គាល់ត្រូវបានធ្វើឡើង ដើម្បីធានាយ៉ាងណាឱ្យអ្នកដើរតួនាទីពាក់ព័ន្ធឱ្យបានច្រើនបំផុតអាចចូលរួមតាមលទ្ធភាព ដែលអាចធ្វើបានរួមទាំងការចូលរួមរបស់ពួកគាត់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ខ្លឹមសាររបាយការណ៍ផងដែរ។

មកដល់ពេលនេះ ប្រទេសកម្ពុជាស្ថិតក្នុងជំហរដ៏ពិសេសមួយ ដែលមានអ្នកដើរតួនាទីជាច្រើននៅក្នុងរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងនៅក្នុងប្រទេស និងពីក្រៅប្រទេស ដោយបន្សីគ្នាជាមួយឆន្ទៈរបស់ពួកគាត់ក្នុងការឈានឆ្ពោះទៅមុខលើកំណែទម្រង់ការថែទាំជំនួស និងសុំកូន។ មានឆន្ទៈថ្មីៗដើម្បីបង្កើតឱ្យមានយុទ្ធវិធីរួមមួយក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។ យើងខ្ញុំរំពឹងថានឹងអាចក្តាប់យកឱកាសដ៏ពិសេសនេះ ដើម្បីបន្តធ្វើឱ្យជីវិតកុមារក្នុងប្រទេសកម្ពុជាកាន់តែមានភាពប្រសើរឡើង ក៏ដូចជាដើម្បីជាឧទាហរណ៍គំរូបង្ហាញអំពីបទពិសោធន៍របស់ប្រទេសកម្ពុជា ដែលជាឧទាហរណ៍ជំរុញទឹកចិត្ត សម្រាប់បណ្តាប្រទេសដទៃទៀតនៅក្នុងការងារកំណែទម្រង់របស់ពួកគេផងដែរ។

Laura Martínez-Mora, Odeta Inte, Maria Herczog និង Mia Dambach ខែ មីនា ឆ្នាំ ២០១៦។




© UNICEF Cambodia/2016/Giacomo Pirozzi

# ០១

# ទិដ្ឋភាពទូទៅសង្ខេបអំពីការការពារកុមារក្នុងប្រទេសកម្ពុជា៖ ការរកឃើញនិងអនុសាសន៍ក្តោបរួមសម្រាប់ការអភិវឌ្ឍសមត្ថភាព

ផ្នែកបន្ទាប់នេះផ្តល់ទិដ្ឋភាពទូទៅសង្ខេបអំពីប្រព័ន្ធសុខុមាលភាពកុមារ និងប្រព័ន្ធការពារកុមារក្នុងប្រទេសកម្ពុជា។ យើងខ្ញុំមិនមានបំណងលើកឡើងអំពីច្បាប់ គោលនយោបាយ ឬការអនុវត្តដែលពាក់ព័ន្ធនីមួយៗនេះឡើយ ដោយហេតុថា ព័ត៌មានលម្អិតទាំងនោះត្រូវបានសិក្សាលម្អិតរួចហើយដោយអ្នកស្រាវជ្រាវដទៃទៀត និងការស្រាវជ្រាវកំពុងធ្វើឡើង (សូមមើលឧបសម្ព័ន្ធទី ១)។ យើងខ្ញុំជឿជាក់ថា ព័ត៌មានទាំងនេះផ្តល់ជូននូវបរិបទមួយចំនួនសម្រាប់អនុសាសន៍អភិវឌ្ឍសមត្ថភាពដែលត្រូវបានស្នើឡើងនាពេលក្រោយ។

## សិទ្ធិកុមារជាទូទៅ

ប្រទេសកម្ពុជាមានប្រជាជនសរុបប្រមាណ ១៥ លាននាក់ ដោយក្នុងនោះ ៣២ ភាគរយ មានអាយុក្រោម ១៥ ឆ្នាំ (ទិន្នន័យឆ្នាំ ២០១៤)។[5] សង្គ្រាមស៊ីវិលក្នុងអំឡុងពេលគ្រប់គ្រងដោយរបបខ្មែរក្រហមចន្លោះឆ្នាំ ១៩៧៥-១៩៧៩ បានធ្វើឱ្យមនុស្សយ៉ាងហោចណាស់ ១,៥ លាននាក់ ស្លាប់ដោយសារការសម្លាប់ពលកម្មធ្ងន់ធ្ងរដោយបង្ខំ ជំងឺ និងការអត់ឃ្លាន ហើយលទ្ធផល

5 ទិន្នន័យប្រជាសាស្ត្ររបស់បណ្តាញការងារការថែទាំកាន់តែប្រសើរ៖ www.bettercarenetwork.org/regions-countries/asia/southeastern-asia/cambodia (Sources: World Bank, UNICEF, UNDP HDR 2015, DHS 2014).

កើតមានក្រោយរបបនេះ ក៏បានជះឥទ្ធិពលគួរជាទីកត់សម្គាល់ចំពោះប្រទេសកម្ពុជាផងដែរ។ បន្ថែមលើនេះទៀត យោងតាមរបាយការណ៍ហានិភ័យពិភពលោក ឆ្នាំ ២០១៤ (World Risk Report 2014)[6] ៖ «ប្រទេសកម្ពុជា គឺជាប្រទេសមានហានិភ័យចំណាត់ថ្នាក់ទី ៩ ក្នុងពិភពលោកដោយគ្រោះមហន្តរាយ ដែលបង្ករឡើងដោយ ធម្មជាតិ និង សមត្ថភាព ក្នុងការសម្របខ្លួនរបស់ប្រជាជនកម្ពុជា និងរបស់រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុងការទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់ នៅមានកម្រិត ។» អង្គការយូនីសេហ្វ បានចាត់ទុកប្រទេសកម្ពុជាជាប្រទេសមានចម្ការមីនច្រើនចំណាត់ថ្នាក់ទីបីក្នុងពិភពលោកដោយភាគច្រើននៃជនរងគ្រោះគឺជាកុមារឃ្វាលគោក្របី ឬកុមារដែលកំពុងលេងនៅក្នុងទីវាល។ យោងតាមសន្ទស្សន៍ទាសភាពសកលឆ្នាំ ២០១៦ (Global slavery index 2016) ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទីបី ជាប្រទេសមានអត្រារីកសាយភាយខ្ពស់បំផុតនៃទាសករសម័យទំនើប បើគិតតាមសមាមាត្រប្រជាជន។[7] វិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជាបន្តកើនឡើង ដោយក្នុងនោះមានអ្នកទេសចរ ៧00 000 នាក់ ក្នុងឆ្នាំ ២០១៣ ហើយបានកើនឡើងដល់ ៤,៥ លាននាក់ ក្នុងឆ្នាំ ២០១៤ ដែលផ្តល់ឱកាសមុខរបរ ប៉ុន្តែក៏បង្កើនភាពងាយរងគ្រោះដល់កុមារចំពោះអ្នកទេសចរផ្លូវភេទ។[8] ដូចគ្នានេះដែរ បាតុភូតទេសចរណ៍តាមមណ្ឌលកុមារកំព្រាបង្កើនហានិភ័យធ្វើឱ្យកុមាររងការកេងប្រវ័ញ្ចពីអ្នកទេសចរអន្តរជាតិ។

បើទោះជាស្ថិតក្នុងបរិបទដែលមានលក្ខណៈអវិជ្ជមាន និងតម្រូវការដូចបានពោលខាងលើក្តី ប៉ុន្តែប្រទេសកម្ពុជាមានការឈានឡើងគួរជាទីកត់សម្គាល់។ របាយការណ៍ប្រចាំឆ្នាំ ២០១៥ របស់អង្គការយូនីសេហ្វ បានរៀបរាប់នូវការរីកចំរើនគួរអោយកត់សម្គាល់ «មានការសិក្សាជាច្រើន ត្រូវបានកើតឡើងក្នុងឆ្នាំ ២០១៥ ដែលបានយកមកធ្វើគោលនយោបាយ។ ការសិក្សាអំពីបន្ទុកផ្នែកសេដ្ឋកិច្ចបណ្តាលមកពីអំពើហិង្សា ដែលផ្អែកលើការរកឃើញពីការស្ទាបស្ទង់មតិស្តីពីអំពើហិង្សាប្រឆាំងកុមារ (VAC) ឆ្នាំ ២០១៣ ត្រូវបានផ្សព្វផ្សាយកាលពីខែ ធ្នូ ឆ្នាំ ២០១៥ ដើម្បីយល់កាន់តែច្បាស់អំពីផលប៉ះពាល់នៃអំពើហិង្សាប្រឆាំងកុមារ និងប៉ាន់ប្រមាណអំពីបន្ទុកសេដ្ឋកិច្ចទាក់ទងជាមួយទិដ្ឋភាពផ្នែកសុខភាព ការសិក្សាដ៏សំខាន់មួយស្តីពីផលប៉ះពាល់នៃទេសន្តប្រវេសន៍លើកុមារ ក៏ត្រូវបានធ្វើឡើងចប់សព្វគ្រប់ផងដែរ។ ការចុះឈ្មោះចូលរៀនរបស់កុមារអាយុចាប់ពីបីឆ្នាំ ដល់ប្រាំឆ្នាំ នៅក្នុងសាលារៀនអប់រំកុមារតូច ក៏បានកើនឡើងជាលំដាប់ចាប់ពី ២៥,៤ ភាគរយ ក្នុងឆ្នាំ ២០១១ កើនឡើងរហូតដល់ ៣៥,៣ ភាគរយ ក្នុងឆ្នាំ ២០១៥ អាស្រ័យដោយមានការរីកដុះដាលនៃចំនួនសាលាមត្តេយ្យចាប់ពី ៣៧ សាលា នៅក្នុងខេត្តចំនួនបី រហូតដល់ ៧៥ សាលា ក្នុងខេត្តចំនួនប្រាំ។»[9] ក្នុងឆ្នាំ ២០១៥ ៩៤ ភាគរយនៃទារកទើបកើតថ្មីទាំងអស់បានចុះសំបុត្រកំណើតក្នុងរយៈពេល ៣០ ថ្ងៃដំបូងក្រោយពេលកើត នៅក្នុងស្រុកគោលដៅចំនួន ១១ របស់អង្គការយូនីសេហ្វ បើប្រៀបធៀបជាមួយអត្រា ៨៨ ភាគរយ ក្នុងឆ្នាំ ២០១៤។ ចាប់ពីឆ្នាំ ២០១១ មក កុមារលើសពី ៣៥ 000 នាក់ ត្រូវបានតភ្ជាប់ទៅកាន់សេវានានា ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការបំបែកចេញពីគ្រួសារដោយមិនចាំបាច់ ដែលនេះជាសមិទ្ធផលមួយកើតចេញពីកម្មវិធី 3PC[10]។ បើគិតត្រឹមតែឆ្នាំ ២០១៥ តែមួយប៉ុណ្ណោះ យើងឃើញថា មានកុមារសរុបចំនួន ៥ ៦១៨ នាក់ យុវជនចំនួន ២ ២២៥ នាក់ និងគ្រួសារចំនួន ៣ ៣៧៩ គ្រួសារ បានទទួលអត្ថប្រយោជន៍ពី សេវាការពារកុមារ ដែលជាសមិទ្ធផលកើតចេញពីដៃគូរបស់កម្មវិធី 3PC។

6 https://ehs.unu.edu/news/news/world-risk-report-2014.html#files

7 មូលនិធិ Walk free៖ www.globalslaveryindex.org/methodology/ និង www.bettercarenetwork.org/sites/default/files/Global%20Slavery%20Index%202016.pdf

8 មូលនិធិ Walk free៖ www.globalslaveryindex.org/methodology/ និង www.bettercarenetwork.org/sites/default/files/Global%20Slavery%20Index%202016.pdf

9 www.unicef.org/about/annualreport/files/Cambodia_2015_COAR.pdf

10 3PC គឺជាភាពជាដៃគូត្រីភាគីរវាងក្រសួង សអយ អង្គការយូនីសេហ្វ និងអង្គការ Friends International (FI)។ អង្គការ FI សម្របសម្រួលឱ្យមានបណ្តាញគ្រប់ដណ្តប់មួយលើអង្គការសង្គមស៊ីវិល (ដៃគូអនុវត្ត) ចំនួន ៩ បន្ថែមទៀត ដើម្បីផ្តល់សេវាការពារកុមារនៅកម្រិតមូលដ្ឋាន។ ដៃគូអនុវត្តទាំងនោះធ្វើការជាមួយអង្គការសហគមន៍ (បណ្តាញដៃគូ) ចំនួន ៤0 ថែមទៀត ដើម្បីផ្តល់សេវានានា។ ក្នុងនោះក៏មានដៃគូបច្ចេកទេសចំនួន ៦ ដែលផ្តល់សេវាឯកទេសជាលក្ខណៈកិច្ចសន្យាផងដែរ។



# ការគាំទ្រដល់គ្រួសារ

## ការទប់ស្កាត់ការបំបែកចេញពីគ្រួសារ និងសមាហរណកម្ម

ក្នុងឆ្នាំ ២០១៥ ស្ថិតិរបស់រដ្ឋាភិបាលបានបង្ហាញថា ៥.៨ ភាគរយនៃកុមារអាយុក្រោម ១៨ ឆ្នាំ បានបាត់បង់ឪពុក ឬម្ដាយ ឬបាត់បង់ទាំងឪពុក និងម្ដាយ។ បន្ថែមលើនេះទៀត ប្រជាជនកម្ពុជាប្រមាណ ១៩ ភាគរយ រស់នៅក្រោមបន្ទាត់ភាពក្រីក្រក្នុងឆ្នាំ ២០១៣។ ប្រកាស (បទបញ្ញត្តិ)[11] ដែលពាក់ព័ន្ធបានគូសបញ្ជាក់យ៉ាងច្បាស់អំពីភារកិច្ចរបស់រដ្ឋាភិបាលក្នុងការចុះទៅសួរសុខទុក្ខកុមារ ឬគ្រួសារប្រឈមហានិភ័យក្នុងការបំបែកចេញពីគ្រួសារ ក៏ដូចជានីតិវិធីដើម្បីបើកសំណុំរឿង និងការទទួលខុសត្រូវ ដើម្បីធ្វើសកម្មភាពអន្តរាគមន៍។ ទោះយ៉ាងណាក្តីជាការចាំបាច់ដែលគួរបង្កើនកញ្ចប់ថវិកាឱ្យបានគ្រប់គ្រាន់ និងការបណ្ដុះបណ្ដាលសមស្រប ដើម្បីផ្តល់លទ្ធភាពគ្រប់គ្រាន់ឱ្យដៃគូនានាអាចធ្វើការងារដូចដែលបានកំណត់ទាំងអស់នេះ។ ថ្វីបើមានការផ្តួចផ្តើមគំនិតជាវិជ្ជមានក្នុងកម្រិតយ៉ាងធំសម្បើមនៅទូទាំងប្រទេសក្នុងការពង្រឹងគ្រួសារក្តី ប៉ុន្តែជារឿយៗ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុមានកម្រិតកំណត់ដែលជាមូលហេតុរារាំងភាពជោគជ័យនិងនិរន្តរភាព ( សូមមើលអនុសាសន៍ទី ១៖ កិច្ចសហប្រតិបត្តិការ អនុសាសន៍ទី ៣៖ ការបណ្ដុះបណ្ដាល និងអនុសាសន៍ទី ៥៖ ការទប់ស្កាត់ជុំទី ២ )។



# ការឆ្លើយតបចំពោះការថែទាំជំនួស

គេនៅពុំបានដឹងអំពីចំនួនជាក់លាក់នៃកុមារប្រឈមហានិភ័យនៃការបំបែកចេញពីគ្រួសារ ឬបាត់បង់ការថែទាំពីគ្រួសារក្នុងប្រទេសកម្ពុជានៅឡើយ។ ប្រព័ន្ធទិន្នន័យមេដើម្បីតាមដានវាយតម្លៃ និងចងក្រងជាឯកសារនូវហានិភ័យទាំងនេះ ពុំទាន់មាននៅឡើយ ( សូមមើលអនុសាសន៍ទី ២ )។ កុមារមកពីគ្រួសារក្រីក្រក្នុងប្រទេសកម្ពុជា មានភាពងាយរងគ្រោះយ៉ាងខ្លាំង ដោយជារឿយៗត្រូវប្រឈមមុខជាមួយកាតំរាមកំហែងប្រចាំថ្ងៃចំពោះសុខភាព ការអប់រំ សុវត្ថិភាព និងការអភិវឌ្ឍជាទូទៅរបស់គេ។ ជារៀងរាល់ថ្ងៃ ក្នុងប្រទេសកម្ពុជា កុមារជួបបទពិសោធន៍រងការរំលោភបំពាន អំពើហិង្សា ការកេងប្រវ័ញ្ច និងការព្រងើយកន្តើយ។ បញ្ហាទាំងអស់នេះ ជារឿយៗតែងត្រូវបានធ្វើឱ្យកាន់តែអាក្រក់ឡើង ដោយសារវិសមភាពយេនឌ័រ ការផាត់ចេញពីសង្គមនៃជនក្រីក្រតាមទីប្រជុំជន និងជនបទ និងឥរិយាបទអវិជ្ជមាន និងការរើសអើងចំពោះជនជាតិដើមភាគតិច និងជនពិការ។[12]

មាន ច្បាប់ និងគោលនយោបាយជាច្រើនគួរឱ្យចាប់អារម្មណ៍ដែលគ្របដណ្ដប់លើស្ថានភាពដូចបានលើកឡើងខាងលើ ( សូមមើល បញ្ជីគន្ថនិទ្ទេស )។ ទោះយ៉ាងណាក្តី គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិកុមារបានបង្ហាញក្តីបារម្ភចំពោះការកើនឡើងនូវចំនួនកុមារក្នុងមណ្ឌលកុមារកំព្រាក្នុង

11 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្តីពីនីតិវិធីដើម្បីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ (ខែ តុលា ឆ្នាំ ២០១១) មាត្រា ៦។

12 ការការពារកុមារ www.unicef.org/cambodia/2.Child_Protection.pdf; Beth L. Rubenstein, Lindsay Stark: A Forgotten Population: Estimating the Number of Children Outside of Households in Cambodia, Global Social Welfare, June 2016, Volume 3, Issue 2, pp 119–124, www.unicef.org/cambodia/MAPPING_REPORT_5_provinces_ENG.pdf

ប្រទេសរដ្ឋភាគីចំនួន ៦៥ ភាគរយ នៅចន្លោះរវាងឆ្នាំ ២០០៥ ដល់ ២០០៨ ហើយមណ្ឌលថែទាំកុមារបន្តចាត់ទុកជាជម្រើសដ៏ល្អបំផុត»។ គណៈកម្មាធិការកត់សម្គាល់ថា «មួយភាគបីនៃកុមារស្ថិតក្នុងមណ្ឌលថែទាំកុមារ នៅមានឪពុក ឬម្ដាយនៅរស់នៅឡើយ។ មណ្ឌលថែទាំកុមារនៅតែពុំទាន់បានចុះបញ្ជី និងពិនិត្យតាមដានបានត្រឹមត្រូវ ហើយមានការចាត់កញ្ចប់ថវិកាមិនគ្រប់គ្រាន់ និងកង្វះបុគ្គលិកថែទាំកុមារដែលបានទទួលការបណ្ដុះបណ្ដាលល្អជាមូលហេតុរារាំងដល់ការអនុវត្តគោលនយោបាយ និងគោលការណ៍ណែនាំរបស់រដ្ឋភាគីប្រកបដោយប្រសិទ្ធភាព»។

បន្ថែមលើនេះទៀត ការផ្ទៀងផ្ទាត់លើការអនុវត្តតាមបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសសម្រាប់កុមារ របស់កម្ពុជា បានជួបបញ្ហាប្រឈមមួយចំនួន អាស្រ័យដោយការរីកដុះដាលដូចផ្សិតនៃមណ្ឌលថែទាំកុមារ និងដោយសារតែពុំមែនគ្រប់មណ្ឌលថែទាំកុមារទាំងនោះសុទ្ធតែមានអនុស្សរណៈការយោគយល់គ្នាជាមួយក្រសួង ស.អ.យ នៅឡើយ។[13] មណ្ឌលថែទាំកុមារជាច្រើនបន្តប្រតិបត្តិការដោយពុំមានការអនុញ្ញាត។ ដើម្បីអាចយល់កាន់តែច្បាស់អំពីចំនួននៃមណ្ឌលថែទាំកុមារ ក្រសួង ស.អ.យ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ កម្មវិធី 3PC និង អង្គការ USAID បានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារចំនួនពីរលើក លើកទីមួយធ្វើឡើងក្នុងរាជធានីខេត្តអាទិភាពទាំងប្រាំ កាលពីចន្លោះខែ វិច្ឆិកា ឆ្នាំ ២០១៤ ដល់ខែ កុម្ភៈ ឆ្នាំ ២០១៥ បន្ទាប់មកទៀត គឺបណ្ដាខេត្តដែលនៅសេសសល់ ត្រូវបានធ្វើឡើងចាប់ពីខែ តុលា ដល់ខែ ធ្នូ ឆ្នាំ ២០១៥។ របាយការណ៍បឋមស្ដីពីរាជធានីខេត្តទាំងប្រាំ បានចេញផ្សាយក្នុងខែ មីនា ឆ្នាំ ២០១៦។ ក្នុងខែ កុម្ភៈ ឆ្នាំ ២០១៧ របាយការណ៍កំណត់ទីតាំងមណ្ឌលថ្នាក់ជាតិ ក៏ត្រូវបានផ្សព្វផ្សាយផងដែរ។ ការកំណត់ទីតាំងកន្លែងថែទាំកុមារបានរកឃើញ ចំនួន ៦៣៩ កន្លែង កំពុងមានប្រតិបត្តិការក្នុងប្រទេសកម្ពុជា។ ផ្អែកលើរបាយការណ៍ដែលរាយការណ៍ដោយផ្ទាល់ពីបុគ្គលិកកន្លែងថែទាំ ទាំងនោះបង្ហាញឱ្យឃើញថា កន្លែងថែទាំកុមារទាំងអស់នេះ អាចចែកចេញជាប្រាំប្រភេទគឺ៖ មណ្ឌលថែទាំកុមារ (៤០៦ កន្លែង) ផ្ទះ និងកន្លែងស្នាក់នៅបណ្ដោះអាសន្នក្នុងគ្រាមានអាសន្ន (២៥ កន្លែង) ផ្ទះស្នាក់នៅជាក្រុម (៧១ កន្លែង) វត្តអារាម និងកន្លែងថែទាំតាមបែបសាសនានៅក្នុងអាគារសាសនា (៦៥ កន្លែង) និងអន្តេវាសិកដ្ឋានដែលផ្ដល់កន្លែងស្នាក់នៅដល់សិស្ស (៧២ កន្លែង)។ ចំនួនសរុបនៃកុមារកំពុងរស់នៅក្នុងកន្លែងថែទាំកុមារទាំង ៦៣៩ កន្លែង មានចំនួន ២៦ ១៨៧ នាក់ (៤៨ ភាគរយជាស្ត្រី)។ យុវជនវ័យក្មេងចំនួន ៩ ១៨៧ នាក់ថែមទៀត ដែលមានអាយុចន្លោះពី ១៨ ដល់ ២៤ ឆ្នាំ (៣៦ ភាគរយជាស្ត្រី) ត្រូវបានរាយការណ៍ថា កំពុងរស់នៅក្នុងកន្លែងថែទាំ ៦៣៩ កន្លែង។ កុមារសរុបចំនួន ១៦ ៥៧៩ នាក់ (៤៧ ភាគរយជាស្ត្រី) ត្រូវបានរាយការណ៍ថា កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារចំនួន ៤០៦ កន្លែង។ ផ្អែកលើតួលេខប្រជាជនឆ្នាំ ២០១៥ បានន័យថា កុមារម្នាក់ក្នុងចំណោម កុមារកម្ពុជា ៣៥០ នាក់ រស់នៅក្នុងមណ្ឌលថែទាំកុមារ។ ជាកិច្ចឆ្លើយតប ក្រសួង ស.អ.យ បានព្រមព្រៀងលើគោលដៅគួរជាទីសុទិដ្ឋិនិយមមួយក្នុងការធ្វើសមាហរណកម្មកុមារ ៣០ ភាគរយ កំពុងរស់នៅក្នុងមណ្ឌលថែទាំក្នុងខេត្តអាទិភាពទាំងប្រាំ ត្រឡប់ទៅគ្រួសារនិងសហគមន៍វិញ ត្រឹមឆ្នាំ ២០១៨។

ថ្មីៗនេះ នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៥ ប្រទេសកម្ពុជាបានអនុម័តលើអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ដោយផ្ដល់ការទទួលខុសត្រូវ និងការចេញអាជ្ញាប័ណ្ណដល់មណ្ឌលទាំងនោះទៅឱ្យក្រសួង ស.អ.យ ។ អនុក្រឹត្យនេះចែងថា៖ «ការអនុញ្ញាតឱ្យកុមារស្នាក់នៅក្នុងមណ្ឌលថែទាំកុមារ គឺជាជម្រើសចុងក្រោយ និងជាជម្រើសបណ្ដោះអាសន្ន ហើយអាចធ្វើឡើងតែនៅក្រោយពេលបានស្រាវជ្រាវរកឪពុកម្ដាយ សាច់ញាតិ ឬអាណាព្យាបាល ឬឪពុកម្ដាយធម៌អស់លទ្ធភាពហើយ»។ អនុក្រឹត្យនេះ ក៏បានដាក់បញ្ចូលនាយកដ្ឋានបច្ចេកទេសឱ្យធ្វើការកំណត់អត្តសញ្ញាណមណ្ឌលថែទាំកុមារ ចុះធ្វើអធិការកិច្ច គ្រប់គ្រងដំណើរការនៃការផ្ដល់ការអនុញ្ញាតដល់គ្រឹះស្ថានមណ្ឌលថែទាំកុមារ និងបង្កើតការតាមដានបន្ត និងការគាំទ្រដល់គ្រួសារក្រោយពេលបង្រួបបង្រួមឱ្យជួបជុំគ្រួសារ ។

13 រហូតមកទល់ពេលថ្មីៗនេះនៅពុំទាន់មានអាណត្តិច្បាស់លាស់របស់ក្រសួង សអយ ក្នុងការមើលខុសត្រូវលើមណ្ឌលថែទាំកុមារទាំងអស់នោះឡើយ។ ស្ថានភាពមានការប្រែប្រួលដោយមានការអនុម័តអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារក្នុងខែកញ្ញា ឆ្នាំ ២០១៥ ដែលបានផ្ដល់អាណត្តិឱ្យក្រសួង សអយ មើលខុសត្រូវលើមណ្ឌលថែទាំលើកុមារគ្រប់ប្រភេទ ហើយបានបញ្ជាក់ច្បាស់ថា គ្រប់គ្រឹះស្ថានទាំងអស់ចាំបាច់ត្រូវទទួលការអនុញ្ញាតពីក្រសួង សអយ។ ដំណើរការនៃការផ្ដល់ការអនុញ្ញាតសម្រាប់គ្រឹះស្ថានទាំងអស់ បានចាប់ផ្ដើមរួចហើយ ប៉ុន្តែនៅពុំបានបញ្ចប់រួចរាល់នៅឡើយ។

# ស្មុំកូន

កាលពីអតីតកាល ស្មុំកូនក្នុងប្រទេសពុំមានប្រជាប្រិយភាពខ្លាំងនោះទេក្នុងប្រទេសកម្ពុជា។ មូលហេតុ ដោយគេមិនសូវដឹងច្បាស់អំពីនីតិវិធី «ការចំណាយក្រៅផ្លូវការ» និងដោយសារប្រជាជនចូលចិត្តប្រើប្រាស់នីតិវិធីក្រៅផ្លូវការ ដោយគ្រាន់តែរក្សាកុមារទុក ដោយពុំស្វែងរកការអនុញ្ញាតតាមផ្លូវការ។ ក្នុងខែតុលា ឆ្នាំ ២០១៦ ក្រសួងយុត្តិធម៌បានចេញផ្សាយសេចក្តីពន្យល់ស្តីពីស្មុំកូនក្នុងប្រទេស ដើម្បីផ្តល់ការបញ្ជាក់កាន់តែច្បាស់លាស់ថែមទៀតស្តីពីស្មុំកូនក្នុងប្រទេសកម្ពុជា។ សេចក្តីពន្យល់បានចងក្រងច្បាប់បញ្ញត្តិជាធរមានពី ក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីរឿងក្តីមិនមែនជាបណ្តឹង។ សេចក្តីពន្យល់នេះ មានបំណងពន្យល់អំពីដំណើរការ និងផ្តល់ការណែនាំចង្អុលបង្ហាញដល់អ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការនៃស្មុំ កូនក្នុងប្រទេស ជាពិសេសគឺ ចៅក្រម ព្រះរាជអាជ្ញា មេធាវី បុគ្គលិកសង្គមកិច្ច និងអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតទាក់ទងជាមួយគោលការណ៍ដំណើរការ និងឥទ្ធិពលនៃស្មុំកូនក្នុងប្រទេស ក៏ដូចជាដើម្បីគោរពឧត្តមប្រយោជន៍របស់កុមារផងដែរ។

ស្មុំកូនអន្តរប្រទេសចាប់ផ្តើមឡើងក្នុងប្រទេសកម្ពុជានៅពាក់កណ្តាលទសវត្សឆ្នាំ ១៩៨០។ ក្នុងឆ្នាំ ១៩៩៩- ២០០០ ចំនួនស្មុំកូនទៅក្រៅប្រទេសមានការកើនឡើងជាអតិបរមា ហើយមានភាពមិនប្រក្រតីជាច្រើនបានកើតឡើងដែលជាមូលហេតុបណ្តាយអោយមានការផ្អាកបណ្តោះអាសន្ននូវដំណើរការស្មុំ កូនពីចន្លោះឆ្នាំ ២០០១-២០០៣ ដោយប្រទេសប៊ែលហ្សិក កាណាដា ហ្វាំងឡង់ បារាំង លុចហ្សំបួ ហូឡង់ ស្វីស និងសហរដ្ឋអាមេរិកដែលបច្ចុប្បន្ននៅអនុវត្តនៅឡើយ អាស្រ័យដោយករណីការបន្លំភាពមិនប្រក្រតីជាច្រើន ក៏ដូចជាដោយសារកង្វះក្របខ័ណ្ឌផ្នែកច្បាប់នៅថ្នាក់មូលដ្ឋាន និងថ្នាក់គោលនយោបាយពុំមានគ្រប់គ្រាន់ ដើម្បីការពារឧត្តមប្រយោជន៍របស់កុមារ។ ជាកិច្ចឆ្លើយតបរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើការបង្កើតសេចក្តីព្រាងច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសក្នុងឆ្នាំ ២០០៣ ហើយបានអនុម័តជាស្ថាពរនៅចុងឆ្នាំ ២០០៩។ ដូចគ្នានោះដែរ អនុក្រឹត្យជាច្រើនត្រូវបានបង្កើតឡើង (សូមមើលបញ្ជីឯកសារពិគ្រោះ)។ ក្នុងឆ្នាំ ២០០៧ ប្រទេសកម្ពុជាបានផ្តល់ការព្រមព្រៀងដល់អនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣។ ចាប់ពីឆ្នាំ ២០១១ មក ប្រទេសកម្ពុជាបាននិងកំពុងរៀបចំលើការអនុវត្តនា ប្រព័ន្ធស្មុំកូនអន្តរប្រទេសថ្មីមួយដោយផ្អែកលើ HC ១៩៩៣ និង UNCRC។ ក្នុងដំណាក់កាលនេះ មានការផ្អាកស្មុំកូនបណ្តោះអាសន្ន ថ្វីបើអាជ្ញាធរកណ្តាលទទួលបន្ទុកស្មុំកូនបានកំណត់អត្តសញ្ញាណកុមារប្រមាណ ៣៣ នាក់ ដែលមានសេចក្តីត្រូវការពិសេស ហើយអាចត្រូវបានពិចារណាសម្រាប់ស្មុំកូនបាន។ យើងឃើញថាភាគច្រើននៃកុមារទាំងអស់នេះ មានអាយុលើស ១០ ឆ្នាំ ដោយក្នុងនោះប្រសិនបើចំនួនលើសពី ១៥ នាក់ អាចបង្កើតជាបញ្ហាប្រឈមក្នុងការកំណត់អត្តសញ្ញាណរកឪពុកម្តាយចិញ្ចឹមដែលមានសមត្ថភាពអាចមើលថែកូនចិញ្ចឹមឱ្យបានគ្រប់គ្រាន់។ កិច្ចព្រមព្រៀងទ្វេរភាគីត្រូវបានចុះហត្ថលេខាជាមួយប្រទេសអ៊ីតាលី ក្រុង Cataluña (អេស្ប៉ាញ) និង Malta ប៉ុន្តែស្មុំកូនអន្តរប្រទេសនាពេលថ្មីៗនេះនៅពុំទាន់មានដំណើរការឡើងវិញនៅឡើយទេ។

បន្ថែមលើនេះទៀត យើងហាក់ឃើញថា ជនបរទេសមួយចំនួនដែលពុំមានលំនៅដ្ឋានជាប្រចាំក្នុងប្រទេសកម្ពុជា បានស្វែងរកស្មុំកូនក្នុងប្រទេសចំពោះកុមារដែលធ្លាប់ស្ថិតក្រោមការថែទាំរបស់ខ្លួន ហើយបានសុំឱ្យរដ្ឋទទួលទទួលស្គាល់ស្មុំកូននេះ។ នេះជាបញ្ហាមួយសម្រាប់គណៈកម្មាធិការ UNCRC ដែលផ្តល់អនុសាសន៍ឱ្យកម្ពុជាត្រូវធានា៖ «ធ្វើយ៉ាងណាឱ្យគ្រប់ករណីនៃស្មុំកូនត្រូវអនុលោមទាំងស្រុងតាមពិធីសារប្រតិបត្តិការ និងអនុលោមតាមគោលការណ៍ និងបទបញ្ញត្តិនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការទាក់ទងជាមួយស្មុំកូនអន្តរប្រទេស តាមរយៈការអភិវឌ្ឍ និងការអនុវត្តកម្មវិធីដើម្បីទប់ស្កាត់ស្មុំកូនខុសច្បាស់ និងតាមរយៈការធ្វើនិយ័តកម្មលើការផ្តល់អាជ្ញាប័ណ្ណ និងការពិនិត្យតាមដានលើទីភ្នាក់ងារនានា ក៏ដូចជាថ្លៃសេវាដែលត្រូវយកសម្រាប់សេវានានារបស់ខ្លួន។[14]»

14 ការសង្កេតនូវផ្នែកសន្និដ្ឋាននៃរបាយការណ៍ដាក់ជូនដោយប្រទេសកម្ពុជាក្រោមមាត្រា ១២ វាក្យខ័ណ្ឌ ១ នៃពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារស្តីពីការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព និងសម្ភារៈអាសអាភាសកុមារ (ខែ កុម្ភៈ ឆ្នាំ ២០១៥) វាក្យខ័ណ្ឌ ១៧ ឃ)។

# អនុសាសន៍ទី ១

## កំណត់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់លើកកម្ពស់កិច្ចសហប្រតិបត្តិការអោយបានរឹងមាំ និងធានាឱ្យមានថវិកាគ្រប់គ្រាន់

**ST** កិច្ចព្រមព្រៀងអំពីសកម្មភាព និងការទទួលខុសត្រូវជាក់លាក់។

**MT** ពង្រឹងកិច្ចសហប្រតិបត្តិការអោយកាន់តែបានរឹងមាំថែមទៀតរវាងអ្នកទទួលខុសត្រូវដែលមានភារកិច្ច។

**LT** ធ្វើការស្រាវជ្រាវ ដើម្បីជួយសម្រួលដល់ការតស៊ូមតិ ដើម្បីឱ្យមានឆន្ទៈនយោបាយក្នុងការធានាឱ្យមានកញ្ចប់ថវិកាគ្រប់គ្រាន់។

ជាគោលការណ៍ ក្រសួង ស.អ.យ ជាក្រសួងនាំមុខទទួលខុសត្រូវក្នុងការការពារកុមារ រួមទាំងការថែទាំជំនួស និងសុំកូនអន្តរប្រទេស ដោយមានអ្នកតំណាងនៅថ្នាក់ខេត្ត ពោលគឺមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (មន្ទីរ ស.អ.យ) និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា នៅថ្នាក់ស្រុក (មន្ទីរ ស.អ.យ)។ ស្របគ្នានេះដែរ មានក្រសួងជាច្រើនទៀតដែលពាក់ព័ន្ធជាមួយបញ្ហាការពារកុមារ។[15] ឧ. ក្រសួង មហាផ្ទៃ ទទួលខុសត្រូវក្នុងការចេញសំបុត្រកំណើត ហើយកាលពីមុន គឺជាអ្នកទទួលខុសត្រូវក្នុងការចុះបញ្ជីអង្គការ NGO ក្នុងមូលដ្ឋាន[16]។ ក្រសួងធម្មការ និង សាសនា (MoCR) ទទួលខុសត្រូវក្នុងការមើលការខុសត្រូវចំពោះការថែទាំកុមារនៅតាមវត្តអារាម ក៏ដូចជាតាមព្រះវិហារសាសនាគ្រឹះនានា ដែលជារឿយៗ បានដំណើរការការថែទាំកុមារ "ក្រៅផ្លូវការ" ចំណែកក្រសួងយុត្តិធម៌ទទួលបន្ទុកដំណើរការផ្នែកច្បាប់ទាក់ទង និងការសុំកូនក្នុងស្រុក។[17] ចំណែកក្រសួងសុខាភិបាល (MoH) និងក្រសួង ស.អ.យ ទទួលខុសត្រូវចំពោះកុមារពិការ។ ដូចគ្នាជាមួយក្រសួង ស.អ.យ ដែរ ក្រសួងនីមួយៗ ដែលបានលើកឡើងខាងលើមានអ្នកតំណាងនៅថ្នាក់ក្រោមជាតិ នៅថ្នាក់ឃុំ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារឃុំសង្កាត់ (គ.ក.ន.ក) គឺជាស្ថាប័នដែលត្រូវបានការចាត់តាំងអោយទទួលខុសត្រូវលើការពិនិត្យតាមដាន និងការផ្តល់សេវាដល់កុមារ និងគ្រួសារប្រឈមហានិភ័យ ទោះបីតាមពិតពួកគាត់ពុំទាន់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីអនុវត្តមុខងារទាំងអស់នោះក្តី។

15 សូមមើលមាត្រា ៦ នៃ ប្រកាសស្តីពីនីតិវិធីដើម្បីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ (ខែ តុលា ឆ្នាំ ២០១១)។

16 មុនការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ពុំមានការតម្រូវឱ្យចុះបញ្ជីមណ្ឌលថែទាំកុមារនៅក្រោមក្រសួងជាក់លាក់ណាមួយនោះឡើយ។ ហេតុនេះ NGO ជាតិដែលមានប្រតិបត្តិការមណ្ឌលថែទាំកុមារ ត្រូវចុះបញ្ជីអង្គការ NGO ជាមួយ MoI ចំណែក NGO អន្តរជាតិត្រូវចុះបញ្ជីជាមួយក្រសួងការបរទេស។

17 នៅក្នុងក្រសួង សអយ សុំកូនថ្នាក់ជាតិ គឺស្ថិតនៅក្រោមអាណត្តិរបស់នាយកដ្ឋានសុខភាពកុមារ។

ក្នុងតំបន់មួយចំនួន សង្គមស៊ីវិលបានដើរតួនាទីក្នុងការផ្តល់សេវាដល់គ្រួសារ និងកុមារ ដែលងាយរងគ្រោះ។ ការងារនេះបាននិងដំណើរការក្នុងភាពជាដៃគូ និងមានលក្ខណៈដាច់តែឯងផងដែរ។ ឧ. កម្មវិធី 3PC ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១ ដោយអង្គការ មិត្តសំឡាញ់ ដែលមានកិច្ចសហការជាមួយអង្គការយូនីសេហ្វ និងក្រសួង ស.អ.យ។ ចាប់ពីឆ្នាំ ២០១៥ មក កម្មវិធី 3PC បាននាំអង្គការ NGOs ចំនួន ១២ និងបណ្តាញអង្គការតាមសហគមន៍ចំនួន ៤១ ដើម្បីផ្តល់សេវាការពារដល់កុមារដែលងាយរងគ្រោះបំផុតជារៀងរាល់ឆ្នាំ។[18] ដូចគ្នានេះដែរ FCF បានដឹកនាំសមាគមន្ធដៃគូអនុវត្តចំនួន ៥៥។ ដែលបានបង្កើតឡើងក្នុង ខែកញ្ញា ឆ្នាំ២០១៥ FCF ព្យាយាមភ្ជាប់ភាគីពាក់ព័ន្ធនានាវិស័យពីរខុសគ្នា «ដើម្បីដោះស្រាយបញ្ហាសង្គមជាក់លាក់  តាមរយៈការប្រើប្រាស់របៀបវារៈរួមគ្នាផ្សារភ្ជាប់សកម្មភាព និងកំណត់និយមន័យ ព្រមទាំងប្រើប្រាស់វិធានការជោគជ័យរួមគ្នា»។[19] សម្ព័ន្ធភាពសកលសម្រាប់កុមារ កំពុងបង្កើតការសម្របស្រួល និងមជ្ឈមណ្ឌលព័ត៌មានដែលជួយសម្រួលការប្រាស្រ័យទាក់ទង។ អង្គការសង្គ្រោះកុមារមើលខុសត្រូវលើសកម្មភាពនានាដែលបាន និងកំពុងអនុវត្តដោយអ្នកអនុវត្តជាច្រើន តាមរយៈការផ្តួចផ្តើមគំនិត «គ្រួសាររឹងមាំពេលរស់នៅជាមួយគ្នា» (FAST) និងតាមដានលើអនុក្រុមវិស័យចំនួនបួនគឺ៖ ១) ការពង្រឹងប្រព័ន្ធរដ្ឋាភិបាល ២) ការឆ្លើយតបដោយផ្ទាល់ចំពោះកុមារ និងគ្រួសារតាមរយៈសេវាសង្គមកិច្ចអោយកាន់តែប្រសើរ ៣)ការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់និង ៤) ការប្តូរគំរូនៃការថែទាំដោយការផ្លាស់តាមមណ្ឌល។ ករណីមួយចំនួនទៀត ការថែទាំនៅតាមវត្តអារាមបែបប្រពៃណី ក៏ត្រូវបានផ្តល់ដល់គ្រួសាររស់នៅក្នុងភាពក្រីក្រផងដែរ។ បន្ថែមលើនេះទៀត អង្គការសាសនាក៏ផ្តល់ការថែទាំដល់កុមារ និងគ្រួសាររបស់ពួកគេផងដែរ។

អាស្រ័យដោយមានអ្នកដើរតួនាទីជាច្រើនក្នុងវិស័យកិច្ចការពារកុមារ ក៏ដូចជាមានច្បាប់ និងក្របខ័ណ្ឌគោលនយោបាយជាច្រើន តែអ្វីដែលនៅខ្វះខាតនោះគឺសកម្មភាព និងការទទួលខុសត្រូវ។ ឧ. យើងបានឮ អំពីតម្រូវការក្នុងការពង្រឹងប្រព័ន្ធកិច្ចសហការផ្ទៃក្នុងរវាងក្រសួងនានា ទៅតាមការដែនកំណត់នៃការទទួលខុសត្រូវជាក់ស្តែង។ ដូច្នេះ អាជ្ញាធរកម្ពុជាក្នុងរយៈពេលខ្លី គួររៀបចំឱ្យមានបញ្ជីផ្ទៀងផ្ទាត់/ក្រាហ្វិកលំហូរការងារសម្រាប់ការថែទាំជំនួស និងសកម្មភាពទាក់ទងជាមួយស្មុំកូន និងមុខងារផងដែរ។ ការងារនេះអាចសម្រេចបានតាមរយៈការបង្កើតឱ្យមានអង្គការលេខ ដោយគូសបញ្ជាក់អំពីអាជ្ញាធរឬស្ថាប័នដែលត្រូវបានអនុញ្ញាតដោយច្បាប់កម្ពុជា។[20] គណៈកម្មាធិការជាតិ ដើម្បីកិច្ចការពារកុមារបង្កើតឡើងក្នុងឆ្នាំ ២០១៥ ដែលប្រតិបត្តិការនៅក្នុងក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ (ទទួលខុសត្រូវក្នុងការសម្របសម្រួលស្ថាប័នរដ្ឋាភិបាលទាក់ទងជាមួយសិទ្ធិកុមារ) អាចជាស្ថាប័នមួយដ៏ល្អ ដើម្បីជួយសម្របសម្រួលការកំណត់ការទទួលខុសត្រូវ។[21]

ដូចគ្នានេះដែរ កិច្ចខិតខំជាលក្ខណៈប្រព័ន្ធ និងផ្តោតគោលដៅដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកមានភារកិច្ចបំពេញមុខងារគួរត្រូវបានអនុវត្តក្នុងរយៈពេលខ្លី ដោយចាប់ផ្តើមជាមួយការផ្តួចផ្តើមដែលមានស្រាប់។ គណៈកម្មាធិការដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស.អ.យ គួរលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការក្រោមការជួយជ្រោមជ្រែងរបស់សង្គមស៊ីវិល ដូចជាសម្ព័ន្ធភាពសកលសម្រាប់កុមារ /FCF ដែលបានទទួលភារកិច្ចឱ្យបង្កើតការសម្របសម្រួល និងធ្វើជាមជ្ឈមណ្ឌលព័ត៌មាន។ មានឱកាសជាច្រើនដើម្បីពង្រឹងធនធាន ដែលមានស្រាប់ និងដើម្បីដាក់កិច្ចខិតខំជារួម ដោយស្ថាបនាបន្ថែមលើសមិទ្ធផលជាទីគាប់ចិត្តកើតមានឡើងក្នុងប្រទេសកម្ពុជារួច

18 ការវាយតម្លៃរបស់ DCOF-UNICEF ក្នុងឆ្នាំ ២០០៩-២០១២ អំពី «ការពង្រឹងប្រព័ន្ធដើម្បីការពារកុមារងាយរងគ្រោះ និងគ្រួសារក្នុងប្រទេសកម្ពុជា»៖ www.socialserviceworkforce.org/system/files/resource/files/DCOF%20UNICEF%20Assessment%20of%20Strengthening%20Systems%20to%20Protect%20Vulnerable%20Children%20and%20Families%20in%20Cambodia.pdf.

19 http://familycarefirst.com/

20 សូមមើលមគ្គុទេសក៍សម្រាប់ការអនុវត្តល្អ លេខ១៖ ការអនុវត្ត និងប្រតិបត្តិការអនុសញ្ញាស្មុំកូនឆ្លងប្រទេសក្រុងឡាអេ ឆ្នាំ១៩៩៣ ច្បាប់ស្តីពីគ្រួសារ (Jordan Publishing Ltd) ឆ្នាំ ២០០៨ (ចាប់ពីពេលនេះទៅហៅថា «គោលការណ៍ណែនាំអំពីការអនុវត្តល្អលេខ ១») ឧបសម្ព័ន្ធ ៦ ថ្វីបើអាចអនុវត្តបានចំពោះស្មុំកូនក្តី ប៉ុន្តែគួរបង្កើតឱ្យមានសៀវភៅមគ្គុទេសក៍ប្រហាក់ប្រហែលនេះសម្រាប់ការថែទាំជំនួស។ សូមកត់សម្គាល់ថា អាជ្ញាធរកណ្តាលផ្នែកស្មុំកូនរបស់អាមេរិកបានធ្វើផែនទីនីតិវិធី និងអាជ្ញាធរទទួលខុសត្រូវរួចមកហើយ ហើយប្រហែលជាអាចជាជំនួយដ៏បាន។

21 សូមមើល៖ www.cncc.gov.kh។ គណៈកម្មាធិការនេះ អាចត្រូវបំពេញមុខងារប្រហាក់ប្រហែលជាមួយក្រសួងទាំង ១៣ របស់រដ្ឋាភិបាល ដែលបង្កើតឱ្យមានជាគណៈកម្មាធិការដឹកនាំថ្នាក់ជាតិ ដើម្បីឆ្លើយតបចំពោះបញ្ហាអំពើហិង្សាប្រឆាំងកុមារក្នុងអំឡុងឆ្នាំ ២០១៥។

មកហើយ (សូមមើលអនុសាសន៍ទី ២៖ ប្រព័ន្ធទិន្នន័យមេ អនុសាសន៍ទី ៣៖ ការចងក្រងការបណ្ដុះបណ្ដាលផ្ទៃក្នុង។ សូមមើលអនុសាសន៍ទី ៤៖ បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ថ្នាក់ជាតិ អនុសាសន៍ទី ១១៖ ការបង្កើតបណ្ដុំការថែទាំដោយឪពុកម្ដាយធម៌។ល។)។ ម៉្យាងទៀតអាចមានការលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការតាមរយៈការបណ្ដុះបណ្ដាលតាមវិស័យ (សូមមើលអនុសាសន៍ទី ៣៖ ការបណ្ដុះបណ្ដាល)។ ដូចបានបញ្ជាក់ខាងដើម មជ្ឈមណ្ឌលព័ត៌មានអាចប្រមូលផ្ដុំព័ត៌មានដែលមានកន្លងមកនៅក្នុងប្រព័ន្ធទិន្នន័យមេតែមួយ។

ក្នុងរយៈពេលមធ្យម កិច្ចខិតខំ ដើម្បីស្ថាបនាកិច្ចសហប្រតិបត្តិការចាំបាច់ ត្រូវបន្តទៅទៀត ដោយក្នុងនោះរួមមានទាំងការដាក់បញ្ចូលការថែទាំនៅតាមវត្តអារាម និងតាមមណ្ឌលសាសនាដែលកំពុងផ្ដល់ការថែទាំឱ្យចូលរួមក្នុងការពិភាក្សាជាយុទ្ធសាស្ត្រដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការផ្ដល់ការថែទាំអោយកាន់តែប្រសើរ។ ឱកាសដើម្បីស្ថាបនាស្ពានតភ្ជាប់ជាមួយក្រុមទាំងអស់នេះ ដែលជារឿយៗតែងធ្វើសកម្មភាពជាឯករាជ្យ អាចត្រូវបានសម្របសម្រួលដោយក្រុមមានមូលដ្ឋានលើផ្នែកជំនឿដទៃទៀត ដែលចូលរួមយ៉ាងសកម្មនៅក្នុងកំណែទម្រង់ក្នុងការថែទាំជំនួស។ យើងបានដឹងថា អង្គការ កុមារក្នុងគ្រួសារ ដែលជាដៃគូមួយរបស់ ACCIR បានបង្កើតឡើងក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០០៥ ហើយបានចុះបញ្ជីជាផ្លូវការ និងត្រូវបានទទួលស្គាល់ជាអ្នកផ្ដល់សេវាការថែទាំជំនួសដែលមានមូលដ្ឋាននៅតាមគ្រួសារដំបូងបំផុតនៅកម្ពុជាក្នុងឆ្នាំ ២០០៦ ដែលមានគោលជំហរដ៏ល្អបំផុតដើម្បីបើកកិច្ចសន្ទនានេះ។ ព័ត៌មានដែលប្រមូលបានគួរត្រូវបានដាក់បញ្ចូលនៅក្នុងគេហទំព័រកណ្ដាលមួយទាក់ទងជាមួយអ្នកផ្ដល់សេវាសំខាន់នានា។[22]

នៅពេលដែលភារកិច្ច និងការទទួលខុសត្រូវត្រូវបានកំណត់ច្បាស់លាស់ ហើយកិច្ចសហប្រតិបត្តិការត្រូវបានធ្វើឱ្យប្រសើរឡើងជាអតិបរមា នោះការចាត់កញ្ចប់ថវិកាឱ្យបានគ្រប់គ្រាន់មានភាពចាំបាច់ដើម្បីធានាការផ្ដល់សេវាប្រកបដោយគុណភាពដែលមានលក្ខណៈប្រកបដោយនិរន្តរភាព។ នៅដំណាក់កាលនេះ ជាការសំខាន់ណាស់ដែលត្រូវមានការប្ដេជ្ញាចិត្តផ្នែកនយោបាយដើម្បីយល់អំពីគុណតម្លៃផ្នែកសង្គម និងសេដ្ឋកិច្ចរយៈពេលវែងនៃការវិនិយោគលើកុមារ។ យើងសូមលើកទឹកចិត្តដល់រដ្ឋាភិបាលឱ្យធ្វើការយ៉ាងជិតស្និទ្ធជាមួយការផ្ដួចផ្ដើមគំនិត ឬការងារប្រហាក់ប្រហែលនេះ ដែលអាចជួយ «កំណត់ផលចំណេញផ្នែកសង្គម និងសេដ្ឋកិច្ចរយៈពេលវែងបានមកពីការវិនិយោគលើកុមារ។ ឧបករណ៍នេះនឹងរួមបញ្ចូលគំរូផ្នែកសេដ្ឋកិច្ចមួយដែលឈរលើព័ត៌មានស្ដីពីការចំណាយលើសេវានានា និងយុទ្ធវិធីនានា ដើម្បីគាំទ្រដល់កុមារ និងគ្រួសារដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ។ តាមរយៈការប្រើប្រាស់ទិន្នន័យការសិក្សារយៈពេលយូរដែលមានស្រាប់ គំរូនេះនឹងជួយស្វែងយល់អំពីលទ្ធផលរំពឹងទុកសម្រាប់កុមារ គ្រួសារ និងសង្គម»។[23] គួរចាត់ឱ្យមានកញ្ចប់ថវិកាសម្រាប់ការគាំទ្ររបស់រដ្ឋចំពោះគ្រួសារ និងការអភិវឌ្ឍនូវកម្មវិធីសុខុមាលភាពថ្នាក់ជាតិ ប្រហាក់ប្រហែលជាមួយបណ្ដាប្រទេសដទៃ។[24] ដូចគ្នានេះដែរ គួរកំណត់ថវិកាសម្រាប់ការអនុវត្តគោលដៅសមាហរណកម្មកុមារ ៣០ ភាគរយនៅទូទាំងប្រទេសដែលចែងថា «ការអនុញ្ញាតឱ្យកុមារស្នាក់នៅក្នុងមណ្ឌលថែទាំកុមារ គឺជាជម្រើសចុងក្រោយ និងជាជម្រើសបណ្ដោះអាសន្ន ហើយអាចធ្វើឡើងបានតែនៅក្រោយពេលការស្រាវជ្រាវរកឪពុកម្ដាយទាំងពីរ ឬឪពុក ឬម្ដាយ សាច់ញាតិ ឬអាណាព្យាបាល ឬឪពុកម្ដាយធម៌ត្រូវបានធ្វើអស់លទ្ធភាពហើយ»។[25]

22 See: http://www.community.nsw.gov.au/for-agencies-that-work-with-us/child-protection-services

23 www.eurochild.org/projects/childonomics/ ឧបករណ៍នេះពិនិត្យ «លើការចំណាយផ្នែកសង្គមរយៈពេលវែងផ្សារភ្ជាប់ជាមួយការវិនិយោគមិនបានគ្រប់គ្រាន់ និងការផ្ដល់មូលនិធិមិនចំគោលដៅនៃប្រព័ន្ធការថែទាំហួសសម័យ ដែលបំបែក និងផាត់កុមារងាយរងគ្រោះ និងគ្រួសាររបស់ពួកគេឱ្យខិតកាន់តែឆ្ងាយថែមទៀត (...) ឧបករណ៍នេះ នឹងផ្ដល់មធ្យោបាយដើម្បីចូលរួមក្នុងកិច្ចសន្ទនាជាមួយក្រសួងហិរញ្ញវត្ថុ និងអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងការចំណាយសាធារណៈនៅក្នុងវិស័យផ្សេងៗទាំងអស់។ ឧបករណ៍នេះ ក៏អាចត្រូវបានប្រើប្រាស់ដើម្បីជះឥទ្ធិពលលើអ្នកផ្ដល់ជំនួសឯកជន និងអ្នកផ្ដល់ជំនួសសប្បុរសធម៌ ដោយក្នុងនោះ ប្រព័ន្ធនិរន្តរភាពមិនអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ»។

24 ចំណងទាក់ទងរវាងការការពារកុមារ និងអភិបាលកិច្ចល្អ៖ www.terredeshommes.org/wp-content/uploads/2013/06/20130315_the_links_between_child_protection_and_good_governance.pdf at 10-14; Taking child protection to the next level in Kenya www.unicef.org/protection/files/Kenya_CP_system_case_study.pdf, Building a national child protection system in Ghana: From evidence to policy and practice at 15-19, www.unicef.org/protection/files/Ghana_CP_system_case_study.pdf

25 មាត្រា ១១ អនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (ឆ្នាំ ២០១៥)។

## អនុសាសន៍ទី ១

# កំណត់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ លើកកម្ពស់កិច្ចសហប្រតិបត្តិការឱ្យបានរឹងមាំ និងធានាឱ្យមានថវិកាគ្រប់គ្រាន់

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| កិច្ចព្រមព្រៀងអំពីសកម្មភាព | ១ អភិវឌ្ឍបញ្ជីផ្ទៀងផ្ទាត់/ក្រាហ្វិចលំហូរការងារនៃសកម្មភាពពាក់ព័ន្ធជាមួយការថែទាំជំនួស និងសុំកូន ដោយមានការដាក់មុខងារយោងទៅតាមក្របខ័ណ្ឌការងារថ្នាក់ជាតិ។<br>២ អភិវឌ្ឍឱ្យមានតារាងអង្គការលេខ គូសបញ្ជាក់អំពីសមត្ថកិច្ច ឬស្ថាប័នដែលត្រូវបានអនុញ្ញាតដោយច្បាប់កម្ពុជា។ | គណៈកម្មាធិការជាតិការពារកុមារ និងក្រសួងពាក់ព័ន្ធទាំងអស់រួមគ្នា ដឹកនាំដោយក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF, 3PC, FCF. ISS if mandated could assist in the drafting of checklist/ flowchart/ organi-gramme. Alternatively CORAM could cover this through Theory of Change work | ២០១៨ |
| ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នមានសមត្ថកិច្ច | ១ រៀបចំការបណ្តុះបណ្តាលអន្តរវិស័យឱ្យបានទៀងទាត់ស្តីពីការថែទាំជំនួស និងសុំកូន ដល់ភាគីពាក់ព័ន្ធទាំងអស់ ដោយប្រើកម្មវិធីសិក្សាដូចគ្នា (ឧ. ការអភិវឌ្ឍនូវកំណត់សម្គាល់អន្តរក្រសួង និងការបណ្តុះបណ្តាលស្តីពីការអនុវត្ត)។ | គណៈកម្មាធិការជាតិការពារកុមារ និងក្រសួងពាក់ព័ន្ធទាំងអស់រួមគ្នា។ | UNICEF, Global Alliance for Children, Royal University of Phnom Penh and the National Institute of Social Affairs | ២០១៨ តទៅ |
| កិច្ចព្រមព្រៀងអំពីការទទួលខុសត្រូវ | ១ គណៈកម្មាធិការត្រូវរៀបចំកិច្ចប្រជុំតុមូលដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធទាំងអស់ ដើម្បីឈានដល់កិច្ចព្រមព្រៀង។<br>២ គណៈកម្មាធិការត្រូវបង្កើតក្រុមដឹកនាំ ដើម្បីរៀបចំកិច្ចព្រមព្រៀងឱ្យចប់ជាស្ថាពរ។<br>៣ កំណត់សម្គាល់អន្តរក្រសួង ដែលត្រូវសរសេរព្រាងដោយគូសបញ្ជាក់អំពីការទទួលខុសត្រូវ និងការបំពេញមុខងារ។ | គណៈកម្មាធិការ និងក្រសួងពាក់ព័ន្ធទាំងអស់ ដឹកនាំដោយក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |

## រយៈពេលមធ្យម (២០១៩-២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| បន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នមានសមត្ថកិច្ច និងអង្គការផ្អែកជំនឿ | ១ ការបង្កើតមជ្ឈមណ្ឌលព័ត៌មានឱ្យចូលរួមជាស្ថាពរដោយមានព័ត៌មានជំរឿនដែលអាចឱ្យអ្នកអាចពាក់ព័ន្ធបើកមើលបាន នៅក្នុងគេហទំព័រ។<br>២ ចាំបាច់ត្រូវមានកិច្ចខិតខំយ៉ាងសកម្ម ជាយុទ្ធសាស្ត្រ ដើម្បីដាក់បញ្ចូលក្រុមផ្តល់ការថែទាំនៅតាមវត្តអារាម និងតាមបែបជំនឿ។ | ដឹកនាំដោយក្រសួង ស.អ.យ ធ្វើការជាមួយគណៈកម្មាធិការជាតិការពារកុមារ និង ក្រសួងពាក់ព័ន្ធទាំងអស់។ | UNICEF, Global Alliance for Children, Royal University of Phnom Penh and the National Institute of Social Affairs. CIF/ ACCIR could help engage with faith based groups. | ២០១៩ តទៅ |

## រយៈពេលវែង (ហួសពីឆ្នាំ ២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| ធ្វើការស្រាវជ្រាវដើម្បីសម្របសម្រួលដល់ការតស៊ូមតិឱ្យមានឆន្ទៈនយោបាយក្នុងការធានាឱ្យមានកញ្ចប់ថវិកាគ្រប់គ្រាន់ | ១ ធ្វើការស្រាវជ្រាវ ដើម្បីកំណត់រកផលចំណេញផ្នែកសង្គម និងសេដ្ឋកិច្ចរយៈពេលវែង ដែលបានលទ្ធផលមកពីការវិនិយោគលើកុមារ (២០២០-២០២២)។<br>២ បង្កើយការស្រាវជ្រាវឱ្យចូលរួមជាស្ថាពរក្នុងឆ្នាំ ២០២៣។<br>៣ ផ្អែកលើការស្រាវជ្រាវ ត្រូវតស៊ូមតិចំពោះក្រសួងហិរញ្ញវត្ថុឱ្យមានកញ្ចប់ថវិកាឱ្យបានគ្រប់គ្រាន់។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF, Childonomics | ២០២៣ តទៅ |
| ការចាត់កញ្ចប់ថវិកា | ១ ពិនិត្យលើប្រព័ន្ធសុខុមាលភាពដទៃទៀតរបស់រដ្ឋ ដើម្បីយល់អោយបានច្បាស់ថា តើអ្វីខ្លះដែលអាចធ្វើបានសម្រាប់ប្រទេសកម្ពុជា។<br>២ ធានាឱ្យមានការគាំទ្រពីរដ្ឋដល់គ្រួសារ តាមរយៈកម្មវិធីសុខុមាលភាពជាតិ។ | ក្រសួងពាក់ព័ន្ធទាំងអស់។ | UNICEF | ២០២៣ តទៅ |

# អនុសាសន៍ទី

# ២

## បង្កើតប្រព័ន្ធទិន្នន័យមេ ថ្នាក់ជាតិ ស្តីពីកុមារប្រឈម ការបំបែកចេញពីគ្រួសារ (ក្នុងករណីអន្តរាគមន៍បានចាប់ផ្តើមរួចហើយ) និងអំពីកុមារស្ថិតក្នុងការថែទាំជំនួស (ពោលគឺចាប់តាំងពីចូលកន្លែងថែទាំរហូតដល់ ចេញកន្លែងថែទាំ)

**ST** ធ្វើបញ្ជី អំពីការចុះបញ្ជីដែលមានស្រាប់ និងកំណត់រកការអនុវត្តល្អៗដែលមានស្រាប់ក្នុងការគ្រប់គ្រងលើការចុះបញ្ជី។

**MT** ស្វែងរកមូលនិធិ ដើម្បីបង្កើតប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិ និងធ្វើតេស្តប្រព័ន្ធទិន្នន័យមេនេះនៅតំបន់ណាមួយ ឬច្រើនតំបន់។

**LT** អនុវត្តប្រព័ន្ធទិន្នន័យមេទូទាំងប្រទេស។

ប្រព័ន្ធទិន្នន័យមេអេឡិចត្រូនិចសព្វជ្រុងជ្រោយនឹងជួយកំណត់អត្តសញ្ញាណកុមារបានត្រឹមត្រូវ និងពិនិត្យតាមដានកុមារទាំងអស់ដែលចូលមកក្នុងការថែទាំ។ ប្រព័ន្ធទិន្នន័យមេ គឺជាឧបករណ៍គន្លឹះមួយសម្រាប់ការគ្រប់គ្រងករណី និងដើម្បីធានាឱ្យបានថាកុមារទាំងអស់បានធ្វើផែនការអចិន្ត្រៃយ៍ និងទទួលអត្ថប្រយោជន៍ពីជម្រើសការថែទាំល្អបំផុត។ ប្រព័ន្ធទិន្នន័យមេក៏អាចជួយដល់អ្នកប្រកបវិជ្ជាជីវៈនានា ដូចជាអ្នកធ្វើគោលនយោបាយ អ្នកតស៊ូមតិ អ្នកស្រាវជ្រាវ និងអ្នកផ្តល់សេវានានា បង្កើតប្រព័ន្ធការពារកុមារដែលអាចឆ្លើយតបចំពោះសេចក្តីត្រូវការរបស់កុមារបានគ្រប់គ្រាន់។ ដូចគ្នានេះដែរ ចំពោះទិន្នន័យដែលត្រូវរក្សាការសម្ងាត់ ទិន្នន័យនោះអាចដកយកទៅសម្រាប់ធ្វើគោលនយោបាយ និងផែនការបាន។

ច្បាប់កម្ពុជាតម្រូវឱ្យមានការចុះបញ្ជី ច្រើនចំពោះកុមារដែលរស់នៅក្នុងកន្លែងថែទាំកុមារ (ឧ. ឯកសារអំពីកិច្ចខិតខំក្នុងការរក្សាកុមារនៅជាមួយគ្រួសារ និងការបង្រួបបង្រួមជាមួយគ្រួសារមុនពេលចាប់ផ្តើមធ្វើផែនការអចិន្ត្រៃយ៍[26] ការចុះបញ្ជីកុមារដែលត្រូវបានគេបោះបង់សំណុំឯកសារ[27] សម្រាប់កុមារម្នាក់ៗដែលត្រូវបានរក្សាដោយមណ្ឌលថែទាំកុមារ និងអ្នកផ្តល់ការថែទាំជំនួសនៅក្នុងសហគមន៍[28] ការចុះបញ្ជីកុមារដែលនៅក្រោមអំណាចមេបានៃការថែទាំរបស់ក្រសួង ស.អ.យ[29] ការចុះបញ្ជីកុមារដែលអាចសុំកូនអន្តរប្រទេស)[30]។

26 ប្រកាសឆ្នាំ ២០១១ ស្តីពីនីតិវិធីដើម្បីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ មាត្រា ២៤។
27 ច្បាប់ស្តីពីសុំកូនឆ្លងប្រទេស មាត្រា ១១។
28 ប្រកាសឆ្នាំ ២០០៦ ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ការថែទាំកុមារនៅមណ្ឌលថែទាំ មាត្រា ៨ និងប្រកាសឆ្នាំ ២០០៨ ស្តីពីបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសសម្រាប់កុមារនៅក្នុងសហគមន៍ មាត្រា ៩។
29 ច្បាប់ស្តីពីសុំកូនឆ្លងប្រទេស មាត្រា ១២។
30 ច្បាប់ស្តីពីសុំកូនឆ្លងប្រទេស មាត្រា ១៣។

ប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិមានលក្ខណៈសព្វជ្រុងជ្រោយអាចបង្កើតបានដោយផ្អែកលើមូលដ្ឋានផ្អែកច្បាប់ ដែលមានស្រាប់។ ឥឡូវនេះបញ្ហាប្រឈម គឺធ្វើយ៉ាងណាដើម្បីបង្កើតប្រព័ន្ធទិន្នន័យមេ ដែលអាចភ្ជាប់ទំនាក់ទំនងរវាងការចុះបញ្ជីដែលមានស្រាប់ទាំងអស់ទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ខេត្តនិងការដាក់បញ្ចូលបញ្ជីថ្មីៗទាំងឡាយណា ដែលត្រូវបង្កើតឡើងថែមទៀត (ឧ. ការចុះបញ្ជីកុមារដែលអាចដាក់ឱ្យសុំកូនបាន និងការសុំកូនក្នុងប្រទេសជាដើម សូមមើលអនុសាសន៍ទី ២០)។ រាល់ប្រព័ន្ធទិន្នន័យមេ ដែលសម្របសម្រួលនៅថ្នាក់កណ្តាលគួរត្រូវបានស្ថាបនាឡើងផ្អែកលើប្រព័ន្ធប្រមូលទិន្នន័យរដ្ឋបាលថ្នាក់ឃុំ (ពោល គឺប្រព័ន្ធទិន្នន័យមេឃុំ)។

សម្រាប់រយៈពេលខ្លី ភារកិច្ចដំបូងគឺត្រូវបង្កើតបញ្ជីនៃកាចុះបញ្ជីដែលមានស្រាប់ទាំងអស់ ទាំងនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ហើយត្រូវកំណត់អត្តសញ្ញាណអាជ្ញាធរទទួលបន្ទុកលើការចុះបញ្ជីនៅថ្នាក់នីមួយៗ។ បន្ថែមលើប្រព័ន្ធទិន្នន័យមេរបស់រដ្ឋាភិបាលយើងក៏បានដឹងដែរថា អ្នកដើរតួនាទីសង្គមស៊ីវិលក៏មានការចុះបញ្ជីផងដែរ។ ការចុះបញ្ជីដោយអង្គការសង្គមស៊ីវិលទាំងនេះរួមមានដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់អង្គការទស្សនៈពិភពលោក ប្រព័ន្ធទិន្នន័យមេរបស់កម្មវិធី 3PC ដែលកត់ត្រាករណីទាំងអស់ ដែលបានទទួលតាមរយៈបណ្តាញទូរស័ព្ទទាន់ហេតុការណ៍របស់ខ្លួន ហើយផែនការរបស់ FCF ដើម្បីបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានពហុទីភ្នាក់ងារមួយ។ បញ្ជីសារពើភ័ណ្ឌនេះនឹងជួយកំណត់ថាតើមានវិធានការការពារកុមារជាក់លាក់ណាមួយដែល មានរាយការណ៍ទន់ខ្សោយ និងមានការតភ្ជាប់គ្នាមិនទាន់បានល្អ[31] តើមានតម្រូវការឱ្យមានការចុះបញ្ជីថែមទៀត ឬទេ តើតំបន់ជាក់លាក់ណាមួយជួបប្រទះបញ្ហាប្រឈមក្នុងការអនុវត្តធំធេង ហើយតើមានធាតុណាមួយដែលរារាំងអ្នកប្រើប្រាស់មិនចេះអក្សរក្នុងការប្រើប្រាស់ការចុះបញ្ជីនេះ ឬទេ។ រាល់បញ្ហាប្រឈមទាំងអស់ចាំបាច់ត្រូវបានកត់ត្រាទុក។

បញ្ជីនេះនឹងផ្តល់ឱកាសក្នុងការកំណត់អត្តសញ្ញាណលើការចុះបញ្ជីទាំងអស់នោះ ដែលបំពេញមុខងារបានសមស្រប ហើយអាចដើរតួនាទីជាគំរូ។ បន្ថែមលើនេះទៀតបញ្ជីសារពើនេះនឹងផ្តល់ឱកាស ដើម្បីធ្វើឱ្យប្រាកដថា តើមានទម្រង់ជាលក្ខណៈបទដ្ឋានត្រូវបានប្រើប្រាស់ឬទេ តើទម្រង់ទាំងនោះងាយស្រួលយល់សម្រាប់សារធារណជន ឬទេ និងតើមានសេចក្តីត្រូវការដើម្បីកែលម្អទម្រង់ ដែលមានស្រាប់ ឬត្រូវបង្កើតទម្រង់ថ្មី។ ការងារនេះនឹងជួយបំពេញបន្ថែមទៅលើការងារក្នុងការបន្ស៊ីទម្រង់ ដែលមានស្រាប់ឱ្យមានលក្ខណៈស៊ីសង្វាក់គ្នា។

ជំនាញការដែលបង្កើតបញ្ជីសារពើភ័ណ្ឌនេះ គួរសរសេរព្រាងរបាយការណ៍មួយ ដែលដាក់បញ្ចូលអនុសាសន៍ស្តីពីធនធានដែលត្រូវការទាក់ទងជាមួយឧបករណ៍ ការបង្កើតទម្រង់ ការសម្របសម្រួល ការចុះបញ្ជីដែលមានស្រាប់ និងការបង្កើតប្រព័ន្ធទិន្នន័យមេរួមគ្នាព្រមទាំងការបណ្តុះបណ្តាលលើអ្នកគ្រប់គ្រងការចុះបញ្ជីនោះ។ របាយការណ៍អាចផ្តល់អនុសាសន៍ផ្អែកលើប្រព័ន្ធទិន្នន័យមេ ដែលមានស្រាប់នៅក្នុងបណ្តាប្រទេសដទៃ។[32]

អនុសាសន៍នេះ គួរត្រូវបានពិចារណាផ្សារភ្ជាប់ជាមួយ CPIMs គាំទ្រដោយ FCF ហើយអាចពិចារណាលើការប្រើប្រាស់ PRIMERO[33] ដែលជាកម្មវិធីសហ្វវែរប្រភពបើកចំហរ ដោយហេតុថាជម្រើសនេះទំនងជាអស់ថ្លៃតិចជាងច្រើន បើធៀបនឹងជម្រើស ដែលត្រូវទិញ។

សម្រាប់រយៈពេលមធ្យម អាជ្ញាធរកម្ពុជាចាំបាច់ត្រូវស្វែងរកមូលនិធិ ដើម្បីអនុវត្តអនុសាសន៍ទាក់ទងជាមួយប្រព័ន្ធទិន្នន័យមេ។ អាជ្ញាធរកណ្តាលសម្រាប់សុំកូនជាច្រើនមកពីរដ្ឋទទួលបានបង្ហាញចំណាប់អារម្មណ៍លើលទ្ធភាពក្នុងការប្រមូលផ្តុំធនធាន ដើម្បីជួយបង្កើតប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិនេះ។ ពេលបានទទួលមូលនិធិ ដែលចាំបាច់រួចហើយ ប្រព័ន្ធទិន្នន័យមេ

31 ឧ. ការធានាឱ្យបានថា រាល់ការចុះបញ្ជីទាំងអស់ទាក់ទងជាមួយវិធានការការពារ និងសុំកូនមានការតភ្ជាប់គ្នានឹងអាចជួយបង្កើនប្រសិទ្ធភាពការងារធ្វើឡើងដោយ NGOs ដែលផ្តល់សេវាក្នុងវិស័យការបង្រួបបង្រួមគ្រួសារ និងការថែទាំជំនួសនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ន ពុំទាន់មានបណ្តាញច្បាស់លាស់សម្រាប់ចែករំលែកព័ត៌មានស្តីពីកុមាររវាង NGOs និងអាជ្ញាធរទេ។ ការចុះបញ្ជីនឹងមានសារៈសំខាន់ជាខ្លាំងសម្រាប់ការចែករំលែកព័ត៌មានដែល NGO នីមួយៗមាន។

32 ឧ. សូមមើលគម្រោងការពារកុមារបែបរួមបញ្ចូលរបស់ប្រទេសឥណ្ឌា (ICPS) គម្រោងគាំទ្រថ្នាក់កណ្តាលរបស់រដ្ឋាភិបាលជាមួយភាពជាដៃគូសង្គមស៊ីវិល www.cara.nic.in/writereaddata/uploadedfile/NTESCL_635761170436561995_final_icps.pdf។ ក្នុងប្រទេស Lithuania ក្រុងនីមួយៗមានការចុះបញ្ជីក្នុងមូលដ្ឋានរបស់ខ្លួនផ្ទាល់ ដោយក្នុងនោះរួមមានដូចជាសេវាសង្គមកិច្ច និងការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលគ្រួសារនីមួយៗបានទទួល និងតើការចាត់កញ្ចប់ថវិកានោះត្រូវបានប្រើប្រាស់ដោយរបៀបណា។ ក្រុងចាំបាច់ត្រូវផ្តល់ព័ត៌មាននេះទៅដល់ប្រព័ន្ធទិន្នន័យមេថ្នាក់កណ្តាល។ ក្រសួងសន្តិសុខសង្គម និងការងារទទួលបន្ទុកលើប្រព័ន្ធទិន្នន័យមេថ្នាកកណ្តាល ហើយគ្រប់គ្រង និងមើលខុសត្រូវលើការកត់ត្រាទិន្នន័យឱ្យបានត្រឹមត្រូវ។ សូមមើល៖ www.spis.lt។ ក្នុងប្រទេស Scotland អាជ្ញាធរមូលដ្ឋានទាំងអស់ទទួលខុសត្រូវក្នុងការរក្សាការចុះបញ្ជីថ្នាក់កណ្តាលមួយ ដោយក្នុងនោះមានទាំងកូនស្លាប់ក្នុងពោះដែលជាកម្មវត្ថុនៃផែនការការពារកុមារអន្តរទីភ្នាក់ងារ ( សូមមើល៖ www.gov.scot/Resource/0045/00450733.pdf) ឧទាហរណ៍ផ្សេងៗទៀតនៅក្នុងប្រទេសអូស្ត្រាលី៖ www.dhs.vic.gov.au/about-the-department/plans,-programs-and-projects/programs/children,-youth-and-family-services/looking-after-children-in-victoria-lac/lac-references-and-reports/looking-after-children-assessment-and-records-redevelopment និងនៅក្នុងចក្រភពអង់គ្លេស៖ www.gov.uk/government/uploads/system/uploads/attachment_data/file/419595/Working_Together_to_Safeguard_Children.pdf

33 http://www.primero.org/

រួមមួយអាចត្រូវបានបង្កើតឡើង។ ជំហានបន្ទាប់ទៀត គឺត្រូវផ្តល់ការបណ្តុះបណ្តាល ដែលចាំបាច់ដល់អ្នកប្រកបរបរវិជ្ជាជីវៈជាអ្នកគ្រប់គ្រងលើប្រព័ន្ធទិន្នន័យមេនេះ។ ក្រុមការងារស្រាវជ្រាវសូមផ្តល់អនុសាសន៍ឱ្យធ្វើតេស្តសាកល្បង ដើម្បីពិនិត្យមើលថាតើការចុះបញ្ជី និងប្រព័ន្ធទិន្នន័យមេត្រូវតភ្ជាប់យ៉ាងដូចម្តេចតាមរយៈគម្រោងសាកល្បងនៅក្នុងតំបន់ណាមួយ ឬពីរតំបន់។ ការធ្វើតេស្តសាកល្បងនេះនឹងផ្តល់ឱកាស ដើម្បីវាយតម្លៃថាតើអ្វីខ្លះដែលត្រូវកែសម្រួល និងធ្វើការសម្របទៅតាមអ្វីដែលចាំបាច់។

សម្រាប់រយៈពេលវែង គោលបំណងគឺ ដើម្បីអាចអនុវត្តប្រព័ន្ធទិន្នន័យមេជាបណ្តើរៗក្នុងតំបន់ដទៃទៀត ហើយចុងក្រោយនឹងត្រូវអនុវត្តនៅទូទាំងប្រទេស។ សំណុំឯកសាររបស់កុមារគួរស្ថិតនៅក្នុងប្រព័ន្ធទិន្នន័យមេឱ្យបានយូរបំផុតតាមការចាំបាច់ ដោយក្នុងនោះត្រូវដាក់បញ្ចូលនូវព័ត៌មានស្តីពីការថែទាំជំនួស (ឧ. អន្តរាគមន៍បឋម និងការថែទាំដោយឪពុកម្តាយធម៌ក្នុងករណីអាសន្ន) រហូតដល់សុំកូនអន្តរប្រទេស។ ជាការសំខាន់ផងដែរ ដែលត្រូវមានការគ្រប់គ្រងលទ្ធភាពចូលទៅបើកមើលទិន្នន័យទាំងអស់នេះឱ្យបានសមស្រប។

## អនុសាសន៍ទី ២

## បង្កើតប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិដែលមានការសម្របសម្រួលសព្វជ្រុងជ្រោយស្តីពីកុមារប្រឈមហានិភ័យ ចំពោះការបំបែកចេញពីគ្រួសារ (ពោលគឺក្នុងករណីអន្តរាគមន៍បានចាប់ផ្តើមរួចហើយ) និងកុមារស្ថិតក្នុងកន្លែងថែទាំ (ពោលគឺចាប់ពីចូលដល់ចេញពីកន្លែងថែទាំ)

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បញ្ជីប្រព័ន្ធទិន្នន័យមេដែលមានស្រាប់ | ១ បញ្ជីប្រព័ន្ធទិន្នន័យមេរបស់រដ្ឋាភិបាល (នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និងអាជ្ញាធរទទួលខុសត្រូវ។<br>២ បញ្ជីប្រព័ន្ធទិន្នន័យមេរបស់ អង្គការសង្គមស៊ីវិលដែលមានស្រាប់។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| តារាងនៃប្រព័ន្ធទិន្នន័យមេ ដែលមានស្រាប់ | ១ បង្កើតម៉ាទ្រិចនៃប្រព័ន្ធទិន្នន័យមេទាំងអស់។<br>២ ចំណុចខ្លាំង/ចន្លោះប្រហោងក្នុងការគ្រប់ដណ្តប់របស់ប្រព័ន្ធទិន្នន័យមេ/មុខងារ និងលក្ខណៈសម្បត្តិងាយស្រួលសម្រាប់អ្នកប្រើប្រាស់។<br>៣ ធ្វើសេចក្តីព្រាងរបាយការណ៍ស្តីពីធនធានដែលត្រូវការ (ឧបករណ៍ ទម្រង់ការសម្របសម្រួលលើការចុះបញ្ជីដែលមានស្រាប់។ល។)។<br>៤ កិច្ចប្រជុំតុមូល ដើម្បីព្រមព្រៀងគ្នាលើការបង្កើតប្រព័ន្ធទិន្នន័យមេរួមមួយ (ការបញ្ចូលទិន្នន័យលទ្ធភាពបើកមើលឯកជនភាព។ល។)។ | ក្រសួង ស.អ.យ ជាមួយក្រសួងពាក់ព័ន្ធទាំងអស់។ | UNICEF, 3PC, FCF | ២០១៨ |

## រយៈពេលមធ្យម (២០១៩-២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| កំណត់ថវិកា | ១ កំណត់ថាតើអាជ្ញាធរកណ្តាលផ្នែកស្មុំកូនណាមួយមានឆន្ទៈដើម្បីប្រមូលផ្តុំធនធានតាមរយៈ HCCH និង ISS ដើម្បីបង្កើតប្រព័ន្ធទិន្នន័យមេ។<br>២ ប្រមូលផ្តុំធនធានដាក់ទៅក្នុងមូលនិធិឯករាជ្យមួយដែលអាចប្រហែលជាស្ថិតក្រោមការគ្រប់គ្រងរបស់យូនីសេហ្វ។<br>៣ នៅពេលដែលធនធានត្រូវបានកំណត់រួចរាល់ហើយ ត្រូវបង្កើតប្រព័ន្ធទិន្នន័យមេរួមមួយដោយមានការផ្តល់ជំនួយបច្ចេកទេសតាមការចាំបាច់។ | ក្រសួង ស.អ.យ និងក្រសួងហិរញ្ញវត្ថុ។ | យូនីសេហ្វ 3PC, FCF, HCCH និង ISS។ | ២០១៩ តទៅ |
| អនុវត្តសាកល្បងប្រព័ន្ធទិន្នន័យមេ | ១ អនុវត្តសាកល្បងប្រព័ន្ធទិន្នន័យមេនៅក្នុងតំបន់មួយ ឬពីរ។<br>២ កែសម្រួលប្រព័ន្ធទិន្នន័យមេឱ្យដំណើរការដោយរលូន។<br>៣ បណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធទិន្នន័យមេ។ | ក្រសួង សអយ។ | UNICEF, 3PC, FCF | ២០១៩ តទៅ |

## រយៈពេលវែង (ហួសពី ២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| ការដាក់ឱ្យអនុវត្តប្រព័ន្ធទិន្នន័យមេ | ១ ថវិកាសម្រាប់ប្រតិបត្តិការប្រព័ន្ធទិន្នន័យមេជាបន្ត។ សូមកត់សម្គាល់ថា ប្រសិនបើប្រើ PRIMERO[34] ថវិកានេះអាចមានទំហំតូចប៉ុណ្ណោះ។<br>២ អនុវត្តប្រព័ន្ធទិន្នន័យមេជាបណ្តើរៗទៅកាន់តំបន់ដទៃទៀត។<br>៣ ការបណ្តុះបណ្តាលថ្នាក់តំបន់។<br>៤ ការវាយតម្លៃដោយឯករាជ្យទៅលើប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិ។<br>៥ កែសម្រួលប្រព័ន្ធទិន្នន័យមេឱ្យដំណើរការដោយរលូន។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

34 http://www.primero.org/

# អនុសាសន៍ទី ៣

## ពង្រឹងវិស័យការងារសង្គមកិច្ច និងការបណ្តុះបណ្តាល អ្នកប្រកបវិជ្ជាជីវៈអាជីពវិស័យសង្គមទាំងអស់

**ST** រៀបចំកែសម្រួលកម្មវិធី ដែលមានស្រាប់ អោយមានស្តង់ដាបទដ្ឋានបណ្តុះបណ្តាលតែមួយ (របស់រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល)។

**MT** ធ្វើសេចក្តីព្រាងសៀវភៅណែនាំការអនុវត្ត និងការពិនិត្យតាមដានប្រកាស និងគោលនយោបាយជាតិដែលពាក់ព័ន្ធនានា។

បង្កើតក្រុមចល័តទទួលបន្ទុក "យុត្តិធម៌កុមារមេត្រី"។

បកប្រែវគ្គសិក្សាតាមប្រព័ន្ធអ៊ីនធើណេតបើកចំហទូលំទូលាយស្តីពីការថែទាំជំនួសទៅជាភាសាខ្មែរ។

**LT** បង្កើតវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់អ្នកផ្តល់សេវាសង្គមកិច្ច។

បុគ្គលិកសង្គមកិច្ចមានជំនាញ អ្នកជំនួយការសង្គមកិច្ច និងអ្នកចិត្តវិទ្យាកុមារត្រូវបានកំណត់ឃើញថា គឺជាសេចក្តីត្រូវការរួមមួយ ហើយជាកិច្ចឆ្លើយតប ចំពោះសេចក្តីត្រូវការនេះ គឺទាមទារនូវយុទ្ធវិធីបែបសព្វជ្រុងជ្រោយរយៈពេលវែងមួយ ដើម្បីពង្រឹងវិស័យនេះ អោយបានគ្រប់ជ្រុងជ្រោយ។ ការងារនេះតម្រូវឱ្យមានការបណ្តុះបណ្តាលដល់អ្នកប្រកបវិជ្ជាជីវៈនាពេលបច្ចុប្បន្ន ជាពិសេស គឺអ្នកផ្តល់សេវាសង្គមកិច្ច។ ភាគីពាក់ព័ន្ធទាំងអស់បានឯកភាពថា នេះជាសកម្មភាព អាទិភាពមួយ។ រាល់ការបណ្តុះបណ្តាល បន្ទាប់មកទៀត ចាំបាច់ត្រូវពង្រឹងបន្ថែមលើការងាររបស់យូនីសេហ្វ ដើម្បីបំពាក់លក្ខណៈសម្បត្តិអោយបានគ្រប់គ្រាន់ដល់បុគ្គលិកសង្គមកិច្ចទាំង ៣០ នាក់ ដែលជាបុគ្គលិករដ្ឋាភិបាលនាពេលបច្ចុប្បន្ន ព្រមទាំងផ្តល់ធនធានការបណ្តុះបណ្តាលដទៃទៀត ដែលបានបង្កើតឡើងដោយដៃគូ។ ដៃគូបច្ចេកទេសសំខាន់ៗអាចរួមមានទាំងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលមានថ្នាក់បរិញ្ញាបត្រផ្នែកសង្គមកិច្ចវិទ្យា និងថ្នាក់អនុបណ្ឌិតក្នុងផ្នែកសង្គមកិច្ចវិទ្យា ព្រមទាំងវិទ្យាស្ថានជាតិសង្គមកិច្ចរបស់ក្រសួង ស.អ.យ ដែលនាពេលថ្មីៗនេះ មានបង្រៀនវគ្គការសិក្សាកម្រិតឧត្តមសិក្សាផ្នែកសង្គមកិច្ចវិទ្យា។ កិច្ចខិតខំខាងលើនេះ គួរត្រូវបានបំពេញបន្ថែមដោយការងាររបស់ FCF ដើម្បីបង្កើតបទដ្ឋានអប្បបរមា សម្រាប់បុគ្គលិកសង្គមកិច្ច ការផ្តួចផ្តើមគំនិត ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្សព្វផ្សាយវិជ្ជាជីវៈនេះ និងការវាយតម្លៃសេចក្តីត្រូវការការបណ្តុះបណ្តាលរបស់បុគ្គលិកសង្គមកិច្ចទាក់ទងជាមួយសិទ្ធិកុមារធ្វើឡើងដោយអង្គការ Hagar និងអង្គការជំហានដំបូងកម្ពុជា។

ការបណ្តុះបណ្តាលបានប្រព្រឹត្តិទៅដាច់ពីគ្នាពុំមានលក្ខណៈជាប្រព័ន្ធនៅឡើយ។ យុទ្ធវិធីខាងលើមានភាពចាំបាច់ណាស់ បើគិតទៅលើភាពពាក់ព័ន្ធជាមួយភាគីពាក់ព័ន្ធដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ (សូមមើលអនុសាសន៍ទី ១) បូករួមជាមួយអត្រាការផ្លាស់ប្តូរការងារដ៏ខ្ពស់របស់បុគ្គលិក ជាលទ្ធផលធ្វើឱ្យបាត់បង់

ចំណេះដឹងផ្នែកស្ថាប័ន។ ម៉្យាងទៀតវាមានមានសារៈសំខាន់ខ្លាំងណាស់ ដែលក្រសួងនានា ដូចជា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងធម្មការ និងសាសនា (រួមទាំងភាគីថ្នាក់ក្រោមជាតិរបស់ពួកគេ ដូចជា គកនក និងមេភូមិជាដើម) បានទទួលវគ្គការបណ្តុះបណ្តាល ស្តីពីការថែទាំជំនួស និងបញ្ហាសុំកូន។

នៅក្នុងរយៈពេលខ្លី យើងផ្តល់អនុសាសន៍ឱ្យដាក់ការបណ្តុះបណ្តាល ដែលមានបច្ចុប្បន្នទាំងរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលឱ្យស្ថិតនៅថ្នាក់កណ្តាល ដើម្បីបង្កើតវគ្គការបណ្តុះបណ្តាលគំរូដែលមានលក្ខណៈស្តង់ដា។ អ្នកផ្តល់សេវានីមួយៗ មានសៀវភៅបណ្តុះបណ្តាល ដ៏ច្រើនសន្ធឹកសន្ធាប់ ដែលអាចទាញយកមកប្រើប្រាស់បាន ឧទាហរណ៍ ដូចជា ម៉ូឌុលស្តីពីការបំពាក់សមត្ថភាពដល់ឪពុកម្តាយក្នុងតួនាទីជាអ្នកមើលថែកុមារ (ឧ.កុមារក្នុងគ្រួសារ កុមាររីករាយម្លប់តាប៉ាង) ក៏ដូចជាការរក្សាកុមារឱ្យនៅរួមគ្នាជាមមួយគ្រួសារ (ឧ. អង្គការទំនុកចិត្តកុមារកម្ពុជា អង្គការមិត្តសំឡាញ់អន្តរជាតិ និងអង្គការប្រតិបត្តិការកុមារកម្ពុជា)។ គេអាចទាញយកឧបករណ៍ការបណ្តុះបណ្តាលអន្តរជាតិដូចជា Moving Forward[35] សន្លឹកព័ត៌មានតាមវិស័យរបស់ ISS មគ្គុទេសក៍ សម្រាប់ការអនុវត្តល្អលេខ ១៖ ការអនុវត្ត និងប្រតិបត្តិការអនុសញ្ញាសុំកូនអន្តរប្រទេសឆ្នាំ ១៩៩៣ និងមគ្គុទេសក៍សម្រាប់ការអនុវត្តល្អលេខ ២៖ ការទទួលស្គាល់គុណភាព និងស្ថាប័នបានទទួលស្គាល់គុណភាពផ្នែកសុំកូន។ (សូមមើលអនុសាសន៍ទី ៦ ស្តីពីតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិកមណ្ឌលថែទាំកុមារស្តីពីការធ្វើសមាហរណកម្ម និងអនុសាសន៍ទី ៧ ស្តីពីការបណ្តុះបណ្តាលប្តូរវេនគ្នារបស់អ្នកស្ម័គ្រចិត្តសហគមន៍)។

ឧបករណ៍បណ្តុះបណ្តាលក្នុងទម្រង់ជា សៀវភៅណែនាំសម្រាប់ការអនុវត្ត[36] និងការពិនិត្យតាមដានរបស់កម្ពុជាផ្តោតការយកចិត្តទុកដាក់លើច្បាប់ និងគោលនយោបាយជាតិ ដែលពាក់ព័ន្ធអាចត្រូវបានបង្កើតឡើងនៅក្នុងរយៈពេលខ្លី។ សៀវភៅណែនាំប្រភេទនេះ អាចដើរតួនាទីជាសៀវភៅណែនាំផ្នែកនីតិវិធីសម្រាប់អ្នកប្រកបវិជ្ជាជីវៈ និងអ្នកធ្វើការអមវិជ្ជាជីវៈទាំងអស់ដែលពាក់ព័ន្ធនៅក្នុងការងារការពារកុមារ។ ការងារនេះចាំបាច់ត្រូវពិចារណាលើសេចក្តីត្រូវការផ្សេងៗ ឧ. សម្រាប់រយៈពេលវែង អ្នកធ្វើការអមវិជ្ជាជីវៈ ដែលមានបទពិសោធន៍អាចមានបទពិសោធន៍ច្រើន ហើយបានចូលរួមការបណ្តុះបណ្តាលជាច្រើនរបស់ NGO ប៉ុន្តែពួកគេប្រហែលជាខ្វះខាតការបណ្តុះបណ្តានៅថ្នាក់សាកលវិទ្យាល័យ និងមូលដ្ឋានផ្នែកទ្រឹស្តីសម្រាប់ការងាររបស់ខ្លួន ចំណែកអ្នកវិជ្ជាជីវៈទើបបញ្ចប់ការសិក្សាថ្មីៗពីកម្មវិធីបរិញ្ញាបត្រផ្នែកសង្គមកិច្ចវិទ្យា និងអនុបណ្ឌិតផ្នែកសង្គមកិច្ចវិទ្យា ប្រហែលជាចេះចាំស្ទាត់ខាងផ្នែកគោលការណ៍ និងទ្រឹស្តីសង្គមកិច្ច ប៉ុន្តែកំពុងធ្វើការ ដើម្បីទទួលបានបទពិសោធន៍ការងារជាក់ស្តែង។ ការអភិវឌ្ឍឱ្យមានសៀវភៅដូចដែលបានពោលខាងលើអាចទាមទារឱ្យមានការសម្របសម្រួលរវាងក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិលក្នុងតំបន់នានា ដើម្បីបង្កើតភាពជាម្ចាស់/ការប្តេជ្ញាចិត្ត ដើម្បីជំរុញការអនុវត្តវិធានមានសមត្ថកិច្ចដូចដែលបានពោល។

ជាឧទាហរណ៍ នៅក្នុងទម្រង់ទទួលយកកុមាររបស់ក្រសួង ស.អ.យ (ទាំងនៅក្នុងសំណៅនាពេលបច្ចុប្បន្ន និងសំណៅដែលបានកែសម្រួលរួច) ដើម្បីកំណត់ថា តើត្រូវប្រមូលព័ត៌មានអ្វីខ្លះ នៅពេលណា និងធ្វើឡើងដោយនរណាជាដើម។ ឧទាហរណ៍មួយទៀត អាចជាការត្រៀមសំណុំឯកសារ សម្រាប់កុមារនីមួយៗ[37] ដោយក្នុងនោះរួមមានទាំងការវាយតម្លៃផ្នែកចិត្តសង្គម ផ្នែកច្បាប់ និងផ្នែកវេជ្ជសាស្ត្រក៏ដូចជាការផ្សព្វផ្សាយនូវសៀវភៅរឿងរ៉ាវជីវិត ដោយក្នុងនោះអាចទាញយកគោលគំនិតពីគំរូ ដែល ISS ធ្លាប់បានធ្វើ។[38] ឧទាហរណ៍អំពីខ្លឹមសារបន្ថែមទៀត អាចផ្តោតការយកចិត្តទុកដាក់លើកាងារបង្ការសមាហរណកម្មត្រឡប់ទៅគ្រួសារវិញ ការថែទាំដោយឪពុកម្តាយធម៌ និងសុំកូន (សូមមើលសៀវភៅប្រតិបត្តិការ សម្រាប់ធ្វើការជាមួយសំណុំឯកសារសុំកូនអន្តរប្រទេសបង្កើតឡើងក្នុង ខែកក្កដា ឆ្នាំ២០១១ ដោយអ្នកពិគ្រោះយោបល់ ICAA និង HCCH)។ល។

បន្ថែមលើការបណ្តុះបណ្តាលផ្តោតជាក់លាក់លើប្រទេសកម្ពុជាក៏អាចមានតម្លៃផងដែរក្នុងការពិចារណា ថាតើស្ថាប័នអន្តរជាតិនានា ដូចជាសម្ព័ន្ធភាពសកលសម្រាប់កុមារសម្ព័ន្ធភាពបុគ្គលិកសង្គមកិច្ចសកល ឬអង្គការយូនីសេហ្វជាដើម អាចបកប្រែវគ្គ

35 Cantwell, N.; Davidson, J.; Elsley, S.; Milligan, I.; Quinn, N. (2012). Moving Forward: Implementing the ‘Guidelines for the Alternative Care of Children’. UK: CELCIS www.alternativecareguidelines.org

36 Cantwell, N.; Davidson, J.; Elsley, S.; Milligan, I.; Quinn, N. (2012). Moving Forward: Implementing the ‘Guidelines for the Alternative Care of Children’. UK: CELCIS www.alternativecareguidelines.org

37 ISS Manual: http://www.iss-ssi.org/images/practices/ISS-ManualEnglish.pdf

38 សៀវភៅរឿងជីវិតរបស់ ISS៖ www.iss-ssi.org/index.php/en/what-we-do-en/cwd-en

សិក្សាតាមអ៊ីនធើណេតបើកទូលាយទ្រង់ទ្រាយធំ (MOOC) ស្ដីពីការថែទាំជំនួសទៅជាភាសាខ្មែរ។[39] ការងារនេះអាចមានគុណសម្បត្តិក្នុងការផ្ដល់ជូនដល់អ្នកប្រកបវិជ្ជាជីវៈរាប់ពាន់នាក់ឱ្យអាចបើកមើលខ្លឹមសារការបណ្ដុះបណ្ដាលអន្តរជាតិធ្វើឡើងដោយជំនាញការនាំមុខសំខាន់ៗ។

ចំពោះសកម្មភាពរយៈពេលមធ្យម យើងសូមផ្ដល់អនុសាសន៍ឱ្យមានការបង្កើតក្រុមគ្រូបណ្ដុះបណ្ដាលចល័ត ដើម្បីផ្ដល់ការបង្រៀន «តាមបទដ្ឋាន» ស្ដីពីសៀវភៅណែនាំអំពីការអនុវត្តនិងការពិនិត្យតាមដានរបស់កម្ពុជា។ ក្រុមគ្រូបណ្ដុះបណ្ដាលចល័តនេះ អាចរួមមាន មន្ទីរ ស.អ.យ ភាគីក្រសួងនៅថ្នាក់តំបន់ក៏ដូចជាអ្នកធ្វើការងារជួរមុខ ដែលផ្ដល់សេវារួមគ្នាជាមួយក្រុមផ្អែកជំនឿសាសនា។ ដៃគូកម្មវិធី 3PC និង FCF អាចស្ថិតក្នុងគោលជំហរដ៏ប្រសើរបំផុតក្នុងការផ្ដល់ការណែនាំ ថាតើគួរផ្ដោតគោលដៅទៅលើក្រុមណាខ្លះ។ គំនិតអំពីគម្រោងនេះត្រូវបានអភិវឌ្ឍឡើងដោយ ISS ប្រទេសប៊ុលការី[40] ដោយក្នុងនោះ សិក្ខាសិលាបង្ហាញតាមដងផ្លូវត្រូវបានដាក់ឱ្យធ្វើឡើងសម្រាប់ចៅក្រម និងបុគ្គលិកសង្គមកិច្ច ដែលផ្ដោតគោលដៅលើអ្នកប្រកបវិជ្ជាជីវៈជាង ៨៥០ នាក់ (ចៅក្រម ២៥០នាក់) នៅទូទាំងប្រទេស។ ក្នុងអំឡុងពេលការបណ្ដុះបណ្ដាលនីតិវិធីនេះ ព័ត៌មានចំណេះដឹង និងបទពិសោធន៍ត្រូវបានប្រមូលដោយរួមមានទាំងទិន្នន័យ (សូមមើលអនុសាសន៍ទី ២ ស្ដីពីប្រព័ន្ធទិន្នន័យមេ)។ គោលបំណងមួយ គឺដើម្បីធានាឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់កុមារនៅក្នុងដំណើរការនីតិវិធីយុត្តិធម៌ ដែលអាចផ្ដល់លទ្ធផលឱ្យមានបទដ្ឋានយុត្តិធម៌កុមារមេត្រី ដែលកំណត់ក្របខ័ណ្ឌការងារសម្រាប់បទដ្ឋានអប្បបរមាវិជ្ជាជីវៈនៃអ្វីដែលអាចធ្វើឡើងបានក្នុងការអនុវត្តជាក់ស្ដែង (ឧ. នរណាអាចឆ្លើយតប និងការគាំទ្រអ្វីខ្លះដែលអាចផ្ដល់ឱ្យបាន)។

សម្រាប់រយៈពេលវែង យើងសូមណែនាំឱ្យមានការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីលើកទឹកចិត្តចំនួនអ្នកប្រកបវិជ្ជាជីវៈកាន់តែច្រើនជាពិសេស គឺបុគ្គលិកជំនួយការសង្គមកិច្ច ដើម្បីចូលទៅក្នុងប្រព័ន្ធដោយពុំចាំបាច់ត្រូវការការបណ្ដុះបណ្ដាលទូលំទូលាយ និងបទពិសោធន៍ ដើម្បីដើរតួនាទីជាអ្នកគាំទ្រដល់បុគ្គលិកសង្គមកិច្ច។[41] ការងារនេះអាចផ្ដោតការយកចិត្តទុកដាក់លើការបណ្ដុះបណ្ដាលបុគ្គលិកអមវិជ្ជាជីវៈ ដោយប្រើកម្មវិធីសិក្សាជាបទដ្ឋាន ទទួលស្គាល់គុណភាពពីរដ្ឋាភិបាល និងការបង្កើតឱ្យមានដំណើរការទទួលស្គាល់គុណភាព ដើម្បីទទួលស្គាល់ការបណ្ដុះបណ្ដាលរបស់ពួកគេ។ កម្មវិធីសិក្សាខាងលើអាចត្រូវបានបង្កើតឡើងក្នុងភាពជាដៃគូជាមួយសាកលវិទ្យាល័យ និង NGOs ពាក់ព័ន្ធ។ គោលការណ៍ណែនាំសម្រាប់បុគ្គលិកជំនួយការអ្នកប្រកបវិជ្ជាជីវៈសង្គមកិច្ចអាចជួយផ្ដល់ក្របខ័ណ្ឌការងារ។[42] ការបណ្ដុះបណ្ដាលបែបនេះ បានទទួលជោគជ័យក្នុងប្រទេសជាច្រើន រួមទាំងនៅអឺរ៉ុបបូព៌ាកណ្ដាល អាមេរិកឡាទីនអាមេរិកខាងជើង និងចក្រភពអង់គ្លេស ដោយមានការអនុវត្តបែបបន្សាំ (សូមមើលអនុសាសន៍ទី ១០៖ ការថែទាំដោយឪពុកម្ដាយធម៌)។ ឧទាហរណ៍មួយគឺ «យុទ្ធវិធីសញ្ញាសុវត្ថិភាព»[43] ដែលបច្ចុប្បន្នកំពុងត្រូវបានប្រើប្រាស់នៅខេត្តបាត់ដំបង ដោយអង្គការអនាគតកុមារ Children’s Future (CFI) ដើម្បីបង្កើតស្ថេរភាពបណ្ដាញគ្រួសារ សម្រាប់កុមាររស់នៅក្នុងការថែទាំដោយសាច់ញាតិ និងដើម្បីការពារកុមារដែលកំពុងរស់នៅក្រោមការថែទាំរបស់គ្រួសារឱ្យរួចផុតពីអំពើហិង្សាក្នុងគ្រួសារ ការជួញដូរ និងទេសន្តប្រវេសន៍ឆ្លងដែនខុសច្បាប់។ អង្គការទំនុកចិត្តកុមារកម្ពុជា កំពុងអនុវត្តសាកល្បងយុទ្ធវិធីនេះតាមរយៈ FCF ដោយមានការពិគ្រោះយោបល់ពី CFI ហើយសង្ឃឹមថានឹងបណ្ដុះបណ្ដាលបុគ្គលិកជំនួយការសង្គមកិច្ចយ៉ាងហោចណាស់ ៣៥ នាក់ ឱ្យក្លាយជាគ្រូប្រភេទនេះ។ យុទ្ធវិធីនេះ អាចត្រូវបានពង្រីកបន្ថែម ប្រសិនបើទទួលបានជោគជ័យ។ អង្គការម្លប់តាប៉ាង ក៏ធ្លាប់បានចាប់ផ្ដើមបណ្ដុះបណ្ដាលបុគ្គលិកសង្គមកិច្ចឈានមុខរបស់ខ្លួនឱ្យប្រើប្រាស់ក្របខ័ណ្ឌការងារសញ្ញាសុវត្ថិភាព ដើម្បីឆ្លើយតបជាមួយករណីការការពារកុមារមានហានិភ័យខ្ពស់ ក្នុងបរិបទការងារផ្លូវភេទ និងការប្រើប្រាស់គ្រឿងញៀនដែរ។ សម្រាប់រយៈពេលវែង កម្មវិធីអាចត្រូវបានអភិវឌ្ឍក្នុងលក្ខណៈមួយឱ្យបុគ្គលិកអមវិជ្ជាជីវៈសង្គមកិច្ចអាចក្លាយជាអ្នកប្រកបវិជ្ជាជីវៈនេះនាពេលក្រោយ ដូចជា តាមរយៈការទទួលបានក្រេឌីត សម្រាប់បទពិសោធន៍ បូករួមជាមួយការបណ្ដុះបណ្ដាលបន្ថែមមួយចំនួនទៀត ដែលអាចមានន័យថា ពួកគាត់នឹងបានទទួលបៀវត្សកាន់តែខ្ពស់ជាងមុន។

39 CELCIS ត្រូវបានចាត់បេសកកម្មដោយក្រុមថ្នាក់ដឹកនាំអន្តរទីភ្នាក់ងារមួយរួមមានសមាសភាព BCN, FICE, Hope and Homes for Children, IFSW, RELAF និង Save the Children ដែលដឹកនាំដោយ International Social Service និង SOS Children’s Villages ដើម្បីអភិវឌ្ឍ MOOC ពោលគឺជាវគ្គបណ្ដុះបណ្ដាលមួយមានរយៈពេលប្រាំមួយសប្ដាហ៍ ដើម្បីជួយសម្រួលដល់អ្នកអនុវត្តគោលការណ៍ណែនាំអង្គការសហប្រជាជាតិដែលបានដាក់សម្ពោធក្នុងខែឧសភា ឆ្នាំ ២០១៧។

40 ព័ត៌មានបន្ថែមអាចរកមើលបានជាភាសាអង់គ្លេសនៅក្នុងសៀវភៅ យុត្តិធម៌កុមារមេត្រី បទដ្ឋានសម្រាប់កុមារនៅក្នុងបញ្ហាច្បាប់ស៊ីវិល អាចបើកមើលបាននៅ៖ http://iss-bg.org/bg/publikatsii/

41 www.devex.com/news/why-countries-need-better-social-protection-programs-rich-or-not-88543

42 http://www.socialserviceworkforce.org/resources/para-professionals-social-service-workforce-guiding-principles-functions-and-competencies

43 www.signsofsafety.net/signs-of-safety-2

## អនុសាសន៍ទី ៣

# ពង្រឹងវិស័យការងារសង្គមកិច្ច និងការបណ្ដុះបណ្ដាល អ្នកប្រកបវិជ្ជាជីវៈអាជីពវិស័យសង្គមទាំងអស់

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការធ្វើបញ្ជីបណ្ដុះបណ្ដាលដែលមានស្រាប់ទាំងអស់ | ១ ធ្វើបញ្ជីបណ្ដុះបណ្ដាលរបស់រដ្ឋាភិបាល ដែលមានស្រាប់ទាំងអស់។<br>២ ធ្វើបញ្ជី បណ្ដុះបណ្ដាលរបស់ CSO ដែលមានស្រាប់ទាំងអស់។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| តារាងនៃការបណ្ដុះបណ្ដាលដែលមានស្រាប់ | ១ បង្កើតតារាងនៃការបណ្ដុះបណ្ដាលទាំងអស់។<br>២ កិច្ចប្រជុំតុមូល ដើម្បីព្រមព្រៀងគ្នាលើការបណ្ដុះបណ្ដាល ដែលមានសក្ដានុពល និងចន្លោះប្រហោងនៅក្នុងការបណ្ដុះបណ្ដាល។ | ក្រសួង ស.អ.យ ជាមួយក្រសួងពាក់ព័ន្ធទាំងអស់។ | UNICEF, 3PC, FCF | ២០១៨ |
| បង្កើតសៀវភៅណែនាំស្ដីពីការអនុវត្តសព្វជ្រុងជ្រោយ ដើម្បីធ្វើជាសៀវភៅបណ្ដុះបណ្ដាល | ១ បង្កើតសៀវភៅណែនាំ បណ្ដុះបណ្ដាលស្ដីពីបទដ្ឋានកម្ពុជាដែលមានស្រាប់ ដោយប្រើប្រាស់ឧទាហរណ៍ពាក់ព័ន្ធ ពីម៉ាទ្រិច និងការអនុវត្តប្រកបដោយសក្ដានុពលនៅកម្រិតអន្តរជាតិ។<br>២ ផ្សព្វផ្សាយសេចក្ដីព្រាងទីមួយទៅដល់អ្នកជំនាញការជាតិ និងអន្តរជាតិ។<br>៣ បង្ហើយសៀវភៅណែនាំឱ្យចប់ជាស្ថាពរដោយអ្នកជំនាញការមួយក្រុមតូច (កម្ពុជា និងពីខាងក្រៅ)។<br>៤ ធ្វើការបណ្ដុះបណ្ដាលដល់រដ្ឋាភិបាល រួមទាំងក្រសួង ស.អ.យ ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល។ល។ និងអ្នកដើរតួនាទីសង្គមស៊ីវិល។ | ក្រសួង ស.អ.យ សភភព និងវិទ្យាស្ថានជាតិសង្គមកិច្ច។ | UNICEF, 3PC, FCF, HCCH and ISS | ២០១៨ តទៅ |
| MOOC សាកល្បងស្ដីពីការថែទាំជំនួស | ១ ពិនិត្យលទ្ធភាពបកប្រែទៅជាភាសាខ្មែរ។<br>២ លើកទឹកចិត្តការចូលរួមក្នុង MOOC ដោយអ្នកដើរតួនាទីទាំងអស់ រួមទាំងអ្នកដើរតួនាទីរដ្ឋាភិបាល និងសង្គមស៊ីវិល។ | ក្រសួង ស.អ.យ។ | UNICEF, Global Social Service Workforce Alliance | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
| ក្រុមគ្រូបណ្តុះបណ្តាលចល័ត (ផ្តោតគោលដៅលើអ្នកផ្តល់សេវា) | ១ បំពាក់សមត្ថភាព និងកំណត់រកសៀវភៅណែនាំ «គ្រូបណ្តុះបណ្តាល»។<br>២ ផ្តល់ការបណ្តុះបណ្តាលដល់ថ្នាក់តំបន់ដោយចាប់ផ្តើមពីខេត្តទាំង ៩ ដែលមានចំនួនកុមារក្នុងមណ្ឌលថែទាំកុមារ ច្រើនផ្អែកលើរបាយការណ៍កំណត់ទីតាំងកន្លែងថែទាំ និង/ឬខេត្តដែលមានចំនួនប្រជាជនមាន «អត្តសញ្ញាណប័ណ្ណជនក្រីក្រ» ខ្ពស់បំផុត។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩ តទៅ |
| **រយៈពេលវែង (ហួសពី ២០២៣)** | | | | |
| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
| បង្កើតការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់បុគ្គលិកផ្នែកសង្គមកិច្ច | ១ បង្កើតកម្មវិធីសិក្សាដោយមានជំនួយបច្ចេកទេសពីខាងក្រៅ។<br>២ កំណត់រកអ្នកផ្តល់សេវាដែលមានស្រាប់ (ឧ. គិលានុប្បដ្ឋាកសហគមន៍ បុគ្គលិកជាយុវជន) ដើម្បីយកកម្មវិធីសិក្សាទៅអនុវត្ត។<br>៣ អនុវត្តសាកល្បង ដើម្បីធ្វើតេស្តកម្មវិធីសិក្សានៅក្នុងតំបន់មួយ/ពីរ។<br>៤ កែសម្រួលកម្មវិធីសិក្សាឱ្យរលូន។<br>៥ ចាប់ផ្តើមអនុវត្តកម្មវិធីសិក្សា។<br>៦ ការវាយតម្លៃដោយឯករាជ្យទៅលើកម្មវិធីសិក្សា។ | ក្រសួង ស.អ.យ សភភព និងវិទ្យាស្ថានជាតិសង្គមកិច្ច។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

# ០២

# ការគាំទ្រដល់គ្រួសារ៖ ការរកឃើញ និងអនុសាសន៍ ការអភិវឌ្ឍសមត្ថភាព



© UNICEF Cambodia/2017/Ayphalla Te

# អនុសាសន៍ទី

# ៤

## ផ្តល់ភាព អំណាចដល់ឪពុកម្តាយក្នុងការថែទាំកូនរបស់ខ្លួន ដើម្បីឱ្យគ្រួសារអាចនៅរួបរួមគ្នាបាន (ពោល គឺជាវិធានការបង្ការជុំទីមួយ)

| | |
|---|---|
| **ST** | បង្កើតបណ្តាញទូរស័ព្ទទាន់ហេតុការណ៍នៅថ្នាក់ជាតិដែលប្រមូលផ្តុំនៅថ្នាក់កណ្តាលនូវសេវានានាសម្រាប់គ្រួសារ កុមារ និងអ្នកប្រកបវិជ្ជាជីវៈ និងបុគ្គលិកជំនួយវិជ្ជាជីវៈទាំងអស់ (សម្របសម្រួល និងប្រមូលផ្តុំធនធាន)។ កសាងសមត្ថភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) និង គកនក ជាអ្នកផ្តល់សេវាជួរមុខ។ |
| **MT** | ក្រុមការងារចល័តដើម្បីផ្តល់តំណភ្ជាប់ទៅកាន់សេវាមូលដ្ឋាននានា (ផ្តោតការយកចិត្តទុកដាក់លើតំបន់មានអត្តសញ្ញាណប័ណ្ណក្រីក្រ ជនអនាថា អំពើហិង្សា និងសេវាមានកម្រិតកំណត់)។ |
| **LT** | សកម្មភាពចុះបញ្ជីកំណើតជាសកល។ បង្កើតឱ្យមានកម្មវិធីតាមទូរស័ព្ទដៃឆ្លាតវៃ ដែលមានសេវាផ្សេងៗទាំងអស់សម្រាប់គ្រួសារ។ |

ការបង្ការកុំឱ្យមានតម្រូវការការថែទាំជំនួស ចាំបាច់ត្រូវតែជាអាទិភាពគ្រប់ប្រទេសទាំងអស់ បើគិតទៅតាមការទទួលយកជាសកលថា «គ្រួសារដែលជាកោសិកាមូលដ្ឋានរបស់សង្គម និងបរិស្ថានធម្មជាតិសម្រាប់ការរីកលូតលាស់ និងសុខុមាលភាពគ្រប់សមាជិករបស់ខ្លួន ជាពិសេសគឺកុមារគួរបានទទួលការការពារ និងការជួយជ្រោមជ្រែងដែលចាំបាច់ ដើម្បីធ្វើយ៉ាងណាឱ្យស្ថាប័ននេះ អាចបំពេញការទទួលខុសត្រូវរបស់ខ្លួនយ៉ាងពេញលេញនៅក្នុងសហគមន៍។»[44] ទស្សនៈនេះ គឺជាស្នូលដ៏សំខាន់ដោយក្នុងនោះចំណងគ្រួសារដ៏រឹងមាំតាមបែបប្រពៃណី និងជំនឿយ៉ាងទូលំទូលាយ ដែលចាត់ទុកថា «គេត្រូវការមនុស្សមួយភូមិ ដើម្បីចិញ្ចឹមក្មេងម្នាក់» និងផ្តល់សំណាញ់សុវត្ថិភាពធម្មជាតិទប់ទល់ជាមួយការបំបែកចេញពីគ្រួសារនៅក្នុងប្រទេសកម្ពុជា។ ជាការចាំបាច់ណាស់ ដែលត្រូវមានលទ្ធភាពទទួលបានសេវាជាមូលដ្ឋាន ដើម្បីគាំទ្រដល់ឪពុកម្តាយទាំងអស់ មិនថាជាឪពុកម្តាយបង្កើត ឪពុកម្តាយធម៌ ឬឪពុកម្តាយចិញ្ចឹមនៅក្នុងការបំពេញតួនាទីមើលថែទាំកុមារ យើងឃើញថា បច្ចុប្បន្ននៅក្នុងអង្គការយូនីសេហ្វកំពុងមានការស្វែងរកយុទ្ធសាស្ត្រចិញ្ចឹមបីបាច់កូនជាលក្ខណៈវិជ្ជមាន។

ជាកិច្ចឆ្លើយតបចំពោះអនុសាសន៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ UNCRC[45] និង ស្ថាបនាបន្ថែមលើកិច្ចខិតខំនាពេលបច្ចុប្បន្នក្នុងការកែលម្អលទ្ធភាពទទួលបានសេវា យើងបានកត់សម្គាល់ឃើញថា ភាគច្រើនលើសលប់នៃអ្នកផ្តល់សេវាការពារកុមារមាន «បណ្តាញទូរស័ព្ទទាន់ហេតុការណ៍» ជាក់លាក់តាមតំបន់របស់ខ្លួនសម្រាប់ការបញ្ជូន។ ជារឿយៗ លេខទាំងនេះផ្តល់ព័ត៌មានអំពីសេវាប្រហាក់ប្រហែលគ្នាពេលខ្លះបង្កើតឱ្យមានការភាន់ច្រឡំសម្រាប់អ្នកប្រើប្រាស់ជាសក្តានុពលមិនដឹងត្រូវប្រើប្រាស់លេខមួយណា។ ដោយកត់សម្គាល់ឃើញគុណតម្លៃដ៏ខ្ពស់នៃប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ទាំងនេះ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យអនុវត្តប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ថ្នាក់ជាតិ ដើម្បីប្រមូលផ្តុំព័ត៌មាន និងធនធាននៅរយៈពេលខ្លី។ សកម្មភាពផ្សព្វផ្សាយព័ត៌មាន គឺជាការចាំបាច់ណាស់ ដើម្បីធានាឱ្យមានការជ្រួតជ្រាបទូលំទូលាយដូចជាលេខទូរស័ព្ទទាន់ហេតុការណ៍ ABC ដែលទាមទារឱ្យ

44 បុព្វកថានៃ UNCRC: www.ohchr.org/en/professionalinterest/pages/crc.aspx

45 ក្នុងឆ្នាំ ២០១១ គណៈកម្មាធិការ UNCRC ៖ «ផ្តល់អនុសាសន៍ថា ភាគីរដ្ឋក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិត្រូវពង្រឹងសេវាប្រឹក្សាយោបល់ដែលមានស្រាប់សម្រាប់ឪពុកម្តាយ បន្តអភិវឌ្ឍក្រោរអប់រំគ្រួសារ និងការយល់ដឹងតាមរយៈមធ្យោបាយនានា ឧទាហរណ៍ដូចជា ការបណ្តុះបណ្តាលសម្រាប់ឪពុកម្តាយស្តីពីការថែទាំកុមារតូចមគ្គុទេសក៍សម្រាប់ឪពុកម្តាយ និងការទទួលខុសត្រូវរួមគ្នាក្នុងការចិញ្ចឹមបីបាច់កូន ដោយយោងទៅតាមមាត្រា ១៨ នៃអនុសញ្ញា។ គណៈកម្មាធិការក៏ផ្តល់អនុសាសន៍ថាភាគីរដ្ឋចាំបាច់ត្រូវស្ថាបនាប្រព័ន្ធការពារកុមារ ដើម្បីពិនិត្យតាមដានគ្រួសារដែលត្រូវការវិធានការគាំទ្រ ដើម្បីអាចផ្តល់ការថែទាំ និងការយកចិត្តទុកដាក់បានយ៉ាងសមស្របចំពោះកូនៗរបស់ខ្លួន។»

មានការស្ថាបនាប្រព័ន្ធទិន្នន័យមេនៃសេវានានា ដែលតភ្ជាប់ទៅកាន់សេវា/លេខទូរស័ព្ទនីមួយៗ ក៏ដូចជាការបណ្តុះបណ្តាលបុគ្គលិក និងការផ្តល់ការអភិបាលចំពោះបុគ្គលិកទាំងនោះ (សូមមើលអនុសាសន៍ទី ២៖ ប្រព័ន្ធទិន្នន័យមេ និងអនុសាសន៍ទី៣៖ ការបណ្តុះបណ្តាល)។ បើគិតទៅលើតំណែងរបស់ គកសក និង គកនក នៅក្នុងឃុំនីមួយៗ និងទំហំនៃភាពតំណាងពួកគេជាអ្នកដើរតួនាទីដ៏ចាំបាច់នៅក្នុងសកម្មភាពផ្សព្វផ្សាយព័ត៌មាន និងការបង្កើតប្រព័ន្ធទិន្នន័យមេ ប្រសិនបើពួកគេបានទទួលការបំពាក់លក្ខណៈសមស្រប ហើយបានទទួលការអភិវឌ្ឍសមត្ថភាព (សូមមើលអនុសាសន៍ទី៥)។

ដើម្បីគាំទ្រលទ្ធភាពទទួលបានសេវាសម្រាប់គ្រួសារកំពុងមានសេចក្តីត្រូវការខ្ពស់បំផុត សម្រាប់រយៈពេលមធ្យម (ឧ. អ្នកដែលមានអត្តសញ្ញាណប័ណ្ណជនក្រីក្រ ជនអនាថា[46] អ្នកជួបអំពើហិង្សា[47] និងប្រជាជនមិនអាចចូលទៅដល់បាន) ក្រុមការងារចល័តនៃអ្នកផ្តល់សេវាទៅតាមខេត្តនានាគួរត្រូវបានបង្កើតឡើង។ ក្រុមចល័តអាចរួមមានសមាសធាតុអ្នកប្រកបវិជ្ជាជីវៈមានជំនាញខាងការអប់រំសុខភាពការងារផ្នែកច្បាប់ និងសង្គមកិច្ចជាការល្អបំផុតគឺជាមន្ត្រីរាជការ។ គោលបំណងនៃក្រុមចល័តនេះ គឺដើម្បីតភ្ជាប់គ្រួសារទៅកាន់គ្លីនិកសុខភាព អ្នកផ្តល់សេវាអប់រំ និងសេវា ដែលមានស្រាប់ដទៃទៀត តើសេវាណាខ្លះដែលពួកគាត់នៅត្រូវការ (សូមមើលអនុសាសន៍ទី ៥៖ ការកំណត់ទីតាំងសេវា)។ សេវានេះត្រូវបានដាក់ឱ្យប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពក្នុងរាជធានីភ្នំពេញ តាមរយៈរថយន្តពេលយប់ ដោយផ្តោតគោលដៅលើអ្នកប្រឈមហានិភ័យចំពោះការកេងប្រវ័ញ្ចផ្លូវភេទ ជាហេតុធ្វើឱ្យគេអាចផ្តល់សេវាការទប់ស្កាត់/អន្តរាគមន៍តាំងពីដំបូង។ ដើម្បីធានាឱ្យមានផលធំបំផុត ការផ្តួចផ្តើមគំនិតនេះចាំបាច់ត្រូវតែជាការផ្តួចផ្តើមគំនិតដឹកនាំដោយរដ្ឋាភិបាល និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកផ្តល់សេវានៅមូលដ្ឋាន ដូចជា ដៃគូកម្មវិធី 3PC និង FCF ជាដើម។

ថ្វីបើមានភាពប្រសើរឡើងក្នុងការចុះបញ្ជីកំណត់ដូចបានបញ្ជាក់ពីខាងដើម ការចុះបញ្ជីកំណើតទូទាំងប្រទេស គឺនៅមានកង្វះខាតនៅឡើយ។[48] មូលហេតុដែលត្រូវបានផ្តល់ឱ្យសម្រាប់បញ្ហានេះ គឺមានផ្សេងៗជាច្រើន ដូចជា ដោយសារផ្ទះនៅឆ្ងាយពីឃុំ ថ្លៃធ្វើដំណើរ ការបាត់ឯកសារចុះបញ្ជីសំខាន់ៗ និងនៅក្នុងករណីមួយចំនួន គឺដោយសារថ្លៃចំណាយលើការចុះឈ្មោះ «ក្រៅផ្លូវការ/បន្ថែម»។ ការបំពេញបាននូវសិទ្ធិនេះ គឺមានចំណងទាក់ទងយ៉ាងជិតស្និទ្ធចំពោះការសម្រេចបាននូវសិទ្ធិផ្សេងៗទៀតជាច្រើនមានដូចជា សិទ្ធិទទួលបានឈ្មោះ សញ្ជាតិ បានដឹងអំពីដើមកំណើត និងលក្ខណៈសម្បត្តិ ដើម្បីអាចទទួលបានសេវានានារបស់ខ្លួនឯង។ បើយោងទៅលើជោគជ័យការផ្តួចផ្តើមគំនិតឧបករណ៍សៀវភៅកំណត់ត្រាភូមិ ដែលបានប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០១៥[49] ដោយក្នុងនោះមេភូមិប្រើប្រាស់សៀវភៅនេះ ដើម្បីកត់ត្រាចំនួនកុមារកើតនៅក្នុងខែនីមួយៗ អ្នកដើរតួនាទីសំខាន់ៗទាំងអស់នេះ គួរបានទទួលការបណ្តុះបណ្តាល ដើម្បីជួយសម្របសម្រួលដល់ការចុះបញ្ជីកំណើត ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ។ ប្រហែលគឺជាការឆ្លាតវៃក្នុងការលើកកម្ពស់ក្នុងការចុះបញ្ជីកំណើតកាន់តែទូលំទូលាយថែមទៀតនៅក្នុងមន្ទីរពេទ្យ ព្រោះថាទារកភាគច្រើនលើសលប់កើតនៅទីនោះ។ ថ្វីបើឃុំមានសមត្ថកិច្ចក្នុងការចុះបញ្ជីកំណើតក្តី ប៉ុន្តែបុគ្គលិកសង្គមកិច្ចនៅក្នុងគ្រឹះស្ថាននានា ដូចជា មន្ទីរពេទ្យកុមារអង្គរ (AHC) អាចទទួលបានការបណ្តុះបណ្តាលស្តីពីការជួយជ្រោមជ្រែងដល់គ្រួសារលើបញ្ហានានា ដូចជាការបំពេញទម្រង់ការចុះបញ្ជីកំណើតបន្ថែមទៅលើការផ្តល់កាតពណ៌លឿង (សូមមើលអនុសាសន៍ទី ៦៖ សមាហរណកម្ម)។

ការផ្តួចផ្តើមគំនិតរយៈពេលវែង អាចទាក់ទងជាមួយការបង្កើតឱ្យមានកម្មវិធីប្រើប្រាស់ក្នុងទូរស័ព្ទដៃ ដែលកំណត់ទីតាំងសេវាដែលមានស្រាប់ទាំងអស់ ដែលផ្តល់ដោយក្រសួងនានា។ ក្រុមការងារនេះ ថែមទាំងអាចប្រាប់សូម្បីតែអំពីថាតើគ្រួសារកំពុងរស់នៅតំបន់ក្រីក្របំផុត និងស្ថានភាពលំបាកបំផុតមានលទ្ធភាពទទួលបានឧបករណ៍ទាំងនេះ ឬយ៉ាងណា។ ព័ត៌មានដែលមាននៅក្នុងកម្មវិធីប្រើប្រាស់ក្នុងទូរស័ព្ទនេះ ចាំបាច់ត្រូវមានជាច្រើនទម្រង់ (ឧ. តាមបែបប្រពៃណី រូបភាព/រូបសញ្ញា) ដែលអាចឱ្យគេចូលទៅរកបានដោយងាយស្រួល ជាពិសេសគឺសម្រាប់អ្នកដែលមិនចេះអក្សរ។ កម្មវិធីប្រើប្រាស់ក្នុងទូរស័ព្ទបែបនេះ អាចបំពេញបន្ថែមជាមួយគម្រោង «ព័ត៌មានសម្រាប់ជីវិត» ដែលត្រូវបានសម្ភោធនៅលើ Facebook.org (local name: Free Basics ក្នុងឆ្នាំ ២០១៥ ដែលមានបំណងបញ្ជូនសារសំខាន់ៗដល់ប្រជាជនដែលពុំមានលទ្ធភាពប្រើអ៊ីនធើណេត[50] ក៏ដូចជាគម្រោងមួយចំនួនទៀត ដូចជា Urbanrefuge ជាដើម។[51]

46 ក្រសួងផែនការកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ការប៉ាន់ប្រមាណអំពីកុមារអនាថានៅក្រុងទាំងប្រាំពីរក្នុងប្រទេសកម្ពុជា (ឆ្នាំ ២០១៦)

47 ក្រសួងកិច្ចការនារីកម្ពុជា ការរកឃើញពីអំពើហិង្សាប្រឆាំងកុមារក្នុងប្រទេសកម្ពុជា៖សេចក្តីសង្ខេបការស្ទាបស្ទង់មតិឆ្នាំ ២០១៣ (ឆ្នាំ ២០១៤)

48 គណៈកម្មាធិការ UNCRC បានលើកឡើងទាក់ទងជាមួយការចុះសំបុត្រកំណើតកម្រិតទាប ជាពិសេសក្នុងតំបន់ជនបទ និងភូមិជនបទនៅក្នុងការសង្កេតសន្និដ្ឋានរបស់ខ្លួន (OPAC) ឆ្នាំ ២០១៥។

49 www.unicef.org/about/annualreport/files/Cambodia_2015_COAR.pdf

50 www.unicef.org/about/annualreport/files/Cambodia_2015_COAR.pdf

51 http://www.urbanrefuge.org/

## អនុសាសន៍ទី ៤

# ផ្តល់អំណាចដល់ឪពុកម្តាយក្នុងការថែទាំកូនរបស់ខ្លួន ដើម្បីឱ្យគ្រួសារអាចនៅរួបរួមគ្នាបាន (ពោល គឺជាវិធានការបង្ការជុំទីមួយ)

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បញ្ជី បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ដែលមានស្រាប់ទាំងអស់ | ១ បញ្ជី បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ដែលមានស្រាប់ទាំងអស់។<br>២ បញ្ជី សេវាដែលមានស្រាប់ទាំងអស់ចែកទៅតាមតំបន់ (អនុសាសន៍ទី ៥)។<br>៣ កសាងសមត្ថភាព គកសក និង គកនក ឱ្យសម្របសម្រួលយុទ្ធសាស្ត្រទប់ស្កាត់។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| តារាងបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ដែលមានស្រាប់ | ១ ផ្អែកលើបញ្ជីត្រូវបង្កើតម៉ាទ្រិចមួយអំពីបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ និងសេវាទាំងអស់នៅក្នុងទម្រង់ដាក់ឱ្យនៅថ្នាក់កណ្តាល។<br>២ បង្កើតបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ថ្នាក់ជាតិមួយ ដែលផ្អែកលើព័ត៌មានដាក់នៅថ្នាក់កណ្តាល។<br>៣ ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបណ្តាញទូរស័ព្ទទាន់ហេតុការណ៍។<br>៤ ការតស៊ូមតិ និងការផ្សព្វផ្សាយព័ត៌មានអំពីបណ្តាញទូរស័ព្ទទាន់ហេតុការណ៍។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |

## រយៈពេលមធ្យម (២០១៩-២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| ក្រុមការងារអ្នកផ្តល់សេវាចល័ត (តំណភ្ជាប់ដោយផ្ទាល់ពីគ្រួសារទៅសេវា) | ១ កំណត់សេវាសុខភាព ការអប់រំ សង្គមកិច្ច ។ល។ ជាផ្នែកនៃក្រុមចល័តនេះ។<br>២ ការបណ្តុះបណ្តាលក្រុមចល័ត ដើម្បីផ្តល់សេវាដោយផ្ទាល់ទៅដល់គ្រួសារ។<br>៣ ក្រុមចល័តមានលទ្ធភាពទៅដល់តំបន់ដាច់ស្រយាល។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩ តទៅ |
| យុទ្ធនាការចុះបញ្ជីកំណើតជាសកល | ១ ការបណ្តុះបណ្តាលអង្គភាពសង្គមកិច្ចនៅក្នុងមន្ទីរពេទ្យនានាឱ្យជួយសម្រួលដល់ការចុះបញ្ជីកំណើត។<br>២ ការបណ្តុះបណ្តាលមេភូមិឱ្យជួយសម្រួលដល់ការចុះបញ្ជីកំណើត/សៀវភៅកត់ត្រា។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩-២០២៣ |

## រយៈពេលវែង (ហួសពី ២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| បង្កើតកម្មវិធីក្នុងទូរស័ព្ទឆ្លាតវៃអំពីសេវាដែលមានស្រាប់ទាំងអស់ | ១ ធ្វើបច្ចុប្បន្នភាពជាប្រចាំលើបញ្ជី សេវានៅក្នុងប្រព័ន្ធទិន្នន័យមេថ្នាក់កណ្តាលមួយ។<br>២ អភិវឌ្ឍកម្មវិធីប្រើប្រាស់ក្នុងទូរស័ព្ទឆ្លាតវៃ។<br>៣ ធ្វើតេស្តសាកល្បងកម្មវិធីនេះជាមួយក្រុមគោលដៅផ្តោតជាក់លាក់។<br>៤ ធ្វើតេស្តសាកល្បងនៅក្នុងតំបន់អនុវត្តគម្រោងសាកល្បងចំនួនមួយ/ពីរ។<br>៥ សម្ពោធកម្មវិធីក្នុងទូរស័ព្ទឆ្លាតវៃ ដើម្បីប្រើប្រាស់ទូទាំងប្រទេស។ | ក្រសួង ស.អ.យ និងក្រសួងបច្ចេកវិទ្យា។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

# អនុសាសន៍ទី

# ៩

## បង្កើតវិធានការសំណាញ់សុវត្ថិភាព ដើម្បីការពារកុមារប្រឈមហានិភ័យនៅពេលការបង្ការជុំទីមួយពុំ បានផល (ពោល គឺជាវិធានការបង្ការជុំទីពីរ)

**ST**

ប្រមូលព័ត៌មានអំពីសេវាការថែទាំជំនួស/ស៊ុំកូនដែលមានស្រាប់ និងថ្មីៗដោយផ្អែកលើ៖

1) ការចុះអនុស្សារណៈយោគយល់ ដែលផ្តល់អាជ្ញាប័ណ្ណដល់អ្នកផ្តល់សេវា។

2) សម្ភារៈដែលបានចែករំលែកគ្នានៅក្នុងកិច្ចប្រជុំប្រចាំខែ គកនក។

ពង្រីកការកំណត់ទីតាំងសេវាសង្គម (សូចនាករ ១៣ ដោយមានការចុះបញ្ជីកំណើតជំងឺអេដស៍ ពិការភាព។ល។) ដោយដាក់បញ្ចូលសុខភាព/ការអប់រំ។ល។

**MT**

បង្កើតសេវាបញ្ជីអាស័យដ្ឋានទំនាក់ទំនងនៅថ្នាក់ជាតិ។

ប្រព័ន្ធការគ្រប់គ្រងករណីមានឯកភាពគ្នា។

បង្កើតសេវាការថែទាំបណ្តោះអាសន្ន។

**LT**

បង្កើតមណ្ឌលកុមារខេត្តសម្រាប់ការផ្តល់ជំនួយ។

យុទ្ធនាការលើកកម្ពស់ការយល់ដឹងទូទាំងប្រទេស ដើម្បីរក្សាគ្រួសារឱ្យនៅជួបជុំគ្នា។

ថ្វីត្បិតតែសេវាមូលដ្ឋានត្រូវបានផ្តល់ដល់គ្រួសារទាំងឡាយក្តី ប៉ុន្តែនៅគ្រប់ប្រទេសទាំងអស់តែងតែមានគ្រួសារមួយចំនួនដែលប្រឈមហានិភ័យខ្ពស់ចំពោះការបំបែកចេញពីគ្រួសារ និងទាមទារនូវការគាំទ្របន្ថែម។ ក្នុងប្រទេសកម្ពុជា អ្នកទាំងនេះរួមមានឧទាហរណ៍ដូចជា គ្រួសាររស់នៅក្នុងភាពក្រីក្រ មានជនពិការភាពក្នុងគ្រួសារ កុមារដែលត្រូវបានទុកនៅកន្លែងកំណើតពេលឪពុកម្តាយធ្វើចំណាកស្រុក កុមារត្រូវគេរំលោភបំពាន និងព្រងើយកន្តើយ។[52] យើងបានឮជាបន្តបន្ទាប់ថា កត្តាជំរុញដ៏សំខាន់មួយសម្រាប់ការបំបែកចេញពីគ្រួសារ គឺការមើលឃើញឱកាសការរៀនសូត្រនៅមណ្ឌលថែទាំកុមារ អាស្រ័យដោយសាលារៀននៅក្នុងតំបន់ តាមធម្មតាតែងមានធនធានអន់ខ្សោយ និងត្រូវចំណាយក្រៅផ្លូវការ។ ការងាររបស់ FCF គឺដើម្បីអភិវឌ្ឍសន្ទស្សន៍កុមារងាយរងគ្រោះ នឹងអាចជួយកំណត់អត្តសញ្ញាណកុមារប្រឈមហានិភ័យខ្ពស់ទាំងអស់នោះបាន។ មានឱកាសដ៏ច្រើន ដើម្បីកែលម្អកិច្ចសហការឱ្យកាន់តែប្រសើរថែមទៀតសម្រាប់អ្នកធ្វើការនៅក្រសួង ស.អ.យ និងក្រសួងអប់រំយុវជន និងកីឡា (ក្រសួង អ.យ.ក) ក៏ដូចជានៅផ្ទៃក្នុងអង្គការនានា ដូចជានាយកដ្ឋានអប់រំ និងកិច្ចការការពារកុមាររបស់អង្គការយូនីសេហ្វជាដើម។

ចាំបាច់ត្រូវមានការឆ្លើយតបដែលបានសម្រួលតាមតម្រូវការជាក់ស្តែង ដើម្បីឆ្លើយតបចំពោះកត្តាជំរុញធ្វើឱ្យមានការបំបែកចេញពីគ្រួសារទាំងនេះ។ នៅពេលខ្វះយុទ្ធវិធីផ្តោតគោលដៅនៅថ្នាក់ជាតិ កិច្ចខិតខំនៅដាច់ៗពីគ្នាតាមលក្ខណៈភូមិសាស្ត្រតែងកើតមាន។ ឧ. អង្គការម្លប់តាប៉ាងធ្វើការជាមួយគ្រួសារដើម្បីបង្កើតអាជីវកម្មខ្នាតតូច ដោយផ្តល់ម៉ាស៊ីនដេរដល់ម្តាយដែលចិញ្ចឹមកូនម្នាក់ឯង ក៏ដូចជាការផ្តល់សម្ភារៈផ្គត់ផ្គង់ពេលមានអាសន្ន និងការថែទាំវេជ្ជសាស្ត្រដោយឥតគិតថ្លៃ។ ដូចគ្នានេះដែរ ក្នុងឆ្នាំ ២០១៥ អង្គការយូនីសេហ្វផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យពង្រឹងការវិនិយោគ និងការផ្តល់សេវាសង្គមកិច្ចដល់ស្ត្រី និងកុមារងាយរងគ្រោះនៅក្នុងឃុំចំនួន ១០១ “ដោយបានផ្តល់អត្ថប្រយោជន៍ដល់កុមារចំនួន ១២៦៩១

នាក់ អាយុក្រោមមួយឆ្នាំ ដែលមានការចុះបញ្ជីកំណើតស្ត្រីមានផ្ទៃពោះចំនួន ១០៣១៥ នាក់ មានលទ្ធភាពទទួលបានការពិនិត្យផ្ទៃពោះ ការសម្រាលកូននៅគ្រឹះស្ថានសុខាភិបាល និងការថែទាំក្រោយសម្រាល ហើយកុមារចំនួន ៣០ ៥៥០ នាក់ អាយុចាប់ពីបីឆ្នាំដល់ប្រាំឆ្នាំបានទៅរៀននៅសាលាមត្តេយ្យសហគមន៍។»[53]

សូម្បីតែនៅពេលមានវត្តមានសេវាជាក់លាក់ហើយក្តី ក៏យើងឃើញថាសេវាទាំងនោះពុំមែនត្រូវគេស្គាល់ជានិច្ចកាលនោះឡើយ។ សម្រាប់រយៈពេលខ្លី យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យស្ថាបនាបន្ថែមលើការងាររបស់ UNICEF/3PC ស្តីពីការកំណត់ទីតាំងសេវាសង្គមកិច្ច ដើម្បីឱ្យមានព័ត៌មាននៅថ្នាក់កណ្តាលស្តីពីអ្នកផ្តល់សេវាទាំងអស់។ មកដល់សព្វថ្ងៃនេះ អង្គការ FI និងមិត្តសម្លាញ់ បានបង្កើតសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវា ដោយបានចងក្រងព័ត៌មានអំពី NGOs ចំនួន ៥៨ និងជួយកំណត់រកចន្លោះប្រហោងក្នុងការផ្តល់សេវា។ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យកិច្ចខិតខំរបស់ 3PC ត្រូវបានពង្រីកបន្ថែម ដើម្បីដាក់បញ្ចូលនូវព័ត៌មានអំពីសុខភាព ការអប់រំសេវាផ្នែកច្បាប់។ល។ ដូចគ្នានេះដែរ ព័ត៌មានគួរត្រូវបានប្រមូលដោយធ្វើការសង្ខេបព័ត៌មានអំពីសេវាដែលត្រូវបានអនុម័ត ដែលមាននៅក្នុងអនុសារណៈយោគយល់ ផ្តល់ដោយក្រសួងទាំងអស់ (អប់រំសុខាភិបាលយុត្តិធម៌ សេវាសង្គមកិច្ចស្ត្រី។ល។)។ អាចមានការជួលអ្នកពិគ្រោះយោបល់ឯករាជ្យម្នាក់ដើម្បីធ្វើការងារនេះ។ ព័ត៌មានអំពីសេវានាពេលបច្ចុប្បន្ន និងសេវាថ្មីៗក៏អាចត្រូវបានប្រមូលនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ គកនក ដែលអ្នកផ្តល់សេវាភាគច្រើនចូលរួមផងដែរ។ មន្ទីរ ស.អ.យ គួរទទួលខុសត្រូវក្នុងការចែកព័ត៌មានទៅតាមក្រុម។ ការងារនេះអាចជាផ្នែកមួយនៃសៀវភៅណែនាំសម្រាប់ គកនក ដែលយូនីសេហ្វបានធ្វើសេចក្តីព្រាង នៅក្នុងឆ្នាំ ២០១៧។

បន្ថែមលើនេះទៀត ដូចបានបញ្ជាក់ក្នុងអនុសាសន៍ទី ៤ មកហើយថា តួនាទីរបស់ គកសក និង គកនក ក្នុងការអភិវឌ្ឍយន្តការតាមដានច្បាស់លាស់ និងក្នុងការកៀងគរធនធាន ដើម្បីគាំទ្រកុមារ និងគ្រួសារប្រឈមហានិភ័យនៃការបំបែកចេញពីគ្រួសារ ក៏ពុំគួរត្រូវបានមើលស្រាលនោះឡើយ។ ការស្ថាបនាយុទ្ធសាស្ត្រទប់ស្កាត់ ដោយឈរលើមូលដ្ឋានវត្តមាននៅទូទាំងប្រទេសរបស់គណៈកម្មាធិការទាំងពីរនេះ នឹងអាចជួយធានានូវភាពជាម្ចាស់របស់រដ្ឋាភិបាល និងនិរន្តរភាពរយៈពេលវែង។ ទោះយ៉ាងណាក្តី បើគិតទៅតាមធនធានដែលពួកគាត់មានចាំបាច់ត្រូវអភិវឌ្ឍសមត្ថភាពរបស់ពួកគាត់តាមរយៈការវិនិយោគ និងការបណ្តុះបណ្តាលថែមទៀត។

សម្រាប់រយៈពេលមធ្យម យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យប្រើប្រាស់ព័ត៌មាននេះ ដើម្បីអភិវឌ្ឍជាបញ្ជីអាសយដ្ឋានទំនាក់ទំនងសេវានៅថ្នាក់ជាតិជាការល្អគួរស្ថិតក្នុងទម្រង់ជាប្រព័ន្ធទិន្នន័យមេអេឡិចត្រូនិច។ ព័ត៌មាននេះ ក៏អាចដាក់តាំងបង្ហាញនៅក្នុងខិត្តប័ណ្ណ និងនៅក្នុងកម្មវិធីទូរស័ព្ទដៃឆ្លាតវៃ ក៏ដូចជាប្រើប្រាស់សម្រាប់បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ថ្នាក់ជាតិផងដែរ (សូមមើលអនុសាសន៍ទី ៤)។

ស្រដៀងគ្នានេះផងដែរ យើងខ្ញុំបានទទួលការលើកទឹកចិត្តឱ្យមើលប្រព័ន្ធគ្រប់គ្រងករណីតាមអ៊ីនធើណេត បង្កើតឡើងដោយអង្គការកុមារក្នុងគ្រួសារ តាមរយៈ FCF ដែលត្រូវបានរចនាឡើងជាប្រភេទកម្មវិធី open sourced ហើយមនុស្សទាំងអស់អាចយកមកប្រើបានដោយឥតគិតថ្លៃ។ កម្មវិធីនេះ ជួយសម្រួលឱ្យមានការផ្ទេរព័ត៌មានក្នុងលក្ខណៈឯកភាពគ្នារវាងអង្គការនានា និងដាក់កំណត់សម្គាល់ករណី ការទទួលកុមារចូល និងការពិនិត្យតាមដានបន្តបន្ទាប់ទៀតឱ្យនៅថ្នាក់កណ្តាល។ ជាការពិតណាស់ ការងារនេះបានន័យថា ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសអ្នកសង្គមកិច្ច និងក្រសួងនានា ត្រូវព្រមព្រៀងគ្នាលើធាតុចូលទិន្នន័យ ដែលអាចតម្រូវឱ្យមានការបណ្តុះបណ្តាល (សូមមើលអនុសាសន៍ទី ១៖ កិច្ចសហប្រតិបត្តិការ និងអនុសាសន៍ទី ៣ ៖ ការបណ្តុះបណ្តាល)។ ការវាយតម្លៃហានិភ័យ គួរត្រូវបានស្ថាបនានៅក្នុងប្រព័ន្ធនេះ ដើម្បីការពារសុវត្ថិភាពពីការប្រើប្រាស់បំពាន។ កាធ្វើសវនកម្មជាទៀងទាត់លើសំណុំឯកសារដោយក្រសួង ស.អ.យ គួរឆ្លើយតបចំណុចស្មុគស្មាញនានា។ ទោះយ៉ាងណាក្តី បច្ចុប្បន្នគឺនៅក្នុងដំណាក់កាលដំបូងនៅឡើយ ហើយសម្រាប់រយៈពេលវែង យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យមានការពង្រីកប្រព័ន្ធនេះឱ្យធំទូលាយថែមទៀត ពេលដែលមានព័ត៌មានហើយ។ ការផ្តួចផ្តើមគំនិតនេះគួរបំពេញបន្ថែមទៅលើការងារជាបន្ត ដើម្បីបន្សីជាមួយទម្រង់របស់ក្រសួង ស.អ.យ ដែលមានស្រាប់ទាំង ២៨ ដោយ FI។

52 សូមមើលផងដែរ ក្រសួងផែនការកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ការប៉ាន់ប្រមាណថ្នាក់ជាតិអំពីកុមារនៅក្នុងមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា (ឆ្នាំ ២០១៦) និងក្រសួងកិច្ចការនារីកម្ពុជា ការរកឃើញពីអំពើហិង្សាប្រឆាំងកុមារក្នុងប្រទេសកម្ពុជា៖សេចក្តីសង្ខេបការស្ទាបស្ទង់មតិឆ្នាំ ២០១៣ (ឆ្នាំ ២០១៤)

53 www.unicef.org/about/annualreport/files/Cambodia_2015_COAR.pdf

មានការសង្កេតឃើញនៅកន្លែងផ្សេងទៀតថា «ថ្វីបើភាពក្រីក្រមានការលើកឡើង ដោយខ្លួនឯងដោយម្តាយឪពុក និងអ្នកមើលថែកុមារ ថាជាមូលហេតុចម្បងនៃការបំបែកចេញពីគ្រួសារក្តី ប៉ុន្តែទាល់តែមានព្រឹត្តិការណ៍ជាអវិជ្ជមានមួយ ឬប៉ះពាល់ដល់គ្រួសារដែលកំពុងជួបការលំបាករួចហើយប៉ុណ្ណោះ ដែលគ្រួសារសម្រេចចិត្តបោះបង់កូនរបស់ខ្លួន»។[54] ចំណុចនេះជួយពន្យល់អំពីមូលហេតុដែលយើងឃើញថា ពុំមែនគ្រប់គ្រួសារទាំងអស់ដែលរស់នៅក្នុងភាពក្រីក្រសុទ្ធតែបោះបង់ ឬឈប់ទទួលយកកូនរបស់ខ្លួន។ ការថែទាំជាបណ្តោះអាសន្នអាចជាមធ្យោបាយមួយក្នុងការផ្តល់ការបន្ធូរបន្ថយបណ្តោះអាសន្ន។ ឧ. ការថែទាំជាបណ្តោះអាសន្នផ្តល់ដោយអង្គភាពសង្គមកិច្ចរបស់អាចត្រូវបានចម្លងយកទៅអនុវត្តក្នុងមន្ទីរពេទ្យដទៃទៀត។ យុទ្ធវិធីរបស់ពួកគេក្នុងការផ្តល់ការថែទាំបណ្តោះអាសន្ន សម្រាប់ទារកទើបកើតថ្មី និងកំណត់រកការគាំទ្រ/សេវាសម្រាប់គ្រួសារកំពុងជួបវិបត្តិបានផ្តល់លទ្ធផលឱ្យអាចធ្វើសមាហរណកម្មទៅកាន់គ្រួសារវិញស្ទើរតែទាំងស្រុង។ ឧទាហរណ៍អំពីប្រទេសអ៊ុយក្រែនស្តីពីការទប់ស្កាត់ក្នុងលក្ខណៈប្រតិសកម្មក្នុងមន្ទីរពេទ្យក៏អាចត្រូវបានពិចារណាថាជាឧបករណ៍មួយ ដើម្បីបំពាក់ដល់ម្តាយក្នុងការថែទាំទារកទើបនឹងកើតថ្មីផងដែរ។[55] ដូចគ្នានេះដែរសេវា «សម្រាកមួយរយៈពេលខ្លី» សម្រាប់កុមារពិការក្នុងប្រទេសរុស្ស៊ី[56] គឺជាគំរូដ៏មានប្រយោជន៍ ដើម្បីជាឯកសារយោង។ សេវានេះមានភាពបត់បែនក្នុងការឆ្លើយតបតាមសេចក្តីត្រូវការរបស់គ្រួសារនីមួយៗ ហើយការថែទាំអាចត្រូវបានផ្តល់ជូននៅក្នុងផ្ទះរបស់កុមារផ្ទាល់ ឬនៅក្នុងផ្ទះរបស់អ្នកមើលថែ។ ការងារស្តីពីការថែទាំបណ្តោះអាសន្ន អាចជួយបំពេញបន្ថែមដល់ការងារថែទាំដោយឪពុកម្តាយធម៌រយៈពេលខ្លី ដែលកំពុងបន្ត (សូមមើលផ្នែកទី ២)។

សម្រាប់រយៈពេលមធ្យម ដោយស្ថាបនាបន្ថែមលើការងាររបស់អង្គការទំនុកចិត្តនៃកុមារកម្ពុជា ដោយក្នុងនោះមណ្ឌលតាមសហគមន៍[57] ផ្តល់ការជួយជ្រោមជ្រែងដល់គ្រួសារប្រឈមហានិភ័យ ហើយសេវានេះអាចត្រូវបានវាយតម្លៃ ដើម្បីពិនិត្យមើលលើសក្តានុពលក្នុងការចម្លងទៅអនុវត្តនៅទូទាំងប្រទេស។ អង្គការ ILO កំពុងអនុវត្តសាកល្បងនូវមជ្ឈមណ្ឌលព័ត៌មានជនទេសន្តប្រវេសន៍ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មាន[58] ដោយមានការផ្តល់មូលនិធិរហូតដល់ចុងឆ្នាំ ២០១៨។

នៅក្នុងរយៈពេលវែង ប្រសិនបើមណ្ឌលសហគមន៍អាចត្រូវបានចម្លងយកទៅអនុវត្តបន្ថែមទៀត មណ្ឌលនេះនឹងក្លាយជាមធ្យោបាយមួយក្នុងការលើកកម្ពស់ការយល់ដឹងជូនដល់ក្រុមងាយរងគ្រោះអំពីអត្ថប្រយោជន៍នៃការថែទាំតាមគ្រួសារ និងអាចឆ្លើយតបចំពោះជំនឿចាក់ឫសយ៉ាងជ្រៅ ដែលចាត់ទុកថាការថែទាំក្នុងមណ្ឌលផ្តល់លក្ខខណ្ឌរស់នៅ និងឱកាសការអប់រំប្រសើរជាងការថែទាំនៅតាមគ្រួសារ។ យុទ្ធនាការខាងលើធ្វើឡើងជាភាសាខ្មែរ អាចត្រូវបានផ្សព្វផ្សាយក្នុងសាលារៀនក្នុងមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងមណ្ឌលសុខភាពសហគមន៍ ។ល។ ខ្លឹមសារនៃយុទ្ធនាការនេះអាចទាញចេញពីយុទ្ធនាការប្រាស្រ័យទាក់ទង «កុមារពុំមែនជាឧបករណ៍ទាក់ទាញទេសចរ» និង «សូមកុំបង្កើតកុមារកំព្រាបន្ថែមទៀត» បង្កើតឡើងដោយអង្គការ FI។ ឧទាហរណ៍ស្តីពីការផ្តួចផ្តើមគំនិតប្រកបដោយជោគជ័យនៅកន្លែងដទៃទៀត រួមមានដូចជា យុទ្ធសាស្ត្រការប្រាស្រ័យទាក់ទងរបស់ '#SpeakUpForMe' ធ្វើឡើងដោយអង្គការ Families First ក្នុងប្រទេសឥណ្ឌូនេស៊ី[59] បានចាប់សម្តោធតាមរយៈបណ្តាញសង្គមក្នុងតំបន់អាមេរិកឡាទីន[60] និងយុទ្ធនាការដកហូតពីមណ្ឌលថែទាំសម្រាប់កុមារអាយុចាប់ពីសូន្យដល់បីឆ្នាំ ក្នុងអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត និងរដ្ឋឯករាជ្យរបស់រដ្ឋខំមិនវែល (Commonwealth) តំបន់ CEE/CIS[61] ក៏ដូចជានៅមេរិកឡាទីន។[62] យុទ្ធសាស្ត្រយុទ្ធនាការការផ្លាស់ប្តូរអាកប្បកិរិយា C4D ក៏អាចត្រូវបានពិចារណាជាគំរូការផ្សព្វផ្សាយមួយទៀតផងដែរ។

54 Pien Bos, Fenneke Reysoo and Mia Dambach, Qualitative research into the root causes of child abandonment and child relinquishment in Viet Nam (International Social Service, 2013) – at the request of MOLISA and UNICEF Viet Nam.

55 www.hopeandhomes.org.ua/eng/cases/4f8eaefaca550/.

56 Cantwell, N.; Davidson, J.; Elsley, S.; Milligan, I.; Quinn, N. (2012). Moving Forward: Implementing the 'Guidelines for the Alternative Care of Children'. UK: CELCIS: www.alternativecareguidelines.org

57 www.cambodianchildrensfund.org/programs/ (see community outreach).

58 www.ilo.org/dyn/migpractice/migmain.showPractice?p_lang=en&p_practice_id=84

60 www.youtube.com/watch?v=t2A0-EyVYaU&list=PL31VPFl_z_Y9u1jX8JG4yQgK3e-z4kJsJ&index=1 "#HablaPorMi" in Spanish at www.hablapormi.org

61 www.europe.ohchr.org/Documents/Press/Dynamics%20of%20deinstitutionalization%20-%20Developments%20in%20Eastern%20Europe%20Jean%20Claude%20Legrand.pdf and www.unicef.org/ceecis/Reform_Efforts.pdf

62 RELAF y UNICEF (2015), Model of prevention of abandonment ad institutionalisation of small children". Available in Spanish: www.relaf.org/materiales/Modelo Prevencion.pdf

## អនុសាសន៍ទី ៥

# បង្កើតវិធានការសំណាញ់សុវត្ថិភាព ដើម្បីការពារកុមារប្រឈមហានិភ័យនៅពេលការបង្ការជុំទីមួយពុំបានផល (ពោល គឺជាវិធានការបង្ការជុំទីពីរ)

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បញ្ជី អំពីអ្នកផ្តល់សេវាទាំងអស់ក្នុងផ្នែកការថែទាំជំនួស/សុំកូន | ១ ពង្រីកការកំណត់ទីតាំងសេវាសង្គមកិច្ចនៅទូទាំងប្រទេស ដើម្បីដាក់បញ្ចូលសេវាដទៃទៀតផងដែរ។<br>២ ស្ថាបនាបន្ថែមលើសៀវភៅព័ត៌មានទំនាក់ទំនងរបស់ FI និងមិត្តសម្លាញ់។<br>៣ បញ្ជី អំពីអនុសារណៈយោគយល់ពាក់ព័ន្ធដែលមានស្រាប់ទាំងអស់ ដើម្បីកំណត់អត្តសញ្ញាណសេវា។<br>៤ ការវាយតម្លៃលើព័ត៌មានប្រមូលបាននៅ គកនក ស្តីពីអ្នកផ្តល់សេវា។<br>៥ កសាងសមត្ថភាពរបស់ គកសក និង គកនក ដើម្បីសម្របសម្រួលយុទ្ធសាស្ត្រការទប់ស្កាត់។ | ក្រសួង ស.អ.យ និងក្រសួងទាំងអស់។ | UNICEF, 3PC, FCF, Friends International and Mith Samlanh | ២០១៨ |
| តារាងអ្នកផ្តល់សេវាទាំងអស់ | ១ បង្កើតតារាងសេវាទាំងអស់ នៅក្នុងទម្រង់ថ្នាក់កណ្តាលដោយចែកទៅតាមតំបន់។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បញ្ជីអាសយដ្ឋានទំនាក់ទំនងរបស់សេវាទាំងអស់នៅថ្នាក់ជាតិ | ១ ផ្តោតលើសកម្មភាពរយៈពេលខ្លី ត្រូវបង្កើតសេវាអាសយដ្ឋានទំនាក់ទំនងថ្នាក់ជាតិមួយ។<br>២ កំណត់អត្តសញ្ញាណអ្នកដែលនឹងគ្រប់គ្រងលើបញ្ជីអាសយដ្ឋានទំនាក់ទំនងនេះ។<br>៣ កំណត់អំពីរបៀប ដើម្បីដាក់បញ្ចូលព័ត៌មាន "ថ្មី" និង "ហួសសម័យ"។<br>៤ ផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីវត្តមាននៃបញ្ជីអាសយដ្ឋានទំនាក់ទំនងជូនដល់សាធារណជនទូទៅ និងគ្រួសារប្រឈមហានិភ័យ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩ តទៅ |
| ការគ្រប់គ្រងករណីតាមអ៊ីនធើណេត | ១ ស្ថាបនាបន្ថែមលើការងាររបស់អង្គការ ដើម្បីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងករណីតាមអ៊ីនធើណេត។<br>២ ធ្វើការកំណត់ជាមួយក្រសួងពាក់ព័ន្ធ និងអ្នកដើរតួនាទីដទៃទៀតអំពីការតម្រូវបន្ថែម សម្រាប់ការគ្រប់គ្រងករណី។<br>៣ បង្កើតប្រព័ន្ធគ្រប់គ្រងករណីថ្នាក់កណ្តាលមួយ។<br>៤ ការបណ្តុះបណ្តាលអ្នកប្រើប្រាស់ជាសក្តានុពលទាំងអស់ស្តីពីប្រព័ន្ធការគ្រប់គ្រងករណី។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩-២០២០ |
| ការបង្កើតសេវាថែទាំបណ្តោះអាសន្ន | ១ កំណត់ និងព្រមព្រៀងគ្នាអំពីប្រភេទសេវាការថែទាំបណ្តោះអាសន្នដែលត្រូវការតាមរយៈកិច្ចសហប្រតិបត្តិការថ្នាក់ក្រសួង និងកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល។<br>២ ស្ថាបនាបន្ថែមលើការងារ សង្គមស៊ីវិល និងកំណត់រកទិដ្ឋភាពនានាដែលអាចពង្រីកបន្ថែមទៀត។<br>៣ បង្កើតសេវាជាក់លាក់សម្រាប់គ្រួសារ ដែលមានកូនអាយុចន្លោះពី ០-៣ ឆ្នាំ និងកុមារដែលមានសេចក្តីត្រូវការពិសេស។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២០-២០២៣ |
| បង្កើតមណ្ឌលសហគមន៍ | ១ វាយតម្លៃ អង្គការទំនុកចិត្តកុមារ និងមណ្ឌលសហគមន៍របស់ ILO ដើម្បីកំណត់ថា តើទិដ្ឋភាពអ្វីខ្លះអាចពង្រីកបន្ថែម។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

| រយៈពេលវែង ( ហួសពី ២០២៣ ) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
| បង្កើតមណ្ឌលសហគមន៍ | ១ ពិចារណាថាតើមណ្ឌលគំរូសហគមន៍អាចត្រូវបានបង្កើតឡើងទូទាំងប្រទេស ឬទេ។<br>២ កំណត់ថវិកាសម្រាប់ការអនុវត្ត។<br>៣ រៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាមួយមណ្ឌលសហគមន៍ ដើម្បីចែករំលែកការអនុវត្តប្រកបដោយសក្តានុពល និងការដោះស្រាយបញ្ហា។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ តទៅ |
| យុទ្ធនាការទូទាំងប្រទេស ស្តីពីការដកកុមារចេញពីមណ្ឌលថែទាំដូចក្នុងអនុសាសន៍ទី ៧ | ១ វិភាគយុទ្ធនាការពីប្រទេសដទៃទៀត ដើម្បីកំណត់រកយុទ្ធនាការទាំងឡាយណា ដែលអាចមានប្រយោជន៍ក្នុងប្រទេសកម្ពុជា។<br>២ បង្កើតក្រុមគោលដៅ ដើម្បីបញ្ជាក់ឱ្យដឹងច្បាស់ថាតើសារណាខ្លះ ដែលមានប្រសិទ្ធភាពបំផុត។<br>៣ ស្នើសុំការជួយជ្រោមជ្រែងពីអ្នកអាជីពផ្នែកធ្វើទីផ្សារ ឬអ្នកធ្វើការនៅក្នុងកន្លែងថែទាំ។<br>៤ ចាប់សម្ពោធយុទ្ធនាការទូទាំងប្រទេសក្នុងអំឡុងព្រឹត្តិការណ៍/ទិវា «កម្រិតខ្ពស់» ដើម្បីទាក់ទាញការចាប់អារម្មណ៍ជាអតិបរមា ដោយពិចារណាលើការចូលរួមរបស់អ្នកល្បីឈ្មោះណាម្នាក់ ដូចជាឯកអគ្គរដ្ឋទូតរបស់ យូនីសេហ្វជាដើម។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

# អនុសាសន៍ទី ៦

## ពេលមិនអាចចៀសរួចពីការបញ្ជូនទៅកន្លែងថែទាំជំនួស ត្រូវផ្តោតកិច្ចខិតខំលើ "ការចាប់ផ្តើមជាថ្មី" (ពោល គឺជាវិធានការបង្ការជុំទីបី និងសមាហរណកម្ម)

**ST** លើកទឹកចិត្តឱ្យមានទំនាក់ទំនងជាបន្តជាមួយគ្រួសារកំណើត តាមរយៈការលើកកម្ពស់ការថែទាំដោយសាច់ញាតិ។

អនុវត្តកម្មវិធីការចូលរួមរបស់កុមារ។

បំពាក់លក្ខណៈសម្បត្តិឱ្យអ្នកប្រកបវិជ្ជាជីវៈអាជីពឱ្យដាក់បញ្ចូលសំឡេងរបស់កុមារនៅក្នុងការធ្វើការសម្រេចចិត្ត។

**MT** បង្កើតការចុះបញ្ជីកុមារបង់ចោល ដើម្បីដាក់បញ្ចូលទិន្នន័យប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិ។

ដាក់ឱ្យប្រព័ន្ធការរាយការណ៍ជាកាតព្វកិច្ចដើម្បីកំណត់អត្តសញ្ញាណគ្រួសារប្រឈមហានិភ័យ។

**LT** បណ្តុះបណ្តាលបុគ្គលិកសង្គមកិច្ចនៅក្នុងមន្ទីរ ស.អ.យ ឱ្យផ្តោតការយកចិត្តទុកដាក់លើចំណុចខ្លាំងរបស់គ្រួសារ និងស្វែងយល់អំពីជម្រើសទាំងអស់ដែលមាន។

មិនថាមានកិច្ចខិតខំយ៉ាងណាក្តី កុមារមួយចំនួននៅតែអាចឈានចូលទៅក្នុងប្រព័ន្ធការថែទាំ។ នេះបានន័យថា ជាការលើកកម្ពស់ការវិលត្រឡប់របស់កុមារមកកាន់ការថែទាំរបស់ឪពុកម្តាយវិញនៅគ្រប់ពេលដែលសមស្រប។ ដើម្បីជួយសម្រួលដល់សមាហរណកម្ម គោលការណ៍មួយចំនួនគួរត្រូវបានគោរពតាម ឧ. ដូចជាការលើកទឹកចិត្តឱ្យមានការទំនាក់ទំនងទៅកាន់គ្រួសារកំណើត នៅពេលណាដែលការទំនាក់ទំនងបែបនេះជាឧត្តមប្រយោជន៍របស់កុមារ ការផ្តល់ការថែទាំឱ្យបានកៀកបំផុតតាមដែលអាចធ្វើបានទៅកាន់លំនៅដ្ឋានជាប្រចាំរបស់កុមារ ដើម្បីជួយសម្រួលដល់ការទៅលេងផ្ទះ និងការពិនិត្យឡើងវិញជាប្រចាំយ៉ាងហោចណាស់រៀងរាល់បីខែម្តង។ ការចង្អុលបង្ហាញទិសដៅបន្ថែមទៀត ត្រូវបានផ្តល់ជូននៅក្នុងគោលការណ៍ណែនាំស្តីអំពីសមាហរណកម្មកុមារដាក់សម្ភោធក្នុង ខែកញ្ញា ឆ្នាំ២០១៦។[64] គោលការណ៍ទាំងនេះ ជាច្រើនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្របខ័ណ្ឌការងារផ្នែកច្បាប់ និងគោលនយោបាយជាតិ។[65]

សម្រាប់រយៈពេលខ្លី មធ្យោបាយមួយក្នុងការលើកកម្ពស់ការទំនាក់ទំនងជាបន្តជាមួយគ្រួសារកំណើត គឺតាមរយៈការចាត់អាទិភាពការថែទាំជាមួយសាច់ញាតិ ឧ.ដូចដែលបានអនុវត្តយ៉ាងជោគជ័យដោយអង្គការ កុមារក្នុងគ្រួសារ និងម្លប់តាប៉ាង។ ការថែទាំដោយសាច់ញាតិ ក៏ដូចគ្នាជាមួយការថែទាំដោយគ្រួសារបង្កើត ឬគ្រួសារធម៌ដែរ គឺត្រូវការការគាំទ្រនៅក្នុងតួនាទីការមើលថែរបស់ពួកគេ ដើម្បីធានាបាននូវនិរន្តរភាព ប៉ុន្តែខុសប្លែកពី "ការរៀបចំឱ្យការថែទាំពីមនុស្សមិនដែលស្គាល់"។[66] មិនខុសពីបណ្តាប្រទេសជាច្រើន ដែលមានបញ្ហាទេសន្តប្រវេសន៍ ការថែទាំដោយសាច់ញាតិក្នុងប្រទេសកម្ពុជា ច្រើនតែធ្វើឡើងដោយយាយតា ហើយអាចពាក់ព័ន្ធជាមួយភាពស្មុគស្មាញផ្សេងៗដូចជាការថមថយសុខភាព ហើយប្រហែលជាចាំបាច់ត្រូវមានការថែទាំបណ្តោះអាសន្ន (សូមមើលអនុសាសន៍ទី ៥៖ ការថែទាំបណ្តោះអាសន្ន)។

63 សូមមើលនូវគោលការណ៍ណែនាំអង្គការសហប្រជាជាតិ វាក្យខ័ណ្ឌ ១១ ១៥ ២២ ៤០ ៤៩-៥២ ៦៧៖ www.unicef.org/protection/alternative_care_Guidelines-English.pdf

64 www.familyforeverychild.org/our-impact/guidelines-on-childrens-reintegration/?utm_source=partners&utm_medium=social&utm_campaign=Guidelines%20Launch

65 សូមមើលបញ្ជីស្ថានភាពហានិភ័យ និងការវាយតម្លៃលើហានិភ័យ និងចំណុចខ្លាំងនៅក្នុងគ្រួសារសេវារក្សាចំណាងគ្រួសារ៖ ជំពូកទី៤ ប្រកាសស្តីពីនីតិវិធី ដើម្បីអនុវត្តគោលនោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ (ឆ្នាំ ២០១១) និងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីជួយជ្រោមជ្រែងដល់គ្រួសារ និងកុមារងាយរងគ្រោះ៖ ជំពូកទី ១ និយមន័យនៃស្ថានភាពប្រឈមហានិភ័យ និងតម្រូវការអន្តរាគមន៍៖ ជំពូកទី២ ផ្នែកទី១ និងសេវារក្សាចំណងគ្រួសារ៖ ជំពូកទី៤ ដំណើរការពិនិត្យតាមដាន៖ ជំពូកទី៤ ផ្នែកទី៦ គោលការណ៍ណែនាំ និងឧបករណ៍សម្រាប់ការអនុវត្តប្រកាសស្តីពីនីតិវិធី ដើម្បីអនុវត្តគោលនយោបាយការថែទាំជំនួសសម្រាប់កុមារ (២០១៣)។

66 Marie Connolly, Meredith Kiraly, Lynne McCrae and Gaye Mitchell, A Kinship Care Practice Framework: Using a Life Course Approach, British Journal of Social Work Advance Access published May 9, 2016.

## អនុសាសន៍ទី ៦

# ពេលមិនអាចចៀសរួចពីការបញ្ជូនទៅកន្លែង ថែទាំជំនួសត្រូវផ្តោតកិច្ចខិតខំលើ "ការចាប់ផ្តើមជាថ្មី" (ពោល គឺជាវិធានការបង្ការជុំទីបី និងសមាហរណកម្ម)

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| លើកកម្ពស់ការថែទាំដោយសាច់ញាតិ | ១ រៀបចំវគ្គផ្តល់ព័ត៌មានស្តីអំពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការថែទាំដោយសាច់ញាតិនៅក្នុងសហគមន៍ ដោយមានសក្ខានុពលជាផ្នែកមួយនៃយុទ្ធសាស្ត្រផ្លាស់ប្តូរអាកប្បកិរិយា។<br>២ បង្កើតគោលនយោបាយដើម្បីចាត់អាទិភាពការថែទាំដោយសាច់ញាតិ។<br>៣ កំណត់ប្រភពធនធានសម្រាប់ការអនុវត្តគោលនយោបាយ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| ការបណ្តុះបណ្តាលបុគ្គលិកមណ្ឌលថែទាំកុមារអំពីសមាហរណកម្ម | ១ ការបណ្តុះបណ្តាលអំពីអត្ថប្រយោជន៍នៃសមាហរណកម្ម រួមទាំងបញ្ហាប្រឈមក្នុងការអនុវត្ត។<br>២ ក្នុងអំឡុងពេលការបណ្តុះបណ្តាលត្រូវកំណត់រកច្រក ដើម្បីជម្នះបញ្ហាប្រឈម។<br>៣ បង្កើតសេវាគាំទ្រសម្រាប់ការអនុវត្តសមាហរណកម្មប្រកបដោយប្រសិទ្ធភាពផ្អែកលើការអនុវត្តដែលមានស្រាប់។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |

## រយៈពេលខ្លី (២០១៨)

| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
|---|---|---|---|---|
| ណែនាំឱ្យមានកម្មវិធីការចូលរួមរបស់កុមារ | ១ ធ្វើបញ្ជី កម្មវិធីដែលមានស្រាប់ ដែលលើកទឹកចិត្តដល់ការចូលរួមរបស់កុមារ។<br>២ ពិចារណាអំពីកម្មវិធីការចូលរួមរបស់កុមារពីខាងក្រៅ។<br>៣ បន្សុំកម្មវិធី និងការអនុវត្តនៅទូទាំងប្រទេស ផ្សារភ្ជាប់ជាមួយគោលការណ៍ណែនាំកម្មវិធីស្តីពីសមាហរណកម្ម។<br>៤ បណ្តុះបណ្តាលអ្នកដើរតួនាទីនានាស្តីពីការចូលរួមរបស់កុមារ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |

## រយៈពេលមធ្យម (២០១៩-២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
|---|---|---|---|---|
| ការចុះបញ្ជីកុមារបោះបង់ត្រូវបានផ្សារភ្ជាប់ជាមួយប្រព័ន្ធទិន្នន័យមេទូទាំងប្រទេសដូចក្នុងអនុសាសន៍ទី ២ | ១ កំណត់រកគោលនយោបាយ ដើម្បីឆ្លើយតបចំពោះការបោះបង់កុមារចោលរួមទាំងអាជ្ញាធរទទួលខុសត្រូវ។<br>២ បង្កើតប្រព័ន្ធទិន្នន័យមេ ដើម្បីដាក់ព័ត៌មានស្តីពីការបោះបង់កុមារចោលឱ្យនៅថ្នាក់កណ្តាល។ ការចុះបញ្ជីអាចស្ថិតក្រោមការថែទាំរបស់ គកនក។<br>៣ កំណត់រកអាជ្ញាធរ ដើម្បីគ្រប់គ្រងលើការចុះបញ្ជី។<br>៤ ផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយអំពីការចុះបញ្ជីនៅស្ថានីយ៍ប៉ូលិស តុលាការ។ល។ | ក្រសួង ស.អ.យ ក្រសួងយុត្តិធម៌។ | UNICEF, 3PC, FCF | ២០១៩ តទៅ |

| រយៈពេលវែង ( ហួសពី ២០២៣ ) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
| ឆ្លើយតបចំពោះមូលហេតុនៃការបំបែកកុមារចេញពីគ្រួសារ | ១ ធ្វើការសិក្សាស្ដីពីការបោះបង់ និងការលែងចង់បានកុមារ។<br>២ ផ្ដែកលើការសិក្សា ត្រូវកំណត់រកអនុសាសន៍បែបអនុវត្តជាក់ស្ដែង ដើម្បីឆ្លើយតបបុព្វហេតុឬសគល់ ( លទ្ធភាពទទួលបានការអប់រំ "ដោយគិតថ្លៃ" )។<br>៣ បង្កើតសេវានានា ដែលផ្ដោតគោលដៅលើបុព្វហេតុឬសគល់។<br>៤ បង្កើតយុទ្ធនាការទូទាំងប្រទេស ប្រឆាំងការបោះបង់កុមារចោល និងការលែងចង់បានកុមារត្រឡប់មកវិញ។ | ក្រសួង ស.អ.យ និងក្រសួងបច្ចេកវិទ្យា។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

បន្ថែមលើនេះទៀត ដើម្បីបង្កើនជោគជ័យនៃសមាហរណកម្មថែមទៀត ការពិចារណាដ៏ចាំបាច់មួយ គឺការចូលរួមរបស់កុមារ។[67] ក្នុងបរិបទនៃគោលដៅថ្នាក់ជាតិក្នុងការធ្វើសមាហរណកម្មកុមារ ៣០ ភាគរយ កង្វល់ដែលត្រូវបានលើកឡើង គឺពុំមានផ្នែកណាមួយនៃដំណើរការនេះនាពេលបច្ចុប្បន្នអនុញ្ញាតឱ្យអ្នកប្រកបវិជ្ជាជីវៈអាជីពមានពេលវេលា ដើម្បីធ្វើការជាមួយកុមារ និងពន្យល់អំពីមូលហេតុ ដើម្បីឱ្យពួកគេចូលមកក្នុងប្រព័ន្ធការថែទាំ និងតើហេតុអ្វីបានជាពួកគេត្រូវត្រឡប់ទៅផ្ទះវិញ។ ហេតុនេះ ចាំបាច់ត្រូវបង្កើតឱ្យមានកម្មវិធីការចូលរួមយ៉ាងសកម្មពីកុមារ។ ការងារនាពេលអនាគតរបស់ FCF ក្នុងការណែនាំឱ្យមានសន្និសីទគ្រួសារ[68] អាចជាមធ្យោបាយមួយ ដើម្បីសម្របសម្រួលឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់។ នៅប្រទេសហូឡង់សន្និសីទគ្រួសារនេះបានក្លាយជាផ្នែកមិនអាចកាត់ចេញបានមួយនៃច្បាប់ស្ដីពីការការពារកុមារ ហើយសន្និសីទប្រភេទនេះ បច្ចុប្បន្នគឺជាការអនុវត្តជាកាតព្វកិច្ចនៅក្នុងដំណើរការនៃការថែទាំ។[69]

ការធានាឱ្យមានការរួមបញ្ចូលកុមារប្រាកដជាតម្រូវឱ្យមានការបណ្ដុះបណ្ដាលបុគ្គលិកមណ្ឌលថែទាំកុមារអំពីការធ្វើសមាហកម្មជាពិសេសក្នុងករណីដែលមានវត្តមានទស្សនៈភាន់ច្រឡំ ( សូមមើលអនុសាសន៍ទី ៣៖ ការបណ្ដុះបណ្ដាល )។ មានការសង្កេតឃើញនៅកន្លែងផ្សេងទៀតថា "ក្នុងពេលខ្លះ បុគ្គលិកអាចសន្មតដោយខុសឆ្គងថា ពេលដែលឪពុកម្ដាយពុំមកសួរសុខទុក្ខកូនស្ថិតក្នុងមណ្ឌលការពារសង្គម (SPC) ( សមមូលជាមួយមណ្ឌលថែទាំកុមារ ) ជាប្រចាំ នោះគឺជាសញ្ញាមួយនៃកង្វះចំណាប់អារម្មណ៍ដែលផ្ទុយជាមួយបញ្ហាផ្សេងៗទៀត ដូចជាខ្វះសមត្ថភាពធ្វើដំណើរមកកាន់មណ្ឌលការពារសង្គម ដែលមានទីតាំងឆ្ងាយពីផ្ទះរបស់គ្រួសារ ហើយក្នុងករណីមួយចំនួនការធ្វើដំណើរមកសួរសុខទុក្ខអាចបង្កការឈឺចាប់ខ្លាំងពេក ( ពោលគឺជាការរំលឹកឱ្យចងចាំអំពីអសមត្ថភាពរបស់ពួកគេក្នុងការមើលថែកូនឱ្យបានត្រឹមត្រូវ )។"[70]

67 មាត្រា ១២ នៃ UNCRC និងអនុសាសន៍ទូទៅលេខ ១២៖ សិទ្ធិរបស់កុមារ ដើម្បីឱ្យត្រូវបានគេស្ដាប់ឮ។
សូមមើលជាឧទាហរណ៍អំពីសន្និសីទគ្រួសារនៅ៖ https://aifs.gov.au/cfca/publications/family-group-conferencing-australia-15-years

68 www.eigen-kracht.nl/assets/uploads/2015/05/20140000_Transforming_Care_The_new_welfare_state_RvPagée-EU-Forum-Rest.Justice.pdf, www.ncbi.nlm.nih.gov/pmc/articles/PMC4574617/, http://english.wodc.nl/onderzoeksdatabase/2384-evaluatie-van-de-inzet-van-(familie)netwerkberaad-eigen-kracht-conferenties-(ekc)-in-jeugdbescherming.aspx

69 Pien Bos, Fenneke Reysoo and Mia Dambach, Qualitative research into the root causes of child abandonment and child relinquishment in Viet Nam (International Social
70 Service, 2013) – at the request of MOLISA and UNICEF Viet Nam

ក្នុងករណីនៃការបោះបង់កុមារចោល (ការលះបង់សមត្ថកិច្ចជាឪពុកម្តាយជាអនាមិកភាព) សម្រាប់រយៈពេលមធ្យម យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យបង្កើតប្រព័ន្ធចុះបញ្ជីមួយ ដែលផ្តោតទិន្នន័យទៅដល់ប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិ (សូមមើលអនុសាសន៍ទី ២៖ ប្រព័ន្ធទិន្នន័យមេ)។ ដោយហេតុថា ក្រសួង ស.អ.យ មានអាណត្តិអនុវត្តសកម្មភាពតាមដានរកប្រភពរយៈពេល ៦ ខែ ពួកគេច្បាស់ជាមានការទទួលខុសត្រូវផ្នែកប្រតិបត្តិការ។ ការចុះបញ្ជីនេះអាចជួយសម្រួលដល់ការធ្វើសមាហរណកម្មក្នុងករណីគ្រួសារបានផ្លាស់ប្តូរចិត្ត ឬពេលដែលកុមារត្រូវបាននាំចេញមកដោយខុសច្បាប់។ ដូចគ្នានេះដែរ កិច្ចខិតខំធ្វើសមាហរណកម្មអាចត្រូវបានសម្របសម្រួលដោយការប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងសង្គម ដូចជាតាមរយៈការអប់រំគ្រូបង្រៀនឱ្យចេះកំណត់អត្តសញ្ញាណកុមារប្រឈមហានិភ័យ និងក្នុងការផ្តល់ការគាំទ្រ។ នាពេលក្រោយទៀត ការងារនេះអាចពាក់ព័ន្ធជាមួយប្រព័ន្ធការរាយការណ៍ជាកាតព្វកិច្ចសម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពទាំងអស់ ដែលធ្វើការដោយផ្ទាល់ជាមួយកុមារី[71] ហេតុនេះបញ្ហាប្រឈមអាចត្រូវបានកំណត់ឃើញភ្លាមៗ។ អនុសាសន៍នេះអាចត្រូវបានពិចារណាតាំងពីដំបូងជាផ្នែកមួយនៃសៀវភៅណែនាំរបស់ គកនក ដែលត្រូវបានសរសេរព្រាងក្នុងឆ្នាំ ២០១៧។

ដូចគ្នានេះដែរ សម្រាប់រយៈពេលវែង សមាហរណកម្មប្រកបដោយនិរន្តរភាពទាមទារការផ្តោតការយកចិត្តទុកដាក់លើចំណុចខ្លាំងរបស់គ្រួសារ និងការចំណាយពេលដើម្បីធ្វើឱ្យស្ថានភាពមានស្ថេរភាព។ ប្រសិនបើគ្មានការឆ្លើយតប ចំពោះមូលហេតុដែលធ្វើឱ្យមានការបំបែកកុមារចេញពីគ្រួសារតាំងពីដំបូងទេ ប្រាកដជាមានហានិភ័យខ្ពស់ក្នុងការបន្តបំបែកកុមារចេញពីគ្រួសារទៅមុខទៀត (សូមមើលអនុសាសន៍ទី ៤៖ ការបង្ការជុំទីមួយ និងអនុសាសន៍ទី ៥៖ ការបង្ការជុំទីពីរ)។ ការងារនេះច្បាស់ជាត្រូវការឱ្យមានការបណ្តុះបណ្តាលបុគ្គលិកមន្ទីរ ស.អ.យ ដើម្បីធានាឱ្យបានថា ជម្រើសជាសក្តានុពលត្រូវបានគោរពតាម និងកត់សម្គាល់យ៉ាងត្រឹមត្រូវមុនពេលអនុញ្ញាតឱ្យកុមារចូលទៅក្នុងប្រព័ន្ធការថែទាំ "ជាផ្លូវការ" (សូមមើលអនុសាសន៍ទី ៣៖ ការបណ្តុះបណ្តាល និងអនុសាសន៍ទី ៧៖ ការតាមដាន)។

71 See: www.community.nsw.gov.au/preventing-child-abuse-and-neglect/resources-for-mandatory-reporters/how-to-make-a-report

# អនុសាសន៍ទី

# ៧

## ណែនាំឱ្យមានយន្តការតាមដានប្រកបដោយប្រសិទ្ធភាព

**ST** កែលម្អសមត្ថភាពអ្នកពិនិត្យតាមដានដើម្បីអាចបំពេញតួនាទីរបស់ពួកគេបានត្រឹមត្រូវ។

**MT** បង្កើតលក្ខខណ្ឌវិនិច្ឆ័យទទួលយកកុមារក្នុងលក្ខណៈឯកភាពគ្នាសម្រាប់អ្នកផ្តល់សេវាថែទាំក្នុងរដ្ឋាភិបាល និងឯកជន។

**LT** យុទ្ធនាការការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការរក្សាគ្រួសារឱ្យនៅរួមគ្នា និងផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់នៃមណ្ឌលថែទាំកុមារ។

ធានាលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពដោយឥតគិតថ្លៃ។

ការតាមដានត្រូវបានកំណត់និយមន័យថាជា "នីតិវិធីដែលត្រូវបានទទួលស្គាល់ និងមានលក្ខណៈជាប្រព័ន្ធ ដើម្បីធានាឱ្យបានថាការថែទាំជំនួសសម្រាប់កុមារត្រូវបានប្រើប្រាស់តែនៅពេលចាំបាច់ ហើយកុមារបានទទួលការគាំទ្រសមស្របបំផុត ដើម្បីឆ្លើយតបទៅតាមសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់ពួកគេ។"[72] នៅក្នុងបរិបទសុខុមាលភាពកុមារ និងការការពារកុមារពាក្យនេះអាចត្រូវបានពិពណ៌នាថាជាកម្រងគោលនយោបាយជាយុទ្ធសាស្ត្រ និងកម្មវិធីដើម្បីទប់ស្កាត់ការប្រើប្រាស់ការថែទាំនៅខាងក្រៅផ្ទះ ជាពិសេសគឺ មណ្ឌលថែទាំកុមារ។[73]

ក្នុងអំឡុងការចុះទស្សនៈកិច្ចរបស់យើង យើងបានកត់សម្គាល់ឃើញតម្រូវការរបស់អ្នកទទួលបន្ទុកតាមដានក្នុងការរក្សាឯករាជ្យភាពមួយចំនួន ដើម្បីចៀសវាងជម្លោះផលប្រយោជន៍។ ឧ. មណ្ឌលថែទាំកុមារទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុចំពោះកុមារម្នាក់ៗក្រោមការថែទាំរបស់ខ្លួន ហេតុនេះហើយពួកគេប្រហែលជាបានទទួលការលើកទឹកចិត្តក្នុងការបង្កើន ឬរក្សាចំនួនកុមារ។ ថ្វីបើមន្ទីរ ស.អ.យ ស្ថិតក្នុងគោលជំហរល្អ ដើម្បីជាអ្នកតាមដានលើផែនការសកម្មភាពជាតិ ដែលបានលើកឡើងអំពីគកនក ថាមានតួនាទីតាមដានក្តី ប៉ុន្តែការអនុវត្តជាក់ស្តែងយើងឃើញថា ពួកគេទាំងពីរពុំមានធនធានឡើយ ឧ.ដូចជាធនធានដើម្បីធ្វើដំណើរទៅកាន់គ្រួសារ ហើយក៏ពុំមានសមត្ថភាព ដើម្បីធ្វើការវាយតម្លៃ និងស្នើឡើងនូវជម្រើសប្រកបដោយនិរន្តរភាពដែរ។ ដោយហេតុថាគិលានុប្បដ្ឋាកយិកាផ្នែកសុខភាពសហគមន៍មានវត្តនៅក្នុងឃុំមូលដ្ឋាននីមួយៗ យើងខ្ញុំសូមស្នើថា ការបំពាក់លក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យពួកគាត់ក្នុងរយៈពេលខ្លី ដើម្បីធ្វើការជាមួយមន្ទីរ ស.អ.យ និងសហគមន៍ស្ត្រីកម្ពុជា ដើម្បីការអភិវឌ្ឍ (CCWD) ដើម្បីវាយតម្លៃលើគ្រួសារប្រឈមហានិភ័យ។ ប្រព័ន្ធមុខពីរនេះ អនុញ្ញាតឱ្យគេអាចបង្កើនប្រសិទ្ធភាពធនធាន

72 Cantwell, N.; Davidson, J.; Elsley, S.; Milligan, I.; Quinn, N. (2012). Moving Forward: Implementing the 'Guidelines for the Alternative Care of Children'. UK: CELCIS www.alternativecareguidelines.org

73 Herczog, M, Gatekeeping, Building on the Momentum Alternative Care Conference, Geneva, October 2016.

និងកាត់បន្ថយការអនុវត្តខុសច្បាប់ជាសក្តានុពល។ ជាជម្រើសមួយទៀត ការបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តសហគមន៍ក៏អាចធ្វើឡើងបានដែរ ដោយក្នុងនោះយើងឃើញជាឧទាហរណ៍ដូចជាមិត្តភក្តិចំនួន ៣០០០០ នាក់ របស់គ្រួសារបានទទួលការបណ្តុះបណ្តាល ដើម្បីធ្វើការកំណត់អត្តសញ្ញាណពីដំបូងនៅក្នុងប្រទេស រ៉្វាន់ដា។[74]

យើងខ្ញុំសូមលើកទឹកចិត្ត ឱ្យមានការបង្កើតនូវលក្ខខណ្ឌវិនិច្ឆ័យការទទួលយកកុមារក្នុងលក្ខណៈឯកភាពគ្នាសម្រាប់អ្នកផ្តល់ការថែទាំក្នុងរដ្ឋាភិបាល និងឯកជនដោយត្រូវដាក់បញ្ចូលនៅក្នុងសៀវភៅណែនាំការអនុវត្ត និងការពិនិត្យតាមដានរបស់កម្ពុជា ( សូមមើលអនុសាសន៍ទី ៣៖ ការបណ្តុះបណ្តាលសម្រាប់រយៈពេលមធ្យម។ ការធ្វើបែបនេះអាចជួយកំណត់បទដ្ឋានគំរូច្បាស់លាស់របស់សេចក្តីត្រូវការបែបជាក់ស្តែង ដើម្បីអាចត្រូវបានឆ្លើយតបមុនពេលកុមារចូលទៅក្នុងប្រព័ន្ធការថែទាំ។ ការងារនេះអាចរួមមានឯកសារតាមដាន ការកត់សម្គាល់នូវកិច្ចខិតខំជាក់ស្តែងណាមួយដែលត្រូវបានធ្វើឡើង ដើម្បីគាំទ្រដល់គ្រួសារ និងការធ្វើសមាហរណកម្ម។ ដោយឡែកដោយសារការអប់រំត្រូវបានគេមើលឃើញថា ជាកត្តាជំរុញដ៏ចម្បងមួយធ្វើឱ្យមានការបំបែកកុមារចេញពីគ្រួសារ យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យមានឯកសារតាមដានដែលកត់សម្គាល់ ថាតើមានការគាំទ្រជាក់ស្តែងអ្វីខ្លះសម្រាប់ការអប់រំ ត្រូវបានផ្តល់ជូនដល់គ្រួសារ ដូចជា ឯកសណ្ឋានសិស្ស សៀវភៅសិក្សា។ល។ ដើម្បីប្រយុទ្ធប្រឆាំងទស្សនៈយល់ខុសដែលចាត់ទុកថា កុមារបានទទួលការអប់រំប្រសើរជាងពេលនៅក្នុងមណ្ឌលថែទាំកុមារ យើងខ្ញុំសូមលើកទឹកចិត្តឱ្យរចនាយុទ្ធនាការការលើកកម្ពស់ការយល់ដឹងជូនដល់សាធារណជនទូទៅ ដែលគូសបញ្ជាក់ឱ្យឃើញអំពីសារៈសំខាន់នៃការរក្សាគ្រួសារឱ្យរស់នៅជួបជុំគ្នា និងផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់នៃមណ្ឌលថែទាំកុមារ ( សូមមើលអនុសាសន៍ទី ៥៖ ការទប់ស្កាត់ជុំទី ២ )។ ជាការពិតណាស់យុទ្ធនាការនេះចាំបាច់ត្រូវបានទទួលការគាំទ្រយ៉ាងជាក់ស្តែងតាមរយៈការកែលម្អលទ្ធភាពទទួលបានការអប់រំដោយឥតគិតថ្លៃយ៉ាងពិតប្រាកដសម្រាប់កុមារគ្រប់រូប។ ការងារនេះ គួរផ្សារភ្ជាប់ជាមួយការងារយុទ្ធសាស្ត្រផ្លាស់ប្តូរអាកប្បកិរិយា ដែលកំពុងបន្ត។ ក្រសួងអប់រំយុវជន និងកីឡា ក៏ចាំបាច់ត្រូវឆ្លើយតបចំពោះបញ្ហាដែលបានកត់សម្គាល់ឃើញដទៃទៀត ដូចជាប្រាក់បៀវត្សទាបរបស់គ្រូបង្រៀន កង្វះហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងគ្រូទារថ្លៃឈ្នួលបង្រៀនបន្ថែមជាដើម ដោយចំណុចទាំងអស់នេះសុទ្ធតែត្រូវបានអះអាងរួចហើយដោយគណៈកម្មាធិការអង្គការសហប្រជាជាតិ ដើម្បីសិទ្ធិកុមារក្នុងឆ្នាំ ២០១១។[75]

74 https://www.unicef.org/rwanda/RWA_resources_friendsofFamily.pdf

75 (c) នៅតែខ្វះខាតហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅក្នុងរដ្ឋភាគី ជាពិសេស គឺបរិក្ខារនានាដូចជា បង្គន់អនាម័យ និងទឹកស្អាតសម្រាប់បរិភោគ ក៏ដូចជាសម្ភារៈសម្រាប់សិស្សពិការ ជាពិសេសគឺនៅក្នុងតំបន់ជនបទ (d) ថ្វីបើរដ្ឋភាគីបានបញ្ជាក់ប្រាប់ក្នុងអំឡុងកិច្ចសន្ទនាថា បញ្ហានៃការបង់ថ្លៃឈ្នួលបង្រៀនបន្ថែមដល់គ្រូ ត្រូវបានឆ្លើយតបហើយក្តី ប៉ុន្តែប្រាក់បៀវត្សរបស់គ្រូនៅទាបនៅឡើយ ឯកម្រិតជាទូទៅនៃអំពើពុករលួយដែលមាននៅក្នុងរដ្ឋភាគីបាននាំឱ្យមានលទ្ធភាពដែលធ្វើឱ្យគ្រូយកលុយ ដើម្បីឱ្យសិស្សប្រឡងជាប់ http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC%2fC%2fKHM%2fCO%2f2&Lang=en

អនុសាសន៍ទី

៧

# ណែនាំឱ្យមានយន្តការតាមដានប្រកបដោយប្រសិទ្ធភាព

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បំពាក់លក្ខណៈសម្បត្តិគ្រប់គ្រាន់ដល់គិលានុប្បដ្ឋាយិកាផ្នែកសុខភាពសង្គម | ១ ការបណ្តុះបណ្តាល គគនគ គគសគ គិលានុប្បដ្ឋាកយិកាផ្នែកសុខភាពសង្គម និង មន្ទីរ សអយ អំពីការតាមដាន។<br>២ វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំស្តីពីការតាមដានជូនដល់ «អ្នកតាមដាន» ទាំងអស់។ | ក្រសួង ស.អ.យ និង ក្រសួងសុខាភិបាល។ | UNICEF, 3PC, FCF | ២០១៨ |
| យុទ្ធនាការដកកុមារចេញពីមណ្ឌលថែទាំនៅទូទាំងប្រទេស (អនុសាសន៍ទី ៥) | ១ វាយតម្លៃប្រសិទ្ធភាពនៃយុទ្ធនាការ De-I ក្នុងអនុសាសន៍ទី ៥ និងសម្រួលឡើងវិញសម្រាប់យុទ្ធនាការតទៅមុខទៀត។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| **រយៈពេលមធ្យម (២០១៩-២០២៣)** | | | | |
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| លក្ខខណ្ឌវិនិច្ឆ័យទទួលយកកុមារចូលក្នុងប្រព័ន្ធថែទាំដែលមានលក្ខណៈឯកភាពគ្នាសម្រាប់អ្នកផ្តល់ការថែទាំក្នុងរដ្ឋាភិបាល និង ឯកជន | ១ កំណត់លក្ខខណ្ឌវិនិច្ឆ័យទទួលយកកុមារចូលក្នុងប្រព័ន្ធថែទាំក្នុងចំណោមក្រសួងពាក់ព័ន្ធ CSOs និងស្ថាប័នដទៃទៀត។<br>២ លក្ខខណ្ឌវិនិច្ឆ័យនៅក្នុងទម្រង់ទទួលយកកុមារ «បទដ្ឋាន» ជាកាតព្វកិច្ច។<br>៣ បង្កើតទម្រង់ទទួលយកកុមារចូលស្តីពី ថាតើវិធានការការអប់រំអ្វីខ្លះត្រូវបានផ្តល់ជូនដល់គ្រួសារ។<br>៤ បកស្រាយបញ្ជាក់អំពីអ្វីដែលគួរធ្វើពេលខ្វះព័ត៌មាន។<br>៥ ដាក់ទម្រង់ «ទទួលកុមារចូល» ទាំងអស់ឱ្យនៅថ្នាក់កណ្តាលក្នុងប្រព័ន្ធទិន្នន័យមេក្នុងអនុសាសន៍ទី ២។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩ តទៅ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| **តើចាំបាច់ត្រូវមានអ្វីខ្លះ?** | **តើនឹងត្រូវអនុវត្តដោយរបៀបណា?** | **តើនរណាទទួលខុសត្រូវ?** | **តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ?** | **រយៈពេល** |
| យុទ្ធនាការទូទាំងប្រទេសក្នុងការដកកុមារចេញពីមណ្ឌលថែទាំ (អនុសាសន៍ទី ៥) | ១ ការបណ្តុះបណ្តាលជាបន្តដល់អ្នកដើរតួនាទីទាំងអស់ ស្តីពីសមាហរណកម្ម។ | ក្រសួង ស.អ.យ និងក្រសួងបច្ចេកវិទ្យា។ | UNICEF, 3PC, FCF | ២០២៣ តទៅ |



© UNICEF Cambodia/2018/Todd Brown

# ០៣

# ការថែទាំដោយឪពុកម្ដាយធម៌៖ ការរកឃើញ និងអនុសាសន៍ផែនការអភិវឌ្ឍសមត្ថភាព

ដូចបានពិពណ៌នាខាងដើមមកហើយថា កិច្ចខិតខំក្នុងការការពារ និងការតាមដានចាំបាច់ត្រូវអភិវឌ្ឍឱ្យមាន ដោយហេតុថាកិច្ចខិតខំទាំងនេះអាចជួយការពារសុវត្ថិភាពទប់ទល់ជាមួយការយកកុមារទៅដាក់នៅក្រៅផ្ទះ ដោយមិនចាំបាច់ (សូមមើលផ្នែកទី ២)។ ថ្វីបើមានកិច្ចខិតខំទាំងអស់នេះហើយក្ដី កុមារមួយចំនួននៅតែត្រូវបានបំបែកចេញពីឪពុកម្ដាយរបស់ខ្លួន ហើយត្រូវការឱ្យមានការថែទាំជំនួស។ ក្នុងករណីបែបនេះ ចាំបាច់ត្រូវមានក្របខ័ណ្ឌការងារ ដើម្បីធានាឱ្យបានថា រដ្ឋបំពេញការទទួលខុសត្រូវរបស់ខ្លួនក្នុងការផ្ដល់ការថែទាំប្រកបដោយគុណភាព ដែលទំនុកបម្រុងដល់សេចក្ដីត្រូវការជាលក្ខណៈបុគ្គលរបស់កុមារ។ ជាការល្អបំផុត ជម្រើសបែបនេះគួរផ្ដល់អាទិភាពដល់ការថែទាំនៅតាមគ្រួសារ ដូចជាការថែទាំដោយសាច់ញាតិ និងការថែទាំដោយឪពុកម្ដាយធម៌ ក្នុងលក្ខណៈមួយដែលជាការបំពេញបន្ថែម ចំពោះការគាំទ្រដែលត្រូវបានផ្ដល់ជូនដល់គ្រួសារកំណើត។ ចាំបាច់ត្រូវមានការរក្សាតុល្យភាពយ៉ាងប្រុងប្រយ័ត្នបំផុតទាក់ទងជាមួយការចាត់ធនធាន ដើម្បីចៀសវាងភាពលម្អៀងក្នុងការផ្ដល់ "ការគាំទ្រ" ដល់គ្រួសារឪពុកម្ដាយធម៌ ដោយក្នុងនោះគ្រួសារឪពុកម្ដាយធម៌បានទទួលការគាំទ្រច្រើនជាងគ្រួសារកំណើត។ ក្នុងករណីមួយចំនួន ប្រសិនបើគ្រួសារកំណើតបានទទួលការគាំទ្រដូចគ្នាជាមួយអ្នកមើលថែជាឪពុកម្ដាយធម៌នោះ ការបំបែកចេញពីគ្រួសារពុំទំនងជាកើតមានឡើង។

ជាកិច្ចឆ្លើយតប ចំពោះចំនួនកុមារដែលកើនឡើងគួរជាទីកត់សម្គាល់នៅក្នុងការថែទាំជំនួស រដ្ឋាភិបាលបានប្រមើលឃើញនូវក្របខ័ណ្ឌការងារផ្នែកច្បាប់ និងផ្នែកគោលនយោបាយក្នុងចំនួនដ៏ច្រើនលើសលប់ (សូមមើល បញ្ជីគន្ថនិទ្ទេស)។ យើងហាក់ឃើញមានការថែទាំជំនួសនៅតាម "គ្រួសារ" សុទ្ធសាធចំនួនបីប្រភេទដែលត្រូវបានទទួលស្គាល់ក្នុងប្រទេសកម្ពុជា ពោលគឺ ការថែទាំក្រៅផ្លូវការ[76] ការថែទាំដោយសាច់ញាតិ និងការថែទាំដោយឪពុកម្ដាយធម៌។[77] ការថែទាំនៅតាមគ្រួសារបែបនេះ

76 ការអនុវត្តប្រកាសស្ដីពីនីតិវិធីដើម្បីអនុវត្តគោលនយោបាយការថែទាំជំនួសសម្រាប់កុមារ (ឆ្នាំ ២០១៣) (ជំពូក ៩ ផ្នែកទី ២ ការថែទាំក្រៅផ្លូវការជាអចិន្ត្រៃយ៍ដោយសាច់ញាតិ)

77 សូមមើលប្រកាសស្ដីពីនីតិវិធីដើម្បីអនុវត្តគោលនយោបាយការថែទាំជំនួសសម្រាប់កុមារ (ឆ្នាំ ២០១១) (មាត្រា ២៧ នីតិវិធីសម្រាប់ការថែទាំជាអចិន្ត្រៃយ៍ដោយសាច់ញាតិ មាត្រា ២៩ នីតិវិធីសម្រាប់ការថែទាំជាអចិន្ត្រៃយ៍ដោយឪពុកម្ដាយធម៌មិនមែនជាសាច់ញាតិ) និងការអនុវត្តប្រកាសស្ដីពីនីតិវិធីដើម្បីអនុវត្តគោលនយោបាយថែទាំជំនួសសម្រាប់កុមារ (ឆ្នាំ ២០១៣) (ជំពូក ៧ ផ្នែកទី ២ អាទិភាពនៃការយកកុមារទៅដាក់ក្នុងការថែទាំជំនួស)។

អាចបម្រើឧត្តមប្រយោជន៍របស់កុមារ ប្រសិនបើអ្នកថែទាំកុមារបានទទួលការគាំទ្រគ្រប់គ្រាន់។ ការស្រាវជ្រាវធ្វើឡើងដោយអង្គការទស្សនៈពិភពលោកកម្ពុជា ក្នុងឆ្នាំ ២០១៤ ស្តីពីកម្មវិធីមូលដ្ឋាននៅតាមសហគមន៍ ដោយក្នុងនោះរួមទាំងការថែទាំដោយឪពុកម្តាយធម៌ផងដែរ បានផ្តល់គំនិតយល់ដឹងបន្ថែមទៀតស្តីពីភាពខុសគ្នានៅក្នុងការផ្តល់សេវា។[78]

យើងបានមើលឃើញឆ្លងតាមរយៈកិច្ចប្រជុំរបស់យើងថា កុមារជាច្រើនកំពុងរស់នៅក្នុងការថែទាំក្រៅផ្លូវការ និងការថែទាំដោយសាច់ញាតិក្រៅផ្លូវការជាមួយសមាជិកគ្រួសារ អ្នកជិតខាង និងមិត្តភក្តិដោយពុំមានការចូលរួមពាក់ព័ន្ធពីអាជ្ញាធរមានសមត្ថកិច្ចឡើយ។ មិនខុសពីកុមារដទៃទៀតទាំងអស់នោះឡើយ កុមារដែលកំពុងរស់នៅក្នុងការរៀបចំបែបផ្លូវការ ប្រហែលជាខ្វះខាតសេវាជាមូលដ្ឋានជាច្រើន និង/ឬទាមទារនូវសេវាផ្តោតគោលដៅ ឬសេវាឯកទេសជាច្រើន។ ការគាំទ្រប្រភេទនេះ ត្រូវបានផ្តល់ដោយអង្គការនានាដូចជា អង្គការកុមារនៅក្នុងគ្រួសារ[79] អង្គការ Hagar និងអង្គការកុមាររីករាយ។[80] ទោះយ៉ាងណាក្តី យើងហាក់ឃើញថា ការថែទាំដោយសាច់ញាតិផ្លូវការ ដោយមានការអនុម័តពីអាជ្ញាធរមានសមត្ថកិច្ច ការមើលខុសត្រូវ និងការគាំទ្រ គឺពុំសូវសម្បូរឡើយ។ ថ្វីបើយើងបានទទួលភស្តុតាងជាលក្ខណៈ ការរៀបរាប់សាច់រឿងអំពីលក្ខណៈសម្បត្តិនៃការថែទាំក្រៅផ្លូវការ និងការថែទាំដោយសាច់ញាតិក្នុងប្រទេសកម្ពុជាក្តី យើងពុំស្ថិតក្នុងគោលជំហរដើម្បីលើកឡើងអំពីនិន្នាការណាមួយឡើយ អាស្រ័យដោយអាណត្តិរបស់យើងមានកម្រិតកំណត់។

ការថែទាំដោយឪពុកម្តាយធម៌ត្រូវបានផ្តល់ជូនដោយអ្នកដើរតួនាទីក្នុងសង្គមស៊ីវិលជាច្រើននៅទូទាំងប្រទេស ដោយជាចម្បងគឺផ្តោតការយកចិត្តទុកដាក់លើតំបន់ជាក់លាក់។ នៅពុំទាន់មានវត្តមានប្រព័ន្ធនៅថ្នាក់កណ្តាល និងប្រព័ន្ធនៅទូទាំងប្រទេសនៅឡើយ។ យើងនៅពុំទាន់បានដឹងអំពីចំនួនអ្នកដើរតួនាទីជាក់លាក់នៅឡើយ ថ្វីបើតួលេខនេះ គឺអាចប៉ាន់ស្មានប្រហាក់ប្រហែលដោយយោងទៅលើចំនួន ការចុះអនុសារណៈក្តី។ ទោះយ៉ាងណាក្តី យើងបានដឹងថា ពុំមែនគ្រប់អ្នកផ្តល់សេវាទាំងអស់សុទ្ធតែបានទទួលអាជ្ញាប័ណ្ណនោះឡើយ។ អង្គការនីមួយៗផ្តល់សេវាគ្រប់គ្រងករណីដល់កុមាររហូតដល់ ៥០ នាក់ និងមើលខុសត្រូវលើអ្នកមើលថែជាឪពុកម្តាយធម៌ក្នុងចន្លោះចាប់ពី ៥ ដល់ ២៥ នាក់ក្នុងមួយឆ្នាំៗ។

គោលការណែនាំអង្គការសហប្រជាជាតិកំណត់និយមន័យការថែទាំដោយឪពុកម្តាយធម៌ថា «ស្ថានភាពដែលកុមារត្រូវបានអាជ្ញាធរមានសមត្ថកិច្ចយកទៅដាក់នៅកន្លែងមួយ សម្រាប់គោលបំណងនៃការថែទាំជំនួសក្នុងបរិស្ថានគ្រួសាររបស់គ្រួសារដទៃក្រៅពីគ្រួសាររបស់កុមារ ជាគ្រួសារដែលត្រូវបានជ្រើសរើសមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុម័ត និងស្ថិតក្រោមការមើលខុសត្រូវ ដើម្បីផ្តល់ការថែទាំដល់កុមារ។»[81] លក្ខណៈសម្បត្តិជាមូលដ្ឋាននៃការថែទាំដោយឪពុកម្តាយធម៌ រួមមាន «ការរៀបចំក្នុងការថែទាំដែលត្រូវបានបញ្ជា ឬស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ច មិនថាស្ថិតនៅលើមូលដ្ឋានគ្រាអាសន្ន រយៈពេលខ្លី ឬរយៈពេលវែងក្តី ដោយក្នុងនោះកុមារត្រូវបានយកទៅដាក់ក្នុងផ្ទះរបស់គ្រួសារ ដោយក្នុងនោះអ្នកមើលថែត្រូវបានជ្រើសរើសរៀបចំខ្លួន និងផ្តល់ការអនុញ្ញាតឱ្យផ្តល់ការថែទាំដល់កុមារ ត្រូវស្ថិតក្រោមការមើលខុសត្រូវ ហើយអាចទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬផ្នែកការគាំទ្រដទៃទៀត ឬការប៉ះប៉ូវសងសម្រាប់ការងារចិញ្ចឹមកុមារនេះ។»[82] ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ការថែទាំ

79 www.childreninfamilies.org/programs.

80 https://komarrikreaycambodia.wordpress.com/our-programs/alternative-care/

81 វាក្យខណ្ឌ ២៩គ(ii)

82 ឯកសារពិភាក្សាស្តីពី ការកំណត់លក្ខណៈសម្បត្តិមូលដ្ឋាននៃបរិយាកាសការថែទាំជំនួសផ្លូវការសម្រាប់កុមារ (ខែមីនា ឆ្នាំ ២០១៣) ផាតុចេញមួយនៃក្រុមការងារ NGO ទទួលបន្ទុកកុមារដែលគ្មានការថែទាំពីឪពុកម្តាយក្នុងក្រុងហ្សឺណែវ (អនុក្រុមការងារនៃក្រុមអង្គការ NGO សម្រាប់គណៈកម្មាធិការ UNCRC) ចាត់បេសកកម្ម និងផ្តល់ហិរញ្ញវត្ថុដោយបណ្តាញ Better Care Network, Family for Every Child, International Social Service, Save the Children និង SOS Children's Villages International.

ដោយឪពុកម្ដាយធម៌ មិនមែនចាំបាច់ត្រូវតែជាការឆ្លើយតបតែមួយគត់ ដែលត្រូវបានយកមកពិចារណាសម្រាប់កុមារដែលត្រូវបានបំបែកចេញពីគ្រួសាររបស់ខ្លួនឡើយ។ រដ្ឋនីមួយៗមានការទទួលខុសត្រូវក្នុងការផ្ដល់ជម្រើសការថែទាំជាបន្តបន្ទាប់ ដើម្បីធានាថាសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់កុមារនីមួយៗត្រូវបានឆ្លើយតប។ ចំណុចនេះ មានភាពចាំបាច់ណាស់ បើគិតទៅលើទិដ្ឋភាពដែលការថែទាំដោយឪពុកម្ដាយធម៌ ប្រហែលជាពុំសក្ដិសមសម្រាប់គ្រប់កុមារទាំងអស់ដោយសារហេតុផលផ្សេងៗជាច្រើន។ ឧ. កុមារវ័យជំទង់ កុមារដែលបានធំឡើងនៅក្នុងបរិយាកាសជាក្រុម ដូចជាមណ្ឌលថែទាំកុមារ អ្នកចាកចេញពីការមើលថែ កុមាររស់នៅតាមចិញ្ចើមផ្លូវ ឬកុមារចូលចិត្តផ្លាស់ទីច្រើន គឺពុំមែនសុទ្ធតែអាចបានទទួលកន្លែងស្នាក់នៅក្នុងគ្រួសារនោះឡើយ ហើយពួកគេក៏ពុំចង់បានដូច្នេះដែរ។ ការចាប់បង្ខំឱ្យប្រើការចិញ្ចឹមដោយឪពុកម្ដាយធម៌ ជាដំណោះស្រាយសម្រាប់កុមារទាំងអស់ គឺជាទង្វើដ៏ប្រថុយប្រថាន ហើយរឹតតែប្រថុយប្រថានថែមទៀត ក្នុងករណីដែលអ្នកថែទាំជាឪពុកម្ដាយធម៌បានទទួលការវាយតម្លៃពុំដិតដល់ ការទទួលការគាំទ្រមិនគ្រប់គ្រាន់ ហើយមានការមើលខុសត្រូវតិចតួច។

គេអាចមើលឃើញយ៉ាងច្បាស់អំពីគុណប្រយោជន៍នៃការថែទាំដោយឪពុកម្ដាយធម៌ បើប្រៀបធៀបជាមួយការថែទាំក្រៅផ្លូវការដោយគ្មានការគាំទ្រគ្រប់គ្រាន់ ឬការថែទាំនៅមណ្ឌលថែទាំកុមារ។[83] នេះហើយជាមូលហេតុដែលត្រូវធ្វើឱ្យការអភិវឌ្ឍនូវប្រព័ន្ធការថែទាំដោយឪពុកម្ដាយធម៌អោយបានរឹងមាំ ហើយគ្រប់ដណ្ដប់លើប្រទេសទាំងមូល។ អនុសាសន៍ខាងក្រោមនេះផ្ដោតការយកចិត្តទុកលើការអភិវឌ្ឍការថែទាំដោយឪពុកម្ដាយធម៌ តាមរយៈការស្ថាបនាបន្ថែមលើសេវាដែលមានស្រាប់នាពេលបច្ចុប្បន្ន។ ឧ. អង្គការម្លប់ឫស្សី រួមជាមួយអង្គការចំនួន ៤ ដទៃទៀតមាន អង្គការកុមារក្នុងគ្រួសារ អង្គការជំហានដំបូង អង្គការ Mother’s Heart និងអង្គការ Prison Fellowship (គេច្រើនហៅថាជើងខ្លាំងទាំងប្រាំ) ផ្ដល់សេវាការមើលថែទាំដោយឪពុកម្ដាយធម៌ក្នុងគ្រាមានអាសន្ន ក្នុងសមាមាត្រភាគច្រើនលើសលប់។ អង្គការដទៃទៀតធ្វើការលើការថែទាំដោយឪពុកម្ដាយធម៌រយៈពេលខ្លីដូចជា អង្គការម្លប់តាប៉ាង អង្គការកុមាររីករាយ អង្គការមិត្តសម្លាញ់ និងអង្គការកល្យាណមិត្ត ចំណែកអង្គការ FI ផ្ដល់សេវាថែទាំដល់ឪពុកម្ដាយធម៌ទូលំទូលាយ ដោយមានការផ្ដួចផ្ដើមគំនិតដោយឡែកសម្រាប់ទារកត្រូវគេបោះបង់ នៅក្នុងកិច្ចសហការជាមួយមន្ទីរពេទ្យកុមារអង្គរ។[84] CCT ផ្ដល់កម្មវិធីថែទាំដោយឪពុកម្ដាយធម៌ស្របជាមួយកម្មវិធីរក្សាចំណងគ្រួសារ និងកម្មវិធីបង្រួបបង្រួមកុមារឱ្យនៅជាមួយគ្រួសារ។[85] អង្គការកុមារនៅក្នុងគ្រួសារ[86] ផ្ដល់សេវាការថែទាំដោយឪពុកម្ដាយធម៌យ៉ាងទូលំទូលាយ ចាប់តាំងពីសេវាក្នុងគ្រាមានអាសន្នរហូតដល់សេវារយៈពេលវែង។ ថ្វីបើអ្នកផ្ដល់សេវាការថែទាំដោយឪពុកម្ដាយធម៌នីមួយៗមានទម្រង់ប្រតិបត្តិការខុសៗគ្នាក្តី ប៉ុន្តែកត្តាឯកភាពគ្នាជាមូលដ្ឋាន គឺពួកគេមានជំនឿលើសារៈសំខាន់នៃការថែទាំនៅតាមគ្រួសារ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីការធ្វើសមាហរណកម្ម ការថែទាំដោយសាច់ញាតិ និងការថែទាំដោយឪពុកម្ដាយធម៌របស់ពួកគេ។ កត្តាជំរុញទឹកចិត្តក៏អាចទទួលបានពីការអនុវត្តប្រកបដោយសក្ដានុពលរបស់ពួកគាត់ ក៏ដូចជាពីយុទ្ធសាស្ត្រដែលអាចអនុវត្តបានជាលក្ខណៈអន្តរជាតិដើម្បីអភិវឌ្ឍប្រព័ន្ធការថែទាំដោយឪពុកម្ដាយធម៌។[87] យើងក៏បានដឹងផងដែរថា ជាឧទាហរណ៍ អង្គការ Care for Children ធ្វើការជាមួយ FCF ត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើការដោយផ្ទាល់ ជាមួយមណ្ឌលថែទាំកុមាររបស់រដ្ឋ ដើម្បីដាក់ឱ្យមានប្រព័ន្ធការថែទាំដោយឪពុកម្ដាយធម៌នៅក្នុងរយៈពេល ១៨ ខែខាងមុខ។

83 Elizabeth Fernandez, Foster Care, in The Wiley Blackwell Encyclopedia of Family Studies, ed: Constance, L. Shenan, , John Wiley and Sons, 2016, 874-878, A Spotlight on Foster Care, Family for Every Child, 2014: www.familyforeverychild.org/wp-content/uploads/2015/05/A-spotlight-on-foster-care.pdf Corinna Csáky, Keeping Children out of Harmful institutions, Save the Children, 2009; www.savethechildren.org.uk/sites/default/files/docs/Keeping_Children_Out_of_Harmful_Institutions_Final_20.11.09_1.pdf

84 http://friends-international.org/blog/index.php/foster-care-project-siem-reap-baby-vs-story

85 www.cambodianchildrenstrust.org/holistic-family-based-care-hfbc-model

86 www.childreninfamilies.org/foster-care

87 Family for Every Child, The place of foster care in the continuum of care choice: A review of the evidence for policymakers, London, 2015; www.familyforeverychild.org/wp content/uploads/2015/02/Strategies_for_delivering_safe_and_effective_foster_care.pdf

# អនុសាសន៍ទី

# ៨

## ណែនាំឱ្យមានក្របខ័ណ្ឌការងារនីតិកម្មថ្នាក់ជាតិស្តីពីការថែទាំដោយឪពុកម្តាយធម៌ជាផ្នែកមួយនៃការការពារសុខុមាលភាព និងការការពារផ្នែកច្បាប់សព្វគ្រប់សម្រាប់កុមារ និងក្របខ័ណ្ឌគោលនយោបាយ

**ST** ការប៉ាន់ប្រមាណ និងវាយតម្លៃលើ NGO ដែលកំពុងបានប្រតិបត្តិការបច្ចុប្បន្ន ដែលធ្វើកម្មវិធី ដើម្បីបញ្ជាក់ការអនុវត្តមានសក្តានុពល។ ការបង្កើតជម្រើសការថែទាំច្រើនប្រភេទនៅតាមសហគមន៍។

**MT** ការបង្កើតឱ្យមានច្បាប់ផ្តោតជាក់លាក់ការថែទាំដោយឪពុកម្តាយធម៌ ដើម្បីបំពេញទៅលើក្របខ័ណ្ឌការងារ ផ្នែកច្បាប់ និងគោលនយោបាយ។

**LT** វាយតម្លៃ និងកែសម្រួលឱ្យរលូននូវជម្រើសការថែទាំជាច្រើននៅតាមសហគមន៍។

ការផ្តល់សេវាការថែទាំដោយឪពុកម្តាយធម៌ត្រូវបានត្រួសត្រាយនាំមុខ ដោយអង្គការសង្គមស៊ីវិលដ៏ច្រើនសន្ធឹកសន្ធាប់ ដោយក្នុងនោះមានច្រើនប្រភេទ និងគុណភាពនៃសេវាមានលក្ខណៈប្លែកៗគ្នាយ៉ាងខ្លាំង។ សូម្បីតែពេលដែលមានវត្តមានគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីធ្វើបទដ្ឋានលើការអនុវត្តក្តី ប៉ុន្តែគោលនយោបាយទាំងនេះអាចមានការលំបាកដើម្បីអនុវត្តជាក់ស្តែង។

ឧ. ពេលដែលក្រសួង ស.អ.យ តម្រូវឱ្យប្រើប្រាស់ទម្រង់សាមញ្ញទាំង ២៨ ទម្រង់ទាំងអស់នេះ ប្រហែលជាពុំឆ្លុះបញ្ចាំងបានគ្រប់គ្រាន់អំពីសេចក្តីត្រូវការក្នុងការគ្រប់គ្រងករណី ជាលទ្ធផលធ្វើឱ្យមានអង្គការមួយចំនួនអភិវឌ្ឍប្រព័ន្ធស្របគ្នាមួយទៀត។ ដូចគ្នានេះដែរ ថ្វីបើគោលការណ៍មន្ទីរ ស.អ.យ មានភារកិច្ចត្រូវអនុម័តទៅលើការដាក់កុមារនីមួយៗក្តី ប៉ុន្តែសមត្ថភាពរបស់ពួកគាត់នៅមានកម្រិត ហើយតួនាទីនេះមើលទៅហាក់មានលក្ខណៈបែបរដ្ឋបាលច្រើនជាង។ បើគិតទៅលើភាពសម្បូរបែបនៅក្នុងការអនុវត្ត យើងខ្ញុំសូមផ្តល់អនុសាសន៍ថាការប៉ាន់ប្រមាណ និងការវាយតម្លៃលើ NGO កំពុងមានប្រតិបត្តិការបច្ចុប្បន្នទាំងអស់ដែលអនុវត្តកម្មវិធី រួមទាំងអង្គការបែបជំនឿសាសនាផងដែរ ដើម្បីកំណត់ និងបញ្ជាបសកម្មភាពនៅក្នុងរយៈពេលខ្លី។ ព័ត៌មាននេះអាចដាក់បញ្ចូលទៅក្នុងសេវាបញ្ជាអាសយដ្ឋានថ្នាក់ជាតិ (សូមមើលអនុសាសន៍ទី ៥)។

ដូចគ្នានេះដែរ នៅក្នុងពេលអនាគតឆាប់ៗខាងមុខ សេវាជាសកល និងសេវាឯកទេស ដែលជួយសម្រួលដល់កុមាររស់នៅជាមួយគ្រួសារកំណើត ( សូមមើលអនុសាសន៍ទី ៤៖ ការទប់ស្កាត់ជុំទីមួយ ) ចាំបាច់ត្រូវតែផ្តោតគោលដៅដូចគ្នាដែរ ចំពោះកុមារស្ថិតនៅក្រោមការថែទាំរបស់សាច់ញាតិ ការថែទាំដោយឪពុកម្តាយចិញ្ចឹម ផ្ទះស្នាក់នៅជាក្រុមតូចៗ។ល។ ការធ្វើបែបនេះនឹងដាក់បញ្ចូលការលើកកម្ពស់កិច្ចខិតខំសមាហរណកម្ម ( សូមមើលអនុសាសសន៍ទី ៦ ) និងបុគ្គលិកដែលត្រូវការ រួមទាំងតួនាទីរបស់បុគ្គលិក និយមន័យ និងការតម្រូវផ្នែកការផ្តល់មូនិធិផងដែរ។ ការបង្កើតឱ្យមានជម្រើសការថែទាំផ្សេងៗ ជាច្រើននៅថ្នាក់សហគមន៍ក្លាយជាផ្នែកមួយនៃក្របខ័ណ្ឌការងារផ្នែកច្បាប់ថ្នាក់ជាតិ បើយោងទៅលើគោលដៅសមាហរណកម្ម ៣០ ភាគរយនៅថ្នាក់ជាតិ និងផែនការសកម្មភាពជាតិ។[88] ឧ. ផ្ទះស្នាក់នៅជាក្រុម[89] ក្នុងសហគមន៍ប្រហែលជាចាំបាច់ត្រូវអភិវឌ្ឍទ្បើងតាមលក្ខណៈមួយ ដែលចៀសវាងការប្តូរឈ្មោះ និងការកែរូបរាងមណ្ឌលថែទាំកុមារធំៗ ដែលបច្ចុប្បន្នប្រតិបត្តិការមិនបានសមស្រប។ ព្រឹត្តិការណ៍នេះ ប្រាកដជាចាំបាច់ធ្វើឱ្យកើតមានផ្ទះស្នាក់នៅជាក្រុមដែលមិនធំពេក និងមានទំហំមួយដែលកុមារអាចទទួលបានការថែទាំជាលក្ខណៈបុគ្គល។ កម្មវិធីនៅក្នុងគំរូ Hagar សម្រាប់ការស្តានីតិសម្បទាក្មេង ដែលត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ មានកុមារចំនួន ៦ នាក់នៅក្រោមអាយុ ១៦ ឆ្នាំ ក្នុងផ្ទះស្នាក់នៅជាក្រុម ដោយមាន «មេផ្ទះ» ចំនួន ២ នាក់។ ចំនួននេះហាក់មានភាពសមស្រប។ គំនិតបន្ថែមទៀត គឺអាចទាញចេញពីបទពិសោធន៍ជាវិជ្ជមានរបស់ផ្ទះស្នាក់នៅជាក្រុម ដំណើរការដោយ FI និងអង្គការ Community Care First។ ការផ្តល់ឱ្យមានការរស់នៅពាក់កណ្តាលឯករាជ្យអាចពង្រីកបន្ថែមទៅជាកម្មវិធីថ្នាក់ជាតិ សម្រាប់កុមារដែលពុំអាចដាក់ឱ្យស្នាក់នៅក្នុងគ្រួសារបានជានិច្ចជាកាល។

ដោយឈរលើមូលដ្ឋាននៃការប៉ាន់ប្រមាណបែបនេះ សម្រាប់ **រយៈពេលមធ្យម** ច្បាប់ផ្តោតជាក់លាក់លើការថែទាំដោយឪពុកម្តាយធម៌គួរត្រូវបានបង្កើតឡើង ដើម្បីគ្របដណ្តប់លើការជ្រើសរើស ការផ្ទៀងផ្ទាត់ ការត្រៀមរៀបចំ ការមើលខុសត្រូវ ការគាំទ្រ ការតាមដានបន្ត។ល។ ថ្វីបើក្រមបខ័ណ្ឌការងារផ្នែកច្បាប់ និងគោលនយោបាយ ក៏ដូចជាផែនការសកម្មភាពជាតិ មិនចងកាតព្វកិច្ច បានលើកឡើងអំពីការថែទាំដោយឪពុកម្តាយធម៌ក្តី ប៉ុន្តែខ្លឹមសារលម្អិតនៃលិខិតបទដ្ឋានដូចដែលបានលើកឡើងខាងដើម ហាក់បាត់ចំណុចខ្លះ ដោយមានការគូសបញ្ជាក់តែពីក្រសួងទទួលខុសត្រូវប៉ុណ្ណោះ។ ឧទាហរណ៍នៃក្របខ័ណ្ឌការងារផ្នែកច្បាប់ ដែលអាចផ្តល់ការចង្អុលបង្ហាញរួមមានដូចជា ឧ. អាហ្សង់ទីន អូស្ត្រាលី និង អាហ្វ្រិកខាងត្បូង ។ ដូចគ្នានេះដែរ យើងអាចក្រឡេកមើលជាទូទៅលើឧទាហរណ៍ពីបទដ្ឋាន និងពិធីសារនានា ដែលអាចច្របាច់បញ្ចូលទៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្ត និងការពិនិត្យតាមដាន ( សូមមើលអណុសាសន៍ទី ៣ )។

សម្រាប់**រយៈពេលវែង** បើយោងទៅលើការអភិវឌ្ឍនៃជម្រើសជាច្រើននៅតាមសហគមន៍ជាផ្នែកមួយនៃក្របខ័ណ្ឌការងារផ្នែកច្បាប់ក្នុងរយៈពេលខ្លី ជាការល្អ ការពិនិត្យឡើងវិញរៀងរាល់ប្រាំឆ្នាំម្តង គួរត្រូវបានធ្វើឡើងដោយក្រុមការងារឯករាជ្យមួយក្រុម ដើម្បីកំណត់រកនូវបញ្ហាប្រឈមដែលមានស្រាប់ និងឱកាសសម្រាប់ការកែលម្អបន្ថែមទៀត។

88 ឧទាហរណ៍ សូមកត់សម្គាល់នីតិវិធីប្រតិបត្តិការស្តង់ដារ សម្រាប់ការបិទ និងការផ្ទេរពីមណ្ឌលថែទាំកុមារទៅកាន់សេវានៅតាមសហគមន៍ និងគោលដៅធ្វើសមាហរណកម្ម ៣០% ត្រឹមឆ្នាំ ២០១៨។

89 ការថែទាំនៅតាមផ្ទះស្នាក់នៅជាក្រុមត្រូវបានកំណត់និយមន័យថាជា «ទម្រង់មួយនៃការថែទាំជំនួយស ដោយក្នុងនោះកុមារក្នុងចំនួនកំណត់ (មិនលើសពី ១៥ នាក់) ត្រូវបានដាក់ឱ្យរស់នៅក្នុងបរិដ្ឋានគ្រួសារ ក្រោមការមើលខុសត្រូវរបស់អ្នកថែទាំមួយក្រុមតូចដែលមិនជាប់សាច់ឈាមជាមួយកុមារ»។ ផ្ទះស្នាក់នៅជាក្រុម ត្រូវបានដាក់បញ្ចូលទៅក្នុងបរិយាកាសក្នុងសហគមន៍ ប៉ុន្តែពុំមែនដំណើរការដោយសហគមន៍ទេ។ សូមមើលគោលនយោបាយស្តីពីការថែទាំជំនួសសម្រាប់កុមារ ឆ្នាំ ២០០៦។

90 ការគាំទ្រផ្ទះស្នាក់នៅជាក្រុមតូចៗដែលកំពុងរស់នៅអង្គការ Hagar៖https://riselearningnetwork.org/resource/supporting-small-group-family-living-at-hagar-cambodias-recovery-centre-for-sexually-abused-and-exploited-boys/

91 https://friends-international.org/social-services/

92 www.unicef.org/cambodia/Country_kit_Child_Protection_Final_A4.pdf

93 www.relaf.org/Foster%20Care%20in%20Argentina.pdf

94 NSW Children and Young Persons (Care and Protection) Act 1998: www.community.nsw.gov.au/kts/legislation

95 ច្បាប់លេខ ៣៨ ស្តីពីកុមាររបស់អាហ្វ្រិចខាងត្បូងចេញឆ្នាំ ២០០៥៖ www.justice.gov.za/legislation/acts/2005-038%20childrensact.pdf

96 www.bettercarenetwork.org/sites/default/files/Minimum%20Standards%20on%20Alternative%20Care%20for%20Children%20Cambodia.pdf

## អនុសាសន៍ទី ៨

## ណែនាំឱ្យមានក្របខ័ណ្ឌការងារនីតិកម្មថ្នាក់ជាតិស្តីពីការថែទាំដោយឪពុកម្តាយធម៌ ជាផ្នែកមួយនៃការការពារសុខុមាលភាព និងការការពារផ្នែកច្បាប់សព្វជ្រុងជ្រោយ សម្រាប់កុមារ និងក្របខ័ណ្ឌគោលនយោបាយ

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បញ្ជី អ្នកផ្តល់សេវាការថែទាំដោយឪពុកម្តាយធម៌ទាំងអស់ | ១ បញ្ជី អ្នកផ្តល់សេវាការថែទាំដោយឪពុកម្តាយធម៌ទាំងអស់ផ្អែកលើ MoU។ល។<br>២ ដាក់ព័ត៌មានបញ្ចូលទៅក្នុងបញ្ជីអាសយដ្ឋានទំនាក់ទំនងថ្នាក់ជាតិរបស់សេវានៅក្នុងកម្មវិធីដែលត្រូវបានជ្រើសរើស (អនុសាសន៍ទី ៥)។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| បញ្ជាបសេវាការថែទាំដោយឪពុកម្តាយធម៌ជាមូលដ្ឋាន | ១ ការវាយតម្លៃលើ NGO ដែលបានធ្វើកម្មវិធី។<br>២ កំណត់ថា តើទិដ្ឋភាពណាខ្លះដែលដំណើរការបានល្អ និងវិស័យណាខ្លះដែលត្រូវការកែលម្អបន្ថែម។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| ការអភិវឌ្ឍឱ្យមានជម្រើសការថែទាំនៅតាមសហគមន៍ឱ្យបានច្រើនទូលំទូលាយ | ១ កំណត់រកចន្លោះប្រហោងនៅក្នុងការផ្តល់សេវាដោយប្រើប្រាស់បញ្ជីអាសយដ្ឋានទំនាក់ទំនងរបស់សេវានានានៅថ្នាក់ជាតិ។<br>២ កំណត់ ថាតើសេវាដែលមានស្រាប់នាពេលបច្ចុប្បន្នណាខ្លះទាមទារឱ្យមានការអភិវឌ្ឍបន្ថែមទៀត។<br>៣ ពិចារណាអភិវឌ្ឍឱ្យមានផ្ទះស្នាក់នៅជាក្រុមតូចៗក្នុងសហគមន៍ ដើម្បីផ្តល់ជម្រកបណ្តោះអាសន្នសម្រាប់អ្នកទាំងឡាយណាដែលពុំអាចយកទៅដាក់នៅក្នុងការថែទាំដោយឪពុកម្តាយធម៌បាន។<br>៤ ផ្តល់ការបណ្តុះបណ្តាលដល់អ្នកធ្វើការនៅក្នុងវិស័យនេះ (អនុសាសន៍ទី ២)។<br>៥ បង្កើតសេវាជាសកល និងដែលមានការផ្តោតគោលដៅជាក់លាក់ ផ្តល់មូនិធិដោយរដ្ឋាភិបាល (អនុសាសន៍ទី ១)។ | ក្រសួង សអយ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា។ | UNICEF, 3PC, FCF | ២០១៨ តទៅ |

## រយៈពេលមធ្យម (២០១៩-២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
|---|---|---|---|---|
| ធ្វើសេចក្តីព្រាងច្បាប់ផ្តោតជាក់លាក់ទៅលើការថែទាំដោយឪពុកម្តាយធម៌ | ១ បង្កើតកិច្ចប្រជុំតុមូល ដើម្បីពិភាក្សាអំពីអ្វីដែលត្រូវការនៅក្នុងច្បាប់ការថែទាំដោយឪពុកម្តាយធម៌ សព្វគ្រប់ជ្រោយ (ឧ. ការជ្រើសរើស ការត្រៀម ការផ្គូផ្គង ការតាមដានបន្ត ការបង់ប្រាក់។ល។<br>២ ពិនិត្យលើឧទាហរណ៍បទបញ្ញត្តិពីខាងក្រៅ។<br>៣ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានច្បាប់។<br>៤ ដាក់បញ្ចូលការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ និងធ្វើសុខដុមនីយកម្មច្បាប់សុខុមាលភាពកុមារ និងច្បាប់ការពារកុមារដែលបានគ្រោងទុក។<br>៥ ផ្សព្វផ្សាយលិខិតបទដ្ឋានច្បាប់យ៉ាងទូលំទូលាយ។<br>៦ បណ្តុះបណ្តាលអ្នកដើរតួនាទីនានាស្តីពីការអនុវត្ត។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩ តទៅ |
| ដាក់បញ្ចូល "ការថែទាំដោយឪពុកម្តាយធម៌" នៅក្នុងសៀវភៅណែនាំ (អនុសាសន៍ទី៣) | ១ បង្កើតក្រុមប្រឹក្សាប្រឹក្សាយោបល់អំពីអ្វីដែលត្រូវដាក់បញ្ចូលនៅក្នុងសៀវភៅណែនាំការអនុវត្ត។<br>២ ធ្វើតេស្តសាកល្បងផ្ទាល់នៅក្នុងតំបន់ចំនួនមួយ ឬពីរ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩ |

## រយៈពេលវែង (ហួសពី ២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| ប៉ាន់ប្រមាណលើជម្រើសការថែទាំផ្សេងៗជាច្រើនដែលមានមូលដ្ឋាននៅតាមសហគមន៍ | ១ ផ្ដេកលើការងាររយៈពេលខ្លីត្រូវបង្កើតជម្រើសឱ្យមានច្រើន។ ការវាយតម្លៃជាឯករាជ្យមួយគួរត្រូវបានធ្វើឡើងដើម្បីកំណត់វិស័យនានាដែលត្រូវការការកែសម្រួលឱ្យកាន់តែល្អថែមទៀត។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ |

# អនុសាសន៍ទី ៩

## ធានាឱ្យមានការផ្តត់ផ្គង់ហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការថែទាំដោយឪពុកម្តាយធម៌ ដើម្បីអនុវត្តក្របខ័ណ្ឌការងារផ្នែកច្បាប់ និងគោលនយោបាយ

**ST** ធ្វើការឆ្ពោះទៅការចាត់ចែងកញ្ចប់ថវិកាសម្រាប់ប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌នៅថ្នាក់ជាតិ។

**MT** លើកទឹកចិត្តអ្នកដើរតួនាទីសង្គមស៊ីវិលឱ្យដាក់បញ្ចូលសកម្មភាពនានា ដែលនឹងធានានិរន្តរភាពតាមរយៈសហគ្រាសសង្គម រួមទាំងតាមរយៈគ្រួសារឪពុកម្តាយធម៌។

**LT** បង្កើតប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌ជារបស់រដ្ឋ ដោយមានការជួលសេវាពីខាងក្រៅតាមការចាំបាច់។

ការចាត់ថវិកាសម្រាប់ប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌ថ្នាក់ជាតិ រួមទាំងការផ្តល់ប្រាក់ឧបត្ថម្ភកំណត់ដោយច្បាប់។

ការអនុវត្តផែនការសកម្មភាពជាតិ និងបញ្ញត្តិផ្តោតដាក់លាក់លើការថែទាំដោយឪពុកម្តាយធម៌បានប្រកបដោយជោគជ័យសម្រាប់រយៈពេលខ្លី គឺទាមទារនូវការប្តេជ្ញាចិត្តគួរជាទីកត់សម្គាល់ពីរដ្ឋាភិបាលទាក់ទងជាមួយការចាត់កញ្ចប់ថវិកា។ ថ្វីបើប្រហែលជាពុំអាចមានការចាត់កញ្ចប់ថវិកាភ្លាមៗក្តី ប៉ុន្តែរដ្ឋាភិបាលគួរតែធ្វើការភ្លាមៗឆ្ពោះទៅធ្វើយ៉ាងណាឱ្យមានការចាត់កញ្ចប់ថវិកាគ្រប់គ្រាន់នៅក្នុងរង្វង់រដ្ឋាភិបាល ដែលអាចយកមកអនុវត្តសម្រាប់រយៈពេលវែង។ ដូចគ្នាជាមួយបណ្តាប្រទេសទាំងអស់ ដែលការដកកុមារចេញពីមណ្ឌលថែទាំត្រូវបានធ្វើផែនការ និងអនុវត្តមានដូចជា ប្រទេសអូស្ត្រាលី Azerbaijan អាស៊ីកណ្តាល តួកគី និងសហរដ្ឋអាមេរិក ចាំបាច់ត្រូវតែមានការពិចារណាទៅលើបន្ទុកចំណាយដែលអាចកើតមាន។[97] ម្យ៉ាងទៀត ក៏ចាំបាច់ត្រូវមានការត្រៀមរៀបចំឱ្យបានគ្រប់គ្រាន់ជាមុន សម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីព គ្រួសារ និងកុមារផងដែរ។ ជាការល្អបំផុត គ្រួសារ ឪពុកម្តាយធម៌ គួរតែបានទទួលប្រាក់កម្រៃឧបត្ថម្ភដូចគ្នានេះផងដែរ សម្រាប់ការចំណាយជាក់ស្តែង និងសេវារបស់ពួកគាត់។ ការបង់ថ្លៃសេវា រួមទាំងប្រាក់បៀវត្ស និងការធានារ៉ាប់រងសុខភាព/ធានារ៉ាប់រងសោធននិវត្តន៍ ជាលទ្ធផលអាចមានអ្នកដាក់ពាក្យកាន់តែច្រើន និងមានគុណភាពការថែទាំកាន់តែខ្ពស់។[98] ទោះយ៉ាងណាក្តី ប្រាក់ឧបត្ថម្ភពុំគួរក្លាយជាកត្តាលើកទឹកចិត្តចម្បង ដើម្បីក្លាយជាគ្រួសារឪពុកម្តាយធម៌នោះឡើយ។[99]

97 Building and Reforming Child Care systems in Central Asia, Azerbaijan and Turkey Second Central Asia Child Protection Forum, Report , Bishkek, Kyrgyzstan 12—14 May 2009, p28-32: www.unicef.org/ceecis/Report_CP_Forum_Bishkek_Final_11_Aug.pdf, Foster Care payment US: www.childtrends.org/wp-content/uploads/2013/04/Foster-Care-Payment-Rate-Report.pdf Australian Government Financial Support for Foster Families: www.fostercare.org.au/docs/afca_centrelink.pdf

98 Madeleine Tearse, Love Fostering – Need Pay, a UK-wide survey of foster carers about fees, 2010: www.thefosteringnetwork.org.uk/sites/www.fostering.net/files/public/resources/reports/love_fostering_need_pay_0310.pdf Damien W. Riggs, Paul H. Delfabbro, Economies of Care Remuneration and Recognition in Foster Care, Journal of the Association for Research and Mothering, Volume 10, No1, 2009: www.academia.edu/5418635/Economies_of_care_Recognition_and_remuneration_of_foster_carers

99 ឧទាហរណ៍ ក្នុងករណីអង្គការម្លប់ឫស្សី ពួកគេបានទទួលទឹកប្រាក់ ២០ ដុល្លារក្រោយពេលមួយខែៗជាថ្លៃសេវា។ ពួកគេទទួលបាន ២,៥ ដុល្លារក្នុងមួយថ្ងៃសម្រាប់កុមារម្នាក់ៗសម្រាប់ថ្លៃអាហារ និងការចំណាយដទៃទៀត។

ភាគច្រើនអ្នកផ្តល់សេវាការថែទាំដោយឪពុកម្តាយធម៌ស្ទើរតែទាំងអស់ពឹងផ្អែកលើមូលនិធិពីខាងក្រៅ មិនថាជាជំនួយឯកជន និងជំនួយអភិវឌ្ឍក្តី ដែលអាចមានលក្ខណៈមិនប្រាកដប្រជា។ ចាំបាច់ត្រូវធានាឱ្យបាននូវឯករាជភាព និងសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ក្នុងចំណោមអ្នកផ្តល់សេវាទាំងនេះ មានអ្នកផ្តល់សេវាតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានអនុវត្តវិធានការដើម្បីធានានិរន្តរភាពហិរញ្ញវត្ថុ ដោយក្នុងនោះអង្គការ FI ជាអ្នកនាំមុខគេ ដូចជាតាមរយៈភោជនីយដ្ឋាន និងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួនជាដើម។ លក្ខណៈបែបនេះធ្វើឱ្យកម្ពុជាស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ ប្រសិនបើចរន្តមូលនិធិត្រូវបានបង្វែរទៅកន្លែងផ្សេង។ ហេតុនេះសម្រាប់រយៈពេលមធ្យម យើងខ្ញុំសូមផ្តល់អនុសាសន៍ ឱ្យសង្គមស៊ីវិលវិនិយោគលើសហគ្រាសសង្គមដូចជា កន្លែងថែទាំពេលថ្ងៃសម្រាប់កុមារជាដើម[100] និងការផ្តល់សេវាសម្រាប់ជនពិការជនចាស់ជរា និងជនងាយរងគ្រោះដទៃទៀត ដែលអាចជួយបង្កើតឱកាសការងារផងដែរ។ នៅប្រទេសអូស្ត្រាលី បារាំង និងសហរដ្ឋអាមេរិក អ្នកផ្តល់សេវាការថែទាំពេលថ្ងៃនៅតាមផ្ទះស្ថិតក្រោមការគ្រប់គ្រងយ៉ាងត្រឹមត្រូវរាប់ពាន់នាក់ផ្តល់សេវាដល់កុមារនៅក្រោមអាយុចូលសាលាមត្តេយ្យនៅក្នុងផ្ទះរបស់ខ្លួន។[101] សកម្មភាពទាំងនេះ ជួយលើកកម្ពស់ការយល់ដឹងអំពីសេចក្តីត្រូវការរបស់ពួកគេ ហើយគម្រោងការងារបែបនេះជួយជំរុញឱ្យឪពុកម្តាយធម៌អាចធ្វើការ។ល។ ស្របពេលអាចបង្កើតចំណូលបានផងដែរ។

សម្រាប់រយៈពេលវែង ប្រទេសកម្ពុជាត្រូវការភាពជាម្ចាស់ប្រកបដោយប្រសិទ្ធភាពលើប្រព័ន្ធការពារកុមារ ដែលមានដំណើរការល្អរួមទាំងភាពជាម្ចាស់លើផ្នែកថវិកា ដូចនៅប្រទេសប៊ុលការី រ៉ូម៉ានី និងបណ្តាប្រទេស CEE/CIS ដទៃទៀត[102] រួមមានដូចជា ហ្គាណា និងតង់ហ្សានីជាដើម។[103] រដ្ឋាភិបាលគួរតែជាអ្នកនាំមុខគេនៅក្នុងប្រព័ន្ធប្រកបដោយនិរន្តរភាព ដែលមានប្រតិបត្តិការនៅថ្នាក់កណ្តាល ដែលអនុញ្ញាតឱ្យអាចជួលសេវាពីខាងក្រៅក្នុងករណីចាំបាច់។ ទាក់ទងជាមួយការថែទាំដោយឪពុម្តាយធម៌ ការងារនេះគឺរួមបញ្ចូលទាំងការពិចារណាលើការបង់ប្រាក់ឧបត្ថម្ភ តាមការកំណត់ដោយច្បាប់ សម្រាប់អ្នកផ្តល់ការថែទាំផងដែរ។

100 ផែនការសកម្មភាពជាតិ ស្តីពីការថែទាំកុមារតូច និងការអភិវឌ្ឍ ឆ្នាំ ២០១៤-២០១៨ http://planipolis.iiep.unesco.org/upload/Cambodia/Cambodia_Early_childhood_national_action_plan_2014-2018.pdf ផែនការសកម្មភាពជាតិព្យាយាមបង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងការការពារសម្រាប់កុមារអាយុចាប់ពី ០ ឆ្នាំ ដល់ ៦ ឆ្នាំជាពិសេសគឺកុមារមកពីគ្រួសារក្រីក្រ ជនជាតិដើមភាគតិច និងកុមារពិការ ហើយចាត់អាទិភាពកម្មវិធីមត្តេយ្យសិក្សាសហគមន៍ និងការថែទាំកុមារតូច។

101 Home Day-Care Overview; www.babycenter.com/0_home-daycare-overview_46.bc, http://australianhomechildcare.com.au; European Policy on Early Childhood Education and Care http://ec.europa.eu/education/policy/school/early-childhood_en, http://eacea.ec.europa.eu/education/eurydice/documents/thematic_reports/191EN.pdf

102 Mapping Child Protection Systems in the EU Financial Resources and Budget Allocation: http://fra.europa.eu/en/publications-and-resources/data-and-maps/comparative-data/child-protection/budget-allocation

103 Building a national child protection system in Ghana: From evidence to policy and practice: www.unicef.org/protection/files/Ghana_CP_system_case_study.pdf; Building a holistic child protection system, step by step, in the United Republic of Tanzania; http://www.unicef.org/protection/files/Tanzania_CP_system_case_study.pdf

## អនុសាសន៍ទី ៩

# ធានាឱ្យមានការផ្តត់ផ្គង់ហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការថែទាំដោយឪពុកម្តាយធម៌ ដើម្បីអនុវត្តក្របខ័ណ្ឌការងារផ្នែកច្បាប់ និងគោលនយោបាយ

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
| ផ្តួចផ្តើមការងារលើការចាត់កញ្ចប់ថវិកាសម្រាប់ប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌នៅថ្នាក់ជាតិ រួមទាំងការផ្តល់ប្រាក់ឧបត្ថម្ភតាមការកំណត់ដោយច្បាប់ | ១ ធ្វើការជាមួយអ្នកសេដ្ឋសាស្ត្រផ្នែកកុមារវិទ្យា (អនុសាសន៍ទី ២) ការងារស្តង់ដាគំរូរបស់យូនីសេហ្វ[104] និងការផ្តួចផ្តើមគំនិតការស្រាវជ្រាវដទៃទៀត ដើម្បីលើកកម្ពស់ឆន្ទៈនយោបាយឱ្យមានថវិកាជាតិ។<br>២ គណនាការចំណាយនៃការថែទាំក្នុងទម្រង់ផ្សេងៗ និងធនធាន/ការចាត់ចែងជាថ្មីដែលចាំបាច់។<br>៣ ធ្វើផែនការការចំណាយនៃរាល់ទម្រង់ទាំងអស់នៃការថែទាំសមស្រប រួមទាំងប្រាក់ឧបត្ថម្ភតម្រូវដោយច្បាប់សម្រាប់ការថែទាំដោយឪពុកម្តាយធម៌។<br>៤ បង្កើតយុទ្ធសាស្ត្រការតស៊ូមតិជាមួយក្រសួងហិរញ្ញវត្ថុ។ | ក្រសួង ស.អ.យ និង ក្រសួងហិរញ្ញវត្ថុ។ | UNICEF, 3PC, FCF | ២០១៨ តទៅ ដល់ ២០២៣ |

104 https://www.unicef.org/protection/files/UNICEF_CP_Benchmark_proposal_integrated_final_report_rev.pdf

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| លើកទឹកចិត្តនិរន្តរភាពអ្នកផ្តល់សេវាសង្គម | ១ ធ្វើការវិភាគសេចក្តីត្រូវការនៃគម្លាតការផ្តល់សេវាក្នុងសហគមន៍ដែលអាចបំពេញបន្ថែមដោយសហគ្រាសសង្គម។<br>២ គាក់តែង និងគាំទ្រសហគ្រាសសង្គម ការផ្តល់សេវាក្នុងទម្រង់មិនរកផលចំណេញ។<br>៣ បង្កើតសេវាក្នុងមូលដ្ឋាននៅតាមផ្ទះ និងតាមមណ្ឌលដូចជា មណ្ឌលថែទាំពេលថ្ងៃ ECEC អាហារលើរទេះរុញជនពិការ។ល។<br>៤ ផ្តល់ការបណ្តុះបណ្តាល ដើមទុន និងការគាំទ្រជាដើមដល់អាជីវកម្មខ្នាតតូច។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF, local business community | ២០១៩ តទៅ |
| **រយៈពេលវែង (ហួសពី ២០២៣)** | | | | |
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បង្កើតប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌នៅទូទាំងប្រទេស | ១ បង្កើតប្រព័ន្ធទទួលស្គាល់គុណភាពថ្នាក់ជាតិសម្រាប់អង្គការដែលផ្តល់សេវាការថែទាំដល់ឪពុកម្តាយធម៌។<br>២ បង្កើតប្រព័ន្ធមើលខុសត្រូវ ពិនិត្យតាមដាន និងវាយតម្លៃ។<br>៣ ធានាឱ្យមានការចាត់កញ្ចប់ថវិកា សម្រាប់កម្មវិធីថែទាំដោយឪពុកម្តាយធម៌ រួមទាំងធាតុទាំងអស់ ចាប់តាំងពីការជ្រើសរើសរហូតដល់ការចាកចេញពីការថែទាំ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ តទៅ |
| ដាក់ឱ្យមានប្រាក់ឧបត្ថម្ភដែលតម្រូវដោយច្បាប់ដើម្បីគ្របដណ្តប់លើសេចក្តីត្រូវការរបស់កុមារ និងប្រាក់កម្រៃសមាប្រ់ឪពុកម្តាយធម៌ | ១ គណនាការចំណាយនៃតម្រូវការរបស់កុមារដោយអាស្រ័យតៅតាមអាយុ និងសមត្ថភាពរបស់ពួកគេ។<br>២ ពិចារណារចនាសម្ព័ន្ធផ្តល់ប្រាក់ឧបត្ថម្ភដែលតម្រូវដោយច្បាប់ ដែលប្រើប្រាស់ដោយ អង្គការសង្គមស៊ីវិលក៏ដូចជានៅក្នុងបណ្តាប្រទេសដទៃទៀត ដែលអាចផ្តល់ជាជំនួយផ្នែកគំនិត។<br>៣ ព្រមព្រៀងគ្នាលើចំនួនទឹកប្រាក់ឧបត្ថម្ភកំណត់ដោយច្បាប់សម្រាប់ប្រទេសកម្ពុជា (កុមារ និងអ្នកមើលថែ)។ | ក្រសួង ស.អ.យ និង ក្រសួងហិរញ្ញវត្ថុ។ | UNICEF, 3PC, FCF | ២០២៣ |

# អនុសាសន៍ទី

# ១០

## បំពាក់លក្ខណៈសម្បត្តិគ្រប់គ្រាន់ដល់អ្នកប្រកបវិជ្ជាជីវៈ ដើម្បីអាចគាំទ្រអ្នកមើលថែដោយឪពុកម្ដាយចិញ្ចឹមក្នុងតួនាទីជាអ្នកផ្ដល់ការថែទាំកុមារ

**ST** ការដាក់ការបណ្តុះបណ្តាលសម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពការថែទាំដោយឪពុកម្ដាយធម៌ដែលមានបច្ចុប្បន្ននៅថ្នាក់កណ្តាល។ ការអភិវឌ្ឍកម្មវិធីសិក្សាបទដ្ឋានសម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកការថែទាំដោយឪពុកម្ដាយធម៌។

**MT** ការបណ្តុះបណ្តាលនឹងត្រូវធ្វើឡើងតាមរយៈក្រុមអ្នកប្រកបវិជ្ជាជីវៈអាជីពចល័ត។

**LT** ការបង្កើតការបណ្តុះបណ្តាលវិជ្ជាជីវៈ។

បន្ថែមទៅលើអនុសាសន៍ក្ដោបរួម ការបណ្តុះបណ្តាលផ្តោតគោលដៅ សម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពធ្វើការជាមួយគ្រួសារឪពុកម្ដាយធម៌ គឺជាការចាំបាច់ណាស់។ យើងខ្ញុំសូមលើកទឹកចិត្តដល់អ្នកផ្ដល់សេវាការចិញ្ចឹមបីបាច់ ដោយឪពុកម្ដាយធម៌ទាំងអស់ដែលមានសកម្មភាពការបណ្តុះបណ្តាលផ្ទៃក្នុង ថ្វីត្បិតតែមានខ្លឹមសារ និងគុណភាពខុសៗគ្នាក្ដី អ្វីដែលមានសក្ដានុពលបំផុតនោះ គឺការធ្វើឡើងនូវវគ្គបណ្តុះបណ្តាលរួមគ្នា ដូចជាវគ្គបណ្តុះបណ្តាលរៀបចំឡើងដោយ 3PC និងដៃគូ FCF ដែលយើងបានកត់សម្គាល់ឃើញនូវចំណុចសុទិដ្ឋិនិយម ដោយមានការដាក់បញ្ចូលអ្នកដើរតួនាទីរដ្ឋាភិបាលនៅក្នុងករណីមួយចំនួនផងដែរ។

ទោះយ៉ាងណាក្ដី នៅមានការខ្វះខាតការបណ្តុះបណ្តាល ដែលមានលក្ខណៈជាបទដ្ឋាន ដោយពុំមានតម្រូវជាអប្បបរមា ដែលត្រូវអនុវត្តចំពោះគ្រប់ការបណ្តុះបណ្តាលនោះទេ។ យើងខ្ញុំសូមផ្ដល់អនុសាសន៍ នៅក្នុងរយៈពេលខ្លី ឱ្យមានការបណ្តុះបណ្តាលដែលមានបច្ចុប្បន្ននៅថ្នាក់កណ្តាល ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាសព្វគ្រុងជ្រោយ សម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពការថែទាំជំនួសសម្រាប់កុមារទាំងអស់។ ការងារនេះអាចត្រូវបានធ្វើឡើងជាផ្នែកមួយនៃការធ្វើបញ្ជី អ្នកផ្ដល់សេវាថែទាំដោយឪពុកម្ដាយធម៌ទាំងអស់ (អនុសាសន៍ទី ៨)។ ឧ. អ្នកប្រកបវិជ្ជាជីវៈអាជីពចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលស្ដីពីការវាយតម្លៃទៅលើសេចក្ដីត្រូវការផ្នែកការអភិវឌ្ឍខុសៗគ្នារបស់កុមារក្នុងលក្ខណៈជាបុគ្គល (សុខភាព អប់រំ ផ្លូវចិត្ត សង្គម វប្បធម៌ និងស្មារតី) ក៏ដូចជាការបញ្ចប់ជាស្ថាពរនូវទម្រង់បទដ្ឋាន ដែលត្រូវ

បានរចនាឡើង ដើម្បីចាប់យកព័ត៌មានក្នុងលក្ខណៈឯកភាពគ្នា។ ថ្វីបើធាតុចម្បងនឹងត្រូវអនុវត្តចំពោះគ្រប់ការបណ្តុះបណ្តាលក្តី ប៉ុន្តែការបណ្តុះបណ្តាលនោះត្រូវដាក់បញ្ចូលលទ្ធភាព អាចសម្រប ទៅតាមបរិបទមូលដ្ឋាននីមួយៗផងដែរ។ អត្ថប្រយោជន៍នៃ ការបណ្តុះបណ្តាលបែបនេះ អាចជួយលើកកម្ពស់ឱ្យមានគោល វិធីឯកភាពគ្នា និងជួយសម្របសម្រួលដល់ការប្រមូលទិន្នន័យ ពាក់ព័ន្ធដែលនឹងត្រូវយកទៅដាក់ចូលក្នុងទិន្នន័យមេថ្នាក់ជាតិ។ ការបង្កើតឱ្យមានការបណ្តុះបណ្តាលលក្ខណៈស្តង់ដារអាចត្រូវ បានត្រួសត្រាយផ្លូវដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានជាតិសង្គមកិច្ចរបស់រដ្ឋាភិបាល ដោយមានការ ជួយជ្រោមជ្រែងផ្នែកបច្ចេកទេសពីអ្នកដើរតួនាទីផ្នែកសង្គម ស៊ីវិល ដែលមានស្រាប់ក្រោមការដឹកនាំរបស់ក្រសួង ស.អ.យ។ សម្រាប់រយៈពេលមធ្យម ការបណ្តុះបណ្តាល និងកម្មវិធីសិក្សា ទាំងនេះអាចត្រូវបានផ្សព្វផ្សាយ តាមរយៈក្រុមការងារអ្នក ប្រកបវិជ្ជាជីវៈអាជីពចល័ត ដែលបានការទទួលស្គាល់គុណភាព ពីរដ្ឋាភិបាល ក្រុមចល័ត «យុត្តិធម៌កុមារមេត្រី»)។ បច្ចុប្បន្ននេះ មានសមាជិកសហគមន៍មូលដ្ឋាន មេភូមិ គកនក បុគ្គលថែទាំ និងអាជ្ញាធរជាច្រើន ដែលត្រូវការព័ត៌មាន និងបំណិនក្នុងការ ផ្តល់ការជួយជ្រោមជ្រែងឱ្យបានគ្រប់គ្រាន់។ ក្រុមការងារចល័ត របស់អ្នកប្រកបវិជ្ជាជីវៈអាជីពនេះ អាចបង្កើតឱកាសសម្រាប់ ការចែករំលែកព័ត៌មាន ការលើកកម្ពស់ ការយល់ដឹងរបស់អ្នក នៅថ្នាក់មូលដ្ឋាន និងការដាក់បញ្ចូលព័ត៌មាន/ជំនាញទៅក្នុង ការងារការថែទាំនៅតាមសហគមន៍ ដែលមានស្រាប់នៅពេល បច្ចុប្បន្ន។ ដោយហេតុថា គិលានុប្បដ្ឋាកសហគមន៍/ក្រុមគាំទ្រ សុខភាពភូមិមានវត្តមាននៅតាមខេត្តនីមួយៗ ហេតុនេះពួក គាត់ក៏អាចបង្កើនជំនាញបន្ថែម ដើម្បីផ្តល់ការជួយជ្រោមជ្រែង នេះផងដែរ។ ជាអាទិភាពមួយ ក្រុមការងារចល័តអាចស្ថាបនា បន្ថែមលើការងាររបស់អង្គការសេវាសង្គមកិច្ចកម្ពុជា និងអង្គការ សង្គ្រោះកុមារ ដែលកំពុងកំណត់អត្តសញ្ញាណអ្នកប្រកប វិជ្ជាជីវៈពីររូប ដើម្បីក្លាយជាជនបង្គោលសម្រាប់ការថែទាំជំនួស ទៅតាមខេត្តនីមួយៗ។ ជនបង្គោលទាំងពីររូបនេះអាចក្លាយជា គ្រូបង្គោល ដែលធ្វើការជាដៃគូជាមួយអ្នកផ្តល់ការថែទាំជា ឪពុកម្តាយធម៌មានបទពិសោធន៍។[105] ការងារនេះក៏ជួយបំពេញ បន្ថែម ចំពោះកម្មវិធីបណ្តុះបណ្តាលនៅតាមសហគមន៍របស់ អង្គការសង្គ្រោះកុមារ សម្រាប់សមាជិកសហគមន៍ក្នុងមូលដ្ឋាន និងផ្តល់ការគាំទ្រដល់ឪពុកម្តាយ ដើម្បីពង្រឹងសមត្ថភាពរបស់ ពួកគាត់។[106] ចំពោះរយៈពេលវែង យើងខ្ញុំសូមផ្តល់អនុសាសន៍ ឱ្យមានការនុវត្តការបណ្តុះបណ្តាលក្រោមថ្នាក់មធ្យមសិក្សា សម្រាប់បុគ្គលិកនៅក្នុងនាយកដ្ឋានសុខុមាលភាពកុមារ និង ការការពារកុមារ ក៏ដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយរួមទាំង សមាជិក គកនក ផងដែរ។ កម្មវិធីអ្នកជំនួយការអ្នកសង្គកិច្ច គឺមាននៅក្នុងបណ្តាប្រទេសជាច្រើន ហើយអាចត្រូវបានកែ សម្រួលឱ្យត្រូវតាមសេចក្តីត្រូវការ និងស្ថានភាពក្នុងមូលដ្ឋាន[107] ការបណ្តុះបណ្តាល)។

105 សូមមើលជាឧទាហរណ៍៖ www.cwla.org/pride-training/

106 ការពង្រឹងប្រព័ន្ធសហគមន៍សម្រាប់ការការពារកុមារ ៖ https://cambodia.savethechildren.net/sites/cambodia.savethechildren.net/files/library/Brochure_A5_Parenting_FIN_LR2_0.pdf

107 ឧទាហរណ៍ល្អអំពីការបណ្តុះបណ្តាលនិងឱកាសការងារសម្រាប់ជំនួយការសង្គម៖ www.hotcourses.com/courses-by-subject/Safeguarding-Children-Course-CPD-Accredited-courses/56621300/; www.hotcourses.com/courses-by-subject/Safeguarding-Children-courses/56642736/; www.psychologyschoolguide.net/social-work-careers/how-to-become-a-social-work-assistant/; http://collegemouse.com/jobs/how-to-become-a-social-work-assistant.html; https://nationalcareersservice.direct.gov.uk/advice/planning/jobprofiles/Pages/SocialWorkAssistant.aspx; https://collegegrad.com/careers/social-and-human-service-assistants អត្ថបទសៀវភៅស្តីពីការអនុវត្តល្អក្នុងការអនុវត្តការងារសង្គមកិច្ច៖ Joe C. B. Leung, The emergence of social assistance in China , Department of Social Work and Social Administration, University of Hong Kong, International Journal Of Social Welfare, 2006, v. 15 n. 3, at 188- 198; http://hub.hku.hk/bitstream/10722/54334/1/133645.pdf?accept=1; Professional Social Work in East Africa: Towards Social Development, Poverty (Ed: by Spitzer, Helmut, Twikirize, Janestic M.), Fountain Publishers, 2014, Good Practices in Social Service Delivery in South Eastern Europe (ed: Elaine Fultz, Martin Tracy), ILO, Geneva, 2004, www.ilo.org/wcmsp5/groups/public/europe/ro-geneva/sro-moscow/documents/publication/wcms_344663.pdf; Manohar Pawar, Political commitment needed – community social work in the developing countries: Social Work Practice With Local Communities in Developing Countries, Imperatives for Political Engagement;http://sgo.sagepub.com/content/4/2/2158244014538640

## អនុសាសន៍ទី ១០

# បំពាក់លក្ខណៈសម្បត្តិគ្រប់គ្រាន់ដល់អ្នកប្រកបវិជ្ជាជីវៈ ដើម្បីអាចគាំទ្រអ្នកមើលថែដោយឪពុកម្តាយចិញ្ចឹមក្នុងតួនាទីផ្តល់ការថែទាំ

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
| ធ្វើបញ្ជីការបណ្តុះបណ្តាលការថែទាំដោយឪពុកម្តាយធម៌ទាំងអស់ | ១ ធ្វើបញ្ជីការបណ្តុះបណ្តាល ដែលមានស្រាប់ទាំងអស់។<br>២ កំណត់ទិដ្ឋភាពនានា ដែលគួរដាក់ឱ្យមានជាស្តង់ដា និងប្រសិនបើមានចន្លោះប្រហោង។<br>៣ បង្កើតការបណ្តុះបណ្តាលអប្បបរមាសម្រាប់អ្នកផ្តល់សេវាការថែទាំដោយឪពុកម្តាយធម៌ទាំងអស់។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| បង្កើតប្រព័ន្ធទទួលស្គាល់គុណភាពសម្រាប់អ្នកផ្តល់សេវាការថែទាំដោយឪពុកម្តាយធម៌ | ១ ផ្តល់វគ្គបណ្តុះបណ្តាល។<br>២ វាយតម្លៃ និងទទួលស្គាល់គុណភាពអ្នកផ្តល់សេវា ដែលបានអនុលោមតាមការតម្រូវក្នុងការបណ្តុះបណ្តាល។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| ណែនាំឱ្យមានកម្មវិធីសិក្សាសម្រាប់អ្នកប្រកបវិជ្ជាជីវៈធ្វើការជាមួយគ្រួសារឪពុកម្តាយធម៌ | ១ វាយតម្លៃការបណ្តុះបណ្តាល។<br>២ កែលម្អ និងកែសម្រួលការបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរ។<br>៣ ពិចារណាដាក់ឱ្យមានការបណ្តុះបណ្តាលជាកាតព្វកិច្ច (ឧ. គិតជាវគ្គសិក្សា ឬគិតជាម៉ោង។ល។)។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| អនុវត្តវគ្គបណ្តុះបណ្តាលស្តង់ដា | ១ បង្កើតផែនការអនុវត្តថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលស្តង់ដា។<br>២ ប្រើប្រាស់ក្រុមការងារចល័ត ដើម្បីផ្តល់ការបណ្តុះបណ្តាលនាពេលដំបូង។<br>៣ ដាក់ការបណ្តុះបណ្តាលស្តង់ដាជាផ្នែកមួយនៃកំណែទម្រង់ថ្នាក់ជាតិ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩-២០២០ |
| **រយៈពេលវែង (ហួសពី ២០២៣)** | | | | |
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បង្កើតការបណ្តុះបណ្តាលវិជ្ជាជីវៈ (អនុសាសន៍ទី ៣) | ១ បង្កើតការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ឪពុកម្តាយធម៌ និងអ្នកប្រកបវិជ្ជាជីវៈទៅតាមប្រធានបទជំនាញឯកទេស (ឧ. កុមារមានតម្រូវការពិសេស សេចក្តីត្រូវការស្មុគស្មាញ ការរំលោភបំពាន និងការបំភ្លេចកុមារ ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើណេត។ល។<br>២ ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកប្រកបវិជ្ជាជីវៈក្នុងមូលដ្ឋាន សមាជិក គកនក។ល។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

# អនុសាសន៍ទី ១១

## អ្នកថែទាំជាឪពុកម្តាយធម៌៖ ធានាឱ្យមានការវាយតម្លៃ ការត្រៀម និងការគាំទ្រក្នុងការតាមដានឱ្យបានគ្រប់គ្រាន់

**ST**

ការវាយតម្លៃរហ័សលើនីតិវិធីប្រតិបត្តិការរបស់អ្នកផ្តល់សេវាការថែទាំដោយឪពុកម្តាយធម៌នីមួយៗក្នុងប្រទេសកម្ពុជា។

ស្ថាបនាបន្ថែមលើការងាររបស់អ្នកដើរតួផ្នែកសង្គមស៊ីវិល ក៏ដូចជាកម្មវិធីអន្តរជាតិដែលពាក់ព័ន្ធដទៃទៀត។

- ប្រព័ន្ធវាយតម្លៃ និងផ្តល់សិទ្ធិជាលក្ខណៈស្តង់ដាដ៏ហ្មត់ចត់របស់អ្នកមើលថែជាឪពុកម្តាយធម៌គួរត្រូវបានអនុវត្ត។
- សេវាគាំទ្រផ្តោតគោលដៅសម្រាប់អ្នកថែទាំជាឪពុកម្តាយធម៌គួរត្រូវបានបង្កើតឡើង។

**MT**

បង្កើតក្រុមអ្នកមើលថែជាឪពុកម្តាយធម៌ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ការដាក់បញ្ចូលបទដ្ឋានអប្បបរមាការជ្រើសរើសគោលនយោបាយយកកុមារទៅដាក់និងវិធានការ។

សមាហរណកម្មទៅក្នុងបទបញ្ញត្តិថ្មីៗស្តីពីសុខុមាលភាពកុមារ និងការការពារកុមារ។

**LT**

បង្កើតបរិស្ថានមួយ ដែលក្នុងនោះការថែទាំដោយឪពុកម្តាយធម៌ត្រូវបានទទួលយកតាមរយៈសកម្មភាពការលើកកម្ពស់ការយល់ដឹង។

បង្កើតក្របខ័ណ្ឌការងារសម្រាប់ការពិចារណាលើសុំកូនក្នុងប្រទេស ក្នុងរយៈពេលវែងសម្រាប់ករណីការថែទាំដោយឪពុកម្តាយធម៌។

អ្នកប្រកបវិជ្ជាជីវៈគួរត្រូវបានបំពាក់ឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីវាយតម្លៃ និងផ្តល់សិទ្ធិដល់អ្នកថែទាំជាឪពុកម្តាយធម៌ ដែលមានសក្តានុពល ក៏ដូចជាដើម្បីផ្តល់ការគាំទ្រដែលចាំបាច់ ដើម្បីបំពេញតួនាទីផ្តល់ការថែទាំរបស់ពួកគេ។ អ្នកថែទាំជាឪពុកម្តាយធម៌គួរ «ត្រូវបានជ្រើសរើសមានលក្ខណៈសម្បត្តិត្រូវបានអនុម័ត និងស្ថិតក្រោមការមើលខុសត្រូវ ចំពោះការផ្តល់ការថែទាំទាំងនេះ» (គោលការណ៍ណែនាំអង្គការសហប្រជាជាតិ)។ គិតមកដល់សព្វថ្ងៃនេះ អ្នកផ្តល់សេវាសង្គមស៊ីវិលនីមួយៗមាននីតិវិធីផ្ទៃក្នុងរបស់ខ្លួន សម្រាប់ការវាយតម្លៃ និងផ្តល់សិទ្ធិជាថ្មីម្តងទៀត គឺមានកម្រិតគុណភាពខុសៗគ្នា។ ការវាយតម្លៃរហ័សលើនីតិវិធីប្រតិបត្តិការរបស់អ្នកផ្តល់សេវាថែទាំដោយឪពុកម្តាយធម៌នីមួយៗជាផ្នែកមួយនៃការធ្វើបញ្ជីសារពើភ័ណ្ឌ អ្នកផ្តល់ការថែទាំដោយឪពុកម្តាយធម៌ (អនុសាសន៍ទី ៨) គឺមានភាពចាំបាច់ ដើម្បីកំណត់រកការអនុវត្តដែលអាចធ្វើបាន និងមានសក្តានុពល ក៏ដូចជាចន្លោះប្រហោងដែលអាចមាននៅពេលពិចារណាលើបទដ្ឋានអន្តរជាតិក្នុងរយៈពេលខ្លី។ ការវាយតម្លៃបែបនេះ ក៏អាចផ្តល់ឱ្យរដ្ឋាភិបាលនូវរូបភាពកាន់តែត្រឹមត្រូវថែមទៀតថា តើការផ្តល់សេវាថែទាំដោយឪពុកម្តាយធម៌មានភាពគ្របដណ្តប់កម្រិតណា ព្រោះថាពុំមែនគ្រប់សេវាទាំងអស់សុទ្ធតែបានការទទួលស្គាល់គុណភាពនោះឡើយ។

ផ្អែកលើការវាយតម្លៃរហ័សនេះ នឹងស្ថាបនាបន្ថែមលើការអនុវត្តប្រកបដោយសក្តានុពលដែលមានស្រាប់ក្នុងប្រទេសកម្ពុជា និងឧទាហរណ៍ថ្នាក់អន្តរជាតិដែលពាក់ព័ន្ធនានា ប្រព័ន្ធដែលមានលក្ខណៈស្តង់ដាដ៏ហ្មត់ចត់ក្នុងការវាយតម្លៃ និងការផ្តល់សិទ្ធិដល់អ្នកមើលថែជាឪពុកម្តាយធម៌ គួរត្រូវបានអនុវត្ត។ បទដ្ឋានអប្បបរមាសម្រាប់ការវាយតម្លៃការបណ្តុះបណ្តាលសេចក្តីសម្រេចចិត្តក្នុងការយកកុមារទៅដាក់កន្លែងណាមួយ និងការមើលខុសត្រូវលើឪពុកម្តាយធម៌ ជាការនិយាយដោយឡែក គួរស្ថាបនាបន្ថែមលើការអនុវត្តប្រកបដោយសក្តានុពលនៃអ្នកផ្តល់សេវាដែលមានស្រាប់បច្ចុប្បន្ន ដូចជាអង្គការទំនុកចិត្តកុមារកម្ពុជា, កុមារនៅក្នុងគ្រួសារ FI និងម្លប់ឫស្សីជាដើម។ ស្តង់ដាទាំងនេះ

ចាំបាច់ត្រូវគ្របដណ្តប់លើជំនាញផ្សេងៗ ដែលការថែទាំដោយឪពុកម្តាយធម៌ប្រភេទផ្សេងៗត្រូវការមានឧទាហរណ៍ ដូចជាការថែទាំដោយឪពុកម្តាយធម៌សម្រាប់គ្រាអាសន្ន ការថែទាំដោយឪពុកម្តាយធម៌សម្រាប់រយៈពេលខ្លី ការថែទាំដោយឪពុកម្តាយធម៌ សម្រាប់រយៈពេលវែងការថែទាំដោយឪពុកម្តាយធម៌ ដើម្បីផ្តល់ការព្យាបាល។

ដូចគ្នានេះដែរ ជាការចាំបាច់ណាស់ដែលការគាំទ្រដោយអ្នកប្រកបវិជ្ជាជីវៈអាជីពត្រូវបានផ្តល់ជូនទៅដល់អ្នកថែទាំកុមារជាឪពុកម្តាយធម៌ផ្អែកលើកម្មវិធីសិក្សា ដែលមានបច្ចុប្បន្ន[108] និងការអនុវត្តជាសក្តានុពលកម្រិតអន្តរជាតិ។[109] គ្រួសារធម៌ និងកុមាររស់នៅក្នុងផ្ទះគ្រួសារធម៌ត្រូវការការគាំទ្រប្រភេទដូចគ្នាជាមួយសមាជិកដទៃទៀតនៅក្នុងសហគមន៍ដែរ ដូចជាការគាំទ្រផ្នែកសុខាភិបាល ការអប់រំសង្គមកិច្ច។ល។ ពួកគេក៏ត្រូវការការគាំទ្រជាក់លាក់ ដូចជាក្នុងករណីជាច្រើន កុមារស្ថិតក្រោមការថែទាំប្រហែលជាមានសេចក្តីត្រូវការបែបឯកទេស អាស្រ័យដោយការប៉ះទង្គិចធ្ងន់ធ្ងរកន្លងមក ការបំភ្លេច ការបោះបង់ចោល របួសជំងឺជាដើម ដែលពួកគាត់ធ្លាប់ជួបកន្លងមក ( សូមមើល៤ និង៥ ៖ការទប់ស្កាត់ជុំទីមួយ និងទីពីរ )។

ដូចបានពិភាក្សារួចមកហើយថា ដើម្បីអនុវត្តយុទ្ធសាស្ត្រការធ្វើសមាហរណកម្ម និងការដកកុមារចេញពីមណ្ឌលថែទាំដូចមានសព្វថ្ងៃជាការចាំបាច់ណាស់ ដែលត្រូវអភិវឌ្ឍឱ្យមានក្រុមឪពុកម្តាយធម៌មួយក្រុម សម្រាប់រយៈពេលមធ្យម។ យើងអាចនិយាយម្យ៉ាងទៀតបានថា គ្រួសារដែលត្រូវបានត្រៀមខ្លួនយ៉ាងគ្រប់គ្រាន់ ដើម្បីទទួលយកកុមារ អនុលោមតាមសេចក្តីត្រូវការក្នុងការយកកុមារទៅដាក់ឱ្យរស់នៅក្នុងគ្រួសារ ដោយមានប្រព័ន្ធការផ្គូផ្គងសមស្រប។ ស្របពេលដែលអង្គការកុមារនៅក្នុងគ្រួសារមានក្រុមគ្រួសារធម៌មួយក្រុម ដែលមានគ្នាបីទៅបួនគ្រួសារកំពុងរង់ចាំភាគច្រើននៃអ្នកផ្តល់សេវាពុំមានបែបនេះឡើយ។ ក្នុងការអនុវត្តជាក់ស្តែង យើងឃើញថា ការអំពាវនាវឱ្យមានអ្នកថែទាំជាគ្រួសារធម៌ត្រូវបានធ្វើឡើងតាមរយៈបណ្តាញក្នុងមូលដ្ឋាន ដូចជា គកនក ហើយទាល់តែមានកុមារមានតម្រូវការប៉ុណ្ណោះ។ នៅពេលដែលគ្រួសារមានលក្ខណៈសមស្របបំផុតត្រូវបានជ្រើសរើស ការដាក់ពាក្យសុំរបស់អ្នកមើលថែជាគ្រួសារធម៌ ពុំមែនជាកត្តាចាំបាច់ទៀតឡើយ។ មនុស្សមួយក្រុមអាចផ្តល់ការថែទាំបណ្តោះអាសន្នជួយដល់គ្រួសារធម៌នាពេលបច្ចុប្បន្ន ដោយមានអត្ថប្រយោជន៍បន្ថែមដែលពួកគាត់អាចត្រូវបានពិនិត្យតាមដាន និងទទួលបានការគាំទ្រមុនពេលកុមារត្រូវបានយកទៅដាក់ក្រោមការថែទាំរបស់ពួកគាត់។

នៅក្នុងករណីដែលគ្រួសារធម៌ត្រៀមខ្លួនរួចរាល់ ដើម្បីទទួលយកកុមារ គឺនឹងអាចផ្តល់ឱកាស ដើម្បីអាចផ្គូផ្គងកុមារជាមួយគ្រួសារបានដោយសុវត្ថិភាព ( សូមមើល០១៨៖ សារៈសំខាន់នៃការផ្គូផ្គងនៅក្នុងស៊ុំកូន )។ ជាផ្នែកមួយនៃការផ្គូផ្គង បទបញ្ញត្តិស្តីពីការថែទាំដោយគ្រួសារធម៌ គួរដាក់បញ្ចូលរយៈចម្ងាយភូមិសាស្ត្រអតិបរមារវាងគ្រួសារកំណើត ជាមួយគ្រួសារចិញ្ចឹម ដើម្បីជួយសម្រួលឱ្យមានទំនាក់ទំនងជាប្រចាំរវាងកុមារ និងសមាជិកគ្រួសាររបស់ខ្លួន ប្រសិនបើការធ្វើបែបនេះ គឺជាឧត្តមប្រយោជន៍របស់កុមារ។ យើងបានទទួលព័ត៌មានថា FCF មានបំណងអនុវត្តសាកល្បងនូវគណៈកម្មការការថែទាំជំនួស ដែលនឹងមានមុខងារផ្គូផ្គង និងអត្ថប្រយោជន៍នៃក្រសែភ្នែកឯករាជ្យច្រើនគូ។ នៅក្នុងការរចនាគម្រោងសាកល្បងនេះ យើងជឿជាក់ថា ស្ថាប័នមានសមត្ថកិច្ចទាំងឡាយណា ដែលមានមុខងារក្នុងការផ្គូផ្គង ដើម្បីអាចទទួលបានជោគជ័យបានត្រូវតែជាស្ថាប័នរបស់រដ្ឋ ហើយសមាសធាតុរបស់ស្ថាប័ននេះ គឺត្រូវបានរៀបចំឡើង ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍ ដែលអាចកើតមានសក្តានុពល (ឧ. ការផាត់ចេញអ្នក ដែលអាចទទួលបានអត្ថប្រយោជន៍ពីស៊ុំកូន )។ បន្ថែមលើនេះទៀត ការចូលរួមរបស់កុមារគួរត្រូវបានលើកទឹកចិត្ត ហើយគួរមានវិធានការការពារសុវត្ថិភាព ដើម្បីទប់ស្កាត់អំពើពុករលួយ ការប្រើប្រាស់ឯកសារក្លែងបន្លំ និងការរំលោភបំពានដែលអាចមានដទៃទៀត។

នៅពេលផ្គូផ្គងរួចហើយ អ្នកមើលថែជាឪពុកម្តាយធម៌ចាំបាច់ត្រូវបានទទួលការគាំទ្រ ហើយការយកកុមារទៅដាក់នៅក្នុងគ្រួសារនោះ គួរត្រូវបានពិនិត្យឡើងវិញជាប្រចាំដោយមន្ទីរ

108 ការថែទាំដោយឪពុកម្តាយធម៌របស់អង្គការ Friend International និងកម្មវិធី 3PC៖ http://mithsamlanh.org/download/fostercare.pdf and KAP Survey, http://3pc-cambodia.org/wp-content/uploads/KAP-on-Foster-Care-Report-Finalized.pdf

109 Maja Laklija : Foster Care Models in Europe, 2011, supporting foster parents: http://www.bettercarenetwork.nl/dl-17382-1-37371/download/pleegzorgmodellen_in_europa.pdf at 24-30

ស.អ.យ ក្នុងចន្លោះរយៈពេលសមស្របទៅតាមសេចក្ដីត្រូវការ និងអាយុរបស់កុមារីនីមួយៗ។ ក្នុងករណីរបស់អង្គការម្លប់ឫស្សី ពួកគាត់ចុះទៅគ្រួសារឪពុកម្ដាយធម៌ក្នុងមួយខែម្ដង។ ការធ្វើបែបនេះ អាចជួយទប់ស្កាត់ការនឿយហត់ខ្លាំង ហើយជួយកំណត់ឃើញនូវសេវាពិសេសនានា ដែលចាំបាច់សម្រាប់កុមារដែលមានបច្ចុប្បន្ន។ សកម្មភាពនេះទាមទារឱ្យមានអ្នកជួយមានការបណ្ដុះបណ្ដាលត្រឹមត្រូវ និងមានលទ្ធភាពចូលទៅកាន់ព័ត៌មានក្នុងទម្រង់ផ្សេងៗ ដូចជាបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ថ្នាក់ជាតិ ដូចដែលបានស្នើឡើង កម្មវិធីតាមប្រព័ន្ធផ្សព្វផ្សាយ។ល។ ក្នុងករណីការយកកុមារដាក់តាមគ្រួសារធម៌ត្រូវបរាជ័យចាំបាច់ត្រូវមាននីតិវិធី ដើម្បីចៀសវាងការយកទៅដាក់នៅច្រើនកន្លែង។

ការយកកុមារទៅដាក់ក្នុងគ្រួសារធម៌ប្រកបដោយជោគជ័យ ទាមទារឱ្យមានបរិយាកាសប្រកបដោយការគាំទ្រ រួមមានដូចជាអ្នកជិតខាងសាលារៀន។ល។ ហេតុនេះសម្រាប់រយៈពេលវែង យើងខ្ញុំសូមផ្ដល់អនុសាសន៍ឱ្យមានកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីការចិញ្ចឹមដោយឪពុកម្ដាយធម៌។ ការងារនេះអាចជាផ្នែកមួយនៃកម្មវិធីការជ្រើសរើសឪពុកម្ដាយធម៌ ក៏ដូចជាការផ្ដល់ព័ត៌មានប្រាប់សហគមន៍ និងអ្នកប្រកបវិជ្ជាជីវៈជំនួយនៅក្នុងមូលដ្ឋានអំពីការថែទាំដោយឪពុកម្ដាយធម៌ និងសារៈសំខាន់នៃការដែលកុមារជាកូនធម៌ត្រូវបានមនុស្សក្នុងមូលដ្ឋានទទួលយក។ ទោះយ៉ាងណាក្ដី ការជ្រើសរើស និងការរក្សាគ្រួសារធម៌ "ល្អគ្រប់គ្រាន់" សមស្រប គឺពុំមែនជាភារកិច្ចងាយស្រួលនោះឡើយ។ យើងខ្ញុំសូមផ្ដល់អនុសាសន៍ឱ្យយុទ្ធសាស្ត្រ ដែលត្រូវបានអនុវត្តដោយ CoramBAAF[110] រួមទាំងកម្មវិធី ដើម្បីជ្រើសរើសគ្រួសារដែលមានឆន្ទៈសុំកុមារមានសេចក្ដីត្រូវការជាពិសេសយកទៅចិញ្ចឹម និងក្រុមបណ្ដាញមិត្តភក្តិ។

សម្រាប់រយៈពេលវែង គួរបង្កើតក្របខ័ណ្ឌការងារមួយ ដើម្បីពិចារណាលើស្មុំកូនថ្នាក់ជាតិ សម្រាប់ករណីការថែទាំដោយឪពុកម្ដាយធម៌រយៈពេលវែង នៅពេលការធ្វើបែបនេះគឺជាឧត្ដមប្រយោជន៍របស់កុមារ។ ក្នុងករណីបែបនេះ ស្មុំកូនក្នុងប្រទេសគួរត្រូវបានសម្របសម្រួលឱ្យក្លាយជាដំណោះស្រាយអចិន្ត្រៃយ៍ ដូចបានពិពណ៌នានៅក្នុងផ្នែកស្ដីពីស្មុំកូនក្នុងរបាយការណ៍នេះ (សូមមើលផ្នែកទី ៦)។ អាចមានករណីដែលគ្រួសារចិញ្ចឹមប្រហែលជាត្រូវការការគាំទ្របន្ថែម រួមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ ដែលត្រូវបានផ្ដល់ឱ្យរួចហើយទៅដល់គ្រួសារធម៌។

110 http://corambaaf.org.uk/info/fostering#rec

# អនុសាសន៍ទី ១១

# អ្នកថែទាំជាឪពុកម្ដាយធម៌៖ ធានាឱ្យមានការវាយតម្លៃ ការត្រៀម និងការគាំទ្រក្នុងការតាមដានឱ្យបានគ្រប់គ្រាន់

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការវាយតម្លៃរហ័សលើនីតិវិធីប្រតិបត្តិការរបស់អ្នកផ្ដល់សេវាបច្ចុប្បន្ន ក្នុងប្រទេសកម្ពុជា | ១ ធ្វើបញ្ជីនីតិវិធីប្រតិបត្តិការដែលមានស្រាប់ទាំងអស់។<br>២ ការប៉ាន់ប្រមាណ និងវាយតម្លៃលើនីតិវិធីប្រតិបត្តិការដែលមានស្រាប់ទាំងអស់។<br>៣ កំណត់រកនីតិវិធីដែលនឹងត្រូវបញ្ជ្រាប និងចន្លោះប្រហោងនៅក្នុងនីតិវិធី។<br>៤ ធ្វើសេចក្ដីព្រាងនីតិវិធីប្រតិបត្តិការថ្នាក់ជាតិ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ |
| ប្រព័ន្ធដែលមានលក្ខណៈស្តង់ដាក្នុងការវាយតម្លៃ ការផ្ដល់ការអនុញ្ញាត ការពិនិត្យតាមដានអ្នកថែទាំជាឪពុកម្ដាយធម៌ | ១ កំណត់រកការអនុវត្ត ដែលមានស្រាប់នាពេលបច្ចុប្បន្នសម្រាប់ការជ្រើសរើស ការវាយតម្លៃ ការបណ្ដុះបណ្ដាល ការយកកុមារទៅដាក់ និងការមើលខុសត្រូវលើអ្នកមើលថែជាឪពុកម្ដាយធម៌។<br>២ បង្កើតស្តង់ដាអប្បបរមា សម្រាប់ការថែទាំដោយឪពុកម្ដាយធម៌គ្រប់ប្រភេទ (គ្រាអាសន្ន បណ្ដោះអាសន្ន រយៈពេលវែង បែបការព្យាបាល។ល។)។<br>៣ ផ្សព្វផ្សាយស្តង់ដាអប្បបរមាជូនដល់ភាគីពាក់ព័ន្ធទាំងអស់ អ្នកប្រកបវិជ្ជាជីវៈអាជីពដែលធ្វើការនៅក្នុងវិស័យដទៃទៀត (ឧ. សុខាភិបាល អប់រំ ការជំរុញការអនុវត្តច្បាប់ ប្រព័ន្ធយុត្តិធម៌។ល។)។<br>៤ ដាក់ស្តង់ដានេះបញ្ចូលទៅក្នុងក្របខ័ណ្ឌការងារផ្នែកច្បាប់ថ្នាក់ជាតិ។<br>៥ បណ្ដុះបណ្ដាលអ្នកដើរតួនាទីពាក់ព័ន្ធទាំងអស់ស្ដីពីស្តង់ដានេះ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៨ តទៅ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បង្កើតឱ្យមានក្រុមអ្នកថែទាំជាឪពុកម្ដាយធម៌មានលក្ខណៈសម្បត្តិគ្រប់គ្រាន់មួយក្រុម | ១ ចុះឈ្មោះអ្នកថែទាំជាឪពុកម្ដាយធម៌ ដែលត្រូវបានវាយតម្លៃ និងបណ្ដុះបណ្ដាល ដែលត្រូវបានដាក់បញ្ចូលនៅលើបញ្ជីរង់ចាំ ដើម្បីយកកុមារទៅនៅជាមួយគាត់ (ក្រុមអ្នកមើលថែ)។<br>២ ធ្វើកិច្ចប្រជុំជាប្រចាំជាមួយអនាគតអ្នកមើលថែជាឪពុកម្ដាយធម៌ ដើម្បីធ្វើបច្ចុប្បន្នភាពចំណេះដឹង និងបំណិនរបស់ពួកគាត់។<br>៣ ប្រើប្រាស់ក្រុមដែលត្រូវបានជ្រើសរើសនេះជាអ្នកមើលថែបណ្ដោះអាសន្នជួយដល់គ្រួសារឪពុកម្ដាយធម៌ ដែលកំពុងមានប្រតិបត្តិការរួចហើយក្រោមការមើលខុសត្រូវយ៉ាងជិតស្និទ្ធ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩-២០២៣ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| អភិវឌ្ឍបរិស្ថានប្រកបដោយការគាំទ្រសម្រាប់អ្នកមើលថែជាឪពុកម្ដាយធម៌ | ១ ណែនាំឱ្យមានយុទ្ធនាការ ដើម្បីជ្រើសរើសឪពុកម្ដាយធម៌បន្ថែមទៀត។<br>២ អភិវឌ្ឍការលើកកម្ពស់ការយល់ដឹងអំពីសេចក្ដីត្រូវការរបស់កុមារនៅក្នុងការថែទាំដោយឪពុកម្ដាយធម៌។<br>៣ រៀបចំសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់តំបន់ស្ដីពីវិស័យផ្សេងៗនៃការថែទាំជំនួស រួមទាំងការថែទាំដោយឪពុកម្ដាយធម៌ផងដែរ។<br>៤ ពិចារណារៀបចំសន្និសីទថ្នាក់តំបន់ស្ដីពីការថែទាំជំនួស។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០២៣ តទៅ |

# អនុសាសន៍ទី ១២

## កុមារ៖ ធានាឱ្យមានការវាយតម្លៃ ការត្រៀមនិងការគាំទ្រក្នុងការតាមដានឱ្យបានគ្រប់គ្រាន់

**ST** វាយតម្លៃសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់កុមារ រួមទាំងការពិចារណាលើទស្សនៈយល់ឃើញរបស់ពួកគាត់ផងដែរ។

បង្កើតសេវាការថែទាំដោយឪពុកម្តាយធម៌ជាក់លាក់សម្រាប់កុមារមានតម្រូវការពិសេស។

**MT** ដាក់ឱ្យមានសេវាការត្រៀមខ្លួនយ៉ាងរឹងមាំសម្រាប់កុមារ ប្រព័ន្ធការចាកចេញពីការថែទាំប្រកបដោយប្រសិទ្ធភាព និងយន្តការពាក្យបណ្តឹងដែលមានប្រតិបត្តិការ។

**LT** ការវាយតម្លៃដោយឯករាជ្យលើប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌ និងថាតើប្រព័ន្ធនេះឆ្លើយតបតាមសេចក្តីត្រូវការរបស់កុមារយ៉ាងណាខ្លះ។

ការវាយតម្លៃសព្វជ្រុងជ្រោយមួយទៅលើសេចក្តីត្រូវការរបស់កុមារជាលក្ខណៈកុមារ គឺចាំបាច់ណាស់ ( សូមមើល ៧. យន្តការទប់ស្កាត់ )។ ចំពោះកុមារដែលចូលទៅក្នុងប្រព័ន្ធការថែទាំជំនួសក្នុងការអនុវត្តជាក់ស្តែងភារកិច្ចក្នុងការវាយតម្លៃនេះតាមធម្មតាច្រើនតែធ្លាក់ទៅលើសង្គមស៊ីវិល។ ក្នុងករណីកុមារត្រូវការយកទៅដាក់ក្នុងមណ្ឌលថែទាំកុមារ ពួកគាត់ត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គកនក អនុម័តដោយមន្ទីរ ស.អ.យ និងបញ្ជាក់ដោយក្រសួង ស.អ.យ យោងទៅតាមផែនការសកម្មភាពជាតិ។ យើងឃើញថាមន្ទីរ ស.អ.យ មានមុខងារបែបរដ្ឋបាលសុទ្ធសាធ។ ក្នុងការវាយតម្លៃសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់កុមារ ត្រូវផ្តល់ការពិចារណាសមស្របលើទស្សនៈយល់ឃើញរបស់កុមារ ហើយត្រូវលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មរបស់ពួកគេនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។ នេះគឺជាអាទិភាពរយៈពេលខ្លី។ ពេលដែលឃើញថាការថែទាំដោយឪពុកម្តាយធម៌មានភាពសមស្របសម្រាប់កុមាគួរបង្កើតឱ្យមានសេវាត្រៀមខ្លួនជាមុនប្រកបដោយប្រសិទ្ធភាព។[111] កុមារដែលកំពុងចាកចេញពីមណ្ឌលថែទាំកុមារទៅរស់នៅក្នុងបរិយាកាសការថែទាំដោយឪពុកម្តាយធម៌ ត្រូវការការគាំទ្រគ្រប់គ្រាន់ដែលត្រូវបានសម្រួបឱ្យត្រូវទៅតាមសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់ពួកគេ និងត្រូវបានគោរពតាមយ៉ាងសមស្រប។ CCT បានអនុវត្តគំរូការថែទាំនៅតាមគ្រួសារ ដែលអាចពង្រីកបន្ថែម និងបញ្ជ្រាបបន្ថែមទៀតបាននៅក្នុងប្រទេសកម្ពុជា។[112]

នៅក្នុងក្របខ័ណ្ឌការងារប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌ដ៏រឹងមាំ សេវាការថែទាំដោយឪពុកម្តាយធម៌ជាក់លាក់សម្រាប់កុមារមានតម្រូវការពិសេសគួរតែជាអាទិភាពចំពោះមុខ ( សូមមើល៥៖ ការថែទាំបណ្តោះអាសន្ន )។ បញ្ហានេះនឹងត្រូវគ្រប

111 http://fosteringandadoption.rip.org.uk/topics/matching.

112 www.cambodianchildrenstrust.org/family-based-care-model.

ដណ្តាប់នៅក្នុងផែនការអភិវឌ្ឍសមត្ថភាព ដែលបច្ចុប្បន្នកំពុងត្រូវបានពិភាក្សាជាមួយក្រសួង ស.អ.យ អង្គការយូនីសេហ្វ និង ISS។ ការស្ទាបស្ទង់មតិ KSP ធ្វើឡើងដោយកម្មវិធី 3PC ក្នុងឆ្នាំ ២០១៥[113] បង្ហាញឱ្យឃើញអំពីការយល់ដឹងនូវសេចក្តីត្រូវការឱ្យមានការផ្តល់ការថែទាំដោយឪពុកម្តាយធម៌ប្រភេទផ្សេងៗ ក្នុងចំណោមអង្គការ និងអ្នកមើលថែដែលមានបទពិសោធន៍ក្នុងប្រទេសកម្ពុជាជាមួយការថែទាំដោយឪពុកម្តាយធម៌។ ៧៦ ភាគរយនៃអ្នកឆ្លើយតបក្នុងការស្ទាបស្ទង់មតិបានយល់ស្របថា កុមារមានតម្រូវការពិសេសអាចត្រូវបានយកទៅដាក់ក្នុងការថែទាំដោយឪពុកម្តាយធម៌។ ឆ្លងតាមរយៈបទពិសោធន៍ទាំងក្នុងប្រទេស និងអន្តរជាតិបានបង្ហាញឱ្យឃើញនូវការលំបាកក្នុងការយកកុមារមានតម្រូវការពិសេសទៅដាក់នៅក្នុងការថែទាំដោយឪពុកម្តាយធម៌ ឧ. ដូចជា កុមារជនភៀសខ្លួន ឬកុមារទេសន្តប្រវេសន៍ និងកុមារត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ឬកុមារត្រូវគេជួញដូរ។ ករណីទាំងនេះកើតមានជាពិសេសនៅក្នុងស្ថានភាពដែលពុំមានប្រព័ន្ធការគាំទ្រសមស្រប ដូចជាការថែទាំបណ្តោះអាសន្ន ការគាំទ្រនៅតាមសហគមន៍ជាមូលដ្ឋានជាដើម។

សម្រាប់រយៈពេលមធ្យម គួរដាក់ឱ្យមានប្រព័ន្ធការថែទាំសម្រាប់ការចាកចេញពីមណ្ឌលថែទាំប្រកបដោយប្រសិទ្ធភាពមួយ។ ការត្រៀមរៀបចំខ្លួនសម្រាប់ការចាកចេញពីការថែទាំ ត្រូវបានទទួលស្គាល់ និងអនុវត្តដោយអង្គការ NGOs ជាច្រើនធ្វើការនៅក្នុងប្រទេសកម្ពុជា។ អង្គការ FI គឺជាឧទាហរណ៍ដ៏ល្អមួយនៃការត្រៀមរៀបចំសម្រាប់ការចាកចេញពីការថែទាំ ដោយផ្តល់ការប្រឹក្សាយោបល់ ការបណ្តុះបណ្តាលពិសេស និងការអប់រំវិជ្ជាជីវៈ ដើម្បីត្រៀមខ្លួនមនុស្សវ័យក្មេងឱ្យរកចំណូលចិញ្ចឹមជីវិតក៏ដូចជាផ្ទះពាក់កណ្តាលផ្លូវ ដើម្បីជួយសម្របសម្រួលឱ្យមានឯករាជ្យភាព។[114] បន្ថែមលើនេះទៀត យន្តការបណ្តឹងដែលមានប្រតិបត្តិការល្អមួយគួរត្រូវបានអភិវឌ្ឍឱ្យមាន។ នៅក្នុងគោលនយោបាយសម្រាប់ការថែទាំជំនួស សម្រាប់កុមារក្នុងប្រទេសកម្ពុជាមានច្រកតែមួយគត់ សម្រាប់ឱ្យកុមារក្នុងករណីស្នើកូនដាក់ពាក្យបណ្តឹងបាន។ ព័ត៌មានស្តីពីលេខទូរស័ព្ទទាន់ហេតុការណ៍ដែលមានបុគ្គលដែលអាចទំនាក់ទំនងបុគ្គលិក ដែលត្រូវបានចាត់តាំង អ្នកពិនិត្យតាមដានឯករាជ្យ បុគ្គលិកសង្គមកិច្ច ឬសមាជិកសហគមន៍អាចផ្តល់ជំនួយដល់កុមារ ក្នុងការស្វែងរកជំនួយ ប្រសិនបើចាំបាច់។ រដ្ឋាភិបាលប្រទេសញូហ្សេលែន និងចក្រភពអង់គ្លេសផ្តល់ឧទាហរណ៍អំពីប្រព័ន្ធពាក្យបណ្តឹងសព្វជ្រុងជ្រោយ។[115]

នៅក្នុងក្របខ័ណ្ឌការងារប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌ដ៏រឹងមាំការវាយតម្លៃដោយឯករាជ្យលើប្រព័ន្ធការថែទាំដោយឪពុកម្តាយធម៌ទាក់ទងជាមួយសេចក្តីត្រូវការរបស់កុមារគួរត្រូវបានធ្វើឡើង សម្រាប់រយៈពេលវែង (សូមមើលអនុសាសន៍ទី ៨)។

113 ការស្ទាប់ស្ទង់មតិ KAP ដោយកម្មវិធី 3PC៖ការស្ទាបស្ទង់មតិអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តស្តីពីការថែទាំដោយឪពុកម្តាយធម៌៖ http://3pc-cambodia.org/wp-content/uploads/KAP-on-Foster-Care-Report-Finalized.pdf

114 https://friends-international.org/in-cambodia

115 អនុសាសន៍ស្តីពីវិធីដើម្បីឱ្យកុមារ យុវជន និងគ្រួសារអាចអនុវត្តយុទ្ធវិធីបែបយកកុមារជាមជ្ឈមណ្ឌលសម្រាប់ការដោះស្រាយពាក្យបណ្តឹង៖ www.occ.org.nz/assets/Uploads/Reports/Child-rights/Review-of-the-Child-Youth-and-Family-Complaints-Resolution-Policy-and-Procedure.pdf និងការទទួលបានច្រើនបំផុតពីពាក្យបណ្តឹង៖ www.gov.uk/government/uploads/system/uploads/attachment_data/file/273895/getting_the_best_from_complaints.pdf សូមមើលផងដែរនូវការផ្តល់សច្ចាប័នលើពិធីសារជាជម្រើសបន្ថែមទីបីស្តីពីនីតិវិធីការប្រាស្រ័យទាក់ទងនៃ UnCRC ក៏អាចជួយក្នុងការរៀនសូត្របន្ថែម និងការបង្កើតប្រព័ន្ធថ្នាក់ជាតិមួយផងដែរ៖ www.childrightsconnect.org/connect-with-the-un-2/op3-crc

អនុសាសន៍ទី

១២

# កុមារ៖ ធានាឱ្យមានការវាយតម្លៃ ការត្រៀម និងការគាំទ្រក្នុងការតាមដានឱ្យបានគ្រប់គ្រាន់

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការវាយតម្លៃជាលក្ខណៈបុគ្គលទៅលើកុមារ | ១ រៀបចំប្រព័ន្ធចងក្រងឯកសារ ដើម្បីវាយតម្លៃសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់កុមារ ដើម្បីត្រៀមរៀបចំផែនការការយកកុមារទៅដាក់ក្រោមការថែទាំលក្ខណៈបុគ្គល និងផ្តល់ការគាំទ្របន្ត។<br>២ វាយតម្លៃសេចក្តីត្រូវការរបស់កុមារនៅក្នុងមណ្ឌលថែទាំកុមារ (សូមមើលអនុសាសន៍ទី ១៦)។ | ក្រសួង ស.អ.យ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា។ | UNICEF, 3PC, FCF | ២០១៨ |
| លើកទឹកចិត្តឱ្យមានការចូលរួមរបស់កុមារនៅក្នុងការធ្វើផែនការករណី (សូមមើលអនុសាសន៍ទី ៦) | ១ បង្កើតការបណ្តុះបណ្តាលសម្រាប់អ្នកប្រកបវិជ្ជាជីវៈអាជីពស្តីពីនីតិវិធីកុមារមេត្រី។<br>២ ធ្វើសេចក្តីព្រាង កុមារមេត្រីស្តីពីសិទ្ធិកុមារដោយទាញចេញពីសម្ភារៈ ដែលមានស្រាប់នាពេលបច្ចុប្បន្ន (ឧ. ការតំណាង ពាក្យបណ្តឹង ។ល។) | ក្រសួង ស.អ.យ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា។ | UNICEF, 3PC, FCF | ២០១៨ |
| អភិវឌ្ឍការថែទាំដោយឪពុកម្តាយធម៌សម្រាប់កុមារមានតម្រូវការពិសេស | ១ ចាត់ធនធានបន្ថែម សម្រាប់ឪពុកម្តាយធម៌ដែលមើលថែកុមារមានតម្រូវការពិសេស និងតម្រូវការស្មុគស្មាញ។<br>២ បង្កើតការបណ្តុះបណ្តាលឯកទេស និងការមើលខុសត្រូវសម្រាប់ពួកគាត់<br>៣ ផ្តល់ការគាំទ្រ និងសេវាជំនួយទាំងសម្រាប់កុមារទាំងសម្រាប់អ្នកមើលថែជាឪពុកម្តាយធម៌។<br>៤ ចាត់ចែងឱ្យមានឧបករណ៍ និងបរិក្ខារដែលត្រូវការ។<br>៥ វាយតម្លៃលើការផ្តល់សេវាក្នុងមូលដ្ឋានដើម្បីធានាលទ្ធភាពទទួលបានសេវាសុខាភិបាល និងការអប់រំ។<br>៦ ធានាឱ្យមានសេវាការថែទាំបណ្តោះអាសន្ន (សូមមើលអនុសាសន៍ទី ១១) | ក្រសួង ស.អ.យ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា។ | UNICEF, 3PC, FCF | ២០១៨ តទៅ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| **តើចាំបាច់ត្រូវមានអ្វីខ្លះ?** | **តើនឹងត្រូវអនុវត្តដោយរបៀបណា?** | **តើនរណាទទួលខុសត្រូវ?** | **តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ?** | **រយៈពេល** |
| ណែនាំឱ្យមានគោលនយោបាយជាតិស្ដីពីការចាកចេញពីការថែទាំ | ១ ធ្វើបញ្ជីអំពីសេវាដែលមានស្រាប់នាពេលបច្ចុប្បន្ន សម្រាប់អ្នកចាកចេញពីការថែទាំ។<br>២ កំណត់រកការអនុវត្តប្រកបដោយសក្ដានុពល និងចន្លោះប្រហោងដែលមាន។<br>៣ បង្កើតសេវាថ្នាក់ជាតិសម្រាប់អ្នកចាកចេញពីការថែទាំ។<br>៤ បណ្ដុះបណ្ដាលអ្នកផ្ដល់សេវា និងអ្នកប្រកបវិជ្ជាជីវៈអាជីព ដើម្បីផ្ដល់សេវាក្រោយការថែទាំ និងសេវាតាមដានបន្ត។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩ តទៅ |
| បង្កើតយន្តការបណ្ដឹងទូទាំងប្រទេស | ១ ធ្វើបញ្ជីអំពីយន្តការបណ្ដឹងដែលមានស្រាប់នាពេលបច្ចុប្បន្ន។<br>២ កំណត់រកការអនុវត្តប្រកបដោយសក្ដានុពល និងចន្លោះប្រហោងដែលមាន។<br>៣ បង្កើតយន្តការពាក្យបណ្ដឹងថ្នាក់ជាតិ និងពិចារណាឱ្យមានការិយាល័យពលរដ្ឋសម្រាប់កុមារ។<br>៤ រៀបចំខ្លួនអ្នកប្រកបវិជ្ជាជីវៈអាជីព និងអ្នកស្ម័គ្រចិត្តឱ្យទទួលបណ្ដឹងពីកុមារ។<br>៥ នីតិវិធីពាក្យបណ្ដឹងនឹងត្រូវបានផ្សព្វផ្សាយជូនដល់កុមារ និងអ្នកដើរតួនាទីនានា។<br>៦ ជាផ្នែកមួយនៃការបណ្ដុះបណ្ដាល ត្រូវកំណត់ថាតើធ្វើយ៉ាងណាដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះករណីការរំលោភបំពាន។ | ក្រសួង ស.អ.យ។ | UNICEF, 3PC, FCF | ២០១៩-២០២៣ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| **តើចាំបាច់ត្រូវមានអ្វីខ្លះ?** | **តើនឹងត្រូវអនុវត្តដោយរបៀបណា?** | **តើនរណាទទួលខុសត្រូវ?** | **តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ?** | **រយៈពេល** |
| ការវាយតម្លៃដោយឯករាជ្យទៅលើប្រព័ន្ធការថែទាំដោយឪពុកម្ដាយធម៌ | ១ ជាផ្នែកមួយនៃការវាយតម្លៃដោយឯករាជ្យទៅលើប្រព័ន្ធការថែទាំជំនួស (អនុសាសន៍ទី ៨) ត្រូវផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើការបំពេញមុខងាររបស់ប្រព័ន្ធការថែទាំដោយឪពុកម្ដាយធម៌។ | ក្រសួង ស.អ.យ ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និង កីឡា។ | UNICEF, 3PC, FCF | ២០២៣ តទៅ |



© CCT Cambodia/2016

# ០៤

# ស្មុំកូនៈ ការរកឃើញ និងអនុសាសន៍ការអភិវឌ្ឍសមត្ថភាព

រដ្ឋត្រូវយកចិត្តទុកដាក់ជាបញ្ហាអាទិភាព ធ្វើយ៉ាងណាចាត់តាំងឱ្យមានវិធានការសមស្រប ដើម្បីជំរុញកុមារឱ្យស្ថិតក្នុងការថែទាំរបស់គ្រួសារកំណើតរបស់ខ្លួន។[116] ប្រសិនបើពុំអាចរក្សាកុមារឱ្យស្ថិតក្នុងការថែទាំរបស់គ្រួសារកំណើតរបស់ខ្លួនបានទេ រដ្ឋត្រូវខិតខំឱ្យអស់លទ្ធភាព ដើម្បីស្វែងរកដំណោះស្រាយសមស្រប និងជាអចិន្ត្រៃយ៍ដទៃទៀត រួមទាំងការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្ដាយធម៌រយៈពេលវែង ដោយពិចារណាលើឧត្តមប្រយោជន៍របស់កុមារ (សូមមើលផ្នែកទី ៣) និងស្មុំកូន។ ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការពិចារណាចម្បងបំផុតនៅក្នុងស្មុំកូន។ ស្មុំកូនទៅចិញ្ចឹម គួរបានទទួលការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលបានកំណត់ឃើញថា ស្មុំកូននោះគឺអាចអនុញ្ញាតឱ្យធ្វើឡើងបាន។[117] ស្មុំកូនគ្របដណ្ដប់លើនីតិវិធីស្មុគស្មាញជាច្រើនដែលគួរឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់កុមារត្រូវមានប្រសិទ្ធភាពចំណាយ និងទាន់ពេលវេលា។

ក្នុងប្រទេសកម្ពុជា ស្មុំកូនត្រូវបានគ្រប់គ្រងដោយច្បាប់មួយចំនួន ដូចជាក្រមរដ្ឋប្បវេណីច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងវិវាទច្បាប់ស្ដីពីស្មុំកូនអន្តរប្រទេសឆ្នាំ ២០០៩ បទបញ្ញត្តិនានា (ដូចជា ប្រកាស )[118] និងសេចក្ដីសម្រេចដទៃទៀត (សេចក្ដីពន្យល់ស្ដីពីស្មុំកូនក្នុងប្រទេស ឆ្នាំ ២០១៦)។ អនុសាសន៍គន្លឹះនៅចំណុចនេះ គឺត្រូវអនុវត្តក្របខ័ណ្ឌការងារដែលមានស្រាប់នាពេលបច្ចុប្បន្នដែលមានការអភិវឌ្ឍឈានឡើងក្នុងកម្រិតគួរជាទីកត់សម្គាល់ ថ្វីបើដូចមានការបញ្ជាក់ខាងក្រោមថា នៅមានចន្លោះប្រហោងមួយចំនួនដែលចាំបាច់ត្រូវឆ្លើយតប។ រដ្ឋាភិបាលគួរផ្ដល់ធនធានមនុស្ស និងធនធានសម្ភារៈដែលចាំបាច់ និងការបណ្ដុះបណ្ដាលអ្នកប្រកបវិជ្ជាជីវៈអាជីពដែលនឹងអនុវត្តបទបញ្ញត្តិច្បាប់ (សូមមើលអនុសាសន៍ទី ១)។ របាយការណ៍របស់យើងផ្នែកនេះ បង្ហាញជូនអំពីអនុសាសន៍ទូទៅទាក់ទងជាមួយស្មុំកូនក្នុងប្រទេសផង និងអន្តរជាតិផង។ ផ្នែកនេះរៀបរាប់លម្អិតអំពីស្មុំកូនក្នុងប្រទេស និងស្មុំកូនអន្តរជាតិផងដែរ។

116 បុព្វកថានៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩៩៣
117 មាត្រា ២១ នៃ UNCRC
118 សូមមើល ០។

# អនុសាសន៍ទី ១៣

## ពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុងរវាងក្រសួងនានាដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនជាពិសេស គឺក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌

**ST** កែលម្អកិច្ចសហប្រតិបត្តិការផ្នែកស្ថាប័នតាមរយៈការបណ្ដុះបណ្ដាលពហុវិស័យបន្ថែមទៀត។
ចាត់តាំងឱ្យមានចៅក្រមមួយរូបនៅក្នុងតំបន់នីមួយៗ ដែលដើរតួនាទីជាជនបង្គោលសម្រាប់បញ្ហាសុំកូន។

**MT** ពិចារណាលើការផ្ដល់ការព្រមព្រៀងចំពោះអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៦១ ស្ដីពីនីត្យានុកូលកម្មឯកសារ (Apostille)

**LT** ពង្រឹងកិច្ចសហប្រតិបត្តិការតាមរយៈគណៈកម្មាធិការជាតិការពារកុមារ។

អាជ្ញាធរផ្សេងៗជាច្រើនជាប់ពាក់ព័ន្ធនៅក្នុងនីតិវិធីសុំកូន។ ដើម្បីធានាឱ្យមានការពិចារណាលើឧត្តមប្រយោជន៍របស់កុមារជាការសំខាន់ខ្លាំងណាស់ដែលអាជ្ញាធរ ស្ថាប័ន អ្នកប្រកបវិជ្ជាជីវៈអាជីពទាំងអស់ មានការសម្របសម្រួល និងសហប្រតិបត្តិការគ្នាល្អនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ។

មានឧទាហរណ៍យ៉ាងច្បាស់លាស់ស្ដីអំពីកិច្ចសហប្រិតបត្តិការរវាងក្រសួងផ្សេងៗរបស់កម្ពុជា ដូចជាសិក្ខាសិលារៀបចំឡើងដោយក្រសួង ស.អ.យ ក្រោយពេលបេសកកម្មរបស់ក្រុមស្រាវជ្រាវ និងការធ្វើបទបង្ហាញស្ដីពីសេចក្ដីពន្យល់អំពីសុំកូនក្នុងប្រទេស។ ទោះយ៉ាងណាក្ដី កិច្ចខិតខំទាំងអស់នេះចាំបាច់ត្រូវពង្រឹងបន្ថែម ហើយកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នក្នុងប្រទេសកម្ពុជាត្រូវបានកែលម្អឡើងបន្ថែមទៀត។ ដោយឡែក សុំកូនក្នុងប្រទេសមិនគួរត្រូវបានមើលឃើញថាជាបញ្ហាសម្រាប់តែក្រសួងយុត្តិធម៌ ឯសុំកូនអន្តរប្រទេសជាបញ្ហាសម្រាប់តែក្រសួង ស.អ.យ នោះទេ។ ក្រុមការងារសូមផ្ដល់អនុសាសន៍ថា សម្រាប់រយៈពេលខ្លី គួរមានការលម្អបន្ថែមទៀតទៅលើការយល់ឃើញស្ដីពីការបែងចែកការទទួលខុសត្រូវ និងវិធីសាស្ត្រនៃការធ្វើការងារនេះ។ ក្រសួងទាំងពីរមានសំឡេងយ៉ាងសំខាន់ក្នុងអំឡុងដំណាក់កាលជាច្រើននៃនីតិវិធីសុំកូន។ ដោយឡែក ការប្រកាសអំពីលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបានរបស់កុមារ និងសេចក្ដីសម្រេចអំពីសុំកូន ( ទាំងកម្រិតជាតិ និងអន្តរប្រទេស )។ ក្រសួង ស.អ.យ គឺនៅជិតបំផុតជាមួយកុមារ ហើយគួររៀបចំព័ត៌មានសារំតាទាំងអស់ សម្រាប់សេចក្ដីសម្រេចដ៏មានសារៈសំខាន់ទាំងអស់នេះ ចំណែកចៅក្រមក្នុងនាមជាអាជ្ញាធរឯករាជ្យ និងមានគុណវុឌ្ឍិគ្រប់គ្រាន់ ត្រូវធ្វើការសម្រេចស្ថាពរទាំងអស់ផ្អែកលើព័ត៌មាន និងការប្រឹក្សាយោបល់ដែលផ្ដល់ដោយក្រសួង ស.អ.យ។

យើងខ្ញុំសូមផ្តល់អនុសាសន៍ឱ្យមានវគ្គបណ្តុះបណ្តាលរួមគ្នាបន្ថែមទៀតជាមួយអាជ្ញាធរ ក្រសួង ស.អ.យ ដោយក្នុងនោះរួមមានទាំងបុគ្គលិក និងចៅក្រមដែលនឹងត្រូវរៀបចំឡើងដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធនានា ដូចជាក្រសួងសុខាភិបាលជាដើម។ សកម្មភាពរួមគ្នាទាំងនេះ អាចផ្តល់ឱកាសឱ្យអាចមើលឃើញពីចម្ងាយ និងទស្សនៈវិស័យព្រមទាំងអនុញ្ញាតឱ្យអាចប្រៀបធៀបរវាងប្រព័ន្ធផ្សេងៗគ្នានៃគុណតម្លៃ និងវប្បធម៌នៃការប្រកបវិជ្ជាជីវៈអាជីព។ ការរៀបចំសកម្មភាពរួមគ្នាអាចលើកទឹកចិត្តឱ្យមានអន្តរទំនាក់ទំនងរវាងចៅក្រម និងបុគ្គលិកជាអាជ្ញាធរទទួលខុសត្រូវលើការងារសុំកូន។ ការអនុវត្តបែបនេះអាចបានទទួលផ្លែផ្កា និងលើកកម្ពស់ការវាយតម្លៃកាន់តែឆាប់រហ័សថែមទៀតលើសំណុំឯកសារ ដែលត្រូវបានឃាត់ទុកគ្រាន់តែដោយសារមានទស្សនៈយល់ឃើញខុសគ្នាប៉ុណ្ណោះ (សូមមើលអនុសាសន៍ទី ៣៖ ការបណ្តុះបណ្តាល)។

សម្រាប់រយៈពេលខ្លី អ្នកតំណាងរបស់ក្រសួងទាំងពីរ គឺក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌អាចអាន និងផ្តល់យោបល់លើរបាយការណ៍នេះ ចូលរួមក្នុងការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាតុមូលអំពីឯកសារនេះ ហើយព្រមព្រៀងគ្នាលើផែនការសកម្មភាពរួមគ្នាមួយ។

សម្រាប់រយៈពេលខ្លី យើងប្រមើលមើលឃើញថា ក្រសួងយុត្តិធម៌ចាត់តាំងឱ្យមានចៅក្រមមួយក្រុមតូច ដើម្បីធ្វើជាជនបង្គោលលើបញ្ហាសុំកូននៅរាជធានី និងនៅតាមតំបន់ផ្សេងៗ។ ចៅក្រមទាំងអស់នេះអាចបានទទួលការបណ្តុះបណ្តាលពិសេសស្តីអំពីសុំកូនក្នុងប្រទេស។ អត្ថប្រយោជន៍មួយនៃប្រព័ន្ធនេះ គឺដើម្បីបន្ថយសក្តានុពលនៃការអនុវត្តខុសច្បាប់ឱ្យនៅទាបបំផុតជាអប្បបរមា ក្នុងនោះរួមទាំងការបន្លំឯកសារដែលជាកង្វល់បន្តកើតមានសម្រាប់ភាគីពាក់ព័ន្ធជាច្រើន។ មនុស្សមួយចំនួនបានកត់សម្គាល់ឃើញថា វិធីមួយដែលអាចធ្វើបាន ដើម្បីជម្នះលើបញ្ហាការបន្លំឯកសារ គឺឱ្យរដ្ឋាភិបាលពិចារណាក្នុងការផ្តល់ការព្រមព្រៀងទៅលើអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៦១ ស្តីពីនីត្យានុកូលកម្មឯកសារ (Apostille)។[119]

សម្រាប់រយៈពេលមធ្យម/វែង គណៈកម្មធិការជាតិសម្រាប់កុមារ (សូមមើល១) អាចជាស្ថាប័នគន្លឹះ ដើម្បីកែលម្អកិច្ចសហប្រតិបត្តិការរវាងក្រសួងនានា។ ឧ. នៅប្រទេស Lithuani មានក្រុមប្រឹក្សាប្រហាក់ប្រហែលគ្នានេះដែរ (រួមមានសមាសភាពអនុរដ្ឋមន្ត្រីក្រសួងសន្តិសុខសង្គម និងការងារ ក្រសួងអប់រំ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការផ្ទៃក្នុង និងក្រសួងសុខាភិបាល ក៏ដូចជាអ្នកតំណាងរបស់ NGOs) ដែលបានជួយពង្រឹងកិច្ចសហប្រតិបត្តិការ និងសកម្មភាពសម្របសម្រួល។[120]

119 សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ www.hcch.net/en/instruments/specialised-sections/apostille

120 ក្រិត្យចុងក្រោយបំផុតរបស់រដ្ឋមន្ត្រីក្រសួងសន្តិសុខសង្គម និងការងារ៖ https://e-seimas.lrs.lt/portal/legalAct/lt/TAD/df71a8a066e511e5b316b7e07d98304b?jfwid=-ji9gt26lu សមាជិកនៃគណកម្មាធិការនេះ មានអនុរដ្ឋមន្ត្រីនៃក្រសួងសន្តិសុខសង្គម និងការងារ ក្រសួងអប់រំ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការផ្ទៃក្នុង អ្នកតំណាងមកពីស្ថាប័នសាធារណៈដទៃទៀត ដូចជានាយកដ្ឋានគ្រួសារ និងសហគមន៍សេវាការពារកុមារ និងសុំកូនរបស់រដ្ឋ និងសេវាការពារសិទ្ធិកុមារថ្នាក់ក្រុង អ្នកតំណាងសភាសិស្ស ការិយាល័យពលរដ្ឋរបស់កុមារ អ្នកតំណាងរបស់ NGO ចំនួន ៦ (ឧទាហរណ៍ អង្គការសង្គ្រោះកុមារ។ល។)។ សម្រាប់ព័ត៌មានអំពីសកម្មភាព និងពិធីសារ៖ http://www.socmin.lt/lt/veikla/tarybos/tarpzinybine-vaiko-geroves-komisija.html

អនុសាសន៍ទី
១៣

# ពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុងរវាងក្រសួងនានាដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូន ជាពិសេសគឺក្រសួង ស.អ.យ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| គោលម្ការកិច្ចសហប្រតិបត្តិការផ្នែកស្ថាប័នឱ្យកាន់តែប្រសើរថែមទៀត | ១ ផ្សព្វផ្សាយរបាយការណ៍ជូនទៅដល់ក្រសួងពាក់ព័ន្ធ។<br>២ រៀបចំកិច្ចប្រជុំតុមូល ដើម្បីពិភាក្សាលើរបាយការណ៍ និងព្រមព្រៀងគ្នាលើផែនការសកម្មភាពរួមមួយ។ | ក្រសួង ស.អ.យ<br>ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ។ | UNICEF | ២០១៨ |
| ការបណ្តុះបណ្តាលពហុវិស័យ | ១ រៀបចំធ្វើវគ្គបណ្តុះបណ្តាលរួមគ្នាជាមួយក្រសួង ស.អ.យ អាជ្ញាធរបុគ្គលិក ថៅក្រម និងក្រសួងពាក់ព័ន្ធទៅលើផែនការសកម្មភាព។<br>២ ធ្វើវគ្គបណ្តុះបណ្តាលរួមគ្នាប្រចាំឆ្នាំជាមួយក្រសួងពាក់ព័ន្ធ និងអ្នកផ្តល់សេវាដទៃទៀតស្តីពីអាទិភាពដែលបានព្រមព្រៀងគ្នា។ | ក្រសួង សអយ<br>ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ។ | UNICEF, 3PC and FCF | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ចៅក្រមឯកទេសសម្រាប់បញ្ហាសុំកូន | ១ ចាត់តាំងចៅក្រមមួយក្រុមតូចឱ្យក្លាយជាជនបង្គោលសម្រាប់សុំកូនថ្នាក់ជាតិ។<br>២ ការបណ្តុះបណ្តាលចៅក្រមជាជនបង្គោលនៅក្នុងវិស័យនានា ដូចជាការថែទាំជំនួស សុំកូនក្នុងប្រទេស និង ICA។ | ក្រសួងយុត្តិធម៌។ | MoSVY, UNICEF, 3PC and FCF | ២០១៩ តទៅ |
| កាត់បន្ថយសក្ខានុពលសម្រាប់ការអនុវត្តខុសច្បាប់ | ១ សិក្ខាសិលាស្តីពីអត្ថប្រយោជន៍នៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៦១ ស្តីពីនីត្យានុកូលកម្មឯកសារ (Apostille)។<br>២ ពិចារណាលើជំហានដើម្បីឈានទៅដល់ការព្រមព្រៀងលើអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៦១ ស្តីពីនីត្យានុកូលកម្មឯកសារ (Apostille)។ | ក្រសួងពាក់ព័ន្ធទាំងអស់។ | HCCH | ២០២០ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ផ្តល់សិទ្ធិអំណាចដល់គណៈកម្មាធិការជាតិការពារកុមារ | ១ កិច្ចព្រមព្រៀងក្នុងចំណោមក្រសួងទាំងអស់ស្តីអំពីតួនាទីរបស់គណៈកម្មាធិការ។<br>២ បង្កើត អនុស្សារណៈយោគយល់ /កំណត់សម្គាល់ក្រសួងស្តីពីតួនាទីរបស់គណៈកម្មាធិការ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ។ | ក្រសួងពាក់ព័ន្ធទាំងអស់។ | Commission, UNICEF | ២០២៣ តទៅ |

# អនុសាសន៍ទី ១៤

## បង្កើតលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ ដើម្បីកំណត់ឱ្យជាសុំកូនក្នុងប្រទេស ឬសុំកូនអន្តរប្រទេស (លំនៅដ្ឋានជាប្រចាំ)

**ST**

កំណត់និយមន័យថាតើពេលណាទើបជនបរទេសត្រូវបានចាត់ទុកថា ជាអ្នកតាំងលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា។

ផ្សព្វផ្សាយជាសាធារណៈអំពីការតម្រូវនានា ដើម្បីកំណត់ថាតើ PAPs បរទេស អាចសុំកូន ឬមិនអាចសុំកូនក្នុងប្រទេសកម្ពុជា រួមទាំងការហាមឃាត់ប្រឆាំង PAPs បរទេសទាំងឡាយណាដែលពុំមែនជាអ្នកតាំងលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា មិនឱ្យសុំកូនក្នុងប្រទេស។ រដ្ឋទទួល មិនគួរទទួលស្គាល់សុំកូនប្រភេទនេះឡើយ។

ការបណ្តុះបណ្តាលចៅក្រម និងអាជ្ញាធរជាពិសេសនៅថ្នាក់មូលដ្ឋាន។

ការសិក្សាទៅលើលទ្ធភាពនៃការមានលំនៅដ្ឋាន "ជាប្រចាំ" ជាកត្តាតភ្ជាប់នៅក្នុងការសម្រេចចិត្តថា តើសុំកូននោះជាសុំកូនក្នុងប្រទេស ឬអន្តរប្រទេស (ដែលផ្ទុយនឹងលំនៅ "អចិន្ត្រៃយ៍") ក្នុងច្បាប់។

**MT**

បន្តការបណ្តុះបណ្តាលចៅក្រម។

ជាការសំខាន់ណាស់ដែលត្រូវកំណត់ថា តើសុំកូននោះជាសុំកូនក្នុងប្រទេស ឬសុំកូនអន្តរប្រទេស ព្រោះថានីតិវិធីសុំកូនមួយចំនួនមានលក្ខណៈខុសប្លែកគ្នា។ ចំណុចនេះ មានភាពពាក់ព័ន្ធជាពិសេសក្នុងករណីដែលជនបរទេសរស់ក្នុងប្រទេសកម្ពុជា ហើយដំណើរការសុំកូនក្នុងប្រទេស។ ឧ. លំនៅជាប្រចាំរបស់ PAP នឹងមានវិបាកជាក់លាក់ សម្រាប់ពួកគេដោយសារលំនៅនេះនឹងជួយកំណត់ថា តើពួកគេគួរដាក់ពាក្យនៅទីណា ហើយរដ្ឋនឹងវាយតម្លៃថា តើពួកគេមានភាពសមស្រប និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីសុំកូនឬទេ។

យោងតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣ សុំកូនមួយត្រូវបានចាត់ទុកថា ជាសុំកូនអន្តរប្រទេស ពេលដែលកុមារ និង PAPs មានលំនៅដ្ឋានជាប្រចាំក្នុងរដ្ឋចុះកិច្ចសន្យាផ្សេងគ្នា។ អនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣ ពុំដាក់បញ្ចូលវិធាន ដើម្បីកំណត់ នៅពេលលក្ខខណ្ឌសម្រាប់លំនៅដ្ឋានជាប្រចាំមានវត្តមាននោះឡើយ។ ផ្ទុយទៅវិញ លំនៅដ្ឋានជាប្រចាំ គឺជា "សំណួរអំពីអង្គហេតុ" សម្រាប់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាលរបស់រដ្ឋមួយក្នុងការសម្រេច។ លំនៅដ្ឋានជាប្រចាំតាមធម្មតាត្រូវបានចាត់ទុកថា ជាទស្សនាទានបែបអង្គហេតុជាក់ស្តែង ដោយបញ្ជាក់អំពីប្រទេសដែលក្លាយជាចំណុចត្រូវផ្តោតការយកចិត្តទុកដាក់នៃជីវិតក្នុងប្រទេស និងជីវិតវិជ្ជាជីវៈរបស់បុគ្គល។[121] ប្រទេសដែលត្រូវបានតម្រូវឱ្យអនុលោមតាមកាតព្វកិច្ចជាច្រើន ដែលត្រូវបានកំណត់ដោយវិធានរបស់អនុសញ្ញា ដូចជាការត្រៀមរៀបចំរបាយការណ៍ ដែលតម្រូវដោយមាត្រា ១៥ និង ១៦ (ផ្ទុយពីប្រទេសនៃសញ្ជាតិរបស់ជននោះដែលប្រហែលជាពុំមានលទ្ធភាពធ្វើការងារនេះបាន)។

ច្បាប់ស្តីពីសុំកូនអន្តរប្រទេស កំណត់និយមន័យសុំកូនអន្តរប្រទេសថា ជាសុំកូនផ្អែកលើលំនៅអចិន្ត្រៃយ៍របស់កុមារ និង PAPs។[122] សេចក្តីពន្យល់ពីសុំកូនក្នុងប្រទេសឆ្នាំ ២០១៦ បកស្រាយបញ្ជាក់ថា សុំកូនក្នុងប្រទេសអាចត្រូវបានអនុវត្តតែចំពោះជនបរទេសទាំងឡាយណាដែលកំពុងរស់នៅក្នុងប្រទេស

121 សូមមើលមគ្គុទេសក៍អំពីការអនុវត្តល្អលេខ ១ វាក្យខ័ណ្ឌ ៤៩០។ PAPs ច្រើនតែត្រូវបានចាត់ទុកថា មានលំនៅដ្ឋានជាប្រចាំនៅក្នុងប្រទេសមួយផ្អែកលើ៖ បរិមាណពេលវេលាដែលពួកគេបានរស់នៅក្នុងរដ្ឋនោះ នៅពេលពួកគេមានកិច្ចសន្យាការងារមានរយៈពេលមិនកំណត់នៅក្នុងរដ្ឋនោះ និងចេតនារបស់ពួកគេក្នុងការបន្តរស់នៅក្នុងរដ្ឋនោះ សម្រាប់រយៈពេលដែលអាចប្រមើលមើលឃើញបានទៅអនាគត។

កម្ពុជា ហើយដែលត្រូវបានទទួលស្គាល់ដោយច្បាប់កម្ពុជាថាជា “អ្នកតាំងលំនៅអចិន្ត្រៃយ៍”។ ទោះយ៉ាងណាក្ដី ពុំមានការបកស្រាយបញ្ជាក់ស្ដីអំពីរបៀបកំណត់និយមន័យ “អ្នកតាំងលំនៅអចិន្ត្រៃយ៍” នៅក្នុងសេចក្ដីពន្យល់នោះឡើយ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺច្បាប់ស្ដីពីសញ្ជាតិចែងថា ជនបរទេសអាចទទួលបានសញ្ជាតិជាពលរដ្ឋកម្ពុជា ក្រោយពេលតាំងលំនៅរយៈពេល ៣ ឆ្នាំ ឬ ៧ ឆ្នាំជាប់ៗគ្នា អាស្រ័យទៅតាមករណី (ឬក្នុងករណីលើកលែងមួយចំនួន ដោយពុំមានកាលកំណត់រយៈពេល)។

បច្ចុប្បន្ននេះ ជនបរទេសមួយចំនួនដែលពុំមែនជាអ្នកតាំងលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា យកកុមារទៅនៅក្រោមការថែទាំរបស់ខ្លួន ហើយមួយរយៈក្រោយមកក៏ដាក់ពាក្យទៅកាន់តុលាការដើម្បីសុំកុមារនោះ តាមរយៈសុំកូនក្នុងប្រទេស។ សុំកូននេះត្រូវបានធ្វើឡើងដោយពុំគោរពតាមនីតិវិធីដែលមានចែងនៅក្រោមច្បាប់កម្ពុជាឡើយ។ ហេតុនេះ កម្រមានព័ត៌មានដើម្បីបង្ហាញថា តើកុមារត្រូវបានកំណត់ថា ជាកុមារមានតម្រូវការសុំកូនដោយវិធីណា ការចូលរួម/ការយល់ព្រមរបស់គ្រួសារកំណើត និងការផ្គូផ្គង។ល។ បន្ថែមលើនេះទៀត មានក្ដីបារម្ភអំពីការមិនស្គាល់ប្រភពកំណើតរបស់កុមារ និងភាពត្រឹមត្រូវនៃឯកសារ។ ចំណុចនេះបង្កឱ្យមានបញ្ហាយ៉ាងធ្ងន់ធ្ងរ។

សម្រាប់រយៈពេលខ្លី រដ្ឋាភិបាលគួរកំណត់ឱ្យបានច្បាស់លាស់ថា តើពេលណាទើបជនបរទេសត្រូវបានចាត់ទុកថាជាអ្នកតាំងលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា។

បទបញ្ញត្តិថ្មីៗនៅក្នុងសេចក្ដីពន្យល់ឆ្នាំ ២០១៦ ហាមឃាត់ PAPs ជាជនបទេសអ្នកតាំងលំនៅមិនអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា មិនឱ្យសុំកូនក្នុងប្រទេស។ សេចក្ដីពន្យល់នេះផ្ដល់ឧបករណ៍ដ៏ចាំបាច់ ដើម្បីចៀសវាងករណីនៃសុំកូនក្នុងប្រទេសដោយជនបរទេសដែលពុំតាំងលំនៅជាប្រចាំក្នុងប្រទេសកម្ពុជា។ គោលនយោបាយថ្មីនេះ គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈយ៉ាងច្បាស់លាស់ដោយអាជ្ញាធរថ្នាក់ខ្ពស់ ដោយសង្កត់ធ្ងន់លើតម្រូវការក្នុងការបញ្ឈប់ការអនុវត្តនេះ។ បន្ថែមលើនេះទៀត អាជ្ញាធររបស់រដ្ឋជាសញ្ជាតិរបស់ជននោះ និង/ឬជាលំនៅដ្ឋានជាប្រចាំរបស់ PAPs មិនគួរទទួលស្គាល់សេចក្ដីសម្រេចសុំកូនក្នុងប្រទេសដែលត្រូវបានធ្វើឡើង ដោយមិនគោរពតាមនីតិវិធីសមស្របក្នុងប្រទេសកម្ពុជាឡើយ។ ស្ថានទូតបរទេសនានាគួរអនុវត្តយុទ្ធវិធីរួមគ្នាទាក់ទងជាមួយករណីបែបនេះ។

យោងតាមសេចក្ដីពន្យល់ឆ្នាំ ២០១៦ ជនបរទេសដែលស្នាក់នៅបណ្ដោះអាសន្ន ឬមានលំនៅដ្ឋានជាប្រចាំក្នុងប្រទេសកម្ពុជា ហើយចង់សុំកុមារកម្ពុជា គួរសុំតាមរយៈសុំកូនអន្តរប្រទេស (គោរពតាមច្បាប់ស្ដីពីសុំកូនអន្តរប្រទេស) ព្រោះថាអាចមានលទ្ធភាពដែលកុមារនោះត្រូវរើសចេញពីប្រទេសកម្ពុជា។ វិធានចុងក្រោយនេះ គឺផ្ទុយពីអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣ ដែលកម្ពុជា គឺជារដ្ឋភាគីមួយដោយហេតុថា សុំកូនមិនអាចត្រូវបានចាត់ទុកថាជាសុំកូនអន្តរប្រទេសទេ ប្រសិនបើ PAPs និងកុមារមានលំនៅដ្ឋានជាប្រចាំនៅក្នុងប្រទេសដូចគ្នា ពោលគឺក្នុងប្រទេសកម្ពុជា។ ជនបរទេសដែលមានលំនៅដ្ឋានជាប្រចាំក្នុងប្រទេសកម្ពុជាគួរតែអាចដាក់ពាក្យសុំកូនបាន តាមរយៈនីតិវិធីសុំកូនក្នុងប្រទេស។ សុំកូនទាំងអស់នេះ មិនគួរត្រូវបានដំណើរការក្នុងលក្ខណៈជាសុំកូនអន្តរប្រទេសឡើយ។

ដោយឡែក វិធាននេះអាចមានសក្ដានុពលក្លាយជាបញ្ហា ព្រោះថារដ្ឋទទួលជាច្រើនមិនស្ថិតក្នុងជំហរ ដើម្បីសម្រេចចិត្តលើលក្ខណៈសម្បត្តិ និងភាពសមស្របនៃ PAPs ដែលពុំតាំងលំនៅជាប្រចាំនៅក្នុងរដ្ឋរបស់ខ្លួនឡើយ។ ហេតុនេះ រដ្ឋទទួលពុំត្រូវបានអនុញ្ញាតដោយច្បាប់របស់ខ្លួន ដើម្បីចូលរួមក្នុងនីតិវិធីសុំកូនឡើយ។ សេចក្ដីពន្យល់មិនគួរធ្វើនិយ័តកម្មលើបញ្ហាដែលពុំស្ថិតនៅក្រោមយុត្តាធិការកម្ពុជាឡើយ។ គួរវិសោធនកម្មទៅលើសេចក្ដីពន្យល់ ដើម្បីចៀសវាងការផ្ដល់ការរំពឹងទុកខុសឆ្គងដល់ PAPs និងបង្កើតបញ្ហាសម្រាប់កុមារដែលត្រូវបានសុំទៅចិញ្ចឹម។ ដើម្បីទប់ស្កាត់ ការប្រើប្រាស់ខុសឆ្គងជាសក្ដានុពលការតម្រូវដូចគ្នានេះ គួរមានចែងប្រាប់ជនបរទេស ដែលតាំងលំនៅក្នុងប្រទេសកម្ពុជាជាអ្នកដាក់ពាក្យសុំការអនុម័តជាគ្រួសារធម៌។

| 122 មាត្រា ៣។

មានវិបាកមួយទៀតនៃវិធានដែលបានលើឡើងខាងលើ គឺថា PAPs ជាជនបរទេសមួយចំនួន ដែលមានលំនៅដ្ឋានជាប្រចាំយូរអង្វែងក្នុងប្រទេសកម្ពុជា ពុំអាចដាក់ពាក្យសុំកូនក្នុងប្រទេសបាន (ហាមឃាត់ដោយសេចក្តីពន្យល់) និងពុំអាចសុំកូនអន្តរប្រទេសបាន (ដោយសារពួកគេពុំត្រូវបានចាត់ទុកថា តាំងលំនៅជាប្រចាំក្នុងរដ្ឋដែលខ្លួនជាសញ្ជាតិ ហើយរដ្ឋដែលខ្លួនជាសញ្ជាតិប្រហែលជា/ពុំមានឆន្ទៈអនុញ្ញាតចំពោះសុំកូននោះ ព្រោះនឹងធ្វើឱ្យមានទំនាស់ជាមួយកាតព្វកិច្ចជាច្រើន ដែលកំណត់ដោយវិធានរបស់អនុសញ្ញា)។ ចំណុចនេះអាចក្លាយជាគុណវិបត្តិសម្រាប់កុមារមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបាន ដោយហេតុថា PAPs ស្គាល់ប្រទេសកម្ពុជា វប្បធម៌កម្ពុជា និងបែបបទក្នុងប្រទេសកម្ពុជា។ ហេតុនេះ ពួកគេអាចផ្តល់ការថែទាំកាន់តែប្រសើរចំពោះកុមារ។ ប្រទេសកម្ពុជាគួរសិក្សារកវិធី ដើម្បីធានាឱ្យបានថា PAPs ដែលតាំងលំនៅជាប្រចាំក្នុងប្រទេសកម្ពុជាអាចដាក់ពាក្យសុំកូនក្នុងប្រទេស ដោយមានវត្តមានវិធានការការពារសព្វគ្រប់ជ្រុងជ្រោយ (សូមមើល២០)។

សម្រាប់រយៈពេលមធ្យម ជាការសំខាន់ណាស់ ដែលត្រូវបណ្តុះបណ្តាលចៅក្រម និងអាជ្ញាធរ ព្រមទាំងស្ថាប័នដទៃទៀត ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនស្តីអំពីពេលណាដែលត្រូវចាត់ទុកសុំកូនមួយជាសុំកូនក្នុងប្រទេស ឬសុំកូនអន្តរប្រទេស។ ចៅក្រមក្នុងមូលដ្ឋាន និងអាជ្ញាធរប្រហែលជាពុំបានដឹងអំពីអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៩៣ ហើយអាចដំណើរការសុំកូនអន្តរប្រទេសទៅជាសុំកូនថ្នាក់ជាតិ ឬបញ្ច្រាសមកវិញ។ ការបណ្តុះបណ្តាលនឹងអាចជួយទប់ស្កាត់ករណីបែបនេះបាន។

ក្រុមស្រាវជ្រាវសូមផ្តល់អនុសាសន៍ថា សម្រាប់រយៈពេលខ្លី ប្រទេសកម្ពុជាគួរកំណត់ថា តើសុំកូនគឺជាសុំកូនក្នុងប្រទេស ឬអន្តរប្រទេស ដោយផ្អែកលើលំនៅដ្ឋានជាប្រចាំ (និងពុំមែនជាលំនៅដ្ឋានអចិន្ត្រៃយ៍) របស់កុមារ និង PAPs។ ដូចគ្នានេះដែរ ក្នុងប្រទេសកម្ពុជាគួរសិក្សាលទ្ធភាពនៃការផ្លាស់ប្តូរច្បាប់របស់ខ្លួន ដែលនឹងធានាថា អនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣ ត្រូវបានគោរពតាមយ៉ាងត្រឹមត្រូវទាក់ទងជាមួយចំណុចនេះ។

## អនុសាសន៍ទី ១៤

# បង្កើតលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ ដើម្បីកំណត់ឱ្យជាសុំកូនក្នុងប្រទេស ឬសុំកូនអន្តរប្រទេស (លំនៅដ្ឋានជាប្រចាំ)

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| កំណត់និយមន័យ និងការតម្រូវសម្រាប់ការតាំងលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា | ១ កំណត់និយមន័យថា តើពេលណាដែលជនបរទេសត្រូវបានចាត់ទុកថាជាអ្នកតាំងលំនៅអចិន្ត្រៃយ៍។<br>២ ចែករំលែកផ្នែកនៃរបាយការណ៍នេះរបស់យើងជាមួយស្ថានទូតបរទេស។<br>៣ ផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីពន្យល់ឆ្នាំ២០១៦ ដែលហាមឃាត់ PAPs ជនបរទេសតាំងលំនៅពុំមែនអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជាមិនឱ្យសុំកូនក្នុងប្រទេស។<br>៤ ជម្រាបព័ត៌មាន និងបណ្តុះបណ្តាលដល់ស្ថានទូតបរទេស និងអ្នកផ្តល់សេវាដទៃទៀតអំពីបទបញ្ញត្តិថ្មី និងនិយមន័យ។ | ក្រសួងយុត្តិធម៌<br>ក្រសួង ស.អ.យ<br>ក្រសួងការបរទេស។ | UNICEF | ២០១៨ |
| ធ្វើវិសោធនកម្មលើសេចក្តីពន្យល់ | ១ ជួបជាមួយអ្នកដើរតួនាទីពាក់ព័ន្ធ ដើម្បីពិចារណា/ព្រមព្រៀងគ្នាថា ការតម្រូវដូចគ្នាសម្រាប់ជនបរទេសតាំងលំនៅក្នុងប្រទេសកម្ពុជា គឺត្រូវអនុវត្តចំពោះអ្នកដែលដាក់ពាក្យ ដើម្បីសុំការអនុម័តជាគ្រួសារធម៌។ | ក្រសួងយុត្តិធម៌<br>ក្រសួង សអយ។ | UNICEF | ២០១៨ |
| ការបណ្តុះបណ្តាលចៅក្រម និងអាជ្ញាធរ | ១ បង្កើតវគ្គបណ្តុះបណ្តាលជាប្រចាំក្នុងរាជធានីស្តីពីនីតិវិធីសុំកូន។<br>២ ចាប់អនុវត្តវគ្គបណ្តុះបណ្តាលនៅថ្នាក់តំបន់។ | ក្រសួង សអយ<br>ក្រសួងយុត្តិធម៌។ | UNICEF, HCCH and ISS | ២០១៨ តទៅ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការបណ្តុះបណ្តាលបន្តសម្រាប់ចៅក្រម និងអាជ្ញាធរ | ១ ការអនុវត្តវគ្គបណ្តុះបណ្តាលជាប្រចាំ ដែលត្រូវបានបង្កើតឡើងនៅក្នុងរយៈពេលខ្លី។ | ក្រសួង ស.អ.យ ក្រសួងយុត្តិធម៌។ | UNICEF, HCCH and ISS | ២០១៩ តទៅ |
| សិក្សាលទ្ធភាពនៃការមានលំនៅដ្ឋាន «ជាប្រចាំ» ក្នុងន័យផ្ទុយពីការតាំងលំនៅ «ជាអចិន្ត្រៃយ៍» ។ នៅក្នុងច្បាប់ ដើម្បីកំណត់ជា ICA | ១ សិក្សាករណីសុំកូន ដែលត្រូវបានអនុញ្ញាតផ្អែកលើ «លំនៅដ្ឋានជាអចិន្ត្រៃយ៍» ដើម្បីពិនិត្យមើលថា តើមានដែនកំណត់ណាមួយឬទេ។<br>២ ស្វែងរកការចង្អុលបង្ហាញ/ជំនួយបច្ចេកទេសបន្ថែមទៀត ស្តីពីអត្ថប្រយោជន៍នៃការប្រើប្រាស់ «ការតាំងលំនៅជាប្រចាំ»។<br>៣ ប្រសិនបើលំនៅដ្ឋានជាប្រចាំត្រូវបានព្រមព្រៀងថា មានអត្ថប្រយោជន៍ជាង ត្រូវពិនិត្យមើលលទ្ធភាពក្នុងការធ្វើការកែប្រែផ្នែកច្បាប់អនុលោមតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣។ | ក្រសួង សអយ ក្រសួងយុត្តិធម៌។ | UNICEF, HCCH and ISS | ២០២០-២០២៣ |

# អនុសាសន៍ទី

# ១៩

## ប្រកាសលក្ខណៈសម្បត្តិដែលអាចដាក់សុំយកកុមារទៅចិញ្ចឹមបាន ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ និងនៅមុនពេលការផ្គូផ្គងត្រូវបានធ្វើឡើង

**ST** បង្កើត និងអនុវត្តលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ ដើម្បីប្រកាសលក្ខណៈសម្បត្តិអាចដាក់ពាក្យឱ្យសុំកុមារបាន (ផ្នែកច្បាប់ ចិត្តសង្គម និងវេជ្ជសាស្ត្រ)។

ព្រមព្រៀងគ្នាអំពីថាតើនរណានឹងសម្រេចលើភាពអាចដាក់ឱ្យសុំកុមារ បាន និងបង្កើតនីតិវិធីច្បាស់លាស់សម្រាប់ការប្រកាសថាកុមារមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំបាន។

**MT** បណ្តុះបណ្តាលអ្នកជំនាញដែលនឹងចូលរួមក្នុងការប្រកាសលក្ខណៈសម្បត្តិអាចដាក់ពាក្យឱ្យសុំកុមារបាន។

**LT** អនុវត្តគម្រោងសាកល្បងនៅក្នុងខេត្តមួយចំនួន។

កុមារទាំងឡាយណាដែលអាចសុំយកទៅចិញ្ចឹមបាន ជាដំបូងគួរត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន។ ការប្រកាសអំពីលក្ខណៈសម្បត្តិអាចសុំកុមារទៅចិញ្ចឹមបាន គឺជាធាតុផ្សំគន្លឹះមួយ ដើម្បីធានាឱ្យបានថាការសុំកុមារទៅចិញ្ចឹម គឺធ្វើឡើងដើម្បីឧត្តមប្រយោជន៍របស់កុមាររូបនោះ។ ការសុំកុមារទៅចិញ្ចឹមគួរតែផ្អែកលើលក្ខណៈវិនិច្ឆ័យផ្នែកច្បាប់ក៏ដូចជាទិដ្ឋភាពផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងសង្គមផងដែរ។ លក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបានគួរត្រូវបានប្រកាសមិនថាកុមារនោះនឹងត្រូវសុំយកទៅចិញ្ចឹមនៅក្នុងប្រទេស ឬអន្តរប្រទេសក្តី (ថ្វីបើអាចមានលក្ខណៈវិនិច្ឆ័យបន្ថែមត្រូវអនុវត្តចំពោះសុំកូនអន្តរប្រទេសក្តី)។

ក្រមរដ្ឋប្បវេណី (មាត្រា ១០១០) និងច្បាប់ស្តីពីសុំកូនអន្តរប្រទេស (ជំពូកទី IV) បង្កើតលក្ខខណ្ឌវិនិច្ឆ័យផ្នែកច្បាប់មួយចំនួន ដើម្បីកំណត់លក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបានរបស់កុមាររួមទាំងរបៀបធ្វើយ៉ាងណា ដើម្បីទទួលបានការព្រមព្រៀងពីកុមារ (ពេលដែលអាចធ្វើបាន) និងពីឪពុកម្តាយបង្កើត ឬអាជ្ញាធរ និងស្ថាប័នដទៃទៀត។ លក្ខខណ្ឌវិនិច្ឆ័យទាំងនេះ ក៏ត្រូវអនុវត្តចំពោះសុំកូនក្នុងប្រទេសផងដែរ។[123] ច្បាប់ស្តីពីសុំកូនអន្តរប្រទេសតម្រូវឱ្យសំណុំឯកសាររបស់កុមារ ត្រូវមានព័ត៌មានអំពីបរិស្ថានសង្គម កំណត់ត្រាវេជ្ជសាស្ត្រ និងលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបានជាទូទៅរបស់កុមារ។ យើងឃើញយ៉ាងច្បាស់នៅក្នុងច្បាប់ថា គួរតែផ្តល់អាទិភាពដល់កិច្ចខិតខំក្នុងការរក្សា និងបង្រួបបង្រួមកុមារឱ្យនៅជាមួយគ្រួសារកំណើត មុនពេលដាក់ឱ្យមានការសុំកុមារទៅចិញ្ចឹម។[124] បន្ថែមទៅលើលក្ខខណ្ឌវិនិច្ឆ័យផ្នែកច្បាប់ អាជ្ញាធរកម្ពុជាគួរបង្កើតលក្ខខណ្ឌវិនិច្ឆ័យផ្នែកចិត្តសង្គម និងវេជ្ជសាស្ត្រឱ្យបានច្បាស់លាស់សម្រាប់រយៈពេលខ្លី។[125]

ការប្រកាសអំពីលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបានរបស់កុមារគួរធ្វើឡើងដោយផ្អែកលើភស្តុតាង មានព័ត៌មានត្រឹមត្រូវមិនលម្អៀង និងពេញលេញអំពីរូបកុមារផ្ទាល់។ ព័ត៌មានមួយចំនួនអាចរកបាននៅលើប្រព័ន្ធទិន្នន័យមេដែលត្រូវបានណែនាំឱ្យមាន (អនុសាសន៍ទី ២)។ គួរកំណត់ឱ្យច្បាស់នូវដំណើរការ

123 ប្រកាសស្តីពីការថែទាំជំនួស មាត្រា ២៨

124 គោលការណ៍អំណាចស្ថិតនៅថ្នាក់ក្រោមបំផុត ត្រូវបានឆ្លុះបញ្ចាំងយ៉ាងល្អនៅក្នុងអត្ថបទច្បាប់ (ឧ. មាត្រា ២៨ នៃប្រកាសស្តីពីការថែទាំជំនួស មាត្រា ១៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស)។ បញ្ហាគន្លឹះគឺត្រូវអនុវត្តគោលការណ៍នេះនៅក្នុងការអនុវត្តជាក់ស្តែង។

125 សូមមើលមគ្គុទ្ទេសក៍អំពីការអនុវត្តល្អលេខ ១ ខាងលើ កំណត់សម្គាល់លេខ ២១ ជំពូក ៧.២

ដើម្បីធ្វើការសម្រេចចិត្ត ហើយត្រូវដាក់បញ្ចូលនូវព័ត៌មានគាំទ្រ និងភស្តុតាង ដើម្បីឱ្យអ្នកប្រកបវិជ្ជាជីវៈទាំងអស់ដែលពាក់ព័ន្ធ នៅក្នុងការធ្វើការសម្រេចចិត្តអាចមើលឃើញថា តើការសម្រេចចិត្តត្រូវបានធ្វើឡើងដោយរបៀបណា និងហេតុអ្វីបានជាធ្វើការសម្រេចចិត្តបែបនោះ។ ដើម្បីធានាឱ្យអាចធ្វើការងារនេះបាន អាជ្ញាធរ និងស្ថាប័ននានាជាច្រើនត្រូវមានសហប្រតិបត្តិការគ្នាយ៉ាងជិតស្និទ្ធ និងចែករំលែកព័ត៌មានពាក់ព័ន្ធជាមួយគ្នា ជាពិសេស គឺព័ត៌មានទាក់ទងជាមួយការកិច្ចខិតខំដើម្បីរក្សា និងបង្រួបបង្រួមកុមារជាមួយគ្រួសារកំណើត ដូចមានចែងនៅក្នុងច្បាប់។ បន្ថែមលើនេះទៀត ការធ្វើបែបនេះ អាចក្លាយជាវិធីដើម្បីពិនិត្យឡើងវិញលើស្ថានភាពរបស់កុមារ ដែលត្រូវបានដាក់នៅក្នុងគ្រួសារឪពុកម្តាយធម៌អចិន្ត្រៃយ៍ និងវាយតម្លៃថា តើនោះជាវិធានការល្អបំផុតសម្រាប់ពួកគេ ឬទេ ឬថាតើមានជម្រើសដទៃទៀតឬទេ ដូចជាការសុំកុមារទៅចិញ្ចឹមជាដើម។

សម្រាប់រយៈពេលខ្លី អាជ្ញាធរគួរធានាឱ្យបានថា ការប្រកាសអំពីលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបានរបស់កុមារត្រូវបានធ្វើឡើង តាមរយៈនីតិវិធីដែលមានលក្ខណៈគ្រប់គ្រាន់ និងត្រូវបានទទួលស្គាល់។ ទីមួយនីតិវិធីនេះ ត្រូវបានបង្កើតឡើងលើមូលដ្ឋានច្បាស់លាស់ ហើយយកល្អគួរមានមតិធាតុចូលពីអ្នកប្រកបវិជ្ជាជីវៈពហុវិស័យ ដោយអាជ្ញាធរជាអ្នកទទួលខុសត្រូវក្នុងការប្រកាសលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបាន (ឧ. នៅក្នុងប្រទេសមួយចំនួន គឺស្ថាប័នរដ្ឋបាលដូចជាប្រធានមន្ទីររាជធានី/ខេត្តទទួលបន្ទុកសង្គមកិច្ច[126] ឬថៅក្រម)។[127] ទីពីរ គួរកំណត់ពេលវេលាឱ្យបានច្បាស់លាស់ដើម្បីធានាឱ្យបានថាការសម្រេចចិត្តត្រូវបានធ្វើឡើងយ៉ាងទាន់ពេលវេលា។ ការសម្រេចចិត្តអំពីលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបានរបស់កុមារ គួរត្រូវបានធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានឈរលើគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ ដោយពុំឱ្យរំលងការស៊ើបអង្កេតដែលចាំបាច់នានាអំពីប្រភពកំណើតរបស់កុមារ និងការគោរពគោលការណ៍អំណាចស្ថិតនៅថ្នាក់ក្រោមបំផុត។

ការសម្រេចចិត្តអំពីលក្ខណៈសម្បត្តិអាចសុំកុមារទៅចិញ្ចឹមបាន គឺជាធាតុមួយ ដែលនឹងត្រូវដាក់បញ្ចូលនៅក្នុងសំណុំឯកសាររបស់កុមារ ដែលគួរត្រូវដាក់បញ្ចូលផងដែរនូវភស្តុតាងស្តីពីសាវតា និងប្រវត្តិគ្រួសាររបស់កុមារ កិច្ចខិតខំទាក់ទងនឹងការតាមដានរកគ្រួសាររបស់កុមារ និងការបង្រួបបង្រួមកុមារជាមួយគ្រួសារកំណើតវិញ សភាពសុខភាពរបស់កុមារ សេចក្តីត្រូវការផ្នែកការអភិវឌ្ឍរបស់កុមារ និងទស្សនៈយល់ឃើញរបស់កុមារ។

សំណុំឯកសារនេះ នឹងមានសារៈសំខាន់នៅក្នុងពេលអនាគត ពេលដែលកុមារឈានដល់អាយុពេញវ័យ ដើម្បីឱ្យពួកគេអាចកំណត់បានថា តើការសម្រេចចិត្តស្តីពីការសុំពួកគេទៅចិញ្ចឹមត្រូវបានធ្វើឡើងដោយរបៀបណា និងដោយសារហេតុអ្វី។

សម្រាប់រយៈពេលមធ្យម ដើម្បីធានាឱ្យបានថាការប្រកាសអំពីលក្ខណៈសម្បត្តិអាចសុំយកកុមារទៅចិញ្ចឹមបានត្រូវបានប្រកាសដោយមានការធានាសមស្របអាជ្ញាធរ និងអ្នកប្រកបវិជ្ជាជីវៈនានា ជាពិសេស គឺភ្នាក់ងារសង្គមកិច្ច ដែលមានចំណេះដឹងបំណិន និងជំនាញឯកទេសដែលចាំបាច់នានា។ យើងខ្ញុំសូមផ្តល់អនុសាសន៍ថា បន្ទាប់ពីបង្កើតលក្ខខណ្ឌវិនិច្ឆ័យ និងនីតិវិធី ដើម្បីប្រកាសថាកុមារមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបានរួចរាល់ហើយ អ្នកជំនាញឯកទេសត្រូវបណ្តុះបណ្តាលអ្នកសង្គមកិច្ចមួយក្រុម ដែលត្រូវបានជ្រើសរើសឱ្យចូលរួមនៅក្នុងការប្រកាសលក្ខណៈសម្បត្តិអាចសុំយកកុមារទៅចិញ្ចឹមបាន ការបណ្តុះបណ្តាលជួយបង្កើនកិច្ចសហប្រតិបត្តិការ និងជំរុញឱ្យមានការយល់ដឹងរួមគ្នាក្នុងចំណោមអ្នកប្រកបវិជ្ជាជីវៈទាំងអស់ និងទស្សនៈជារួមអំពីករណីទាំងនោះ (សូមមើលអនុសាសន៍ទី ៣៖ ការបណ្តុះបណ្តាល)។ រាល់ការបណ្តុះបណ្តាលដែលធ្វើឡើង ក៏គួរតែដាក់បញ្ចូលនូវតម្រូវការក្នុងការប្រឹក្សាយោបល់ និងរៀបចំខ្លួនកុមារដែលមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបានផងដែរ។

សម្រាប់រយៈពេលវែង កុមារទាំងអស់ដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន ត្រូវដាក់បញ្ចូលនៅក្នុងកន្លែងចុះបញ្ជីកុមារមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន ដែលគួរតែមានការតភ្ជាប់យ៉ាងត្រឹមត្រូវជាមួយប្រព័ន្ធទិន្នន័យមេ (សូមមើលអនុសាសន៍ទី ២)។ ការធ្វើបែបនេះនឹងអាចជួយបញ្ចៀសបញ្ហាប្រឈម ដែលរដ្ឋបាលសុំកូនអន្តរប្រទេស (ICAA) ជួបប្រទះនាពេលបច្ចុប្បន្ននេះ ពោលគឺការទទួលបាននូវសំណុំឯកសារពេញលេញ និងត្រឹមត្រូវសម្រាប់កុមារដែលមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន។ ប្រព័ន្ធទិន្នន័យមេ គឺជាឧបករណ៍គន្លឹះមួយ ដើម្បីចៀសវាងការពន្យាពេល មិនចាំបាច់នៅក្នុងការរៀបចំសំណុំឯកសាររបស់កុមារ ការយកកុមារទៅដាក់នៅកន្លែងណាមួយ និងការចែករំលែកព័ត៌មានគ្នារវាងស្ថាប័នទទួលខុសត្រូវ។ អាជ្ញាធរកម្ពុជាប្រហែលជាចង់ធ្វើផែនការគម្រោងសាកល្បងនៅក្នុងខេត្តចំនួនពីរ ដើម្បីធ្វើតេស្តសាកល្បងលក្ខខណ្ឌវិនិច្ឆ័យ និងនីតិវិធីជាមួយអ្នកប្រកបវិជ្ជាជីវៈទើបបានទទួលការបណ្តុះបណ្តាលថ្មីៗ។

126 ឧទាហរណ៍ ក្នុងប្រទេសកូឡុំប៊ី គឺវិទ្យាស្ថាន Colombian Family Welfare Institute (ICBF: www.icbf.gov.co/portal/page/portal/ICBFEn/WhatWeDo/Adoptions); in China it is the Provincial Departments of Civil Affairs; and in the Philippines the Department of Social Welfare and Development (see Country Profiles: www.hcch.net under Adoption section).

127 Chile (តុលាការគ្រួសារ) និង Peru (សូមមើលឯកសារលក្ខណៈសម្បត្តិប្រចាំប្រទេស www.hcch.net នៅក្រោមផ្នែកសុំកូន)

## អនុសាសន៍ទី ១៥

# ប្រកាសលក្ខណៈសម្បត្តិអាចដាក់ឱ្យយកកុមារទៅចិញ្ចឹមបាន ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ និងនៅមុនពេលការផ្តូផ្គង ត្រូវបានធ្វើឡើង

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| កំណត់លក្ខណៈវិនិច្ឆ័យទូលំទូលាយ ដើម្បីប្រកាសអំពីលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ | ១ ពិភាក្សានៅក្នុងរង្វង់ក្រសួងដែលពាក់ព័ន្ធអំពីលក្ខខណ្ឌវិនិច្ឆ័យដើម្បីប្រកាសលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន រួមទាំងលក្ខខណ្ឌវិនិច្ឆ័យផ្នែកចិត្តសង្គម និងវេជ្ជសាស្ត្រផងដែរ។[128]<br>២ បង្កើតលក្ខខណ្ឌវិនិច្ឆ័យនៅក្នុងច្បាប់ ឬក្នុងលិខិតបទដ្ឋានក្រសួង។<br>៣ កំណត់រកនីតិវិធីដើម្បីបង្កើតលក្ខខណ្ឌវិនិច្ឆ័យសម្រាប់កុមារនីមួយៗ រួមទាំងការទទួលខុសត្រូវថ្នាក់ក្រសួងផងដែរ។<br>៤ កំណត់រយៈពេលច្បាស់លាស់ដើម្បីធានាឱ្យបានថាការសម្រេចចិត្តត្រូវបានធ្វើឡើងយ៉ាងទាន់ពេលវេលា។<br>៥ ផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយជូនដល់ភាគីពាក់ព័ន្ធទាំងអស់អំពីលក្ខខណ្ឌវិនិច្ឆ័យ និងនីតិវិធី។ | ក្រសួង ស.អ.យ ក្រសួងយុត្តិធម៌។ | UNICEF | ២០១៨ |

128 សូមមើលមតិយោបល់អំពីការអនុវត្តល្អលេខ ១ ខាងលើ កំណត់សម្គាល់លេខ ២១ ជំពូក ៧.២ និង៖ http://www.iss-ssi.org/images/thematic-facts-sheet/eng/20.Adoptability%20and%20Consent%20doc.pdf

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| កំណត់អត្តសញ្ញាណអ្នកប្រកបវិជ្ជាជីវៈសម្រាប់ការប្រកាសលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ។ | ១ កំណត់អ្នកអាជីពដែលអាចប្រកាសលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ (ឧ. អ្នកអាជីពផ្នែកវេជ្ជសាស្ត្រ អ្នកចិត្តសាស្ត្រ អ្នកសង្គមកិច្ច)។<br>២ កំណត់អត្តសញ្ញាណថាតើអាជ្ញាធរណាខ្លះដែលនឹងទទួលបន្ទុកការប្រកាសលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ (ជាការល្អត្រូវមានមតិជាតុចូលពីអ្នកអាជីពពហុវិស័យ)។<br>៣ កំណត់ពេលវេលាច្បាស់លាស់ ដើម្បីកំណត់លក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ។<br>៤ កំណត់ករណី «តេស្ត» ដើម្បីពិភាក្សាគ្នាក្នុងកិច្ចប្រជុំអន្តរក្រសួងមួយដើម្បីលើកទឹកចិត្តដល់ការរៀនសូត្រ/សហប្រតិបត្តិការ។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF | ២០១៩ តទៅ |
| សំណុំឯកសារសព្វគ្រប់ជ្រោយរបស់កុមារដែលមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន | ១ រៀបចំកិច្ចប្រជុំតុមូលជាមួយក្រសួង អង្គការសង្គមស៊ីវិល និងអ្នកដើរតួនាទីពាក់ព័ន្ធដទៃទៀតដើម្បីកំណត់/ព្រមព្រៀងគ្នាថាតើត្រូវការអ្វីខ្លះនៅក្នុងសំណុំឯកសាររបស់កុមារម្នាក់ៗ (ឧ. សេចក្តីសម្រេចចិត្តលើលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ ភស្តុតាងអំពីសាវតា និងប្រវត្តិគ្រួសាររបស់កុមារ កិច្ចខិតខំទាក់ទងជាមួយការតាមដានរកប្រភពគ្រួសារ និងការបង្រួបបង្រួមកុមារជាមួយគ្រួសារវិញស្ថានភាពសុខភាពរបស់កុមារ សេចក្តីត្រូវការផ្នែកការអភិវឌ្ឍរបស់កុមារ និងទស្សនៈយល់ឃើញរបស់កុមារ)។<br>២ ព្រមព្រៀងគ្នាលើសំណុំឯកសារ "គំរូ"។<br>៣ កំណត់/ព្រមព្រៀងគ្នាលើថាតើនរណាត្រូវទទួលខុសត្រូវលើការប្រមូលទិន្នន័យ។<br>៤ កំណត់/ព្រមព្រៀងគ្នាថាតើនរណាជាអ្នកផ្តល់ព័ត៌មាននេះ។<br>៥ ធ្វើតេស្តអនុវត្តសាកល្បងលើលក្ខខណ្ឌវិនិច្ឆ័យ/នីតិវិធីនៅក្នុងតំបន់ចំនួនពីរ មុនពេលចាប់ផ្តល់ដាក់ឱ្យអនុវត្ត។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF, 3PC and FCF | ២០១៩ តទៅ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| **តើចាំបាច់ត្រូវមានអ្វីខ្លះ ?** | **តើនឹងត្រូវអនុវត្តដោយរបៀបណា ?** | **តើនរណាទទួលខុសត្រូវ ?** | **តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ?** | **រយៈពេល** |
| បណ្តុះបណ្តាលអ្នកដើរតួនាទីដែលពាក់ព័ន្ធលើការទទួលខុសត្រូវដែលបានព្រមព្រៀងគ្នាក្នុងការប្រកាសលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ និងបំពេញសំណុំឯកសារ | ១ បង្កើតការតម្រូវអប្បបរមា។<br>២ ជាជំហានដំបូង ត្រូវបណ្តុះបណ្តាលអ្នកសង្គមកិច្ចមួយក្រុម ដើម្បីអនុវត្តការងារ។<br>៣ បណ្តុះបណ្តាលដល់អាជ្ញាធរ និងអ្នកអាជីពទាំងអស់ដែលអាចចូលរួមពាក់ព័ន្ធក្នុងការប្រកាសលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារ និងបំពេញសំណុំឯកសារ (រួមទាំងបុគ្គលិកមណ្ឌលថែទាំកុមារ មណ្ឌលសាសនាផងដែរ)។ | ក្រសួង ស.អ.យ។ | UNICEF | ២០១៩-២០២៣ |
| **រយៈពេលវែង (ហួសពី ២០២៣)** | | | | |
| **តើចាំបាច់ត្រូវមានអ្វីខ្លះ ?** | **តើនឹងត្រូវអនុវត្តដោយរបៀបណា ?** | **តើនរណាទទួលខុសត្រូវ ?** | **តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ?** | **រយៈពេល** |
| បង្កើតការចុះបញ្ជីកុមារដែលមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន។ | ១ ផ្តែកលើនីតិវិធីលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន ធានាឱ្យបានថាកុមារទាំងអស់ដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន ត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធចុះបញ្ជីដាក់លាក់ណាមួយ។<br>២ ស្វែងរកជំនួយបច្ចេកទេសដើម្បីធានាឱ្យបានថាការចុះបញ្ជីមានតំណភ្ជាប់យ៉ាងត្រឹមត្រូវជាមួយប្រព័ន្ធទិន្នន័យមេ (សូមមើលអនុសាសន៍ទី ២)។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF | ២០២០ តទៅ |

# អនុសាសន៍ទី ១៦

## ពិនិត្យឡើងវិញលើស្ថានភាពកុមារស្ថិតក្រោមការថែទាំ ដើម្បីពិនិត្យថាតើកុមារអាចទទួលអត្ថប្រយោជន៍ពីសុំកូន ឬយ៉ាងណា

**ST** ពិនិត្យឡើងវិញលើស្ថានភាពរបស់កុមារនៅក្នុងមណ្ឌលថែទាំកុមារ (រួមទាំងការថែទាំនៅតាមកន្លែងសាសនា និងនៅតាមវត្តអារាម)

ធានាឱ្យមានការប្រកាសលក្ខណៈសម្បត្តិអាចឱ្យសុំកុមារទៅចិញ្ចឹមបានយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់កុមារដែលត្រូវការការសុំទៅចិញ្ចឹម

**MT** វិធានការអន្តរកាលសម្រាប់កុមារនៅក្នុងមណ្ឌលថែទាំកុមារ ស្របពេលដែលយុទ្ធសាស្ត្រសុំកូនក្នុងប្រទេសត្រូវបានអនុវត្ត។

**LT** ការពិនិត្យឡើងវិញថ្នាក់ជាតិលើកុមារក្នុងប្រព័ន្ធការថែទាំ (ការថែទាំក្រៅផ្លូវការ ការថែទាំដោយសាច់ញាតិ ការថែទាំដោយឪពុកម្តាយធម៌ ការស្នាក់នៅតាមផ្ទះជាក្រុមតូចៗ។ល។) ដោយប្រើប្រាស់ឧបករណ៍តាមដានវឌ្ឍនភាព។

អាចមានកុមារមួយចំនួនក្នុងប្រព័ន្ធការថែទាំជំនួស ដែលពុំអាចធ្វើសមាហរណកម្មត្រឡប់ទៅកាន់គ្រួសារវិញបាន ដែលអាចទទួលអត្ថប្រយោជន៍ពីសុំកូន ជាដំណោះស្រាយការថែទាំអចិន្ត្រៃយ៍នៅតាមគ្រួសារ។ ដើម្បីអាចសម្រេចបំណងនេះបាន ជាការចាំបាច់ដែលត្រូវកែសម្រួល និងធ្វើបច្ចុប្បន្នភាពសំណុំឯកសាររបស់កុមាររូបនោះ។ ក្រសួង ស.អ.យ បានធ្វើការវាយតម្លៃខ្លះៗទៅលើចំនួន និងលក្ខណៈសម្បត្តិរបស់កុមារស្ថិតក្នុងប្រព័ន្ធការថែទាំក្នុងរាជធានីខេត្តចំនួនប្រាំ ប៉ុន្តែបើតាមអ្វីដែលយើងដឹងការវាយតម្លៃសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់កុមារម្នាក់ៗនៅពុំទាន់បានចេញជាលទ្ធផលនៅឡើយ (សូមមើលអនុសាសន៍ទី ២)។ ជាការល្អ ការងារនេះគួរស្ថាបនាបន្ថែមលើការសិក្សាឆ្នាំ ២០១៦ ស្តីពីការអនុវត្តសហគមន៍ការថែទាំជំនួស សម្រាប់កុមារក្នុងប្រទេសកម្ពុជា ដោយក្នុងនោះរួមមានទាំងការថែទាំនៅតាមទីវត្តអារាម ធ្វើឡើងដោយមជ្ឈមណ្ឌលផ្នែកច្បាប់របស់កុមារ Coram ផងដែរ។

កុមារជាច្រើនត្រូវបានយកទៅដាក់ក្នុងមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា។ ការពន្យាពេលការយកទៅដាក់ក្នុងគ្រួសារអចិន្ត្រៃយ៍សម្រាប់កុមារទាំងអស់នេះ គឺជាដំណើរការផ្ទុយពីគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ។ ហេតុនេះ ក្រុមស្រាវជ្រាវសូមផ្តល់អនុសាសន៍ថា សម្រាប់រយៈពេលខ្លី ក្រសួង ស.អ.យ ត្រូវបង្កើតឱ្យមានក្របខណ្ឌពេលវេលាច្បាស់លាស់សម្រាប់ការពិនិត្យឡើងវិញទៅលើសំណុំឯកសាររបស់កុមារនៅក្នុងមណ្ឌលថែទាំកុមារ។ គួរផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើកុមារមានតម្រូវការពិសេស និងស្មុគស្មាញ។ ក្រសួង ស.អ.យ និងអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ហើយប្រហែលជាអាចជួលអ្នកខាងក្រៅមកពីស្ថាប័នសង្គមស៊ីវិល ដោយផ្អែកលើកម្រងលក្ខខណ្ឌវិនិច្ឆ័យ ដូចជាបទពិសោធន៍ និងឯករាជភាពជាដើម គួរសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីរៀបចំ និងបង្ហើយសំណុំឯកសាររបស់កុមារ ដោយប្រមូលព័ត៌មានអំពីសាវតា និងសេចក្តីត្រូវការរបស់កុមារ។ សេចក្តីថ្លែងការណ៍ការប្តេជ្ញាចិត្តរបស់ក្រសួង ស.អ.យ

ទៅលើការអនុវត្តអនុសាសន៍ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារតម្រូវឱ្យគ្រប់មណ្ឌលថែទាំកុមារទាំងអស់ត្រូវមានផែនការករណីសម្រាប់កុមារម្នាក់ៗ ដែលស្ថិតនៅក្រោមការថែទាំរបស់ពួកគេ។ ក្រសួង ស.អ.យ គួរតាមដានបន្តដើម្បីធានាឱ្យបានថាការតម្រូវទាំងអស់នេះត្រូវបានអនុវត្តតាម ហើយកំណត់ប្រព័ន្ធមួយ ដើម្បីពិនិត្យឡើងវិញទៅលើផែនការករណីរបស់កុមារ និងដាក់បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធទិន្នន័យមេនៅថ្នាក់កណ្តាល (អនុសាសន៍ទី ២)។

បន្ទាប់មក ក្រសួង ស.អ.យ គួរវិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មានបច្ចុប្បន្នរបស់ខ្លួនទាក់ទងជាមួយកុមារនៅក្នុងមណ្ឌលថែទាំកុមារនៅក្នុងរាជធានីខេត្តទាំងប្រាំនេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ សម្រាប់ករណីនីមួយៗ ត្រូវធ្វើយ៉ាងណាធានាតុល្យភាពរវាងពេលវេលា ដែលត្រូវចំណាយ ដើម្បីធ្វើសមាហរណកម្មកុមារទៅកាន់គ្រួសារកំណើតរបស់ខ្លួនធៀបជាមួយតម្រូវការ ដើម្បីផ្តល់ដំណោះស្រាយគ្រួសារអចិន្ត្រៃយ៍មួយដល់កុមារ។ រដ្ឋដែលសម្រេចចិត្តលើលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបានឆាប់ពេក ដោយពុំធានាយ៉ាងណាឱ្យការការពារសុវត្ថិភាព ដែលចាំបាច់ត្រូវបានអនុលោមតាមច្បាប់ និងគោលនយោបាយ អាចប្រឈមជាមួយបញ្ហា និងការរំលោភបំពាន។ បញ្ហា និងការរំលោភបំពានទាំងនេះ ទីបំផុតអាចផ្តល់លទ្ធផលឱ្យមានការចាប់បង្ខំអនុវត្តការផ្អាកបណ្តោះអាសន្នលើសុំកូនអន្តរប្រទេស ប្រសិនបើត្រូវបានមើលឃើញថា បញ្ហាទាំងនោះ ពុំអាចទប់ទល់បានទេនោះ។[129] ផ្ទុយទៅវិញក្នុងបណ្តារដ្ឋ ដែលពុំធ្វើការសម្រេចចិត្តទាន់ពេលវេលា កុមារអាចស្ថិតនៅក្នុងមណ្ឌលរយៈពេលវែងពេក។ សុំកូនក្នុងប្រទេស គួរតែជាអាទិភាព សម្រាប់កុមារដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបាន។ ទោះយ៉ាងណាក្តី ក្នុងតថភាពជាក់ស្តែងជារឿយៗ តែងមានឪពុកម្តាយចិញ្ចឹមក្នុងប្រទេសចំនួនតិចតួច។ ចំណុចនេះ ពុំគួររារាំងកុមារដែលត្រូវបានយកទៅដាក់ក្នុងមណ្ឌលជាអចិន្ត្រៃយ៍ មិនឱ្យមានលទ្ធភាពទទួលបានគ្រួសារមួយនោះឡើយ។ ការយឺតយ៉ាវក្នុងការស្វែងរកដំណោះស្រាយ សម្រាប់កុមារទាំងអស់នេះ ពុំមែនជាឧត្តមប្រយោជន៍របស់កុមារឡើយ។ ហេតុនេះ ប្រសិនបើសុំកូនក្នុងប្រទេសពុំអាចធ្វើឡើងបានទេ ត្រូវប្តូរអាទិភាពទៅស្វែងរក PAPs តាមរយៈសុំកូនអន្តរប្រទេសសម្រាប់កុមារទាំងឡាយណា ដែលត្រូវបានដាក់នៅក្នុងមណ្ឌលថែទាំកុមាររយៈពេលវែង។[130]

សម្រាប់**រយៈពេលមធ្យម**ក្នុងអំឡុងពេលការអនុវត្តយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សុំកូនក្នុងប្រទេស (សូមមើលអនុសាសន៍ទី ២០) ប្រទេសកម្ពុជាអាចពិចារណាប្រើប្រាស់វិធានការបណ្តោះអាសន្ន ដើម្បីលើកទឹកចិត្តសុំកូនអន្តរប្រទេសក្នុងករណីពុំអាចមានសុំកូនក្នុងប្រទេស។ គម្រោងអនុវត្តសាកល្បងសម្រាប់កុមារមួយចំនួនតូចនៅក្នុងមណ្ឌលថែទាំកុមារ ដែលឆ្លើយតបតាមលក្ខខណ្ឌវិនិច្ឆ័យជាក់លាក់ សម្រាប់លក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានអាចត្រូវបានបង្កើតឡើង។ បើពុំដូច្នោះទេ កុមារដែលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងមណ្ឌល ដោយមានតម្រូវការជាបន្ទាន់ត្រូវការគ្រួសារប្រាកដជាត្រូវបន្តស្ថិតនៅក្នុងមណ្ឌលនោះ រហូតដល់ពេញវ័យមិនខាន។

សម្រាប់**រយៈពេលវែង** យើងសូមផ្តល់អនុសាសន៍យ៉ាងរឹងមាំឱ្យមានការធ្វើជំរឿនថ្នាក់ជាតិសម្រាប់កុមារទាំងអស់ ដែលកំពុងស្ថិតនៅក្នុងប្រព័ន្ធការថែទាំជំនួសដោយក្នុងនោះរួមមានឧទាហរណ៍ដូចជា ការថែទាំដោយឪពុកម្តាយធម៌ ការស្នាក់នៅក្នុងតាមផ្ទះជាក្រុម ការថែទាំតាមវត្តអារាម និងមណ្ឌលថែទាំកុមារ ព្រមទាំងការថែទាំដែលផ្តល់ដោយក្រុមសាសនាផងដែរ។ សំខាន់ណាស់ដែលរដ្ឋាភិបាលត្រូវមានព័ត៌មានយ៉ាងត្រឹមត្រូវអំពីសេចក្តីត្រូវការរបស់កុមារនៅក្នុងប្រព័ន្ធការថែទាំ ដើម្បីបង្កើតគោលនយោបាយរបស់ខ្លួន។ ឧបករណ៍តាមដានវឌ្ឍនភាព[131] ដែលបានបង្កើតឡើងដោយក្រុមអន្តរទីភ្នាក់ងារមួយអាចជាមធ្យោបាយមួយ សម្រាប់ប្រមូលព័ត៌មាន ដូចដែលបានលើកឡើងខាងលើ។

129 រដ្ឋទាំងឡាយដែលវិនិយោគពេលវេលា និងធនធានគ្រប់គ្រាន់ក្នុងការវាយតម្លៃលើលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបានរបស់កុមារ ធ្វើឱ្យមិនសូវ កើតមានការអនុវត្តខុសច្បាប់ទេ ដូចជានៅប្រទេសហ្វីលីពីន និងអាហ្វ្រិកខាងត្បូងជាដើម។

130 ឧ. ក្នុងប្រទេស Lithuania មានរយៈពេលប្រាំមួយខែសម្រាប់ការស្វែងរកគ្រួសារនៅក្នុងប្រទេស Lithuania។ ប្រសិនបើរកពុំបានគ្រួសារណាមួយក្នុងប្រទេស Lithuania ទេ នោះអាជ្ញាធរនឹងព្យាយាមស្វែងរកគ្រួសារតាមរយៈសុំកូនអន្តរប្រទេស។ ក្នុងប្រទេសអាហ្វ្រិកខាងត្បូង គឺមានរយៈពេល ៦០ ថ្ងៃ ចំណែកនៅបេឡារូស គឺប្រាំមួយខែ ហើយនៅអ៊ុយក្រែនគឺមានរយៈពេលមួយឆ្នាំ។ រយៈពេលអប្បបរមានេះផ្តល់ពេលកំណត់ឱ្យអាជ្ញាធរមូលដ្ឋានក្នុងការស្វែងរកគ្រួសារក្នុងប្រទេស និងធានាឱ្យបានថា កុមាររង់ចាំគ្មានកាលកំណត់។ រយៈពេលកំណត់នេះមានរយៈពេលខុសៗគ្នា អាស្រ័យទៅតាមសេចក្តីត្រូវការរបស់ប្រទេសនីមួយៗ ហើយត្រូវបានបន្ធូរបន្ថយក្នុងករណីមួយចំនួន។ ប្រសិនបើការចុះបញ្ជីទាំងអស់នេះមានរយៈពេលកំណត់ ជាការសំខាន់ណាស់ដែលត្រូវធានាឱ្យបានថា សកម្មភាពពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាពត្រូវបានធ្វើឡើងក្នុងអំឡុងពេលរង់ចាំ ដើម្បីស្វែងរកដំណោះស្រាយក្នុងស្រុក។ ពុំមានប្រយោជន៍អ្វីក្នុងការដាក់រយៈពេលរង់ចាំនោះឡើយប្រសិនបើអ្នកដែលមានលទ្ធភាពចូលទៅកាន់បញ្ជីនេះពុំត្រូវបានប្រគល់ភារកិច្ចឱ្យស្វែងរកដំណោះស្រាយក្នុងប្រទេសសម្រាប់កុមាររូបនេះ។ ម្យ៉ាងទៀត គេក៏អាចនិយាយថា រយៈពេលរង់ចាំមួយឆ្នាំអាចចាត់ទុកថាជារយៈពេលយូរជ្រុល ជាពិសេសសម្រាប់កុមារមានសេចក្តីត្រូវការពិសេស។

131 នេះគឺជាឧបករណ៍មានលក្ខណៈសព្វជ្រុងជ្រោយសម្រាប់វាយតម្លៃលើការអនុវត្តគោលការណ៍ណែនាំអង្គការសហប្រជាជាតិនៅក្នុងបណ្តាប្រទេសនានា៖ www.bettercarenetwork.org/sites/default/files/Tracking%20Progress%20Initiative%20-%20Monitoring%20the%20Guidelines'%20Implementation.pdf

## អនុសាសន៍ទី ១៦

# ពិនិត្យឡើងវិញលើស្ថានភាពកុមារស្ថិតក្រោមការថែទាំ ដើម្បីពិនិត្យថាតើកុមារអាចទទួលអត្ថប្រយោជន៍ពីសុំកូន ឬយ៉ាងណា

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ពិនិត្យឡើងវិញលើស្ថានភាពរបស់កុមារជាបុគ្គលនៅក្នុងមណ្ឌលថែទាំកុមារ។ | ១ កំណត់រយៈពេលច្បាស់លាស់ ដើម្បីពិនិត្យឡើងវិញលើករណីរបស់កុមារទាំងអស់នៅក្នុងមណ្ឌលថែទាំកុមារ (រួមទាំងការថែទាំតាមមណ្ឌលសាសនា និងការថែទាំនៅតាមវត្តអារាម) សូមមើលអនុសាសន៍ទី ១២។<br>២ លើកទឹកចិត្តការចូលរួមរបស់កុមារនៅក្នុងការធ្វើផែនការករណី (សូមមើលអនុសាសន៍ទី ៦)។<br>៣ ផ្អែកលើនីតិវិធី/ការទទួលខុសត្រូវដែលត្រូវបានកំណត់ឃើញ (អនុសាសន៍ទី ១៥) ធ្វើបច្ចុប្បន្នភាពលើសំណុំឯកសាររបស់កុមារនៅក្នុងរាជធានីខេត្តទាំងប្រាំ។<br>៤ ធ្វើការវាយតម្លៃលើសេចក្ដីត្រូវការរបស់កុមារដទៃទៀតទាំងអស់ (ក្រៅពីរាជធានីខេត្តទាំងប្រាំ) ដើម្បីកំណត់រកលទ្ធផលសមស្របបំផុតសម្រាប់គាត់ ដោយរួមទាំងជម្រើសក្នុងប្រទេសកម្ពុជា និងសុំកូនអន្តរប្រទេស។ | ក្រសួង ស.អ.យ។ | UNICEF, 3PC and FCF | ២០១៨ |
| ការប្រកាសអំពីលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបានរបស់កុមារដែលត្រូវការការសុំទៅចិញ្ចឹម | ១ បង្កើតនីតិវិធីសម្រាប់ករណីដែលជម្រើសជំនួសនៅថ្នាក់ជាតិ និងសុំកូនក្នុងប្រទេសពុំអាចធ្វើបានទេ ត្រូវផ្ទេរអាទិភាពផ្ដោតទៅលើការស្វែងរក PAPs តាមរយៈ ICA។<br>២ បណ្ដុះបណ្ដាលអ្នកដើរតួនាទីពាក់ព័ន្ធស្ដីអំពីនីតិវិធីទាំងអស់នេះ។ | ក្រសួង សអយ។ | UNICEF | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| វិធានការបណ្ដោះអាសន្នសម្រាប់កុមារនៅក្នុងមណ្ឌលនៅពេលដែលយុទ្ធសាស្ត្រសុំកូនក្នុងប្រទេសត្រូវបានអនុវត្ត | ១ កំណត់រកកុមារក្នុងចំនួនតិចតួច ដែលពុំអាចដាក់ឱ្យសុំទៅចិញ្ចឹមក្នុងប្រទេសបាន។<br>២ ធានាយ៉ាងណាឱ្យសំណុំឯកសារការសុំយកទៅចិញ្ចឹមអនុលោមតាមអនុសាសន៍ទី ១៥។<br>៣ ធ្វើតេស្តលើនីតិវិធី ICA ជាមួយក្រុមអនុវត្តសាកល្បង។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF, 3PC and FCF | ២០១៩ តទៅ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការពិនិត្យឡើងវិញថ្នាក់ជាតិចំពោះកុមារទៅក្នុងប្រព័ន្ធការថែទាំ | ១ ធ្វើជំរឿនទូទាំងប្រទេសចំពោះកុមារទាំងអស់នៅក្នុងប្រព័ន្ធការថែទាំជំនួស ឧ. ដូចជា រួមទាំងការថែទាំដោយឪពុកម្ដាយធម៌ ផ្ទះស្នាក់នៅជាក្រុម ការថែទាំតាមវត្តអារាម មណ្ឌលថែទាំកុមារ និងការថែទាំផ្ដល់ដោយក្រុមបែបជំនឿសាសនា។<br>២ ចាត់ទុកឧបករណ៍តាមដានវឌ្ឍនភាពជាមធ្យោបាយមួយសម្រាប់ការប្រមូលព័ត៌មានទាំងនេះ។ | ក្រសួង ស.អ.យ។ | UNICEF, 3PC and FCF | ២០២៣ តទៅ |

# អនុសាសន៍ទី ១៧

## បង្កើតបញ្ជីចុះឈ្មោះមួយ ដោយក្នុងនោះមានបញ្ជាក់ចំនួនកុមារដែលមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបានទាំងអស់នឹងត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិ

**ST** បង្កើតបញ្ជីចុះឈ្មោះដែលក្នុងនោះមានទម្រង់ចាំបាច់នានា ដើម្បីចុះឈ្មោះកុមារ។ កំណត់រកមូលនិធិដើម្បីបង្កើតបញ្ជីចុះឈ្មោះ។

**MT** បណ្ដុះបណ្ដាលអ្នកទទួលខុសត្រូវលើបញ្ជីចុះឈ្មោះ។

**LT** ដាក់បញ្ចូលទិន្នន័យរបស់បញ្ជីចុះឈ្មោះលើកុមារដែលមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន នៅក្នុងប្រព័ន្ធទិន្នន័យមេនៅថ្នាក់កណ្ដាលសម្រាប់កុមារស្ថិតក្រោមការថែទាំ (សូមមើលអនុសាសន៍ទី ២)។

បញ្ជីចុះឈ្មោះរួមមួយរបស់កុមារមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន គឺជាឧបករណ៍គន្លឹះមួយក្នុងការអនុវត្តគោលការណ៍អំណាចនៅថ្នាក់ក្រោមបំផុត ព្រោះថាបញ្ជីនេះជួយសម្របសម្រួលជាដំបូងដល់ការស្វែងរក PAPs នៅថ្នាក់ជាតិ ហើយប្រសិនបើរកគ្រួសារមិនបាននៅក្នុងប្រទេសកម្ពុជាទេនោះនឹងជួយសម្របសម្រួលដល់ការស្វែងរកឪពុកម្ដាយចិញ្ចឹមនៅថ្នាក់អន្តរជាតិ ដែលជាមនុស្សស្ថិតក្នុងជំហរល្អបំផុត ដើម្បីឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់កុមារ។

ថ្វីបើច្បាប់ស្ដីពីសុំកូនអន្តរប្រទេសបានបញ្ជាក់រួចហើយ អំពីបញ្ជីចុះឈ្មោះមួយ សម្រាប់កុមារដែលត្រូវបានកំណត់ថាមានលក្ខណៈសម្បត្តិអាចឱ្យសុំយកទៅចិញ្ចឹមបាន សម្រាប់គោលបំណងនៃសុំកូនអន្តរជាតិ (មាត្រា ១៣) ប៉ុន្តែយើងមិនបានដឹងថា តើបទបញ្ញត្តិមួយនេះត្រូវបានអនុវត្តជាក់ស្ដែង ឬទេនោះទ្បើយ។ ផ្អែកលើបញ្ជីចុះឈ្មោះ ដែលមាននាពេលបច្ចុប្បន្ន សម្រាប់កុមារមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបាន ដែលត្រូវការសុំកូនអន្តរប្រទេស សម្រាប់រយៈពេលខ្លីអាជ្ញាធរកម្ពុជាគួរបង្កើតបញ្ជីចុះឈ្មោះមួយ ដែលអាចចុះឈ្មោះកុមារទាំងអស់ ដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបាន។ នៅក្នុងករណីភាគច្រើន នៅពេលកុមារត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបាន គេនៅមិនទាន់ដឹងថា តើកុមារនោះនឹងត្រូវបានសុំទៅចិញ្ចឹមនៅក្នុងប្រទេស ឬអន្តរប្រទេសនោះទ្បើយ។ បញ្ជីចុះឈ្មោះរួមមួយជួយធានានូវការបន្តជាប់ជានិច្ច និងការសម្រេចចិត្តបន្តទៀតទាន់ពេលវេលា។ ហេតុនេះជាការត្រឹមត្រូវណាស់ ដែលត្រូវមានបញ្ជីចុះឈ្មោះរួមមួយ ដែលស្ថិតនៅក្រោមការថែទាំរបស់អាជ្ញាធរសមស្រប ដូចជាក្រសួង សអយ ជាដើម។

បញ្ជីចុះឈ្មោះនេះគួរមានមូលដ្ឋាននៅក្នុងរាជធានី ប៉ុន្តែគួរមានកាតភ្ជាប់ទៅកាន់ខេត្តនានា ដើម្បីជួយសម្រួលដល់មន្ទីរ ស.អ.យ នៅក្នុងខេត្តនីមួយៗ រួមទាំងនៅក្នុងការចុះបញ្ជីកុមារណាដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបាននៅក្នុងខេត្តនោះ។ អាជ្ញាធរគួរសម្រេចចិត្តថា តើនរណានឹងធ្វើជាម្ចាស់ផ្ទះកាន់កាប់លើបញ្ជីឈ្មោះនៅក្នុងខេត្តនោះ។ អាជ្ញាធរកណ្តាលនៃរដ្ឋទទួលជាច្រើនបានបង្ហាញចំណាប់អារម្មណ៍ក្នុងការផ្តល់មូលនិធិ ដើម្បីអភិវឌ្ឍប្រព័ន្ធទិន្នន័យមេដែលបានបញ្ជាក់ខាងលើ។ ការប្រមូលផ្តុំធនធានចាំបាច់ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នឯករាជ្យណាមួយ ដូចជាអង្គការយូនីសេហ្វជាដើម ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍ជាសក្តានុពល។ សម្រាប់រយៈពេលមធ្យម មនុស្សដែលត្រូវបានស្នើឡើងឱ្យមើលខុសត្រូវលើបញ្ជីចុះឈ្មោះ គួរបានទទួលការបណ្តុះបណ្តាល ដើម្បីធ្វើការងាររបស់ខ្លួន ហើយត្រូវបានបំពាក់ឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីពិនិត្យតាមដានយ៉ាងប្រុងប្រយ័ត្នលើរយៈពេល ដែលកុមារស្ថិតនៅក្នុងបញ្ជីចុះឈ្មោះ និងអំពីរបៀប ដើម្បីវាយតម្លៃប្រតិបត្តិការរបស់ប្រព័ន្ធ។ សម្រាប់រយៈពេលវែង បញ្ជីចុះឈ្មោះនេះអាចត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យមេទូទាំងប្រទេសនៃកុមារស្ថិតក្រោមការថែទាំ (សូមមើលអនុសាសន៍ទី ២)។ រាល់ការផ្លាស់ប្តូរលើស្ថានភាពរបស់កុមារគួរត្រូវបានធ្វើបច្ចុប្បន្នភាព។

## អនុសាសន៍ទី ១៧

# បង្កើតបញ្ជីចុះឈ្មោះមួយ ដោយក្នុងនោះកុមារដែលមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបានទាំងអស់នឹងត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យមេថ្នាក់ជាតិ

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ ? | តើនឹងត្រូវអនុវត្តដោយរបៀបណា ? | តើនរណាទទួលខុសត្រូវ ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ ? | រយៈពេល |
| កំណត់រកមូលនិធិសម្រាប់បង្កើតបញ្ជីចុះឈ្មោះ | ១ ទំនាក់ទំនងទៅកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួល ដើម្បីសុំការអះអាងបញ្ជាក់អំពីចំណាប់អារម្មណ៍ក្នុងការផ្តល់មូលនិធិ។<br>២ បង្កើតប្រព័ន្ធមួយដើម្បីឱ្យធនធានប្រមូលបានស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នឯករាជ្យមួយ ដូចជាអង្គការយូនីសេហ្វជាដើម ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍ជាសក្តានុពល។ | ក្រសួង ស.អ.យ។ | UNICEF, HCCH, ISS, Central Authorities from receiving States | ២០១៨ |
| បង្កើតបញ្ជីចុះឈ្មោះដោយក្នុងនោះ កុមារទាំងអស់ដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបានត្រូវបានដាក់បញ្ចូល។ | ១ កំណត់រកម្ចាស់ផ្ទះគ្រប់គ្រងលើបញ្ជីចុះឈ្មោះនៅក្នុងរាជធានី។<br>២ កំណត់ថាតើ ការប្រមូលព័ត៌មាននៅថ្នាក់តំបន់នឹងត្រូវធ្វើឡើងដោយរបៀបណា ហើយនឹងត្រូវបញ្ចូលឱ្យនៅថ្នាក់កណ្តាលដោយរបៀបណា។<br>៣ បង្កើតប្រព័ន្ធទិន្នន័យមេដែលមានជំនួយបច្ចេកទេសពីខាងក្រៅ ប្រសិនបើចាំបាច់។<br>៤ ធ្វើផែនការថាតើ បញ្ជីចុះឈ្មោះនេះនឹងមានតំណភ្ជាប់ជាមួយបញ្ជីចុះឈ្មោះថ្នាក់កណ្តាលក្នុងអនុសាសន៍ទី ២ ដោយរបៀបណា។ | ក្រសួង សអយ។ | UNICEF | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បណ្តុះបណ្តាលមនុស្សទទួលបន្ទុកបញ្ជីចុះឈ្មោះ | ១ បណ្តុះបណ្តាលបុគ្គលដែលគ្រប់គ្រងលើបញ្ជីចុះឈ្មោះ ដើម្បីអាចពិនិត្យតាមដានដោយប្រុងប្រយ័ត្នលើរយៈពេលដែលកុមារស្ថិតនៅក្នុងបញ្ជីចុះឈ្មោះ និងដើម្បីវាយតម្លៃលើប្រតិបត្តិការរបស់ប្រព័ន្ធ។<br>២ បណ្តុះបណ្តាលអ្នកដើរតួនាទីដែលនឹងផ្តព័ត៌មានសម្រាប់ការដាក់បញ្ចូលទិន្នន័យ។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF, 3PC and FCF | ២០១៩ តទៅ |
| **រយៈពេលវែង (ហួសពី ២០២៣)** | | | | |
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ដាក់បញ្ចូលទិន្នន័យនៃបញ្ជីចុះឈ្មោះស្តីពីកុមារដែលអាចសុំទៅចិញ្ចឹមបាននៅក្នុងប្រព័ន្ធទិន្នន័យមេថ្នាក់កណ្តាលសម្រាប់កុមារស្ថិតក្រោមការថែទាំ (សូមមើលអនុសាសន៍ទី ២) | ១ ផ្អែកលើការធ្វើផែនការរយៈពេលខ្លី ត្រូវផ្សារភ្ជាប់បញ្ជីចុះឈ្មោះទៅកាន់ប្រព័ន្ធទិន្នន័យមេទូទាំងប្រទេសសម្រាប់កុមារស្ថិតក្រោមការថែទាំ (សូមមើលអនុសាសន៍ទី ២)។<br>២ បង្កើតលក្ខខណ្ឌតម្រូវដែលទាមទារថា រាល់ការផ្លាស់ប្តូរស្ថានភាពរបស់កុមារចាំបាច់ត្រូវមានការកត់ត្រា ដោយអាចធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួង។ | ក្រសួង ស.អ.យ និងក្រសួងបច្ចេកវិទ្យា។ | UNICEF | ២០២៣ តទៅ |

# អនុសាសន៍ទី

# ១៨

## បង្កើតគណៈកម្មាធិការផ្គូផ្គងដែលជាអ្នកទទួលបន្ទុកស្វែងរក PAPs ល្អបំផុតសម្រាប់កុមារ (ទាំងសម្រាប់សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស)

| | |
|---|---|
| **ST** | បង្កើតគណៈកម្មាធិការផ្គូផ្គង និងនីតិវិធីច្បាស់លាស់ និងមានតម្លាភាព។ |
| **MT** | បណ្តុះបណ្តាលគណៈកម្មាធិការផ្គូផ្គង។ |
| **LT** | អនុវត្តគម្រោងសាកល្បង។ |

ការផ្គូផ្គងសេចក្តីត្រូវការរបស់កុមារជាមួយគុណភាពនៃ ឪពុកម្តាយចិញ្ចឹម គឺមានភាពចាំបាច់ណាស់សម្រាប់ឧត្តមប្រយោជន៍របស់កុមារ។ ការពិចារណាចម្បងក្នុងការសម្រេចចិត្តថាតើ ឪពុកម្តាយចិញ្ចឹមមួយណា គួរត្រូវបានជ្រើសរើសសម្រាប់កុមារជាក់លាក់ណាមួយ គឺជាសមត្ថភាព ដើម្បីឆ្លើយតបទៅតាមសេចក្តីត្រូវការរបស់កុមារជាក់លាក់រូបនោះ។

ការផ្គូផ្គងដ៏ល្អរវាងកុមារដែលមានលក្ខណៈអាចសុំទៅចិញ្ចឹមបានជាមួយឪពុកម្តាយចិញ្ចឹម គឺជាភារកិច្ចទាមទារនូវជំនាញកម្រិតខ្ពស់ ហើយមានភាពចាំបាច់ណាស់ទាំងសម្រាប់កុមារ និងសម្រាប់ PAPs។ ដូច្នេះហើយទើបការងារនេះគួរត្រូវបានធ្វើឡើងដោយក្រុមការងារពហុវិស័យ រួមមានសមាសភាពអ្នកប្រកបវិជ្ជាជីវៈអាជីពការពារកុមារ និងមិនត្រូវទុកឱ្យជាការទទួលខុសត្រូវរបស់បុគ្គលតែម្នាក់ ឬរបស់ឪពុកម្តាយចិញ្ចឹម[132] ដោយយកល្អគួរតែជាអ្នកជំនាញក្នុងវិស័យចិត្តសង្គមបានទទួលការបណ្តុះបណ្តាលលើសុំកូន។ ក្នុងករណីសុំកូនអន្តរប្រទេស ជាការល្អដែលត្រូវអញ្ជើញមេធាវីម្នាក់ឱ្យចូលរួមក្នុងក្រុមការងារ ដើម្បីធានាយ៉ាងណាឱ្យរាល់ការតម្រូវផ្នែកច្បាប់ទាំងអស់ត្រូវបានឆ្លើយតប។ ក្រុមការងារគួរពិចារណាលើសេចក្តីត្រូវការរបស់កុមារក្នុងលក្ខណៈទាំងមូលរួមទាំងថា តើការដាក់កុមារទៅទីនោះអាចឆ្លើយតបទៅតាមសេចក្តីត្រូវការផ្នែកការអភិវឌ្ឍរបស់កុមារ ទស្សនៈយល់ឃើញរបស់កុមារ បំណិនចិញ្ចឹមបីបាច់របស់ឪពុកម្តាយចិញ្ចឹម និងសមត្ថភាពរបស់ឪពុកម្តាយចិញ្ចឹម ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការជាក់ស្តែងរបស់កុមារ ឬទេ (សូមមើល អនុសាសន៍ទី ១៦)។ ការផ្គូផ្គងជាសក្តានុពលគួរស្ថិតក្រោមការត្រួតពិនិត្យដោយអ្នកប្រកបវិជ្ជាជីវៈអាជីព ដើម្បីព្យាយាមទប់ស្កាត់ការបរាជ័យនៃការសុំកូនទៅចិញ្ចឹម។

132 PAPs មិនគួរជ្រើសរើសកុមារដើម្បីសុំទៅចិញ្ចឹមដោយខ្លួនឯងឡើយ (លើកលែងតែជាការសុំទៅចិញ្ចឹមដោយសាច់ញាតិ ប៉ុន្តែក្នុងករណីបែបនេះ លក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានរបស់កុមារគួរត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ជាពិសេសនៅពេលដែលមានតម្រូវការដើម្បីឱ្យដាក់កុមារសម្រាប់សុំ ឬប្រសិនបើសុំកូននោះធ្វើឡើងជាកិច្ចឆ្លើយតបចំពោះការចង់បានរបស់ PAPs)។

នីតិវិធីផ្គូផ្គងមិនគួរចាប់ផ្តើមមុនពេលលក្ខណៈសម្បត្តិ ដើម្បីអាចសុំទៅចិញ្ចឹមបានរបស់កុមារត្រូវបានកំណត់ ហើយឪពុកម្តាយចិញ្ចឹមត្រូវបានអនុម័ត សម្រាប់ស្មុំកូននោះទេ។ ការផ្គូផ្គងបឋម រវាងឪពុកម្តាយចិញ្ចឹមជាមួយកុមារចាំបាច់ត្រូវធ្វើឡើងដោយឈរលើមូលដ្ឋានរបាយការណ៍ស្តីពីកុមារ និងរបាយការណ៍ស្តីពី PAPs ដែលត្រូវបានជ្រើសរើស។ យើងខ្ញុំសូមផ្តល់អនុសាសន៍ថា ការស្រាវជ្រាវរកគ្រួសារដ៏ល្អបំផុត ត្រូវចាប់ផ្តើមឱ្យបានឆាប់បំផុត បន្ទាប់ពីកុមារត្រូវបានប្រកាសថាអាចដាក់ឱ្យសុំទៅចិញ្ចឹមបាន។ ការពន្យាពេលដោយមិនចាំបាច់ក្នុងការស្វែងរកគ្រួសារសមស្របសម្រាប់កុមារអាចផ្តល់ឱ្យមានការខូចខាតដ៏ធ្ងន់ធ្ងរចំពោះសុខុមាលភាពរបស់កុមារ និងឱកាសរបស់កុមារសម្រាប់ការសុំយកទៅចិញ្ចឹម។ គួរកត់សម្គាល់ថា ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស[133] បង្កើតនីតិវិធីផ្គូផ្គងដែលអាចត្រូវបានប្រើប្រាស់ជាមូលដ្ឋាន និងអាចពង្រីកបន្ថែមទៅកាន់ស្មុំកូនក្នុងប្រទេសផងដែរ។

បច្ចុប្បន្ន ក្នុងប្រទេសកម្ពុជាពុំបានការផ្គូផ្គងជាលក្ខណៈវិជ្ជាជីវៈអាជីពសម្រាប់ស្មុំកូនក្នុងប្រទេសទេ។ ជំនួសមកវិញ ឪពុកម្តាយចិញ្ចឹមបង្ហាញខ្លួន ចំពោះមុខចៅក្រមជាមួយកុមារដែលពួកគេបានជ្រើសរើស។ «ស្មុំកូន» ប្រភេទនេះមានបង្កប់គ្រោះថ្នាក់នៅខាងក្នុង បើគិតទៅលើកង្វះយន្តការតាមដាន ដើម្បីពិនិត្យតាមដានថា តើកុមារត្រូវបានកំណត់អត្តសញ្ញាណដោយ PAPs តាមរបៀបណា និងដើម្បីធានាឲ្យមានការអនុវត្តការការពារសុវត្ថិភាពបានគ្រប់គ្រាន់។ យើងខ្ញុំសូមផ្តល់អនុសាសន៍យ៉ាងខ្ពស់ថាត្រូវផ្លាស់ប្តូរការអនុវត្តបែបនេះ ហើយសម្រាប់រយៈពេលខ្លី ត្រូវ៖ ១) បង្កើតគណៈកម្មាធិការផ្គូផ្គងឡើង ដោយមានសមាសភាពអ្នកជំនាញមកពីវិស័យផ្សេងៗគ្នា (ក្រុមការងារពហុវិស័យ) និង ២) បង្កើតនីតិវិធីច្បាស់លាស់ សម្រាប់ការផ្គូផ្គង។ ទាក់ទងជាមួយសមាសភាពនៃគណៈកម្មាធិការផ្គូផ្គងប្រទេសកម្ពុជាអាចដើរតាមបទពិសោធន៍របស់ប្រទេស Burkina Faso ដោយក្នុងនោះគណៈកម្មាធិការពហុវិស័យរួមមានសមាសភាពអគ្គនាយកទទួលបន្ទុកការពារកុមារនាយកទទួលបន្ទុកស្មុំកូន អ្នកតំណាងម្នាក់មកពីប្រព័ន្ធយុត្តិធម៌ សុខាភិបាល សមាគមមណ្ឌលថែទាំកុមារ និងអ្នកចិត្តវិទ្យា។[134] ដូចបានពិភាក្សានៅក្នុងផ្នែកស្តីពីការថែទាំដោយឪពុកម្តាយធម៌ ហើយថាយើងបានដឹងថា FCF នឹងអនុវត្តសាកល្បងគណៈកម្មការថែទាំជំនួស ដែលមានភារកិច្ចធ្វើការផ្គូផ្គងក្នុងបញ្ហាស្មុំកូន។ ថ្វីបើប្រព័ន្ធនេះអាចមានអត្ថប្រយោជន៍ក្តី ប៉ុន្តែដូចបានបញ្ជាក់ខាងដើម ហើយថាចាំបាច់ត្រូវមានការការពារសុវត្ថិភាពចាំបាច់មួយចំនួន ដើម្បីចៀសវាងកុំឲ្យមានទំនាស់ផលប្រយោជន៍ (ឧ. ដកចេញនូវជនទាំងឡាយណា ដែលអាចទទួលអត្ថប្រយោជន៍ពីស្មុំកូន)។ ម្យ៉ាងទៀត ប្រព័ន្ធនេះក៏ត្រូវតែជាប្រព័ន្ធដឹកនាំដោយរដ្ឋាភិបាលផងដែរ និងត្រូវធានាឱ្យមានការចូលរួមពីកុមារ។

ទាក់ទងជាមួយនីតិវិធីការផ្គូផ្គងអាជ្ញាធរកម្ពុជាគួរស្វែងយល់បន្ថែម អំពីគុណសម្បត្តិនៃគណៈកម្មាធិការផ្គូផ្គងទទួលបន្ទុកទាំងស្មុំកូនក្នុងប្រទេស និងស្មុំកូនអន្តរប្រទេស។[135] គណៈកម្មាធិការផ្គូផ្គងរួមគ្នាមួយនឹងជួយសម្រួលដល់ការស្រាវជ្រាវរកគ្រួសារល្អបំផុត សម្រាប់កុមារដែលអាចធ្វើឡើងបានក្នុងពេលឆាប់បំផុត ដោយហេតុថា អ្នកប្រកបវិជ្ជាជីវៈអាជីពនឹងបានដឹងអំពីសំណុំឯកសាររបស់កុមារ និងឪពុកម្តាយចិញ្ចឹមទាំងអស់។ ពួកគេនឹងវាយតម្លៃលើសេចក្តីត្រូវការផ្នែកការអភិវឌ្ឍ ផ្នែកសង្គម ផ្នែកចំណេះដឹង និងផ្នែកវប្បធម៌របស់កុមារ ដែលមានសម្រាប់ឱ្យសុំទៅចិញ្ចឹម ដើម្បីផ្គូផ្គងកុមារទាំងនោះជាមួយឪពុកម្តាយចិញ្ចឹម

133 មាត្រា ២៧។

134 សូមមើលព័ត៌មានស្តីពីប្រទេស Burkina Faso នៅក្រោម: www.hcch.net នៅក្រោមផ្នែក "ស្មុំកូន"។ មានឧទាហរណ៍នៅក្រោមផ្នែកព័ត៌មានស្តីពីប្រទេសដទៃទៀត។

135 អាជ្ញាធរកម្ពុជា អាចស្វែងយល់អំពីគុណសម្បត្តិនៃការដាក់បញ្ចូលការស្វែងរកគ្រួសារធម៌នៅក្នុងគណៈកម្មាធិការផ្គូផ្គង។ អត្ថប្រយោជន៍នៃការមានគណៈកម្មាធិការផ្គូផ្គងនេះ គឺដោយសារគណៈកម្មាធិការអាចជួយធ្វើឱ្យដំណើរការកាន់តែមានភាពសាមញ្ញ ដែលអនុញ្ញាតឱ្យអាចតាមដានករណីបានកាន់តែរហ័ស។ ទោះយ៉ាងណាក្តី ហានិភ័យដែលអាចកើតមានពីការធ្វើបែបនេះ គឺនឹងធ្វើឱ្យមានយន្តការតាមដានកាន់តែតិចនៅក្នុងជំហាន (ពោលគឺ មានអ្នកប្រកបវិជ្ជាជីវៈអាជីពច្រើន) ដើម្បីត្រួតពិនិត្យលើការផ្គូផ្គង ហើយអាចមានលក្ខណៈអំណោយផលកាន់តែច្រើនដល់ការអនុវត្តខុសច្បាប់។ បន្ថែមលើនេះទៀត លក្ខណៈខុសគ្នានៅក្នុងវិធានការការពារកុមារផ្សេងៗគ្នា អាចមិនត្រូវបានគេយកចិត្តទុកដាក់នៅក្នុងដំណើរការការផ្គូផ្គង។

ដោយជាដំបូង គឺព្យាយាមស្វែងរកគ្រួសារនៅក្នុងតំបន់ដូចគ្នាសិន ហើយប្រសិនបើពុំអាចធ្វើបានទេ គឺអាចទៅរកនៅតំបន់ដទៃទៀតក្នុងប្រទេស។ ទីបំផុត ប្រសិនបើចាំបាច់ ពួកគេអាចពិគ្រោះជាមួយបញ្ជីចុះឈ្មោះរបស់ឪពុកម្ដាយចិញ្ចឹម ដែលត្រូវបានអនុម័តសម្រាប់សុំកូនអន្តរប្រទេស។[136] ដើម្បីអាចសម្រេចភារកិច្ចនេះបាន បញ្ជីចុះឈ្មោះនៅថ្នាក់កណ្ដាលមួយរបស់កុមារដែលមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបាន (សូមមើលអនុសាសន៍ទី ១៧) និងឪពុកម្ដាយចិញ្ចឹមទាំងអស់ (សូមមើលអនុសាសន៍ទី ១៩) គឺជាគន្លឹះ ដើម្បីអនុវត្តការងារនេះ។[137]

ជំហានបន្ទាប់នៅក្នុងរយៈពេលមធ្យម គឺត្រូវធានាឱ្យមានការបណ្ដុះបណ្ដាលត្រឹមត្រូវសម្រាប់គណៈកម្មាធិការផ្គូផ្គង។ ដំណើរការផ្ទៀងផ្ទាត់ប្រកបដោយគុណភាព មានភាពចាំបាច់ណាស់ ដើម្បីធានាលទ្ធផលល្អសម្រាប់កុមារ និងឪពុកម្ដាយចិញ្ចឹម។ ការបណ្ដុះបណ្ដាលកាន់តែប្រសើរ និងកាន់តែច្រើន គឺមានភាពចាំបាច់ ដើម្បីអភិវឌ្ឍ និងរក្សាគុណភាពបុគ្គលិកនៅក្នុងផ្នែកសុខុមាលភាពកុមារ។

សម្រាប់រយៈពេលវែង ប្រទេសកម្ពុជាអាចសាកល្បងប្រើប្រាស់គណៈកម្មាធិការផ្គូផ្គងសម្រាប់កុមារមកពីខេត្តក្នុងចំនួនកំណត់។ ការអនុវត្តសាកល្បងនេះអនុញ្ញាតឱ្យអាចធ្វើការកែប្រែដែលចាំបាច់នានា នៅមុនពេលអនុវត្តគណៈកម្មាធិការផ្គូផ្គងនៅថ្នាក់ជាតិ។

136 នៅ Lithuania ជាដំបូង ទីភ្នាក់ងារសុខមាលភាពថ្នាក់តំបន់ ឬថ្នាក់ក្រុង ព្យាយាមបង្រួបបង្រួមកុមារជាមួយគ្រួសារកំណើត ឬសាច់ញាតិដទៃទៀតសិន។ ប្រសិនបើមិនអាចធ្វើបានទេ កុមារអាចត្រូវបានយកទៅដាក់ក្នុងគ្រួសារ Lithuanian ណាមួយសម្រាប់សុំទៅចិញ្ចឹម ចិញ្ចឹមជាឪពុកម្ដាយធម៌ ឬជាអាណាព្យាបាល។ ប្រសិនបើមិនអាចរកគ្រួសារ Lithuanian ណាមួយបានទេ អាជ្ញាធរអាចស្វែងរកគ្រួសារនៅក្នុងបញ្ជីឈ្មោះ PAPs សម្រាប់សុំកូនអន្តរប្រទេស។ នៅសាធារណរដ្ឋ Slovak ពេលតុលាការ Slovak ប្រកាសថាកុមារមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបាន កុមារនោះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះកុមារត្រូវការការការពារជំនួស។ គេច្រើនចង់ស្វែងរកគ្រួសារចិញ្ចឹមដែលស្ថិតក្នុងតំបន់រដ្ឋបាលជាលំនៅរបស់កុមារសិន ហើយបើសិនជាចាំបាច់ នៅពេលបន្ទាប់មកទៀតគេនឹងស្វែងរកនៅក្នុងដែនដី Slovak ទាំងមូល។ ប្រសិនបើមិនអាចបង្កើតទំនាក់ទំនងជាលក្ខណៈផ្ទាល់ខ្លួនរវាងកុមារ និងអនាគតឪពុកម្ដាយចិញ្ចឹមមានលំនៅក្នុងប្រទេសទេ សំណុំឯកសារត្រូវបានបើកចំហរសម្រាប់សុំកូនអន្តរប្រទេស ហើយសំណុំឯកសារនោះត្រូវបានដាក់ជូនទៅមជ្ឈមណ្ឌលសម្រាប់ការការពារផ្នែកច្បាប់អន្តរជាតិរបស់កុមារ និងយុវជន (Centre for International Legal Protection of Children and Youth)។ ការអនុវត្តបែបនេះមានអត្ថប្រយោជន៍ខ្ពស់ព្រោះការអនុវត្តនេះគោរពតាមគោលការណ៍អំណាចស្ថិតនៅថ្នាក់រដ្ឋបាលទាបបំផុតក្នុងប្រទេសផងដែរ (ពេលគឺ តាមរយៈការស្វែងរក PAP នៅក្នុងតំបន់ផ្សេងៗក្នុងប្រទេសកំណើត)។

137 សូមមើលជាឧទាហរណ៍ ប្រទេសប្រេស៊ីល (ច្បាប់ឆ្នាំ ១៩៩០ ស្ដីពីកុមារ និងមនុស្សវ័យជំទង់ មាត្រា ៥០) ប្រទេសប៊ុលការី (សេចក្ដីបញ្ជាលេខ ៣ ស្ដីពីលក្ខខណ្ឌ និងនីតិវិធីដើម្បីផ្ដល់ការយល់ព្រម ចំពោះសុំកូនជាសញ្ជាតិប៊ុលការី សម្រាប់ជនបរទេស ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៣ ផ្នែកទី III); ប្រទេស Chile (ច្បាប់លេខ ១៩.៦២០/១៩៩៩ ស្ដីពីសុំកូន មាត្រា ៥); ប្រទេស Latvia (បទបញ្ញត្តិលេខ ១១១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៣ មាត្រា ៣) ប្រទេស Lithuania (សេចក្ដីសម្រេចលេខ ១៤២២ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០០២ នីតិវិធីសម្រាប់ការចុះបញ្ជីសុំកូននៅក្នុងសាធារណរដ្ឋ Lithuania និងក្រមរដ្ឋប្បវេណី មាត្រា ៣.២១៩)។

# អនុសាសន៍ទី ១៨

## បង្កើតគណៈកម្មាធិការផ្គូផ្គងដែលជាអ្នកទទួលបន្ទុកស្វែងរកឪពុកម្ដាយចិញ្ចឹម ល្អបំផុតសម្រាប់កុមារ (ទាំងសម្រាប់សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស)

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| គណៈកម្មាធិការផ្គូផ្គង | ១ រដ្ឋាភិបាលនឹងត្រូវបង្កើតគណៈកម្មាធិការផ្គូផ្គងមួយដែលរួមមានសមាសធាតុជំនាញការក្រុមការងារពហុវិស័យមកពីវិស័យផ្សេងៗ។ បន្ទាប់មកត្រូវគោរពតាម និងប្រើប្រាស់ការអនុវត្តល្អៗពីបណ្ដាប្រទេសដទៃ។<br>២ រដ្ឋាភិបាលនឹងស្វែងយល់អំពីគុណសម្បត្តិនៃគណៈកម្មាធិការផ្គូផ្គងទទួលបន្ទុកទាំងសុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស។ | ក្រសួង ស.អ.យ ក្រសួងយុត្តិធម៌។ | UNICEF, 3PC and FCF | ២០១៨ |
| នីតិវិធីផ្គូផ្គង | ១ ពិនិត្យលើច្បាប់ស្ដីពីសុំកូនអន្តរប្រទេស[138] ដែលបង្កើតនីតិវិធីផ្គូផ្គងជាមូលដ្ឋានគ្រឹះ ប៉ុន្តែចាំបាច់ត្រូវពង្រីកទៅដល់សុំកូននៅថ្នាក់ជាតិ ហើយដាក់បញ្ចូលការអនុវត្តផ្នែកសីលធម៌ដទៃទៀត (ឧ. នីតិវិធីផ្គូផ្គងមិនត្រូវចាប់ផ្ដើមនៅមុនពេលបានកំណត់លក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបានរបស់កុមារ និងលក្ខណៈសម្បត្តិរបស់ឪពុកម្ដាយចិញ្ចឹម ត្រូវបានអនុម័តឱ្យអាចសុំកូននោះឡើយ)។<br>២ រៀបចំកិច្ចប្រជុំតុមូលជាមួយភាគីពាក់ព័ន្ធនានារួមទាំងអ្នកពាក់ព័ន្ធក្នុងគណៈកម្មការថែទាំជំនួសអនុវត្តសាកល្បង ដើម្បីបង្កើតនីតិវិធីផ្គូផ្គងច្បាស់លាស់/មានតម្លាភាព។<br>៣ ព្រមព្រៀងលើការទទួលខុសត្រូវ។<br>៤ ដាក់បញ្ចូលនីតិវិធីនៅក្នុងច្បាប់ ឬគោលនយោបាយ។ | ក្រសួង សអយ ក្រសួងយុត្តិធម៌។ | UNICEF, 3PC, FCF and IOM | ២០១៨ |

138 មាត្រា ២៧។

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការបណ្តុះបណ្តាលគណៈកម្មាធិការផ្តល់ផ្គង | ១ នៅពេលដែលគោលបំណងរយៈពេលខ្លីត្រូវបានឆ្លើយតបរួចហើយ ត្រូវផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្នុងគណៈកម្មាធិការផ្តល់ផ្គង។<br>២ ផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីនីតិវិធីផ្តល់ផ្គង (ឧ. គេហទំព័រ/ការបោះពុម្ពផ្សាយរបស់អាជ្ញាធរកណ្តាលសម្រាប់សុំកូន)។ | ក្រសួង ស.អ.យ | UNICEF, 3PC, FCF and IOM | ២០១៩ តទៅ |
| **រយៈពេលវែង (ហួសពី ២០២៣)** | | | | |
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| អនុវត្តគម្រោងសាកល្បង | ១ សាកល្បងគណៈកម្មាធិការផ្តល់ផ្គងជាមួយកុមារមកពីខេត្តក្នុងចំនួនកំណត់។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF, 3PC, FCF and IOM | ២០២៣ តទៅ |



# ០៥

# ស្មុំកូនក្នុងប្រទេសនៅកម្ពុជា

© UNICEF Cambodia/2016/Buthdy Sem

ស្មុំកូនក្នុងប្រទេសនៅកម្ពុជា ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រមរដ្ឋប្បវេណីច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹងវិវាទប្រកាសស្តីពីការថែទាំជំនួស និងសេចក្តីពន្យល់ស្តីពីស្មុំកូនក្នុងប្រទេស។ មកដល់បច្ចុប្បន្ននេះ យើងឃើញថា ពុំទាន់មានការត្រៀម ការផ្គូផ្គង ឬការតាមដានបន្ត ចំពោះស្មុំកូនថ្នាក់ជាតិនោះឡើយ។ អវត្តមាននៃស្មុំកូនក្នុងប្រទេសក្នុងការអនុវត្តជាក់ស្តែង ធ្វើឱ្យមានការលំបាកក្នុងការអនុវត្តគោលការណ៍អំណាចស្ថិតនៅថ្នាក់ក្រោមបំផុតឱ្យបានត្រឹមត្រូវមុនពេលធ្វើការសម្រេចចិត្ត ដើម្បីដំណើរការស្មុំកូនអន្តរប្រទេស ដោយហេតុថា ជំហានដ៏មានសារៈសំខាន់មួយបានបាត់ ពោលគឺការស្រាវជ្រាវរកដំណោះស្រាយគ្រួសារអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា តាមរយៈស្មុំកូនក្នុងប្រទេស។

# អនុសាសន៍ទី

# ១៩

## ឪពុកម្តាយចិញ្ចឹម ត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របសម្រាប់សុំកូន ហើយបានទទួលការបណ្តុះបណ្តាល និងការគាំទ្រសមស្របក្នុងអំឡុងពេលនីតិវិធីសុំកូនក្នុងប្រទេស

**ST**

បង្កើតលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ក្នុងការប្រកាសលក្ខណៈសម្បត្តិអាចចូលរួម និងភាពសមស្របរបស់ ឪពុកម្តាយចិញ្ចឹម។

សម្រេចចិត្តថា តើនរណានឹងប្រកាសថាឪពុកម្តាយចិញ្ចឹមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចចូលរួម និងមានភាពសមស្រប ហើយបង្កើតនីតិវិធី។

**MT**

អភិវឌ្ឍកម្មវិធីផ្តល់ព័ត៌មាន និងប្រឹក្សាយោបល់សម្រាប់ ឪពុកម្តាយចិញ្ចឹម។

បណ្តុះបណ្តាលអ្នកប្រកបវិជ្ជាជីវៈអាជីព ដែលនឹងសម្រេចចិត្តលើលក្ខណៈសម្បត្តិអាចចូលរួម និងភាពសមស្របរបស់ឪពុកម្តាយចិញ្ចឹម។

**LT**

បង្កើតបញ្ជីចុះឈ្មោះមួយដែលនឹងរួមបញ្ចូលឪពុកម្តាយចិញ្ចឹមទាំងអស់មានលំនៅដ្ឋានជាប្រចាំក្នុងប្រទេសកម្ពុជា ដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិអាចចូលរួម និងសមស្របសម្រាប់សុំកូន។

សុំកូនគឺជាវិធានការការពារកុមារមួយ ដែលឆ្លើយតបចំពោះសេចក្តីត្រូវការរបស់កុមារជាក់លាក់ណាម្នាក់។ ដើម្បីអាចធ្វើការងារនេះបានប្រកបដោយប្រសិទ្ធភាព ឪពុកម្តាយចិញ្ចឹមគួរត្រូវបានប្រកាសថា មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របសម្រាប់សុំកូនយោងទៅតាមលក្ខខណ្ឌវិនិច្ឆ័យ និងនីតិវិធីជាក់លាក់។ ការងារនេះគួរត្រូវបានធ្វើឡើងមុនពេលការផ្គូផ្គងណាមួយត្រូវបានធ្វើឡើង (សូមមើលអនុសាសន៍ទី ១៩)។ ឪពុកម្តាយចិញ្ចឹម ក៏គួរបានទទួលការបណ្តុះបណ្តាល និងការគាំទ្រសមស្របផងដែរ។

ឪពុកម្តាយចិញ្ចឹម គួរមានវគ្គទទួលព័ត៌មាន និងប្រឹក្សាយោបល់មុនពេលពួកគេសម្រេចចិត្តសុំកូន។ វគ្គផ្តល់ព័ត៌មាន និងប្រឹក្សាយោបល់នឹងផ្តល់ឱកាសឱ្យឪពុកម្តាយចិញ្ចឹមបានរៀនសូត្រមានទស្សនៈប្រាកដនិយមស្តីពីសុំកូនឆ្លុះបញ្ចាំង និងវាយតម្លៃបំណិន និងសមត្ថភាពរបស់ខ្លួនក្នុងការដោះស្រាយជាមួយបញ្ហាប្រឈម ដែលអាចកើតឡើងនៅក្នុងការសុំកូនទៅចិញ្ចឹម និងដើម្បីអាចយល់បានកាន់តែច្បាស់អំពីដំណើរការសុំកូន។ ការប្រឹក្សាយោបល់ និងការគាំទ្រគួរមានបន្តទៅទៀតនៅក្នុងអំឡុងនីតិវិធីសុំកូនទាំងមូល និងអាចនៅក្រោយពេលសុំកូនផងដែរ តាមការចាំបាច់។ គួរតែមានបញ្ជីចុះឈ្មោះមួយ សម្រាប់ឪពុកម្តាយចិញ្ចឹមទាំងអស់ ដែលចង់សុំកូនក្នុងប្រទេសនៅកម្ពុជា។

ក្រមរដ្ឋប្បវេណី[139] បង្កើតលក្ខខណ្ឌវិនិច្ឆ័យមួយចំនួន សម្រាប់ការកំណត់លក្ខណៈសម្បត្តិអាចចូលរួម (លក្ខខណ្ឌវិនិច្ឆ័យផ្នែកច្បាប់) របស់ឪពុកម្តាយចិញ្ចឹម។ ប្រកាសស្តីពីការថែទាំជំនួស[140] បានបញ្ជាក់អំពីលក្ខខណ្ឌមួយចំនួនទាក់ទងជាមួយភាពសមស្របរបស់ឪពុកម្តាយចិញ្ចឹម (ពោលគឺសំណួរផ្នែកចិត្តសង្គម)។

ការវាយតម្លៃឪពុកម្ដាយចិញ្ចឹមក្នុងប្រទេសកម្ពុជា គួរផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើភាពសមស្របរបស់ឪពុកម្ដាយចិញ្ចឹម។ លក្ខខណ្ឌវិនិច្ឆ័យនាពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា ផ្ដោតការយកចិត្តទុកដាក់លើគោលជំហរផ្នែកសង្គមរបស់ PAPs ហិរញ្ញវត្ថុ និងស្តង់ដាផ្ទះសម្បែង។ សម្រាប់រយៈពេលខ្លី លក្ខខណ្ឌវិនិច្ឆ័យបន្ថែមទៀតទាក់ទងជាមួយលទ្ធភាពផ្នែកចិត្តសង្គមរបស់ឪពុកម្ដាយចិញ្ចឹមក្នុងការមើលថែកុមារ ក៏គួរត្រូវបានដាក់បញ្ចូលផងដែរ (ឧ. ប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិគ្រួសារ បុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ស្ថានភាពអាពាហ៍ពិពាហ៍ទំនាក់ទំនងជាមួយសាច់ញាតិសាច់ឆ្ងាយ បរិស្ថានរូបវន្ត/សង្គម ការចិញ្ចឹមបីបាច់កូនជាទូទៅ និងការចិញ្ចឹមបីបាច់កូនបែបជំនាញឯកទេស កត្តាជំរុញទឹកចិត្ត)។ លក្ខខណ្ឌវិនិច្ឆ័យបន្ថែមទាំងអស់នេះ គួរត្រូវបានបង្កើតឡើងនៅក្នុងទម្រង់ផ្លូវច្បាប់ដែលត្រូវការ។ ឪពុកម្ដាយចិញ្ចឹម គួរបានទទួលព័ត៌មានអំពីលក្ខខណ្ឌវិនិច្ឆ័យទាំងអស់ដែលនឹងត្រូវយកមក ដើម្បីវាយតម្លៃពួកគេ។

សម្រាប់រយៈពេលមធ្យម ប្រទេសកម្ពុជាត្រូវការបង្កើតឱ្យមាននីតិវិធី ដើម្បីវាយតម្លៃលក្ខណៈសម្បត្តិអាចចូលរួម និងភាពសមស្របរបស់ឪពុកម្ដាយចិញ្ចឹមនិងកំណត់ថា តើនរណាជាអ្នកទទួលបន្ទុកក្នុងការសម្រេចចិត្តនេះ។ ជម្រើសមួយ គឺអាចចាត់តាំងមន្ទីរ សអយ ជាអង្គភាពទទួលខុសត្រូវឱ្យតែពួកគាត់ត្រូវបានបំពាក់ឱ្យមានលក្ខណៈសម្បត្តិសមស្របហើយ។ ការធ្វើបែបនេះ អនុញ្ញាតឱ្យអាចធ្វើការសម្រេចចិត្តនៅថ្នាក់ខេត្ត ហើយនៅជិតជាមួយឪពុកម្ដាយចិញ្ចឹមបំផុតតាមដែលអាចធ្វើបាន។

ប្រទេសកម្ពុជាក៏ត្រូវការអភិវឌ្ឍឱ្យមានកម្មវិធីផ្ដល់ព័ត៌មាន និងប្រឹក្សាយោបល់សម្រាប់ឪពុកម្ដាយចិញ្ចឹម ដែលដាក់ពាក្យដើម្បីសុំកូនក្នុងប្រទេសផងដែរ ព្រោះថាបច្ចុប្បន្ននៅពុំទាន់មាននៅឡើយ។ ប្រទេសជាច្រើនបានអភិវឌ្ឍកម្មវិធីដែលប្រហែលជាអាចកែសម្រួល ដើម្បីយកមកប្រើសម្របតាមសេចក្ដីត្រូវការរបស់កម្ពុជាបាន។[141] កម្មវិធីទាំងអស់នេះអាចផ្ដល់ដោយអាជ្ញាធរសាធារណៈ (ដោយមន្ទីរ សអយ ក្នុងខេត្តនីមួយៗ) ឬដោយស្ថាប័នឯកជនឯករាជ្យ។ អាជ្ញាធរកម្ពុជាចាំបាច់ត្រូវតែធ្វើការសម្រេចចិត្តថា តើជម្រើសណាមួយជាជម្រើសល្អបំផុតសម្រាប់ប្រទេសកម្ពុជា។ ប្រសិនបើសម្រេចចិត្តថា មន្ទីរ ស.អ.យ ជាអ្នកផ្ដល់សេវាទាំងអស់នេះ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុរបស់មន្ទីរ សអយ ក៏ចាំបាច់ត្រូវពង្រឹងបន្ថែមផងដែរ។ គុណសម្បត្តិមួយរបស់ស្ថាប័នសាធារណៈ គឺថាការងាររបស់ស្ថាប័នទាំងនេះអាចមានភាពងាយស្រួលក្នុងការពិនិត្យតាមដាន ហើយអាចផ្ដល់សេវាដោយឥតគិតថ្លៃ។ អ្នកប្រកបវិជ្ជាជីវៈអាជីពដែលធ្វើការសម្រេចចិត្តលើលក្ខណៈសម្បត្តិអាចចូលរួម និងភាពសមស្របរបស់ឪពុកម្ដាយចិញ្ចឹម គួរតែមានគុណវុឌ្ឍិចាំបាច់នានា (ដោយជាអនុសាសន៍ គួរតែមានសញ្ញាបត្រខាងផ្នែកវិទ្យាសាស្ត្រអាកប្បកិរិយា ដូចជាផ្នែកសង្គមកិច្ចវិទ្យា ឬចិត្តវិទ្យា) ចំណេះដឹងផ្នែកការអនុវត្តជាក់ស្ដែង និងការបណ្ដុះបណ្ដាលសមស្រប។

សម្រាប់រយៈពេលវែង ឪពុកម្ដាយចិញ្ចឹម ដែលត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របដើម្បីសុំកូន គួរត្រូវបានដាក់បញ្ចូលក្នុងបញ្ជីចុះឈ្មោះឪពុកម្ដាយចិញ្ចឹម នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ បញ្ជីចុះឈ្មោះនេះ គឺជាឧបករណ៍គន្លឹះដើម្បីស្វែងរកគ្រួសារល្អបំផុត សម្រាប់កុមារនីមួយៗក្នុងអំឡុងដំណើរការផ្គូផ្គង (សូមមើលអនុសាសន៍ទី ១៨)។ ប្រទេសកម្ពុជានឹងត្រូវការអភិវឌ្ឍបញ្ជីចុះឈ្មោះនេះ សម្រាប់សុំកូនក្នុងប្រទេស និងធានាឱ្យបានថាទិន្នន័យស្ដីពីឪពុកម្ដាយចិញ្ចឹម គឺជាទិន្នន័យបច្ចុប្បន្នភាព។

139 មាត្រា ១០០៩។

140 មាត្រា ២៨ លើកឡើងអំពីប្រវត្តិផ្ទាល់ខ្លួនទាក់ទងជាមួយស្ថិរភាពផ្នែកអារម្មណ៍ និងទំនាក់ទំនងល្អ លំនៅដ្ឋានសមស្រប និងតំបន់រស់នៅមានសុវត្ថិភាព សមត្ថភាពអាចឱ្យកុមារមានលទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាពគ្រប់គ្រាន់ សមត្ថភាពក្នុងការផ្ដល់ការគាំទ្រផ្នែកសម្ភារៈ និងស្មារតីដល់កុមារ និងមានបំណងពិតប្រាកដើម្បីចិញ្ចឹមកូនចិញ្ចឹមនោះដូចកូនបង្កើត និងអារម្មណ៍របស់កូនដទៃទៀតដែលរស់នៅក្នុងគ្រួសារជាមួយគ្នា។

141 ឧទាហរណ៍ ការអនុវត្តតាមគំរូ PRIDE ផ្ដល់ក្របខ័ណ្ឌការងារតាមស្តង់ដារ មានភាពស៊ីសង្វាក់ និងមានរចនាសម្ព័ន្ធសម្រាប់ការជ្រើសរើសផ្នែកលើសមត្ថភាព ការត្រៀមរៀបចំ ការវាយតម្លៃ និងការជ្រើសរើសឪពុកម្ដាយធម៌ និងឪពុកម្ដាយចិញ្ចឹម នៅក្នុងការបណ្ដុះបណ្ដាលពេលផ្ដល់ និងការអភិវឌ្ឍវិជ្ជាជីវៈអាជីពជាបន្ត។ ការអនុវត្តតាមគំរូ PRIDE ត្រូវបានប្រើប្រាស់ទាំងមូល ឬជាផ្នែក នៅក្នុងបណ្ដាប្រទេសចំនួន ២៥ សូមមើល៖ www.cwla.org/pride-training

## អនុសាសន៍ទី ១៩

## ឪពុកម្តាយចិញ្ចឹមត្រូវបានប្រកាសថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមស្របសម្រាប់សុំកូន ហើយបានទទួលការបណ្តុះបណ្តាល និងការគាំទ្រសមស្របក្នុងអំឡុងពេលនីតិវិធីសុំកូនក្នុងប្រទេស

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| លក្ខណៈសម្បត្តិអាចចូលរួម និងភាពសមស្របរបស់ PAPs | ១ បង្កើតលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ ដើម្បីប្រកាសថា ឪពុកម្តាយចិញ្ចឹមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានភាពសមស្រប ដូចបានពោលខាងលើ។<br>២ បង្កើតនីតិវិធី ដើម្បីវាយតម្លៃលក្ខណៈសម្បត្តិអាចចូលរួម និងភាពសមស្របរបស់ឪពុកម្តាយចិញ្ចឹម។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF, 3PC and FCF | ២០១៨ |
| សម្រេចចិត្តថាតើនរណានឹងប្រកាសថា PAPs មានលក្ខណៈសម្បត្តិអាចចូលរួម និងមានភាពសមស្រប ហើយបង្កើតឱ្យមាននីតិវិធី។ | ១ ផ្សព្វផ្សាយលក្ខខណ្ឌវិនិច្ឆ័យឱ្យបានទូលំទូលាយក្នុងចំណោមសាធារណជនទូទៅ។<br>២ កំណត់ថាតើ នរណាជាអ្នកទទួលខុសត្រូវលើការសម្រេចចិត្តនេះ។<br>៣ កំណត់ថា តើអាជ្ញាធរទទួលខុសត្រូវនឹងធ្វើការជាមួយភាគីពាក់ព័ន្ធដទៃទៀតយ៉ាងដូចម្តេច។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| កម្មវិធីផ្តល់ព័ត៌មាន និងប្រឹក្សាយោបល់សម្រាប់ PAPs | ១ បង្កើតឱ្យមានកម្មវិធីផ្តល់ព័ត៌មាន និងប្រឹក្សាយោបល់ សម្រាប់ឪពុកម្តាយចិញ្ចឹមដែលដាក់ពាក្យសុំកូនក្នុងប្រទេស។<br>២ កំណត់ថា តើនរណានឹងអនុវត្តកម្មវិធីនេះ ដោយអាចជាអាជ្ញាធរសាធារណៈ (ឧ. ដោយមន្ទីរ សអយ ក្នុងខេត្តនីមួយៗ) ឬដោយអង្គភាពឯកជនឯករាជ្យ។ | ក្រសួង ស.អ.យ។ | UNICEF | ២០១៩ តទៅ |
| បំពាក់លក្ខណៈសម្បត្តិគ្រប់គ្រាន់ដល់អាជ្ញាធរ/អ្នកផ្តល់សេវាឱ្យអាចវាយតម្លៃ និងត្រៀមខ្លួន PAPs | ១ បណ្តុះបណ្តាល និងផ្តល់ធនធានដល់អាជ្ញាធរទទួលខុសត្រូវ និងអ្នកផ្តល់សេវា។<br>២ ធានាឱ្យមានការបណ្តុះបណ្តាលប្រចាំឆ្នាំ ដើម្បីឆ្លើយតបជាមួយបញ្ហាដែលកើតមានក្នុងនីតិវិធី។ | ក្រសួង សអយ។ | UNICEF, HCCH and ISS | ២០២០-២០២៣ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បញ្ជីចុះឈ្មោះ PAPs | ១ ផ្អែកលើការវាយតម្លៃលើឪពុកម្តាយចិញ្ចឹមទាំងអស់ ដែលមានលំនៅដ្ឋានជាប្រចាំក្នុងប្រទេសកម្ពុជា ត្រូវបង្កើតបញ្ជីចុះឈ្មោះមួយ ដែលមានព័ត៌មានលម្អិតពាក់ព័ន្ធនៅក្នុងនោះ។<br>២ កំណត់ថា តើនរណាជាម្ចាស់ផ្ទះគ្រប់គ្រងលើបញ្ជីចុះឈ្មោះឪពុកម្តាយចិញ្ចឹម។<br>៣ កំណត់ថា តើព័ត៌មានពីថ្នាក់តំបន់ នឹងត្រូវបានដាក់បញ្ចូលមកបញ្ជីចុះឈ្មោះថ្នាក់កណ្តាលតែមួយដោយរបៀបណា។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF | ២០២៣ តទៅ |

# អនុសាសន៍ទី ២០

## លើកកម្ពស់សុំកូនក្នុងប្រទេស

| | |
|---|---|
| **ST** | វិភាគការផ្លាស់ប្តូរនាពេលបច្ចុប្បន្ន និងកំណត់រកឧបសគ្គទាក់ទងជាមួយសុំកូនក្នុងប្រទេស។ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រការតស៊ូមតិស្តីពីការលើកកម្ពស់សុំកូនក្នុងប្រទេស។ |
| **MT** | អនុវត្តយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធសាស្ត្រដទៃទៀត។ |
| **LT** | ផ្តល់ការគាំទ្រជាក់លាក់ដល់គ្រួសារចិញ្ចឹម (មុនពេលក្នុងពេលនិងក្រោយពេលសុំកូន)។ |

គួរផ្តល់អាទិភាពដល់កុមារឱ្យត្រូវបានចិញ្ចឹមដោយគ្រួសារអចិន្ត្រៃយ៍នៅក្នុងប្រទេសដែលពួកគេស្គាល់ច្បាស់បំផុត ពោលគឺកន្លែងដែលពួកគេរស់នៅ។ ដើម្បីអាចធ្វើបែបនេះបាន ចាំបាច់ត្រូវលើកកម្ពស់សុំកូនក្នុងប្រទេស។ ក្នុងរដ្ឋដូចជាប្រទេសកម្ពុជាដែលសុំកូនពុំធ្លាប់ត្រូវបានពិចារណាតាមបែបប្រពៃណីថា ជាជម្រើសក្នុងការថែទាំកុមារដែលគ្មានគ្រួសារ ចាំបាច់ត្រូវលើកកម្ពស់ការយល់ដឹង និងការទទួលយកបែបវប្បធម៌នៃការសុំកូន។ ការស្តាបនាការយល់ដឹងអំពីសេចក្តីត្រូវការឲ្យមានគ្រួសារចិញ្ចឹមអាចទាមទារឱ្យមានការផ្លាស់ប្តូរឥរិយាបថសាធារណៈ។ ក្នុងការអភិវឌ្ឍប្រព័ន្ធសុំកូនថ្នាក់ជាតិមួយ ជាការសំខាន់ណាស់ដែលត្រូវដឹងថា តើអ្វីជាកត្តាដែលកំពុងរារាំងសុំកូនថ្នាក់ជាតិ និងត្រូវពិចារណាថា តើធ្វើយ៉ាងធ្វើណា ដើម្បីអាចលើកទឹកចិត្តគ្រួសារឱ្យសុំកុមារទៅចិញ្ចឹម។

ប្រទេសកម្ពុជាបានឈានជំហាន ដើម្បីលើកកម្ពស់សុំកូនក្នុងប្រទេស។ ជាក់ស្តែងថ្មីៗនេះកម្ពុជាបានបង្កើតសេចក្តីពន្យល់ស្តីពីសុំកូនក្នុងប្រទេសឆ្នាំ ២០១៦ ហើយបានផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម និងភាគីពាក់ព័ន្ធដទៃទៀត។[142]

ក្នុងរយៈពេលខ្លី អាជ្ញាធរកម្ពុជាគួរវិភាគលើបញ្ហាប្រឈមដែលមាននាពេលបច្ចុប្បន្ន និងកំណត់រកឧបសគ្គទាក់ទងជាមួយសុំកូនក្នុងប្រទេស ដោយរួមមានទាំងវិធានការនានាដែលអាចត្រូវបានធ្វើឡើង ដើម្បីជម្នះឧបសគ្គទាំងនោះ។ មេរៀនអាចប្រមូលបានពីការងាររបស់ IOM ដែលនឹងធ្វើការជាមួយអង្គការ កុមារនៅក្នុងគ្រួសារ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ដើម្បីជួយឱ្យអ្នកថែទាំជាឪពុកម្តាយធម៌រយៈពេលវែងសុំកុមារទៅចិញ្ចឹម។ យើងហាក់ឃើញថា មេរៀនក៏អាចប្រមូលបានពីការសាកល្បងគម្រោង FCF ស្តីពីគណៈកម្មការថែទាំជំនួសដែលជាគោលការណ៍នឹងគ្របដណ្តប់លើសុំកូនថ្នាក់ជាតិ។

142 ការបណ្តុះបណ្តាលសម្រាប់ចៅក្រមក្នុងខែធ្នូ ឆ្នាំ ២០១៣ និងក្នុងខែតុលា ឆ្នាំ ២០១៦។

រដ្ឋជាច្រើនបានឈានទៅបង្កើនចំនួនសុំកូនក្នុងប្រទេស តាមរយៈការពន្យល់យ៉ាងច្បាស់អំពីអត្ថន័យនៃសុំកូនដល់សាធារណជនទូទៅ និងធ្វើឱ្យសុំកូនក្នុងប្រទេសជាសេវាឥតគិតថ្លៃ។ យុទ្ធសាស្ត្រការតស៊ូមតិ ដើម្បីលើកកម្ពស់សុំកូនគួរដាក់បញ្ចូលគោលបំណង និងគោលដៅច្បាស់លាស់ ដោយផ្តោតគោលដៅលើក្រុមនានា និងសកម្មភាពដែលបានគ្រោងទុក។ ការតស៊ូមតិគួរត្រូវបានធ្វើឡើងទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។[143]

សម្រាប់រយៈពេលមធ្យម រដ្ឋាភិបាលគួរផ្តោតការយកចិត្តទុកដាក់លើការផ្លាស់ប្តូរឥរិយាបថសាធារណៈ ដើម្បីកសាងការយល់ដឹងអំពីសេចក្តីត្រូវការឱ្យមានគ្រួសារចិញ្ចឹម។ ប្រទេសមួយចំនួនបានទទួលជោគជ័យក្នុងការស្ថាបនាការយល់ដឹងស្តីពីសុំកូនសម្រាប់ជាប្រយោជន៍របស់កុមារ និងគ្រួសារតាមរយៈសេចក្តីប្រកាសជាសាធារណៈ យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមយ៉ាងសកម្មរបស់វិស័យរដ្ឋាភិបាលជាច្រើននៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិ។[144]

ក្នុងរយៈពេលមធ្យម ប្រទេសកម្ពុជាគួរផ្តោតគោលដៅជាពិសេសទៅលើ គកនក និងមណ្ឌលសុខភាពក្នុងសហគមន៍មូលដ្ឋាន ដោយហេតុថា ពួកគេនៅជិតស្និទ្ធជាមួយសហគមន៍ ហើយពួកគេអាចមានតួនាទីគន្លឹះក្នុងការផ្លាស់ប្តូរឥរិយាបថ។

ជាការសំខាន់ណាស់ដែលត្រូវគាំទ្រដល់ឪពុកម្តាយចិញ្ចឹម និងគ្រួសារចិញ្ចឹម ព្រមទាំងកាត់បន្ថយការលំបាកដែលអាចកើតមាននានា។ ឧ. ការដាក់ពាក្យទៅតុលាការ គឺជាបញ្ហាប្រឈមសម្រាប់ឪពុកម្តាយចិញ្ចឹមជាច្រើន។ ហេតុនេះ ក្រុមស្រាវជ្រាវសូមផ្តល់អនុសាសន៍ថា សម្រាប់រយៈពេលវែង ត្រូវមានជំនួយនិងការជួយជ្រោមជ្រែងផ្នែកច្បាប់ដោយឥតគិតថ្លៃក្នុងអំឡុងនីតិវិធីតុលាការ។ ជាជម្រើសមួយទៀត មន្ទីរ ស.អ.យ អាចដាក់ពាក្យទៅកាន់តុលាការ និងបង្ហាញសំណុំឯកសារសុំកូនតំណាងឱ្យឪពុកម្តាយចិញ្ចឹម។ វិធានការមួយទៀត គឺត្រូវថែងអំពីចំនួនទឹកប្រាក់សរុប សម្រាប់កុមារម្នាក់ដែលនឹងលើកទឹកចិត្តឱ្យគេសុំកុមារទៅចិញ្ចឹម។

ប្រទេសកម្ពុជាគួរផ្តល់សេវាក្រោយការយកទៅដាក់នៅក្នុងគ្រួសារចិញ្ចឹមជូនដល់គ្រួសារទាំងនោះ (ឧ. ដូចជានៅក្នុងប្រទេស Lithuania ដែលក្នុងក្រុងនីមួយៗមានអ្នកសង្គមកិច្ចត្រូវបានទទួលស្គាល់គុណភាពយ៉ាងហោចណាស់ពីរនាក់ ដែលផ្តល់ការបណ្តុះបណ្តាលសម្រាប់ឪពុកម្តាយចិញ្ចឹម ហើយសេវាក្រោយ ការយកទៅដាក់នៅគ្រួសារចិញ្ចឹមត្រូវបានផ្តល់ជូនដល់គ្រួសារទាំងនោះ។[145] អាហ្វ្រិកខាងត្បូងក៏ផ្តល់សេវាដូច្នេះដែរ)។ អាជ្ញាធរពាក់ព័ន្ធអាចពិនិត្យតាមដាន និងសិក្សាបញ្ហានានាដែលគ្រួសារចិញ្ចឹមជួបប្រទះ ព្រមទាំងផ្តល់សេវាថ្មីកាន់តែប្រសើរ និងពង្រីកកាន់តែធំសម្រាប់កុមារ និងគ្រួសារ។

143 សូមមើលការផ្តួចផ្តើមគំនិតប្រទេស Ugandan ដើម្បីលើកកម្ពស់សុំកូនក្នុងប្រទេសនៅ៖ http://ugandansadopt.ug/. See also ACPF work to promote national adoptions and prevent illicit practices: http://www.iss-ssi.org/images/News/Illegal_Adoption_ISS_Professional_Handbook.pdf

144 សូមមើលយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកូឡុំប៊ី៖ www.icbf.gov.co/portal/page/portal/PortalICBF/Especiales/prueba/Bienestar/ProgramaAdopciones); and Chile: www.sename.cl/web/que-es-la-adopcion

145 អ្នកសង្គមកិច្ចទាំងនេះផ្តល់ការបណ្តុះបណ្តាល ការវាយតម្លៃ និងការប្រកាសអំពីភាពសមស្របអាចឱ្យសុំទៅចិញ្ចឹមបាន និងការគាំទ្រក្រោយពេលយកទៅដាក់នៅក្នុងការថែទាំជំនួសទាំងនៅក្នុងគ្រួសារធម៌ និងជាមួយអនាគតឪពុកម្តាយចិញ្ចឹម៖ http://www.vaikoteises.lt/media/file/gimk%20dar/GIMK_kontaktai_២០១៧_vasaris.pdf

## អនុសាសន៍ទី ២០

# លើកកម្ពស់ស្មុំកូនក្នុងប្រទេស

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| **តើចាំបាច់ត្រូវមានអ្វីខ្លះ?** | **តើនឹងត្រូវអនុវត្តដោយរបៀបណា?** | **តើនរណាទទួលខុសត្រូវ?** | **តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ?** | **រយៈពេល** |
| កែលម្អស្ថានភាពនាពេលបច្ចុប្បន្ននៅក្នុងស្មុំកូនក្នុងប្រទេស | ១ កំណត់រកឧបសគ្គទាក់ទងជាមួយស្មុំកូនក្នុងប្រទេស រួមទាំងវិធានការដែលអាចត្រូវបានធ្វើឡើង ដើម្បីជម្នះឧបសគ្គទាំងនោះ។<br>២ ពិចារណាក្នុងការដាក់ឱ្យស្មុំកូនក្នុងប្រទេសជាសេវាឥតគិតថ្លៃ។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF, IOM, Children in Families | ២០១៨ |
| យុទ្ធសាស្ត្រការតស៊ូមតិស្តីពីការលើកកម្ពស់ស្មុំកូនក្នុងប្រទេស | ១ រៀបចំយុទ្ធសាស្ត្រតស៊ូមតិដើម្បីលើកកម្ពស់ស្មុំកូន និងពិនិត្យទៅលើឧទាហរណ៍អន្តរជាតិសម្រាប់ជាកត្តាជំរុញទឹកចិត្ត។<br>២ បង្កើតគោលបំណង ក្រុមគោលដៅច្បាស់លាស់ និងផែនការដែលបានគ្រោងទុក។<br>៣ អនុវត្តយុទ្ធសាស្ត្រការតស៊ូមតិ។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF | ២០១៨ |

| រយៈពេលមធ្យម (២០១៩-២០២៣) | | | | |
|---|---|---|---|---|
| **តើចាំបាច់ត្រូវមានអ្វីខ្លះ?** | **តើនឹងត្រូវអនុវត្តដោយរបៀបណា?** | **តើនរណាទទួលខុសត្រូវ?** | **តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ?** | **រយៈពេល** |
| យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធសាស្ត្រដទៃទៀត | ១ ផ្តោតការយកចិត្តទុកដាក់លើការផ្លាស់ប្តូរឥរិយាបថសាធារណៈ ដើម្បីស្ថាបនាការយល់ដឹងអំពីសេចក្តីត្រូវការសម្រាប់គ្រួសារចិញ្ចឹម។<br>២ ស្ថាបនាការយល់ដឹងអំពីស្មុំកូន សម្រាប់ជាអត្ថប្រយោជន៍របស់កុមារ និងគ្រួសារ តាមរយៈសេចក្តីប្រកាសជាសាធារណៈ យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមយ៉ាងសកម្មរបស់វិស័យរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិ។<br>៣ ផ្តោតគោលដៅលើ គកនក និងមណ្ឌលសុខភាពក្នុងសហគមន៍មូលដ្ឋាន ដោយហេតុថា ពួកគេនៅកៀកសហគមន៍ ហើយអាចមានតួនាទីគន្លឹះក្នុងការផ្លាស់ប្តូរឥរិយាបថ។ | ក្រសួង សអយ និងក្រសួងយុត្តិធម៌។ | UNICEF | ២០១៩ តទៅ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការគាំទ្រដាក់លាក់ផ្តល់ជូនដល់គ្រួសារចិញ្ចឹម (មុនពេលក្នុងពេល និងក្រោយពេលសុំកូន)។ | ១ ពិភាក្សា និងបង្កើតការគាំទ្រដាក់លាក់ជូនដល់គ្រួសារចិញ្ចឹម។<br>២ ពិចារណាឱ្យតុលាការផ្តល់ជំនួយ និងការជួយជ្រោមជ្រែងផ្នែកច្បាប់ដោយឥតគិតថ្លៃក្នុងអំឡុងពេលនីតិវិធីតុលាការ។<br>៣ ពិចារណាថាតើ មន្ទីរ សអយ អាចដាក់ពាក្យទៅតុលាការនិងបង្ហាញសំណុំឯកសារតាងនាមឱ្យឪពុកម្តាយចិញ្ចឹមបាន ឬទេ។<br>៤ ពិចារណាថាតើ ទឹកប្រាក់សរុបសម្រាប់កុមារម្នាក់អាចត្រូវបានផ្តល់ជូន ដែលនឹងលើកទឹកចិត្តឱ្យគេសុំកូន។<br>៥ បង្កើតសេវាក្រោយយកកុមារទៅដាក់ក្នុងគ្រួសារចិញ្ចឹម ដើម្បីគាំទ្រដល់គ្រួសារទាំងនោះ។<br>៦ ពិនិត្យតាមដាន និងសិក្សាបញ្ហានានាដែលគ្រួសារចិញ្ចឹមជួបប្រទះ និងផ្តល់សេវាថ្មីមានភាពប្រសើរឡើង និងកាន់តែធំជាងមុនសម្រាប់កុមារ និងគ្រួសារ។ | ក្រសួង ស.អ.យ និងក្រសួងយុត្តិធម៌។ | UNICEF | ២០២៣ តទៅ |




# ០៦

# ស្មុំកូនអន្តរប្រទេសក្នុងប្រទេសកម្ពុជា

ស្មុំកូនអន្តរប្រទេសអាចផ្តល់គុណសម្បត្តិឱ្យមានគ្រួសារអចិន្ត្រៃយ៍ សម្រាប់កុមារដែលពុំអាចរកគ្រួសារសមស្របបាននៅក្នុងរដ្ឋកំណើតរបស់ខ្លួន។[146] ទោះយ៉ាងណាក្តី ដំបូងបំផុតចាំបាច់ត្រូវធានាយ៉ាងណាឱ្យគោលការណ៍នៃអំណាចនៅថ្នាក់ក្រោមបំផុតត្រូវបានអនុវត្ត ហើយដំណោះស្រាយក្នុងស្រុកត្រូវបានយកមកពិចារណាជាមុនសិន។ ចំណុចនេះទាមទារឱ្យមានប្រព័ន្ធការថែទាំជំនួសដែលដំណើរការមួយ (ឧ. ការគាំទ្រដល់គ្រួសារកំណើត និងសមាហរណកម្ម) ក៏ដូចជា ប្រព័ន្ធស្មុំកូនក្នុងប្រទេសដូចបានពិភាក្សាខាងលើ)។ តាមការយល់ឃើញផ្ទាល់របស់យើងខ្ញុំ យ៉ាងហោចណាស់ក៏ត្រូវការពេលពីរឆ្នាំដែរមុនពេលគោលការណ៍អំណាចនៅថ្នាក់ក្រោមបំផុតអាចមានប្រតិបត្តិការដោយរលូន។ ហេតុនេះចាប់ពីពេលនេះរហូតដល់ពេលនោះ យើងខ្ញុំសូមផ្តល់អនុសាសន៍ប្រឆាំង «ការបើកទូលាយ» ទាំងស្រុងចំពោះប្រព័ន្ធស្មុំកូនអន្តរប្រទេស។ ក្នុងអំឡុងអន្តរកាលនេះអ្វីដែលបានលើកឡើងពុំជំទាស់ជាមួយផ្នែកការអនុវត្តគម្រោងសាកល្បងទៅលើច្បាប់ និងគោលនយោបាយស្មុំកូនអន្តរប្រទេសដែលមានជាធរមាននោះឡើយ ជាពិសេសសម្រាប់កុមារមានតម្រូវការពិសេស។

យើងខ្ញុំសូមផ្តល់អនុសាសន៍អោយរដ្ឋ អនុម័តឱ្យមានយុទ្ធវិធីរួមមួយក្នុងការឆ្លើយតបចំពោះសេចក្តីសម្រេចរបស់កម្ពុជាទាក់ទងជាមួយចំណុចនេះ។ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធានាឱ្យបានថា ក្របខ័ណ្ឌការងារស្របច្បាប់ផ្ទៃក្នុងរបស់ខ្លួនអនុលោមតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣។ ទាក់ទងជាមួយចំណុចនេះ ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ក៏ដូចជាប្រកាសជាច្រើនស្តីពីស្មុំកូនអន្តរប្រទេសត្រូវបានអនុម័តក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ (សូមមើលឧបសម្ព័ន្ធទី ២)។ សមិទ្ធផលដ៏ល្អថ្លៃថ្លាទាំងអស់នេះបង្កើតជាមូលដ្ឋានដ៏រឹងមាំសម្រាប់ប្រព័ន្ធការពារកុមារ។

បច្ចុប្បន្នមានបញ្ហាប្រឈមពីរ៖ ទីមួយ គឺដើម្បីធានាឱ្យបានថា ស្មុំកូនអន្តរប្រទេសត្រូវបានដាក់បញ្ចូលយ៉ាងល្អទៅក្នុងប្រព័ន្ធការពារកុមារក្នុងប្រទេស និងគោលការណ៍អំណាចនៅថ្នាក់ក្រោមបំផុតត្រូវបានអនុវត្តនៅគ្រប់ករណីទាំងអស់នៃស្មុំកូនអន្តរប្រទេស។ បញ្ហាប្រឈមទីពីរ គឺក្នុងការអនុវត្តក្របខ័ណ្ឌការងារផ្នែកច្បាប់ឱ្យបានសមស្រប ជាពិសេសដើម្បីធានាឱ្យបានថា អាជ្ញាធរទាំងអស់ដែលចូលរួមក្នុងនីតិវិធីស្មុំកូនមានអំណាច និងធនធានដែលចាំបាច់ ក៏ដូចជា ចំណេះដឹង បទពិសោធន៍ និងការអប់រំដែលចាំបាច់ទាក់ទងជាមួយការការពារកុមារ និងស្មុំកូន។ ចំណុចនេះក៏ទាមទារឱ្យមានបុគ្គលិកសង្គមកិច្ចសមស្រប ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីអនុវត្ត និងពិនិត្យតាមដាននីតិវិធីស្មុំកូនដែលចាំបាច់ទាំងអស់ (សូមមើលអនុសាសន៍ទី ៣)។ នៅផ្នែកបន្ទាប់នេះ ក្រុមការងារស្របពេល ដែលទទួលស្គាល់ថា មានសមិទ្ធផលជាច្រើនបានធ្វើកន្លងរួចមកហើយក្តី ប៉ុន្តែយើងខ្ញុំសូមផ្តោតការយកចិត្តទុកដាក់អនុសាសន៍របស់យើងទៅលើបញ្ហាប្រឈមធំៗដែលនៅសល់ទាក់ទងជាមួយស្មុំកូនអន្តរប្រទេស។

146 បុព្វកថានៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៩៣

# អនុសាសន៍ទី

# ២១

## ផ្តល់ព័ត៌មានអំពីលក្ខណៈសម្បត្តិ និងសេចក្តីត្រូវការរបស់កុមារមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបានដែលត្រូវការសុំកូនអន្តរប្រទេស

**ST** បញ្ជាក់ចំនួន និងប្រភេទកុមារ ដែលត្រូវការគ្រួសារដោយមានការសង្កត់ធ្ងន់ជាក់លាក់ទៅលើកុមារមានតម្រូវការពិសេស (ឧ. ក្មេងធំ ក្រុមបងប្អូនបង្កើតកុមារពិការ)។ បញ្ជាក់ចំនួនការដាក់ពាក្យសុំសុំកូន និងលក្ខណៈសម្បត្តិនៃឪពុកម្តាយចិញ្ចឹមដែលនឹងត្រូវបានទទួលយក។

**MT** គម្រោងសាកល្បងដោយមានការអនុវត្តបញ្ជាសលំហូរនៃសំណុំឯកសារ។

**LT** ពិនិត្យតាមដាន និងតាមដានបន្ត។

ប្រសិនបើរដ្ឋទទួលដឹងថា កុមារណាខ្លះដែលត្រូវការសុំកូនអន្តរប្រទេសក្នុងប្រទេសកម្ពុជា ពួកគេនឹងអាចបញ្ជូនសំណុំឯកសារឪពុកម្តាយចិញ្ចឹម ដែលឆ្លើយតបចំពោះសេចក្តីត្រូវការរបស់កុមារទាំងនោះ។ ដើម្បីចៀសវាងការដាក់សម្ពាធពីប្រទេសទទួលរដ្ឋកំណើតត្រូវបានលើកទឹកចិត្តឱ្យបញ្ជាក់ឱ្យច្បាស់ តាមរយៈអាជ្ញាធរកណ្តាលរបស់ខ្លួននូវដែនកំណត់នានាទាក់ទងជាមួយនឹងប្រភេទការដាក់ពាក្យ សម្រាប់សុំកូនអន្តរប្រទេសដែលខ្លួននឹងទទួលយកដោយយោងទៅលើចំនួន និងលក្ខណៈសម្បត្តិនៃកុមារ ដែលមានលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមជាលក្ខណៈអន្តរប្រទេសក្នុងរដ្ឋនោះ។ រដ្ឋទទួលត្រូវគោរពពាល់ដែនកំណត់នានាដែលបានដាក់ចេញ។[147]

សម្រាប់រយៈពេលខ្លី ផ្អែកលើកលក្ខណៈសម្បត្តិរបស់កុមារនៅក្នុងប្រព័ន្ធទិន្នន័យមេកណ្តាល (អនុសាសន៍ទី ២) ICAA អាចបញ្ជាក់ចំនួន និងលក្ខណៈសម្បត្តិនៃសំណុំឯកសាររបស់ PAPs ដែលត្រូវការ។ ព័ត៌មាននេះអាចត្រូវបានប្រាស្រ័យទាក់ទងប្រាប់ទៅអាជ្ញាធរកណ្តាលនៃរដ្ឋទទួលតាមរយៈដូចជា លិខិតសាមញ្ញជាលាយលក្ខណ៍អក្សរ (សូមមើលអនុសាសន៍បន្ទាប់) ឬគេហទំព័ររបស់ក្រសួង សអយ។ ICAA ក៏អាចបញ្ជាក់លក្ខខណ្ឌវិនិច្ឆ័យ និងការតម្រូវសម្រាប់ឪពុកម្តាយចិញ្ចឹម ដែលចាំបាច់ត្រូវតែមាន។ វិធីសាស្ត្រនេះអាចជួយឱ្យសម្រេចបាននូវកម្មវិធីសុំកូនអន្តរប្រទេស ដែលយកកុមារជាចម្បង តាមរយៈការផ្គូផ្គងកុមារជាក់លាក់ជាមួយគ្រួសារសមស្របបំផុត ហើយជួយឪពុកម្តាយចិញ្ចឹម ដើម្បីចៀសវាងការរំពឹងទុកមិនសមហេតុផលរយៈពេលរង់ចាំយូរបាត់បង់ឆន្ទៈ ក៏ដូចជារារាំងកុំឱ្យមានការខកចិត្ត ចំពោះកុមារផងដែរ។

147 អនុសាសន៍ទី៨ របស់គណៈកម្មាធិការពិសេសឆ្នាំ ២០១៥

កុមារមានសេចក្តីត្រូវការពិសេស គួរមានឪពុកម្តាយចិញ្ចឹមជាអ្នកដែលមានជំនាញពិសេស។ ពុំមែនគ្រប់ PAPs ទាំងអស់សុទ្ធតែមានជំនាញដែលចាំបាច់ ដើម្បីមើលថែកុមារទាំងនេះ។ នាពេលបច្ចុប្បន្ននេះកុមារជាច្រើន ដែលមានតម្រូវការពិសេសរង់ចាំគ្រួសារសមស្របអស់រយៈពេលជាច្រើនឆ្នាំ។ កុមារទាំងនេះមួយចំនួនពុំអាចស្វែងរកគ្រួសារបាន តាមរយៈសុំកូនក្នុងប្រទេសទេ។ ភាពយឺតយ៉ាវនៅក្នុងការចាប់ផ្តើមនីតិវិធីសុំកូន សម្រាប់កុមារទាំងអស់នេះ គឺផ្ទុយជាមួយឧត្តមប្រយោជន៍របស់ពួកគេ។ ហេតុនេះកុមារមានតម្រូវការពិសេសគួរបានទទួលអាទិភាព សម្រាប់សុំកូនអន្តរប្រទេស។ ប្រទេសកម្ពុជាគួរពិចារណាចាប់ផ្តើមនៅក្នុងរយៈពេលមធ្យមនូវគម្រោងសាកល្បង ដើរតាមវិធីសាស្ត្រការដើរបញ្ច្រាសពីលំហូរសំណុំឯកសារ៖[148]

- វាយតម្លៃចំនួន និងលក្ខណៈសម្បត្តិនៃកុមារ ដែលមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានជាកុមារមានសេចក្តីត្រូវការពិសេស
- ចែករំលែកព័ត៌មានលម្អិតទាំងអស់នេះ (រក្សាទុកព័ត៌មានកំណត់អត្តសញ្ញាណទាំងអស់ជាការណ៍សម្ងាត់ ដើម្បីការពារឯកជនភាពរបស់កុមារ) ជាមួយស្ថាប័នបានការទទួលស្គាល់សម្រាប់សុំកូន (AAB) របស់រដ្ឋទទួលដោយក្នុងនោះកិច្ចព្រមព្រៀងសហប្រតិបត្តិការ គឺត្រូវបានចុះហត្ថលេខា រួចហើយទាក់ទងជាមួយសេចក្តីត្រូវការទាំងនោះ
- ស្នើសុំឱ្យរដ្ឋទទួលស្វែងរកឪពុកម្តាយចិញ្ចឹម ដែលមានសមត្ថភាពអាចមើលថែកុមារជាក់លាក់ណាម្នាក់ ដែលជាកុមារមានសេចក្តីត្រូវការពិសេស និង
- បន្ទាប់មកធ្វើការផ្គូផ្គង

ការវាយតម្លៃទៅលើកុមារមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបាន ដែលជាកុមារមានសេចក្តីត្រូវការពិសេសអាចត្រូវបានសម្របសម្រួលដោយការងាររបស់ ISS និងសៀវភៅសម្រាប់អ្នកអាជីពរបស់ ISS ដែលធ្វើការវាយតម្លៃទៅលើសេចក្តីត្រូវការជាលក្ខណៈបុគ្គលរបស់កុមារម្នាក់ៗ (សូមមើលអនុសាសន៍ទី ៣ ស្តីពីការបណ្តុះបណ្តាលការវាយតម្លៃសេចក្តីត្រូវការ ជាបុគ្គលរបស់កុមារ)។

ជាការសំខាន់ដែលត្រូវជម្រាបព័ត៌មានដល់អាជ្ញាធរកណ្តាល និង AABs អំពីសេចក្តីសម្រេចជាវិជ្ជមាន និងជាអវិជ្ជមានស្តីពីការផ្គូផ្គង។ ការផ្តល់ការលើកទឹកចិត្ត ដែលមានលក្ខណៈជំរុញទឹកចិត្តនឹងអាចជួយឱ្យមានកិច្ចសហការនាពេលអនាគតថែមទៀត ព្រោះរដ្ឋទទួលនឹងបានដឹងកាន់តែប្រសើរអំពីរបៀប ដើម្បីត្រៀមខ្លួនឪពុកម្តាយចិញ្ចឹម។

ក្នុងរយៈពេលវែង អាជ្ញាធរគួរពិនិត្យតាមដាន និងវាយតម្លៃសុំកូនជាពិសេសថាតើសេវា និងការគាំទ្រអ្វីខ្លះដែលត្រូវបានផ្តល់ឱ្យដល់កូនចិញ្ចឹម និងគ្រួសាររបស់ពួកគេ។ការងារអាចក្លាយជាឧបករណ៍មួយ ដើម្បីវាយតម្លៃសកម្មភាពរបស់ AABs ។ ប្រសិនបើមានសុំកូនត្រូវអាក់ខានអាជ្ញាធរអាចពិចារណាថា តើមានមូលហេតុធ្ងន់ធ្ងរ ដើម្បីបញ្ឈប់កិច្ចសហប្រតិបត្តិការ ឬយ៉ាងណា។

148 សូមមើលមគ្គុទ្ទេសក៍ពីការអនុវត្តល្អលេខ ១ ៖ កំណត់សម្គាល់លេខ ២០ ខាងលើ វាក្យខ័ណ្ឌ ៣៩៤

# អនុសាសន៍ទី ២១

## ផ្តល់ព័ត៌មានអំពីលក្ខណៈសម្បត្តិ និងសេចក្តីត្រូវការរបស់កុមារមានលក្ខណៈសម្បត្តិអាចដាក់ឱ្យសុំទៅចិញ្ចឹមបានជាលក្ខណៈសុំកូនអន្តរប្រទេស

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បញ្ជាក់ចំនួន និងប្រភេទកុមារដែលត្រូវការគ្រួសារដោយផ្តោតការយកចិត្តទុកដាក់ដាក់លាក់ទៅលើកុមារមានសេចក្តីត្រូវការពិសេស (ឧ. ក្មេងធំ ក្រុមបងប្អូនបង្កើត កុមារពិការ) | ➀ ផ្អែកលើប្រព័ន្ធទិន្នន័យមេនៅថ្នាក់កណ្តាលដូចក្នុងអនុសាសន៍ទី ២ និងប្រព័ន្ធទិន្នន័យមេអំពីសុំកូនក្នុងអនុសាសន៍ទី ១៧ ដែលបញ្ជាក់ពីចំនួន និងប្រភេទនៃកុមារដែលត្រូវការគ្រួសារ។<br>➁ កំណត់រកកុមារដែលមានសេចក្តីត្រូវការពិសេស ហើយរៀបរាប់សេចក្តីត្រូវការពិសេសរបស់ពួកគេនៅក្នុងផ្នែកស្តីពីការទាមទារជាក់លាក់។ | ក្រសួង ស.អ.យ ICAA។ | UNICEF | ២០១៨ |
| បញ្ជាក់ចំនួនការដាក់ពាក្យសុំកូន និងលក្ខណៈសម្បត្តិនៃ PAPs ដែលនឹងត្រូវបានទទួលយក | ➀ ផ្អែកលើចំនួន និងប្រភេទកុមារដែលត្រូវបានកំណត់អត្តសញ្ញាណឃើញ សូមបញ្ជាក់ចំនួន និងលក្ខណៈសម្បត្តិ និងសំណុំឯកសាររបស់ឪពុកម្តាយចិញ្ចឹមដែលត្រូវ។<br>➁ បញ្ជាក់លក្ខខណ្ឌវិនិច្ឆ័យដែលទាមទារ និងការតម្រូវសម្រាប់ PAPs<br>➂ ប្រាស្រ័យទាក់ទងព័ត៌មាននេះទៅកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួល មិនថាតាមរយៈគេហទំព័រ ឬតាមលិខិតគោលនយោបាយក្តី។ | ក្រសួង ស.អ.យ ICAA។ | UNICEF | ២០១៨ |

## រយៈពេលមធ្យម (២០១៩-២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| គម្រោងសាកល្បងដែលប្រើការបញ្ជាសលំហូរសំណុំឯកសារ[149] | ១ ជ្រើសរើសកុមារមានលក្ខណៈសម្បត្តិអាចសុំទៅចិញ្ចឹមបានជាកុមារមានសេចក្តីត្រូវការពិសេសមួយ។<br>២ ចែករំលែកព័ត៌មានលម្អិតរបស់កុមារ (ទុកតែព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបានដើម្បីការពារឯកជនភាពរបស់កុមារ) ជាមួយរដ្ឋទទួលទាំងឡាយណាដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរួចហើយ។<br>៣ កំណត់រយៈពេលសម្រាប់រដ្ឋទទួលឱ្យស្វែងរកឪពុកម្តាយចិញ្ចឹម ដែលសមត្ថភាពមើលថែកុមារជាក់លាក់ណាម្នាក់ ដែលជាកុមារមានសេចក្តីត្រូវការពិសេសរួចហើយធ្វើការផ្គូផ្គង។<br>៤ រដ្ឋទទួលជម្រាបប្រាប់ប្រទេសកម្ពុជាអំពីសេចក្តីសម្រេច ចំពោះការអនុម័តស្ថាពរ។ | ក្រសួង ស.អ.យ ICAA។ | UNICEF, PB, HCCH and receiving States | ២០១៩ តទៅ |
| កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរកណ្តាល និង AABs | ១ បង្កើតទម្រង់បទដ្ឋានដោយគូសបញ្ជាក់ហេតុផលសម្រាប់សេចក្តីសម្រេចចិត្តការផ្គូផ្គង។<br>២ នៅពេលបញ្ចប់សេចក្តីសម្រេចចិត្តការផ្គូផ្គងរួចហើយ សូមជម្រាបប្រាប់អាជ្ញាធរកណ្តាល និង AABs អំពីសេចក្តីសម្រេចចិត្តជាវិជ្ជមាន និងជាអវិជ្ជមានអំពីការផ្គូផ្គងនោះ។ | ក្រសួង ស.អ.យ ICAA។ | MoSVY, ICAA | ២០១៩ តទៅ |

## រយៈពេលវែង (ហួសពី ២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| ពិនិត្យតាមដាន និងតាមដានបន្ត | ១ បង្កើតនីតិវិធីការពិនិត្យតាមដាន និងការវាយតម្លៃលើសុំកូន (រួមទាំងយន្តការបណ្តឹង)។<br>២ ស្នើសុំរដ្ឋទទួលឱ្យអនុវត្តតាមនីតិវិធីខាងលើយ៉ាងទាន់ពេលវេលា។<br>៣ ក្រសួង ស.អ.យ ត្រូវវាយតម្លៃលើភាពអនុលោមតាមច្បាប់។<br>៤ ក្រសួង សអយ ត្រូវពិចារណាបញ្ឈប់កិច្ចសហប្រតិបត្តិការនៅពេលមានភាពមិនអនុលោមតាមជាប្រព័ន្ធ។ | ក្រសួង ស.អ.យ ICAA។ | UNICEF | ២០២៣ តទៅ |

149 សូមមើលមគ្គុទ្ទេសក៍សម្រាប់ការអនុវត្ត លេខ ១ កំណត់សម្គាល់លេខ ២០ ខាងលើ វាក្យខ័ណ្ឌ ៣៩៤

# អនុសាសន៍ទី

# ២២

## កិច្ចសហប្រតិបត្តិការជាមួយរដ្ឋទទួលបន្ទុក និងស្ថាប័ន ដែលមានតួនាទីទទួលស្គាល់គុណភាពសម្រាប់ស្មុំកូនដែលមានចំនួនកំណត់ (AAB)

**ST** រដ្ឋទទួលដែលចង់ធ្វើការក្នុងប្រទេសកម្ពុជាមានយុទ្ធវិធីរួមគ្នា។

ប្រទេសកម្ពុជាសម្រេចចិត្តចាប់ផ្តើមកិច្ចសហប្រតិបត្តិការលើស្មុំកូនអន្តរប្រទេសតែជាមួយបណ្តាប្រទេសក្នុងចំនួនកំណត់ប៉ុណ្ណោះ។

**MT** ប្រទេសកម្ពុជា និងរដ្ឋទទួលផ្តល់ការអនុញ្ញាតដល់ AABs យ៉ាងច្រើនបំផុតពីរក្នុងមួយប្រទេសឱ្យធ្វើការក្នុងប្រទេសកម្ពុជា។

**LT** ការពិនិត្យតាមដានលើសកម្មភាពរបស់ AABs

ប្រទេសកម្ពុជាគួរផ្តោតការងាររបស់ខ្លួនលើការផ្តល់ការគាំទ្រសមស្របដល់គ្រួសារ ហើយក្នុងករណីនៃការស្មុំកូន គឺកម្ពុជាគួរផ្តោតការយកចិត្តទុកដាក់លើការរៀបចំត្រៀមខ្លួនកុមារ ដែលមានលក្ខណៈសម្បត្តិអាចឱ្យសុំទៅចិញ្ចឹមបាន។[150] កម្ពុជាមិនគួរប្រើប្រាស់ធនធានកម្ររបស់ខ្លួន ដើម្បីធ្វើការជាមួយរដ្ឋទទួល AABs និងឪពុកម្តាយចិញ្ចឹមក្នុងចំនួនខ្ពស់ពេកនោះទេ។ ដើម្បីចៀសវាងសម្ពាធជាការល្អ ដែលគោលការណ៍ខាងក្រោមនេះគួរត្រូវបានអនុវត្តតាម៖

- ជ្រើសរើសយកតែអាជ្ញាធរ និង AABs ដែលមានលក្ខណៈអាជីពជាងគេបំផុតដើម្បីធ្វើការជាមួយ
- ស្វែងរកព័ត៌មានពីប្រទេសប្រភពដទៃទៀតអំពី AABs ជាក់លាក់ណាមួយ
- បដិសេធមិនសហការជាមួយរដ្ឋទទួល ឬ AABs ដែលមានការអនុវត្តមិនទាន់ល្អដល់កម្រិត
- ប្រឆាំងចំពោះការដាក់សម្ពាធមិនសមស្របពីប្រទេសទទួល និង AABs ដើម្បីរក្សាការផ្គត់ផ្គង់កុមារ។[151]

ជាកិច្ចចាប់ផ្តើមនៅក្នុងការងាររយៈពេលខ្លី រដ្ឋទទួលគួរមានយុទ្ធវិធីរួម និងធ្វើការរួមគ្នាជាមួយប្រទេសកម្ពុជា។ រដ្ឋទាំងឡាយមិនត្រូវព្យាយាមទាញប្រយោជន៍ផ្អែកលើទំនាក់ទំនងកាលពីមុនមក និងកិច្ចព្រមព្រៀងពីមុនមកទេ។ យើងកត់សម្គាល់ឃើញថារដ្ឋទទួលជាច្រើនមានលិខិតរួមជាលាយលក្ខណ៍អក្សរមកកាន់ប្រទេសកម្ពុជាស្តីពីការសុំការបកស្រាយបញ្ជាក់នៅក្នុងនីតិវិធីស្មុំកូនរបស់ប្រទេសកម្ពុជា។ យើងលើកទឹកចិត្តឱ្យស្ថាបនាបន្ថែមលើយុទ្ធវិធីជារួមគ្នាបែបនេះឱ្យតែយុទ្ធវិធីបែបពុំដាក់សម្ពាធមិនសមស្របមកលើប្រទេសកម្ពុជា។ ឯកភាពគ្នាបែបនេះអាចធ្វើ

150 http://www.iss-ssi.org/images/thematic-facts-sheet/eng/26.Preparation%20of%20the%20child%20eng.pdf

151 សូមមើល HCCH, គោលការណ៍ណែនាំអំពីការអនុវត្តល្អលេខ ២៖ ការទទួលស្គាល់គុណភាព និងស្ថាប័នបានទទួលស្គាល់គុណភាពសម្រាប់ស្មុំកូន Family Law (Jordan Publishing Ltd), 2012 ( ចាប់ពីពេលនេះទៅហៅថា "មគ្គុទ្ទេសក៍ការអនុវត្តល្អលេខ ១" ) វាក្យខណ្ឌទី ៥៥៤។

ឱ្យគេចៀសវាងការបញ្ជូនសារចម្រុះគ្នាមកកាន់ប្រទេសកម្ពុជា និងទប់ស្កាត់ការប្រកួតប្រជែងមិនត្រឹមត្រូវ។ យុទ្ធវិធីនេះត្រូវបានសម្របសម្រួលបន្ថែមទៀត ដោយការងាររបស់យូនីសេហ្វក្នុងនាមជាប្រធានកិច្ចប្រជុំជាប្រចាំរបស់ស្ថានទូតបរទេស។

ប្រទេសកម្ពុជាពុំមានកាតព្វកិច្ចត្រូវសហប្រតិបត្តិការជាមួយគ្រប់រដ្ឋទទួលដែលដាក់ពាក្យសុំការសហប្រតិបត្តិការនោះទេ។ ក្រុមការងារសូមផ្តល់អនុសាសន៍ថា នៅពេលប្រទេសកម្ពុជាសម្រេចចិត្តបើកឱ្យមានសុំកូនអន្តរប្រទេសជាថ្មី កម្ពុជាអាចចាប់ផ្តើមធ្វើសហប្រតិបត្តិការជាមួយប្រទេសក្នុងចំនួនកំណត់ណាមួយ។ អាជ្ញាធរកណ្តាលរបស់កម្ពុជាអាចធ្វើការជ្រើសរើសដោយផ្អែកលើលក្ខណៈសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹម ដែលមានបំណងចង់សុំកូន ប្រភេទនៃកម្មវិធីរៀបចំខ្លួន សម្រាប់ឪពុកម្តាយចិញ្ចឹម និងសេវាក្រោយយកកុមារទៅដាក់ក្រោមការចិញ្ចឹមបីបាច់ដែលមាន។ល។

ICAA ត្រូវបានលើកទឹកចិត្តឱ្យសហប្រតិបត្តិការជាមួយអាជ្ញាធរកណ្តាលនៃរដ្ឋជាប្រទេសប្រភពដទៃទៀត។ មុនពេលសម្រេចចិត្តសហការជាមួយរដ្ឋដទៃណាមួយ ICAA អាចស្វែងយល់បទពិសោធន៍ ដែលអាជ្ញាធរកណ្តាលរបស់រដ្ឋប្រភពដទៃទៀតធ្លាប់មានជាមួយប្រទេសនោះ និង AABs របស់ប្រទេសនោះ។

សម្រាប់រយៈពេលមធ្យម ប្រទេសកម្ពុជាគួរផ្តល់ការអនុញ្ញាតដល់ AABs យ៉ាងច្រើនពីក្នុងមួយប្រទេសដែលខ្លួនបានសម្រេចចិត្តសហប្រតិបត្តិការជាមួយយោងទៅតាមបទបញ្ញត្តិរបស់ខ្លួន។ ចំណុចនេះគួរត្រូវបានប្រាស្រ័យទាក់ទងយ៉ាងច្បាស់លាស់ ដើម្បីចៀសវាងការដាក់សម្ពាធពីរដ្ឋដទៃ និង AABs ដទៃ។ កម្ពុជាក៏អាចបញ្ជាក់ចំនួនករណីដែល AAB នីមួយៗអាចបញ្ជូនបានផងដែរ។

ដើម្បីឱ្យមានគណនេយ្យភាពកាន់តែប្រសើរចំពោះ AABs ប្រទេសកម្ពុជាអាចពិចារណាសម្រាប់រយៈពេលវែង ឱ្យមានការពិនិត្យតាមដានជាប្រចាំទៅលើ AABs កិច្ចប្រជុំប្រចាំឆ្នាំជាមួយពួកគេ និងបង្កើតឱ្យមានជារបាយការណ៍ប្រចាំឆ្នាំ ដែលដាក់បញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុទាក់ទងជាមួយប្រតិបត្តិការរបស់ពួកគេផងដែរ។ ការធ្វើបែបនេះអាចជួយការពិនិត្យតាមដានរបស់ AABs និងជួយធានាថា ការយកកុមារទៅដាក់ក្រោមការចិញ្ចឹមបីបាច់ ពុំផ្តល់លទ្ធផលឱ្យមានការកេងចំណេញផ្នែកហិរញ្ញវត្ថុមិនត្រឹមត្រូវ សម្រាប់អ្នកដែលពាក់ព័ន្ធនោះឡើយ។ ប្រទេសកម្ពុជាក៏គួរពិចារណាធ្វើបញ្ជី AABs ទាំងអស់ដែលធ្លាប់បានដាក់ទណ្ឌកម្ម ដោយសារការធ្វើការដោយមិនត្រឹមត្រូវ ក៏ដូចជាជម្រាបប្រាប់ជាព័ត៌មានជាលក្ខណៈប្រព័ន្ធដល់គ្រប់រដ្ឋទទួលទាំងអស់អំពីបញ្ហានេះ។

## អនុសាសន៍ទី ២២

# កិច្ចសហប្រតិបត្តិការជាមួយរដ្ឋទទួល និងស្ថាប័នដែលបានការទទួលស្គាល់គុណភាពសម្រាប់សុំកូនដែលមានចំនួនកំណត់ (AAB)

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| កិច្ចសហប្រតិបត្តិការលើសុំកូនអន្តរប្រទេស | ១ មុនពេលសម្រេចចិត្តធ្វើសហប្រតិបត្តិការជាមួយរដ្ឋដទៃណាមួយ ត្រូវស្វែងយល់អំពីបទពិសោធន៍ដែលអាជ្ញាធរកណ្តាលដទៃទៀតរបស់ប្រទេសកំណើតធ្លាប់មានជាមួយប្រទេសនោះ និង AABs របស់ប្រទេសនោះ (ការងារនេះអាចផ្តួចផ្តើមឡើងដោយមានសន្និសីទពីចម្ងាយថ្នាក់តំបន់)។<br>២ ផ្អែកលើចំនួនកុមារដែលមានលក្ខណៈអាចដាក់ឱ្យសុំយកទៅចិញ្ចឹមបាន/ខាងលើ (អនុសាសន៍ទី ២១) សូមផ្តួចផ្តើមកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងចំនួនកំណត់ណាមួយ។<br>៣ រៀបចំកិច្ចប្រជុំជាប្រចាំជាមួយស្ថានទូត ដើម្បីគ្រប់គ្រងការរំពឹងទុក។<br>៤ បដិសេធការសហការជាមួយរដ្ឋទទួល ដែលមានការអនុវត្តមិនល្អគ្រប់គ្រាន់ ឬ AABs ដែលមានការអនុវត្តមិនល្អគ្រប់គ្រាន់។ ប្រឆាំងនឹងការដាក់សម្ពាធមិនសមស្របរដ្ឋទទួល និង AABs ដើម្បីរក្សាការផ្គត់ផ្គង់កុមារ។ | ក្រសួង ស.អ.យ ICAA។ | UNICEF, Foreign Embassies | ២០១៨ |

## រយៈពេលមធ្យម (២០១៩-២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| សហប្រតិបត្តិការជាមួយ ABBs | ១ ជ្រើសរើសយកតែអាជ្ញាធរ និង AABs ដែលមានលក្ខណៈអាជីពជាងគេបំផុត ដើម្បីធ្វើការជាមួយ។<br>២ ផ្តល់ការអនុញ្ញាតដល់ AABs យ៉ាងច្រើនបំផុតពីរក្នុងមួយប្រទេស ដើម្បីធ្វើការក្នុងប្រទេសកម្ពុជា។<br>៣ សម្រាប់បណ្តាប្រទេសដែលធ្លាប់មានការរៀបចំពីមុនមកសម្រាប់ AABs ច្រើនជាងពីរត្រូវចរចាកិច្ចព្រមព្រៀងឡើងវិញ។<br>៤ បញ្ជាក់ចំនួនសំណុំឯកសារដែល AAB នីមួយៗ និងអាចបញ្ជូនបានផ្អែកលើអនុសាសន៍ទី ២១។ | ក្រសួង ស.អ.យ ICAA។ | UNICEF | ២០១៩ តទៅ |

## រយៈពេលវែង (ហួសពី ២០២៣)

| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
|---|---|---|---|---|
| សកម្មភាពពិនិត្យតាមដានលើ AABs | ១ រៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាមួយ AABs ដើម្បីពិភាក្សាអំពីការរំពឹងទុករបស់កម្ពុជា។<br>២ ស្នើសុំ AABs ឱ្យបង្កើតរបាយការណ៍ប្រចាំឆ្នាំ ដោយក្នុងនោះត្រូវដាក់បញ្ចូលអំពីរបាយការណ៍ហិរញ្ញវត្ថុទាក់ទងជាមួយប្រតិបត្តិការរបស់គេ។<br>៣ វាយតម្លៃ AABs ក្នុងបរិបទខាងលើ។<br>៤ រាយឈ្មោះ AABs ទាំងអស់ដែលធ្លាប់ត្រូវបានដាក់ទណ្ឌកម្មដោយសារការធ្វើសកម្មភាពមិនត្រឹមត្រូវ ក៏ដូចជាជម្រាបជាព័ត៌មានជាលក្ខណៈប្រព័ន្ធដល់រដ្ឋទទួលដែលពាក់ព័ន្ធអំពីបញ្ហានេះ។ | ក្រសួង ស.អ.យ ICAA ក្រសួងការបរទេស។ | UNICEF | ២០២៣ តទៅ |

# អនុសាសន៍ទី

# ២៣

## និយ័តកម្មលើទិដ្ឋភាពផ្នែកហិរញ្ញវត្ថុនៃការសុំកូន[152]

**ST** ធានាឱ្យមានការអនុវត្តបានត្រឹមត្រូវនូវច្បាប់ស្តីពីទិដ្ឋភាពផ្នែកហិរញ្ញវត្ថុសម្រាប់ ICA។

**MT** ពិភាក្សារកលទ្ធភាពក្នុងការស្នើសុំតែថ្លៃសេវា និងការចំណាយហើយមិនសុំការចូលរួមវិភាគទាន។

**LT** ធានាយ៉ាងណាឱ្យមានការផ្តល់មូលនិធិសមស្របសម្រាប់ប្រព័ន្ធថែទាំជំនួស ដែលមិនពាក់ព័ន្ធទាំងស្រុងជាមួយសុំកូនអន្តរប្រទេស ដើម្បីចៀសវាងភាពពឹងផ្អែក។

ដើម្បីឈានដល់បទដ្ឋាន និងបំពេញបាននូវការធានារបស់អនុសញ្ញាក្រុង ឡាអេ ឆ្នាំ ១៩៩៣ អ្នកប្រកបវិជ្ជាជីវៈជាច្រើនចាំបាច់ត្រូវចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការសុំកូន។ ជាការសមហេតុផលក្នុងការរំពឹងទុកថា ការបង់ប្រាក់ថ្លៃសេវាមានភាពចាំបាច់ចំពោះអ្នកប្រកបរបរវិជ្ជាជីវៈទាំងនេះ មិនថាពួកគាត់ធ្វើការនៅក្នុងការិយាល័យរដ្ឋាភិបាល ឬពុំមែនរដ្ឋាភិបាលក្តី។ ដោយហេតុនេះហើយ ទើបអនុសញ្ញាអនុញ្ញាតឱ្យអាជ្ញាធរ AABs នៅក្នុងរដ្ឋទទួល និងរដ្ឋប្រភពឱ្យអាចយកថ្លៃសេវាក្នុងកម្រិតសមហេតុផល និងស្របច្បាប់ចំពោះសេវាផ្តល់ជូនទាក់ទងជាមួយដំណើរការនៃសុំកូន។[153] ទោះយ៉ាងណាក្តី អនុសញ្ញាហាមឃាត់យ៉ាងច្បាស់មិនឱ្យមានការទទួលយកផ្នែកហិរញ្ញវត្ថុ ឬការទទួលយកដទៃទៀតដែលមិនសមស្រប។[154]

ច្បាប់កម្ពុជាស្តីពីសុំកូនអន្តរប្រទេសចេញឆ្នាំ ២០០៩ បានចែងថាអ្នកសុំកូនត្រូវបង់ការចំណាយ និងថ្លៃសេវាសម្រាប់នីតិវិធីសុំកូន និងការចូលរួមវិភាគទាន ដើម្បីគាំទ្រដល់ជម្រើសការថែទាំជំនួស។ AABs ក៏ត្រូវបង់ថ្លៃសេវាមួយចំនួន ដើម្បីអាចមានសិទ្ធិធ្វើការក្នុងប្រទេសកម្ពុជាផងដែរ។[155] មានការហាមឃាត់មិនឱ្យផ្ទេរប្រាក់ថ្លៃសេវាការបរិច្ចាគ ឬការបង់ប្រាក់គ្រប់ប្រភេទទៅដល់មណ្ឌលកុមារកំព្រា។[156] អ្នកសុំកូនក៏ត្រូវបង់ប្រាក់ក្នុងចំនួនតិចតួចជាថ្លៃសេវាតុលាការផងដែរ។[157]

ប្រកាសស្តីពីការកំណត់ថ្លៃចំណាយ ថ្លៃសេវា និងការបង់វិភាគទាន សម្រាប់សុំកូនអន្តរប្រទេសចេញឆ្នាំ ២០១៣ (ប្រកាសឆ្នាំ ២០១៣) បានកំណត់ការបង់ប្រាក់រួមមួយ ក្នុងចំនួន ៥០០០ ដុល្លា។ សាមសិបភាគរយនៃទឹកប្រាក់នេះ គឺសម្រាប់ការចំណាយ និងថ្លៃសេវាសម្រាប់នីតិវិធីសុំកូន។ ការបង់ថ្លៃសេវា និងការចំណាយនានា សម្រាប់សេវាវិជ្ជាជីវៈ ដើម្បីបំពេញសុំកូននេះ គឺអនុលោមតាមអនុសញ្ញា។ ចំណែកទឹកប្រាក់ ៧០ ភាគរយដែលនៅសល់ គឺសម្រាប់កម្មវិធីការថែទាំជំនួស ដែលត្រូវបង់ទៅដល់មូលនិធិដាក់លាក់នៅរតនាគារជាតិ។ ចំណុចវិជ្ជមានគឺយើងឃើញថា ទឹកប្រាក់ត្រូវបង់ និងអ្នកដែលត្រូវបង់ទឹកប្រាក់ទៅឱ្យគឺ មានភាពច្បាស់លាស់។ ការធានាដទៃទៀតត្រូវបានបង្កើតឡើងនៅក្រោមប្រកាសឆ្នាំ ២០១៣។ មានទស្សនៈមួយ

152 សំណោក្រោមអនុសាសន៍នេះគឺផ្អែកលើកំណត់សម្គាល់ស្តីពីទិដ្ឋភាពផ្នែកហិរញ្ញវត្ថុនៃសុំកូនអន្តរប្រទេស HCCH, 2014.
153 សូមមើលមាត្រា ៣២(២) នៃអនុសញ្ញា។ សូមមើលផងដែរនៅក្នុងមគ្គុទ្ទេសសម្រាប់ការអនុវត្តល្អលេខ ១ ខាងលើ កំណត់សម្គាល់លេខ ២១ វាក្យខ័ណ្ឌ ២២៥ និង
154 មាត្រា ៣២ នៃអនុសញ្ញា។
155 ប្រកាសឆ្នាំ ២០១៤ ស្តីពីនីតិវិធីដើម្បីផ្តល់សិទ្ធិដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស។
156 មាត្រា ២៥។
157 មាត្រា ៣៥។

យល់ឃើញថា មូលនិធិប្រភេទនេះបង្កើតឱ្យមានការអនុវត្តល្អក្រោមលក្ខខណ្ឌមួយចំនួនដូចជា៖ ការកំណត់ជាមុននូវគោលបំណងនៃការបង់វិភាគទានក្នុងលក្ខណៈលម្អិត និងជាលក្ខណៈកម្មវិធីការកំណត់អាជ្ញាធរ ឬស្ថាប័នមើលការខុសត្រូវ និងពិនិត្យតាមដានលើមូលនិធិ និងការរាយការណ៍ជាប្រចាំដោយរដ្ឋប្រភពស្តីពីការប្រើប្រាស់មូលនិធិទាំងអស់នេះ ដើម្បីធានាដល់ម្ចាស់ជំនួយថា មូលនិធិត្រូវបានប្រើប្រាស់ ដើម្បីអត្ថប្រយោជន៍របស់កុមារ ពោលគឺពុំមែនសម្រាប់គោលបំណងដទៃទៀតឡើយ។

ទោះយ៉ាងណាក្តីមូលនិធិប្រភេទនេះជារឿយៗតែងតែអាចមានគ្រោះថ្នាក់ និងហានិភ័យ ជាពិសេសពេលមូលនិធិនេះពុំត្រូវបានមើលខុសត្រូវយ៉ាងត្រឹមត្រូវ ហើយពុំមែនជាកម្មវត្ថុនៃការត្រួតពិនិត្យឃ្លាំមើលដោយប្រុងប្រយ័ត្នពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនោះ។ បទបញ្ញត្តិដ៏រឹងមាំទៅលើមូលនិធិទាំងអស់នេះគឺមានសារៈសំខាន់ជាខ្លាំង។ បន្ថែមលើនេះទៀត ការបង់វិភាគទានដើម្បីគាំទ្រដល់ប្រព័ន្ធការថែទាំជំនួសអាចបង្កឱ្យមានហានិភ័យដោយហេតុថាការបង់វិភាគទានបែបនេះ អាចបំផ្លាញដល់សុចរិតភាពនៃនីតិវិធីសុំកូនដោយសុវត្ថិភាព។ ឧ. ការបង់វិភាគទានអាចជះឥទ្ធិពលធ្វើឱ្យមានការផ្តល់អាទិភាពដល់សុំកូនអន្តរប្រទេសលើសពីដំណោះស្រាយក្នុងប្រទេស ហើយជាលទ្ធផលអាចធ្វើឱ្យពុំមានការគាំទ្រគ្រប់គ្រាន់ទៅដល់គ្រួសារកំណើត និងអវត្តមាន ឬកង្វះខាតការស៊ើបអង្កេតធ្វើឡើងទៅលើភាពដែលអាចដាក់ឱ្យសុំបាននៃកុមារនិង/ឬដំណោះស្រាយការថែទាំជំនួសនៅក្នុងប្រទេសដែលមាន ( ឧ. គោលការណ៍អំណាចស្ថិតនៅក្នុងដៃរដ្ឋបាលថ្នាក់ទាបបំផុតប្រហែលមិនត្រូវបានគោរព )។ គេអាចអះអាងបានថា ទឹកប្រាក់ ៣ ៥00 ដុល្លា សម្រាប់កុមារម្នាក់បើប្រៀបធៀបជាមួយការចំណាយថ្លៃការរស់នៅ គឺជាអត្រាដ៏ខ្ពស់មួយ ហើយជាហេតុឱ្យកើតមានការអនុវត្តខុសច្បាប់ ហើយទឹកប្រាក់នេះអាចដើរតួនាទីជាការលើកទឹកចិត្តឱ្យមាន “ការផលិត” កុមារតាមវិធីមិនសមស្របសម្រាប់សុំកូន។ ការចូលរួមវិភាគទានបង្កើតឱ្យមានភាពពឹងផ្អែករបស់រដ្ឋប្រភពទៅលើមូលនិធិដែលបានផ្តល់ឱ្យតាមរយៈប្រភពធនធានទាំងអស់នេះ ហើយលើកការរំពឹងទុកទៅមួយកម្រិតទៀត ដែលគិតថាពួកគេអាចបន្តទទួលទឹកប្រាក់នេះទៀត។ រដ្ឋដែលចង់ធានាឱ្យមានលំហូរ ដោយស្ថេរភាពនៃមូលនិធិពីខាងក្រៅមកគាំទ្រកិច្ចខិតខំការពារកុមារអាចមានអារម្មណ៍ថា មានកាតព្វកិច្ចធ្វើយ៉ាងណាធានាឱ្យកុមារត្រូវបានផ្គត់ផ្គង់សម្រាប់សុំកូនអន្តរប្រទេស។ ការចូលរួមវិភាគទានក៏អាចបង្កើតឱ្យមានការប្រកួតប្រជែងគ្នារវាងរដ្ឋទទួល និង AABs ដោយក្នុងនោះអ្នកណាដែលផ្តល់ទឹកប្រាក់ច្រើនជាងគេនឹងបានទទួលកុមារក្នុងចំនួនច្រើនជាងគេ។

បន្ថែមលើនេះទៀត តាមទស្សនៈរបស់យូនីសេហ្វ[158] មូលនិធិប្រភេទនេះពុំគួរជាវិធី ដើម្បីផ្តល់ការគាំទ្រពីប្រទេសដទៃ សម្រាប់ការអភិវឌ្ឍសេវាការពារកុមារ និងសេវាការថែទាំជំនួសនៅក្នុងរដ្ឋប្រភពនោះឡើយ។ ពេលការបង់វិភាគទានទៅក្នុងមូលនិធិប្រភេទនេះជាការតម្រូវជាកាតព្វកិច្ច ដើម្បីឱ្យសុំកូនអន្តរប្រទេសអាចធ្វើឡើងបាន អ្នកបង់វិភាគទានអាចមានការជះឥទ្ធិពលតិចតួច ឬពុំមានការជះឥទ្ធិពលអ្វីទាល់តែសោះ លើប្រភេទគម្រោងដែលគេផ្គត់ផ្គង់ហិរញ្ញវត្ថុ និងជាពិសេសអាចពុំមានព័ត៌មានថា តើគម្រោងនោះអនុលោមតាមគោលការណ៍ណែនាំគោលនយោបាយ ដែលត្រូវបានអនុម័តជាអន្តរជាតិនៅក្នុងវិស័យនេះ ឬអត់នោះឡើយ។ ជាលទ្ធផល ការបង់វិភាគទានប្រភេទនេះ ពុំអាចត្រូវបានពិចារណាដោយស្វ័យប្រវត្តិថាជាទម្រង់ “ជំនួយអភិវឌ្ឍ” គួរជាទីចង់បាននោះឡើយ។

ហេតុនេះក្រុមស្រាវជ្រាវសូមផ្តល់អនុសាសន៍ថា សម្រាប់រយៈពេលខ្លី ប្រសិនបើសុំកូនអន្តរប្រទេសចាប់ផ្តើមឡើងវិញ ក្នុងប្រទេសកម្ពុជា នៅពេលសុំកូនអន្តរប្រទេសចាប់ផ្តើមឡើងវិញនោះ អាជ្ញាធរត្រូវអនុវត្តច្បាប់ និងប្រកាសឆ្នាំ ២០១៣ ភ្លាមៗ និងយ៉ាងសព្វជ្រុងជ្រោយ ជាពិសេសទាក់ទងនឹងការចំណាយថ្លៃសេវា។ ការងារនេះទាមទារកិច្ចសហការជាមួយក្រសួងសអយ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សម្រាប់រយៈពេលមធ្យម អាជ្ញាធរកម្ពុជាគួរពិភាក្សាលទ្ធភាពទារយកតែថ្លៃសេវា និងការចំណាយលើការចំណាយជាក់ស្តែងនៃនីតិវិធីសុំកូនប៉ុណ្ណោះ ហើយមិនត្រូវទារថ្លៃវិភាគទាន និងការបរិច្ចាគឡើយ។ ចំណុចនេះមានសារៈសំខាន់ជាពិសេស បើគិតទៅលើស្ថានភាពក្នុងតំបន់មួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលច្រើនតែមាននិន្នាការ និងការអនុវត្តសុំកូនដោយខុសច្បាប់នាពេលកន្លងមក។

ជាចុងក្រោយ សម្រាប់រយៈពេលវែង ប្រទេសកម្ពុជាគួរធានាឱ្យមានបណ្តាញដទៃទៀត សម្រាប់ផ្តល់មូលនិធិដល់ប្រព័ន្ធការថែទាំជំនួស ដោយកាត់ផ្តាច់ចេញទាំងស្រុងពីសុំកូនអន្តរប្រទេស។ និរន្តរភាព និងគុណភាពនៃក្របខ័ណ្ឌការងារការពារកុមារក្នុងប្រទេសកម្ពុជា គឺជាការទទួលខុសត្រូវខ្ពស់បំផុតរបស់រដ្ឋាភិបាល ហេតុនេះហើយសុំកូនអន្តរប្រទេសពុំគួរជាមធ្យោបាយ ដើម្បីផ្តល់ហិរញ្ញវត្ថុដល់ប្រព័ន្ធការពារកុមារនោះឡើយ។ ដោយហេតុថា ការធ្វើបែបនេះអាចបង្កើតឱ្យមានការពឹងផ្អែក និងអាចបំផ្លាញដល់សុចរិតភាពដល់នីតិវិធីសុំកូនដោយសុវត្ថិភាព។

158 កំណត់សម្គាល់ស្តីពីទិដ្ឋភាពផ្នែកហិរញ្ញវត្ថុនៃសុំកូនអន្តរប្រទេស HCCH ឆ្នាំ ២០១៤ វាក្យខ័ណ្ឌ ១៣៤។

# អនុសាសន៍ទី ២៣

# និយ័តកម្មលើទិដ្ឋភាពផ្នែកហិរញ្ញវត្ថុនៃការសុំកូន

| រយៈពេលខ្លី (២០១៨) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ធានាឱ្យមានការអនុវត្តសមស្របនូវបទបញ្ញត្តិច្បាប់ស្តីពីទិដ្ឋភាពផ្នែកហិរញ្ញវត្ថុសម្រាប់សុំកូនអន្តរប្រទេស | ១ រៀបចំកិច្ចប្រជុំតុមូលជាមួយក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកដើរតួនាទីដទៃទៀត ស្តីពីការអនុវត្តជាក់ស្តែងនូវបទបញ្ញត្តិច្បាប់ និងប្រកាសឆ្នាំ ២០១៣ ទាក់ទងជាមួយទិដ្ឋភាពផ្នែកហិរញ្ញវត្ថុ។<br>២ កំណត់ការទទួលខុសត្រូវ និងនីតិវិធី។<br>៣ ផ្សព្វផ្សាយអំពីការទទួលខុសត្រូវ និងនីតិវិធីដែលបានព្រមព្រៀងរួចហើយយ៉ាងទូលំទូលាយ រួមទាំងតាមរយៈគេហទំព័រ ICAA អាជ្ញាធរកណ្តាលនៃរដ្ឋទទួល និងស្ថានទូតបរទេស។ | ក្រសួង ស.អ.យ ICAA ក្រសួងសេដកិច្ច និងហិរញ្ញវត្ថុ។ | UNICEF, 3PC and FCF | ២០១៨ |
| **រយៈពេលមធ្យម (២០១៩-២០២៣)** | | | | |
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| បង្កើតគោលនយោបាយថ្លៃសេវាដោយមានការការពារសុវត្ថិភាពពីការអនុវត្តខុសច្បាប់ | ១ សិក្ខាសាលាស្តីពីរចនាសម្ព័ន្ធថ្លៃសេវារបស់ប្រទេសដទៃទៀត ក៏ដូចជាអត្ថប្រយោជន៍/ហានិភ័យដែលមាននៅក្នុងរចនាសម្ព័ន្ធទាំងនោះ ផ្តល់ជូនសម្រាប់ភាគីពាក់ព័ន្ធនានា។<br>២ ពិភាក្សាលទ្ធភាពក្នុងការទាមទារឱ្យបង់តែថ្លៃសេវា និងការចំណាយជាក់ស្តែងនៅក្នុងនីតិវិធីសុំកូន ហើយពុំទាមទារការបង់វិភាគទាន ឬការបរិច្ចាគ។ | ក្រសួង ស.អ.យ។ | UNICEF | ២០១៩ តទៅ |

| រយៈពេលវែង (ហួសពី ២០២៣) | | | | |
|---|---|---|---|---|
| តើចាំបាច់ត្រូវមានអ្វីខ្លះ? | តើនឹងត្រូវអនុវត្តដោយរបៀបណា? | តើនរណាទទួលខុសត្រូវ? | តើនរណានឹងគាំទ្រ/ប្រភេទនៃការគាំទ្រ? | រយៈពេល |
| ការផ្តល់មូលនិធិត្រឹមត្រូវសម្រាប់ប្រព័ន្ធការថែទាំជំនួស។ | ១ ផ្តោតលើអនុសាសន៍ទី ១ ធានាឱ្យមានការផ្តល់មូលនិធិត្រឹមត្រូវសម្រាប់ប្រព័ន្ធការថែទាំជំនួស ដែលមិនពាក់ព័ន្ធទាំងស្រុងជាមួយ ICA ដើម្បីចៀសវាងការពឹងផ្អែក។<br>២ កំណត់រកបណ្តាញប្រេកផ្សេងទៀត សម្រាប់ការផ្តល់មូលនិធិកាដល់ប្រព័ន្ធការថែទាំជំនួស ដែលមិនពាក់ព័ន្ធទាំងស្រុងជាសុំកូនអន្តរប្រទេស។ | ក្រសួង ស.អ.យ។ | UNICEF | ២០១៩ តទៅ |

# បញ្ជីគន្ធនិទ្ទេស ( ទិន្នន័យបន្ទាប់បន្សំ )

## លិខិតបទដ្ឋានគតិយុត្តិ៖

- ក្រសួងយុត្តិធម៌ សេចក្ដីពន្យល់ស្ដីពីសុំកូនក្នុងប្រទេស ឆ្នាំ២០១៦
- អនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផែនការសកម្មភាពសម្រាប់កែលម្អការថែទាំកុមារ ក្នុងគោលដៅបង្វែរកុមារចំនួន ៣០% ពីមណ្ឌលថែទាំកុមារឱ្យវិលត្រឡប់ទៅគ្រួសាររបស់ពួកគេវិញប្រកបដោយសុវត្ថិភាព ឆ្នាំ២០១៦-២០១៨ (២០១៧)
- រដ្ឋបាលខេត្តកណ្ដាល គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាផែនការប្រតិបត្តិថ្នាក់ខេត្ត ឆ្នាំ២០១៦-២០១៨ (ខេត្តកណ្ដាល) សម្រាប់កែលម្អការថែទាំកុមារក្នុងគោលដៅបង្វែរកុមារចំនួន ៣០% ពីមណ្ឌលថែទាំកុមារឱ្យវិលត្រឡប់ទៅគ្រួសាររបស់ពួកគេវិញប្រកបដោយសុវត្ថិភាព ត្រឹមឆ្នាំ២០១៨ (២០១៦)
- សេចក្ដីព្រាង៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្ដីពីសុំកូនក្នុងប្រទេស
- គោលការណ៍ណែនាំស្ដីពីឧបករណ៍ សម្រាប់អនុវត្តប្រកាសស្ដីពីនីតិវិធីអនុវត្តគោលនយោបាយស្ដីពីការថែទាំជំនួស ចំពោះកុមារ (២០១៣-២០១៤)
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្ដីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស សម្រាប់កុមារដែលត្រូវការការថែទាំពិសេស និងកុមារដែលមានសេចក្ដីត្រូវការពិសេស (ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤)
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្ដីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស ដោយសាច់ញាតិ (ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤)
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្ដីពីរដ្ឋបាលសុំកូនអន្តរប្រទេស (ICAA) (ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤)
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស (ICAA) (ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣)
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្ដីពីនីតិវិធីផ្ដល់ការអនុញ្ញាតជូនទីភ្នាក់ងារសុំកូនអន្តរប្រទេស (ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសរួមស្ដីពីការកំណត់ថ្លៃចំណាយសោហ៊ុយ និងវិភាគទានសម្រាប់សុំកូនអន្តរប្រទេស (ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសរួមស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២)
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រកាសស្ដីពីនីតិវិធីអនុវត្តគោលនយោបាយស្ដីពីការថែទាំជំនួស ចំពោះកុមារ (ខែតុលា ឆ្នាំ២០១១)
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គោលនយោបាយស្ដីពីការថែទាំជំនួស ចំពោះកុមារ (២០០៦)

- ក្រមរដ្ឋប្បវេណី (ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០០៧)
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង
- ក្រមនីតិវិធីរដ្ឋប្បវេណី (ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៦)

## របាយការណ៍រដ្ឋាភិបាលៈ

- ក្រសួងផែនការនៃព្រះរាជាណាចក្រកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ការប៉ាន់ប្រមាណជាតិអំពីចំនួនកុមារនៅក្នុងមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា (២០១៦)
- ក្រសួងផែនការនៃព្រះរាជាណាចក្រកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ការប៉ាន់ប្រមាណអំពីចំនួនកុមារអនាថា នៅក្នុងទីក្រុងចំនួន៧ ក្នុងប្រទេសកម្ពុជា (២០១៦)
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា ការចងក្រងទិន្នន័យបឋម និងគំហើញពីការកំណត់ទីតាំងមណ្ឌលថែទាំកុមារ (២០១៦)
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា ព្រឹត្តិបត្រព័ត៌មានអំពីទិន្នន័យបឋមស្តីពីការកំណត់ទីតាំងមណ្ឌលថែទាំកុមារ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកណ្តាល និងខេត្តព្រះសីហនុ (២០១៦)
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា ការប្តេជ្ញាចិត្តអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (២០១៦)
- ក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា គំហើញពីការអង្កេតស្តីពីអំពើហិង្សាលើកុមារឆ្នាំ២០១៣៖ សេចក្តីសង្ខេប (២០១៤)
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជាដោយបំណងល្អបំផុត៖ ការសិក្សាស្តីពីចេតនា និងការប្រព្រឹត្ត ចំពោះការថែទាំតាមមណ្ឌលក្នុងប្រទេសកម្ពុជា (២០១១)
- រាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូនីសេហ្វ កិច្ចការពារកុមារ ២០១៦-២០១៨ (២០១៦)

# របាយការណ៍អង្គការអន្តរជាតិ៖

- សន្និសីទក្រុងឡាអេស្តីពីច្បាប់ឯកជនអន្តរជាតិ ការបណ្តុះបណ្តាលមន្ត្រីតុលាការក្នុងប្រទេសកម្ពុជា (៣-៦ ធ្នូ ២០១៣)
- សន្និសីទក្រុងឡាអេស្តីពីច្បាប់ឯកជនអន្តរជាតិរបាយការណ៍ស្តីពីជំនួយបច្ចេកទេស ចំពោះសុំកូនអន្តរប្រទេស៖ បេសកកម្មមកប្រទេសកម្ពុជា (១-១២ វិច្ឆិកា ២០១២) ឯកសារផ្ទៃក្នុង
- សន្និសីទក្រុងឡាអេស្តីពីច្បាប់ឯកជនអន្តរជាតិ របាយការណ៍ស្តីពីជំនួយបច្ចេកទេស ចំពោះសុំកូនអន្តរប្រទេស៖ បេសកកម្មមកប្រទេសកម្ពុជា (11 avril au 8 juillet 2011) ឯកសារផ្ទៃក្នុង
- សន្និសីទក្រុងឡាអេស្តីពីច្បាប់ឯកជនអន្តរជាតិ របាយការណ៍ស្តីពីជំនួយបច្ចេកទេស ចំពោះសុំកូនអន្តរប្រទេស៖ បេសកកម្មមកប្រទេសកម្ពុជា (១-១២ វិច្ឆិកា ២០១០) ឯកសារផ្ទៃក្នុង
- មជ្ឈមណ្ឌលអន្តរជាតិនៃសន្និសីទក្រុងឡាអេ សម្រាប់ការសិក្សាអំពីវិស័យយុត្តិធម៌ និងជំនួយបច្ចេកទេស៖ កម្មវិធីជំនួយបច្ចេកទេសសម្រាប់សុំកូនអន្តរប្រទេស (ICATAP) ការផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំត្រៀមលក្ខណៈចាប់ផ្តើមដំណើរការសុំកូនអន្តរប្រទេសឡើងវិញ (២០១០) ឯកសារផ្ទៃក្នុង
- សេចក្តីព្រាង៖ សេចក្តីពន្យល់អំពីសុំកូនក្នុងប្រទេស ដោយផ្អែកលើក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង
- អង្គការយូនីសេហ្វ សង្ខេបសេចក្តីពន្យល់អំពីសុំកូនក្នុងប្រទេស ឯកសារផ្ទៃក្នុង
- រដ្ឋបាលសុំកូនអន្តរប្រទេស (ICAA) សៀវភៅណែនាំអំពីនីតិវិធីសម្រាប់ដោះស្រាយសំណុំឯកសារ សុំកូនអន្តរប្រទេស (ខែវិច្ឆិកា ឆ្នាំ២០១២)
- ក្រុមប្រឹក្សាភិបាលសុំកូនអន្តរប្រទេស របាយការណ៍ស្តីពីជំនួយបច្ចេកទេសដែលបានផ្តល់ជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងអាជ្ញាធរ និងអ្នកពាក់ព័ន្ធដទៃទៀត ដោយក្រុមប្រឹក្សាភិបាលសុំកូនអន្តរប្រទេសនៃប្រទេសហ្វីលីពីន (ICAB) (ខែធ្នូ ឆ្នាំ២០១២) ឯកសារផ្ទៃក្នុង
- របាយការណ៍អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជាចំពោះ USAID ការពង្រឹងប្រព័ន្ធការពារកុមារក្នុងប្រទេសកម្ពុជា (ខែមករា រហូតដល់ខែមីនា ឆ្នាំ២០១៦)
- របាយការណ៍អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជាចំពោះ USAID ការពង្រឹងប្រព័ន្ធការពារកុមារក្នុងប្រទេសកម្ពុជា (ខែមេសា រហូតដល់ ខែមិថុនា ឆ្នាំ២០១៦)
- អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា កំណត់សម្គាល់ស្តីពីយុទ្ធសាស្ត្រការពារកុមារ៖ សេចក្តីព្រាងសម្រាប់ការពិគ្រោះយោបល់ខាងក្រៅ (២០១៦)
- អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា កម្មវិធីការពារកុមារប្រចាំប្រទេស ២០១៦-២០១៨ (២០១៦)
- អង្គការយូនីសេហ្វ ការប្រកាសផ្សព្វផ្សាយសេចក្តីពន្យល់អំពីសុំកូនក្នុងប្រទេស និងសិក្ខាសាលាស្តីពីអនុសញ្ញាក្រុងឡាអេ ១៩-២០ តុលា ២០១៦ (២០១៦)
- អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា លក្ខខណ្ឌយោងសម្រាប់កិច្ចសន្យាជាមួយស្ថាប័ន

## របាយការណ៍អង្គការមិនមែនរដ្ឋាភិបាល៖

- Family Care First, ប្រទេសសម្រេចបានសក្តានុពលរបស់ខ្លួន នៅពេលដែលកុមារសម្រេចសក្តានុពលរបស់ពួកគេ (២០១៦)
- Family Care First, ប្រវត្តិរបស់ Family Care First (ស្លាយ)
- Friends International, សៀវភៅណែនាំរបស់អង្គការ Friends ស្តីពីការថែទាំដោយឪពុកម្តាយធម៌ (២០១៥)
- Friends International, ការអង្កេតទៅលើចំណេះដឹង ឥរិយាបថ និងការប្រព្រឹត្ត (KAP) ទៅលើការថែទាំដោយឪពុកម្តាយធម៌ (២០១៥)
- អង្គការទឹកចិត្តម្តាយ សេចក្តីសង្ខេប
- អង្គការទឹកចិត្តម្តាយ ទឹកចិត្តម្តាយ កក្កដា ២០១៤-មិថុនា ២០១៧៖ ក្របខ័ណ្ឌតក្កភាពរយៈពេល ៣ឆ្នាំ
- សញ្ញានៃសុវត្ថិភាព ឯកសារសង្ខេបព័ត៌មានគ្រប់ជ្រុងជ្រោយ (២០១៤)
- អង្គការទស្សនៈពិភពលោកប្រចាំប្រទេសកម្ពុជា - ផ្នែកការពារកុមារ៖ គម្រោងស្តារឡើងវិញនូវអាការៈបាក់ស្មារតី ជម្រើសថែទាំជំនួសតាមសហគមន៍ក្នុងប្រទេសកម្ពុជា (២០១៤)

## សេចក្តីសង្ខេបព័ត៌មាន៖

- M. RUSSEY, ការថែទាំដោយឪពុកម្តាយធម៌ក្នុងគ្រាអាសន្ន និងចំនុចសំខាន់ៗទាំង៥

# ឧបសម្ព័ន្ធទី ១ បញ្ជីឈ្មោះបុគ្គលដែលបានជួបក្នុងអំឡុងបេសកកម្ម នៅក្នុងប្រទេសកម្ពុជា

## រដ្ឋាភិបាល

### ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង សអយ)

- ឯកឧត្តម សយ ស៊ីផុន រដ្ឋលេខាធិការ
- ឯកឧត្តម តូច ចាន់នី អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស
- លោក រស់ សុខា ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ
- លោកស្រី ថោ ពៅ ប្រធានបុរីទារក និងកុមារជាតិ
- លោកស្រី ម៉ុក ផាន់ណា អ្នកផ្តល់ប្រឹក្សាយោបល់ក្រសួង សអយ ទទួលបន្ទុកមណ្ឌលរដ្ឋ

### រដ្ឋបាលសុំកូនអន្តរប្រទេស

- លោកស្រី ឡេវ សុភារី ប្រធានស្តីទីនៃរដ្ឋបាលសុំកូនអន្តរប្រទេស
- លោកស្រី Khim Sopsosoes អនុប្រធាននាយកដ្ឋានមនុស្សចាស់គ្រប់គ្រង និងអធិការកិច្ច
- លោកស្រី សៅ សម្ផស្ស ប្រធានការិយាល័យនីតិវិធី និងការអនុវត្តសុំកូនអន្តរប្រទេស
- លោកស្រី ថៃម ពិសី អនុប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- លោក សែន សុភី ប្រធានផ្នែកការគ្រប់គ្រងទិន្នន័យ និងកំណត់ត្រា

### មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (មន្ទីរ សអយ)

- លោក ឌិ ម៉ៅ ប្រធានមន្ទីរ សអយ ខេត្តសៀមរាប
- លោក មឿន សុឃុន ជនបង្គោលរបស់មន្ទីរ សអយ ខេត្តសៀមរាប

### ក្រសួងយុត្តិធម៌

- លោកជំទាវ ចាន់ សុទ្ធារី ចៅក្រម និងជារដ្ឋលេខាធិការ
- លោក គី ខឹមលីន អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការយុត្តិធម៌

### ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- លោក ថូ សំណាង ប្រធាននាយកដ្ឋាននីតិកម្ម និងកុងស៊ុល

### ក្រសួងមហាផ្ទៃ

- លោក ហួត ស៊ីនាត អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

### ក្រសួងសុខាភិបាល

- ឯកឧត្តមសាស្ត្រាចារ្យ អ៊ឹម សំអុល អនុរដ្ឋលេខាធិការ
- លោកស្រី ថៃម វិរវណ្ណ អនុប្រធាន DIC

### មន្ទីរពេទ្យកុមារអង្គរ

- លោក សន សុខជា ប្រធានក្រុមការងារសង្គមកិច្ច

### គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ (ខេត្តសៀមរាប)

- លោកស្រី ឃឹម សុខន ជំទប់ទីមួយនៃសង្កាត់សាលាកម្រើក
- លោកស្រី ដួង សុវណ្ណារី ប្រធាន គកនក នៃសង្កាត់សាលាកម្រើក

## ចៅក្រម

- លោក ចាយ ចាន់ដារាវណ្ណ ចៅក្រមសាលាឧទ្ធរណ៍
- ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍

## ស្ថានទូត និងស្ថានកុងស៊ុល

- លោកស្រី Barbara A. Bartsch-Allen លេខាទីមួយ និងប្រធានស្ថានកុងស៊ុល ស្ថានទូតសហរដ្ឋអាមេរិក
- លោក Pascal Burel ស្ថានកុងស៊ុល ស្ថានទូតបារាំង
- លោកស្រី Martina Cannetta, Consular Trustee សាធារណរដ្ឋអ៊ីតាលី
- លោកស្រី Jordana M. Cox លេខាទីពីរ និងអនុប្រធានស្ថានកុងស៊ុល ស្ថានទូតសហរដ្ឋអាមេរិក
- លោកស្រី Pilar Davidson លេខាទីមួយ (អន្តោប្រវេសន៍) ស្ថានទូតអូស្ត្រាលី
- លោក Graeme Harrow ប្រធានស្ថានកុងស៊ុល និងរដ្ឋបាលរបស់ស្ថានទូតអង់គ្លេស
- លោកស្រី Katherine Neidorf ទីប្រឹក្សាផ្នែកកុមារក្នុងស្ថានភាពលំបាក និងការអប់រំរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)

## អង្គការអន្តរជាតិ

### អង្គការយូនីសេហ្វកម្ពុជា

- លោកស្រី Debora Comini ប្រធានអង្គការ
- លោកស្រី Natasha Paddison អនុប្រធានអង្គការ
- លោក លឹម វណ្ណា ជំនួយការកម្មវិធី
- លោក Bruce Grant ប្រធានផ្នែកការពារកុមារ
- លោក ភោគ សុភា មន្ត្រីការពារកុមារ
- លោក ផ្លុង ឆាយ៉ា ជំនាញការផ្នែកការពារកុមារ
- លោក សែម ប៊ុតឌី មន្ត្រីការពារកុមារ
- លោកស្រី Lucia Soleti ជំនាញការផ្នែកការពារកុមារ

### អង្គការ IOM

- លោក Troy Doolez ប្រធានគ្រប់គ្រងកម្មវិធី
- លោក កេង ម៉េងឡាង មន្ត្រីគម្រោង

## NGOs

### អង្គការទំនុកចិត្តកុមារកម្ពុជា

- លោកស្រី Keir Drinnan អ្នកគ្រប់គ្រងទូទៅ
- លោកស្រី Tara Winkler សហស្ថានិក និងនាយកគ្រប់គ្រង

### អង្គការ Children in Families

- លោក Jesse Blaine អ្នកគ្រប់គ្រងទូទៅ
- លោកស្រី Naomy Long នាយកកម្មវិធី
- លោកស្រី Lynny Sor អ្នកគ្រប់គ្រងទូទៅ

### អង្គការ Community Care First

- លោកស្រី Novella Mori.

## អង្គការ Friends Cambodia (ការិយាល័យប្រចាំខេត្តសៀមរាប)

- លោកស្រី Anna Jolly ជំនួយការបច្ចេកទេស
- លោក គង់ សិដ្ឋ អ្នកសម្របសម្រួលសមាហរណកម្មគ្រួសារ

## សម្ព័ន្ធភាពសកលសម្រាប់កុមារក្នុងប្រទេសកម្ពុជា

- លោក ជា កុសល នាយកប្រចាំប្រទេស
- លោក គីម ជឿន រដ្ឋបាល

## អង្គការ Hagar

- លោក Mike Mowlin នាយកប្រតិបត្តិ
- លោកស្រី Sonya Hahm.
- លោកស្រី Elcira Vejar.

## អង្គការ Holt International

- លោកស្រី ជៀម កុសល នាយិកាប្រចាំប្រទេស
- លោក លាង ឡូ ប្រធានគម្រោង/ជំនាញការផ្នែកកុមារ និងគ្រួសារ

## អង្គការទឹកចិត្តម្តាយ

- លោកស្រី Katrina Gliddon នាយកស្ថានិក
- លោកស្រី Emily Scott ជំនួយការនាយក
- លោកស្រី Heather Marshall អ្នកសម្របសម្រួលអ្នកសង្គមកិច្ច
- លោកស្រី សឿង សម្ផស្ស ប្រធានផ្នែកសង្គមកិច្ច
- លោកស្រី ហេង ថារី បុគ្គលិកសង្គមកិច្ច

## អង្គការកុមាររីករាយ

- លោកស្រី ព្រំ គីមឆេង នាយិកាប្រតិបត្តិ
- លោកស្រី ហួត ម៉ារីយ៉ាន ប្រធានកម្មវិធី
- លោកស្រី Camille Monfort មន្ត្រីគៀងគរមូលនិធិ
- លោកស្រី ឡុង សារ៉ន មន្ត្រីគម្រោងថែទាំជំនួស
- លោកស្រី ទិត្យ សុធារី បុគ្គលិកសង្គមកិច្ចផ្នែកថែទាំជំនួស

### អង្គការម្លប់ឫស្សី

- លោកស្រី សារា ឈីន ទីប្រឹក្សាយុទ្ធសាស្ត្រ និងបច្ចេកទេស
- លោកស្រី យិន ម៉ានិត នាយិកាប្រតិបត្តិ
- លោក ស្រីប លីមហេង អ្នកសម្របសម្រួល EFC
- លោក សំ សុធា ប្រធានគ្រប់គ្រងផ្នែកសង្គមកិច្ច
- លោក យស ប្រាក់ ឪពុកធម៌
- លោកស្រី ណៃត សុម៉ាលី ម្ដាយធម៌

### វិទ្យាស្ថានជាតិសង្គមកិច្ច (NISA)

- សំ ចន្ទី គ្រូបង្រៀនបុគ្គលិកសង្គមកិច្ច
- ហៀក ម៉ូរីណា ប្រធានផ្នែកសង្គមកិច្ច
- ខុម ផល្លឿន អនុប្រធាន
- សំ រតនា សាស្ត្រាចារ្យ/គ្រូបង្រៀនបុគ្គលិកសង្គមកិច្ច

### អង្គការសង្គ្រោះកុមារកម្ពុជា

- លោកស្រី Bianca Collier នាយកគម្រោងគ្រួសារកាន់តែរឹងមាំពេលនៅជាមួយគ្នា (FAST)
- លោក Robert Common ជំនាញការការពារកុមាររបស់គម្រោង FAST

### អង្គការសេវាសង្គមកិច្ចកម្ពុជា

- លោកស្រី Ellen Minotti ទីប្រឹក្សាទូទៅ

## អ្នកប្រកបវិជ្ជាជីវៈអាជីពដទៃទៀត

- បូរា អ្នកផ្ដល់ចម្លើយនៃដេប៉ាតេម៉ង់សង្គមកិច្ច នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- លោកស្រី Robin Mauney អ្នកពិគ្រោះយោបល់ ការធ្វើផែនការកម្មវិធីគាំទ្រផ្នែកបច្ចេកទេស
- ការបណ្ដុះបណ្ដាល និងវាយតម្លៃ

# ឧបសម្ព័ន្ធទី ២ បញ្ជីឈ្មោះបុគ្គលដែលបានទំនាក់ទំនង នៅក្រៅប្រទេសកម្ពុជា

## រដ្ឋាភិបាល

### អាជ្ញាធរកណ្តាលទទួលបន្ទុកសុំកូនរបស់ប្រទេសប៊ែលហ្ស៊ិក

- Ms Beatrice Bertrand អាជ្ញាធរកណ្តាលសុំកូនរបស់បារាំង
- Ms Ariane Van den Berghe នាយកអាជ្ញាធរកណ្តាលទទួលបន្ទុកសុំកូនរបស់ Flemish

### អាជ្ញាធរកណ្តាលសុំកូនបារាំង

- Ms Cécile Brunet-Ludet Magistrat, Adjointe à la Mission de l'Adoption Internationale Ministère des Affaires Etrangères.
- Mr Tristan D'Arthuys.

### អាជ្ញាធរកណ្តាលផ្នែកសុំកូនរបស់ប្រទេសន័រវេ

- Ms Reidun Lauvstad ប្រធានផ្នែកអគ្គនាយកដ្ឋានកិច្ចការកុមារ យុវជន និងគ្រួសាររបស់ប្រទេសន័រវេ
- Ms Bente Hoseth ទីប្រឹក្សាជាន់ខ្ពស់ អគ្គនាយកដ្ឋានកិច្ចការកុមារ យុវជន និងគ្រួសាររបស់ប្រទេសន័រវេ

### អាជ្ញាធរកណ្តាលសុំកូនកាណាដា

- Ms Louise Gagnon, Ministère de la Santé et des Services sociaux (Quebec).
- Ms Josee-Anne Goupil, Secrétaire à l'adoption internationale et directrice générale Ministère de la Santé et des Services sociaux (Quebec).
- Mme Michèle Salmon, Autorité centrale fédérale pour la convention de 1993, Directrice adjointe, Equipe à l'adoption internationale, Citoyenneté et Immigration Canada.
- Ms Suzanne Tremblay, Ministère de la Santé et des Services sociaux (Quebec).

### អាជ្ញាធរកណ្តាលសុំកូនរបស់សហរដ្ឋអាមេរិក

- Ms Katherine E Epp.
- Ms Christine A Harold ទីប្រឹក្សាជាន់ខ្ពស់ផ្នែកសុំកូននៃការិយាល័យកិច្ចការកុមារ
- ការិយាល័យកិច្ចការកុងស៊ុលក្រសួងការបរទេសសហរដ្ឋអាមេរិក
- Ms Susan S Jacobs អគ្គរដ្ឋទូត ទីប្រឹក្សាពិសេសសម្រាប់បញ្ហាកុមារ ការិយាល័យកិច្ចការស្ថានកុងស៊ុល សេវាពលរដ្ឋក្រៅប្រទេសរបស់ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិក
- Ms Carine L Rosalia ទីប្រឹក្សាមេធាវី ការិយាល័យកិច្ចការច្បាប់សម្រាប់សេវាពលរដ្ឋក្រៅប្រទេស ការិយាល័យកិច្ចការកុងស៊ុល ក្រសួងការបរទេសសហរដ្ឋអាមេរិក
- Mr John L Ballif ទីប្រឹក្សាជាន់ខ្ពស់ផ្នែកសុំកូន ការិយាល័យកិច្ចការកុមារ ការិយាល័យកិច្ចការកុងស៊ុល ក្រសួងការបរទេសសហរដ្ឋអាមេរិក
- Ms Trish Maskew ប្រធានផ្នែកសុំកូន ការិយាល័យកិច្ចការកុមារ ការិយាល័យកិច្ចការកុងស៊ុល ក្រសួងការបរទេសសហរដ្ឋអាមេរិក

## អង្គការអន្តរជាតិ

### សម្ព័ន្ធភាពសកលសម្រាប់កុមារ

- Ms Kathleen Strottman នាយកប្រតិបត្តិ

### USAID

- Ms Jaime Gow ទីប្រឹក្សាបច្ចេកទេស មជ្ឈមណ្ឌល USAID ផ្នែកកុមារស្ថិតក្នុងការលំបាក
- Mr John Williamson ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ អ្នកចុះកិច្ចសន្យាមូលនិធិកុមារបាត់បង់ជម្រក និងកុមារកំព្រាដែលផ្តល់ការគាំទ្រដល់ផ្នែក EI របស់ USAID

### អង្គការ Care for Children

- លោក Thomas Abbott.

### អង្គការម្លប់តាប៉ាង

- លោក Eve Saosarin នាយក
- លោក David Shoemaker ទីប្រឹក្សាបច្ចេកទេស

## អ្នកប្រកបវិជ្ជាជីវៈដទៃទៀត

- Christian Larsson អ្នកប្រកបវិជ្ជាជីវៈដែលធ្វើការក្នុងប្រទេសកម្ពុជា អស់រយៈពេលជាងមួយទសវត្សរ៍មកហើយ

unicef
for every child

USAID
FROM THE AMERICAN PEOPLE

International Social Service
Service Social International
Servicio Social Internacional
General Secretariat • Secrétariat Général • Secretariado General

HCCH
HAGUE CONFERENCE ON
PRIVATE INTERNATIONAL LAW
CONFÉRENCE DE LA HAYE
DE DROIT INTERNATIONAL PRIVÉ
1893 - 2018
125